
រាជិនីសមុទ្រខ្សាច់ ១
ប្រទេសអ្នកផលិតប្រេងកាតលំដាប់ផ្លូវមុខរបស់ពិភពលោកដូច មិនិស
ម្ចើបតែបើកប្រទេសស្វាគមន៍វិនិយោគិន ជាឱកាសល្អដែលអ្នកនាង អាលីហ្សា
ទាយាទហាងគ្រឿងអលង្ការ ឱបបង្វែចមាសពេជ្រមៅប្រមូលយកលុយពីមហាសេដ្ឋី តែសុខៗ
ក៏ត្រូវចាប់ជីវិតទៅលេចមុខនៅសមុទ្រខ្សាច់ ដោយដៃ ចោរពាលៗ
មិនបានទេ នាងស្អាត ថែមទាំងនៅហ្វ៊ីនម្យ៉ៅត ត្រូវយកជីវិតមកបោះចោល ព្រោះចាប់យកមកសម្លាប់
នាងទទួលយកមិនបានទេ ម្ចើបនាងសម្លែងឫទ្ធិដាក់ ដេរមិនសំចៃហាត់ ដេរឱ្យចោរតាលចងចាំមួយជីវិតៗ
អាលីហ្សា រវល់តែបិទភ្នែកបិទត្រចៀកលេង ម្ចើបមិនដឹងថា
តាមពិតចោរតាលដែលចាប់នាងលើអដាក់លើស្មា ហើយទះកំប៉ះគូទមិនប្រណីគូទ តែព្រះអង្គម្ចាស់
សារីហ្វ អាល់ មិនិស ព្រះរាជវង្សាល់ជាប់ជាន់ខ្ពស់ ដែលកំពុងល្បួកំវាងនឹងសាច់សន្ធឹដូចបណ្តូលចោរ
និងភ្លើតភ្លើននឹងសំឡេងដេរដិតពិភោះចាប់ចិត្តរបស់នាង។
"ឃើសន្យាថាមិនរត់ ខ្ញុំនឹងស្រាយចំណងឱ្យ យល់ព្រមទេ ?"
"ក៏បាន"
"សន្យាទេ ?"
"អ៎ុយ ! ចង់និយាយឃុបឃៀតទេ ខ្ញុំខះកចង់ងាប់ហើយ"
ពេលមានសេរីភាព នាងក៏លើកតែងតែផ្អែមៗ ធឹកច្រោះប្រុសកខ្លាំង តែរសជាតិផ្អែមក្រជាក់
ឱ្យអារម្មណ៍ដូចបានកើតថ្មី មុននឹងសង្កេតថាអ្នកអង្គុយនៅចំពោះមុខគឺផ្លែងលែងលើ ដោយមិនឮច្រើតៗ។
"ម៉េចចាំបាច់ដោះអាវ ?"
"មិនចាំបាច់ធ្វើមុខដូចតួស្រីរឿងប្រណេមលោក ប្រាប់ឱ្យដឹងមុន បើក្នុងលោកនេះ
លែងមានមនុស្សស្រីនៅសល់ ម្ចើបខ្ញុំដឹសយកនាង"
"ស្លាប់ខ្ញុំសិនទៅ បើដល់ពេលនោះ ខ្ញុំដឹសណេកប្អូរអត់ មនុស្សលង់ខ្លួនឯង"
រាជិនីសមុទ្រខ្សាច់ ១
Come to join us
www.facebook.com/yuveakvey
Tel:010687787
ឈុត រាជិនីម្ចាស់សមុទ្រខ្សាច់
ក្បាលទី ហាមដកចំលងក្រុមប៉ុណ្ណោះ
S@rkA

18+
រាជិនីសមុទ្រខ្សាច់ ១

១

មីឌីស

បើនិយាយដល់ប្រទេសមីឌីស ភាគតិចណាស់ដែលដឹងថាប្រទេសនេះ ស្ថិតនៅផ្នែកត្រង់ណានៃភពផែនដីនេះ ហើយអ្នកដែលស្គាល់ឈ្មោះនេះនាំគ្នាប្រាប់ថាមីឌីសជាប្រទេសសមុទ្រខ្សាច់ ហួតហែង ល្ហល្ហែវ ទទេស្អាត គ្មានអ្វីគួរឱ្យចាប់អារម្មណ៍ ជាងនោះទៅទៀត សង្គ្រាមរយៈពេលយូរឆ្នាំកាលពីអតីត និងសារព័ត៌មានទូទាំងពិភពលោក ចាក់ផ្សាយព័ត៌មានអវិជ្ជមានមិនឈប់ឈរ ធ្វើឱ្យមីឌីសគួរឱ្យខ្លាច គ្មានស្ថិរភាព ប៉ុន្តែការពិតទៅ ប្រទេសមីឌីសជាគជ់នៃមជ្ឈិមបូព៌ា ជាប្រទេសដែលមានអាយុកាលយូរយារមកហើយតាំងពីពីរប្រាំរយឆ្នាំមុនគ្រិស្តសករាជ។ បុព្វបុរសរបស់ជនជាតិមីឌីស ជាអរិយជន គ្រប់គ្រង

អាណាចក្រព័រសៀ មិនចាញ់ក្រិច និងរ៉ូម៉ាំង ឈាមជ័រដ៏រឹងមាំត្រូវបានផ្ទេរពី ជំនាន់មួយទៅជំនាន់មួយ មកទល់នឹងបច្ចុប្បន្ននេះអ្នកគ្រប់គ្រងប្រទេសនេះគឺ **ហ្សឺក *ហ្វារីស អាល់ មីឌីស***។

ពេល ហ្សឺក ហ្វារីស ឡើងគ្រប់គ្រងប្រទេស ទើបចំនួនប្រភពហ្គាស ធម្មជាតិបម្រុងក្រោមដី ដែលមានច្រើនលំដាប់ទីមួយរបស់ពិភពលោក និង បរិមាណប្រេងឆៅបម្រុងលំដាប់ទីពីរ វេទិកាពិភពលោក និងអូពិច (*OPEC = Organization of the Petroleum Exporting Countries*) នាំគ្នាងាកមក ចាប់អារម្មណ៍ប្រទេសមីឌីសជាខ្លាំង ព្រោះមិនត្រឹមតែធនធានធម្មជាតិដែលជា ប្រេងឆៅច្រើនមហាសាលប៉ុណ្ណោះទេ មីឌីសក៏ជាអ្នកគ្រប់គ្រងតំបន់សំខាន់នៅ បរិវេណឈូងព័រសៀផងដែរ ចាត់ទុកថាជាចំណុចយុទ្ធសាស្ត្រដែលមើលរំលង មិនបាន តែនយោបាយបើកប្រទេសជាឧបសគ្គធំដែលសូម្បីសហរដ្ឋអាមេរិក និងបណ្តាប្រទេសមានឥទ្ធិពលក៏មិនអាចបង្គាប់បង្ខំមីឌីសបាន។



"ហ្សឺក ហ្វារីស ទើបតែបន្ទរបន្តយ និងព្រមបើកប្រទេស ដើម្បីទទួលអ្នកវិនិយោគកាលពីថ្មីៗនេះ"

ឧបទូតនៃមីឌីសប្រចាំសាធារណៈរដ្ឋកូរ៉េ ប្រាប់មន្ត្រីរដ្ឋបាលកូរ៉េខាងត្បូងនៅជិតគ្នានោះមានកូនក្មេង ដែលជាកូនចៅមន្ត្រីនៅស្ថានទូតកំពុងឈរតម្រង់ជួរនៅខាងមុខ ដើម្បីរង់ចាំស្វាគមន៍។

"ថាទៅបើមីឌីសបិទប្រទេស ក៏មិនកើតទុក្ខបុកម្នេញដែរ ហ្សឺក ហ្វារីស និងហ្សឺក សារីហ្វ ដែលជាប្អូនប្រុស ជាបុគ្គលដែលទទួលបានការទទួលស្គាល់ពីបណ្តាប្រទេសអារ៉ាប់ ហេតុផលមួយគឺសែស្រឡាយជាមួយគ្នា និងហេតុផលមួយទៀតគឺហ្សឺកទាំងពីរជាបុគ្គលរឹងមាំ ឆ្លៀវឆ្លាត ម៉ឺងមាត់ និងមានសច្ចៈ បើខាងយើងធ្វើឱ្យហ្សឺក សារីហ្វ ពេញចិត្តបាន ការចរចានាំចេញទំនិញទៅមីឌីសមិនគួរណាមានបញ្ហាទេ"

"ហើយស្អីដែលធ្វើឱ្យហ្សឺកពេញចិត្ត ?"

ដែលឱ្យមកស្វាគមន៍ភ្ញៀវកំពុងចេចចាច ដឹកនាំដោយនាងតូចវ័យបីឆ្នាំដែល

និយាយពុជាងគេជាងឯង។

"ឬគួរនាំក្មេងៗចេញ ហើយនាំស្រីស្អាតមកស្វាគមន៍វិញ?"

លោកឧបទូតញ្ញាក់ស្មា។

"មិនដឹងទេ នោះជាតួនាទីរបស់ខាងលោក បើថ្នាក់លើពិចារណាហើយ

ថាប្រទេសជាតិបានផលប្រយោជន៍ច្រើនជាងគេ ខាងលោកដឹងតែបានធ្វើជា

ដៃគូជំនួញរបស់មីឌីសជាមិនខាន"

មិនយូរប៉ុន្មានលីមូស៊ីនទំនើប បន្តដោយឡានការពារពីរគ្រឿង អង្គរក្ស

មានអាវុធគ្រប់ដៃក៏រត់មកនៅមុខអគារស្ថានទូតមីឌីស ដែលស្ថិតនៅកណ្តាល

រដ្ឋធានីសេអ៊ូល ទើបមន្ត្រីស្ថានទូតប្រញាប់ចូលទៅបើកទ្វារឡានឱ្យដោយការ

គោរព ហើយគ្រប់គ្នាក៏ធ្វើការគោរពបុគ្គលសំខាន់ដែលចុះពីឡានដោយមិន



ចាំបាច់មានអ្នកណាប្រាប់។

គេជាបុរសដែលមានមាឌធំ រាងខ្ពស់ស្រឡះ ចិញ្ចើមក្រាស់វាត់ឡើងលើ កែវភ្នែកមុតដូចស្ទាំង និងមានពន្លឺភ្លៅគគុក ទឹកមុខប្រាសចាកស្នាមញញឹម នៅមានសាច់ដុំធំៗ ដែលលាក់ក្នុងអាវ មាំមួន មានថាមពលហាក់ដូចពេជ្រទឹកល្អ។ បើពិភពលោកបង្កើតតំណាងសម្រាប់របស់គ្រប់យ៉ាង តាមបញ្ជារបស់ទេវតា បុរសម្នាក់នេះគឺជាតំណាងនៃភាពថ្លៃថ្នូរ ដែលគ្មានអ្វីឱ្យសង្ស័យ។

គេពាក់អាវគ្រែរហ្សសាកលពណ៌អាប់ និងពាក់គុត្រាក្រឡាការ៉ូ ដែលជាស្បែឃ្មុំក្បាលតាមបែបបទជនជាតិមជ្ឈិមបូព៌ា ដោយឈាមជ័រដ៏បិរសុទ្ធដែលបញ្ជាក់ទៅដល់ *ព្រះចៅ អាលីហ្សាហ៍* ដែលធ្លាប់គ្រងរាជ្យ ជាព្រះមហាក្សត្រនៃ *រាជវង្សកាចា* ដូច្នេះហើយគ្រប់យ៉ាងដែលចេញពីមាត់របស់គេគឺបញ្ជា។

"ទ្រង់គឺហ្សឺក សារីហ្វ អាល់ មីឌីស វ៉ាលីនៃហ្វេសសាន និងមកកាន់ទីនេះក្នុងហាន:ជាតំណាងរបស់ ហ្សឺក ហ្វារីស ពេលពួកអឺរ៉ុប ឬអាមេរិចត្រូវការចរចា

ជាមួយរដ្ឋបាលមីឌីស បុគ្គលដំបូងដែលត្រូវចូលជួបគឺអភិបាលក្រុង សារីហ្វ"

មន្ត្រីខាងកូរ៉ែខាងត្បូងឱ្យបប្រាប់គ្នា ព្រោះតារាងពេលវេលាដឹងត្រឹមតែ ទិន្នន័យត្រួសៗ និងអាចប្រែប្រួលបានគ្រប់ពេល។ ហ្វេសសានជាតំបន់ខួងយកប្រេងដែលជាគជ់ពណ៌មាសនៅក្នុងខ្សែភ្នែកពិភពលោក ចំណែកតំណែងវ៉ាលីជាតំណែងធំស្មើនឹងតំណែងអភិបាលខេត្តស្វយ័ត គ្រប់គ្រង និងប្រតិបត្តិតាមបញ្ជាពីទីបញ្ជាកណ្តាល ទាំងហ្សឺក ហ្វារីស ត្រូវការតែងតាំងបុរុសជាខេឌីហ្វ ឬឧបរាជ ប៉ុន្តែហ្សឺក សារីហ្វ បដិសេដ។

"កូរ៉ែខាងត្បូងមិនធ្លាប់ទទួលបានការពិចារណាពី ហ្សឺក សារីហ្វ ទេ ទើបរាងពិបាកបន្តិច ពេលថ្នាក់លើចង់ចរចានាំចេញទំនិញ និងនាំចូលប្រេងពីមីឌីស" មន្ត្រីដដែលឱ្យបបន្ត។

"ហេតុអី ?"

"មានពាក្យចចាមអារាមកាលពីច្រើនឆ្នាំមុន មានស្រីស្អាតម្នាក់បង្កើរឿង



លួចចិញ្ចៀនពេជ្រក្នុងវាំងរបស់ទ្រង់ កាលនោះតាមចាប់ឱ្យច្រវាត់ តែចោរស្រី
នោះរត់រួច សន្និដ្ឋានថាជាស្រីកូរ៉េ"

"អីគេ! ហេតុអ្វីរឿងធំយ៉ាងហ្នឹងគ្មានព័ត៌មាន?"

"រឿងនេះអាចប៉ះពាល់ដល់ទំនាក់ទំនងការទូត ហើយមីឌីសក៏មិនត្រូវ
ការឱ្យប៉ះពាល់ដល់ព្រះមាតារបស់ ហ្ស៊ឺក"

មន្ត្រីម្នាក់នោះឈប់ខ្សឹបខ្សៀវ ហើយឈរត្រង់ខ្លួន ពេលបុគ្គលសំខាន់
ងាកមកមើលដោយខ្សែភ្នែកសោះកក្រោះ ខណៈនោះ ឧបទូតមីឌីសប្រចាំ
សាធារណរដ្ឋកូរ៉េជាមួយបុគ្គលជាន់ខ្ពស់របស់រដ្ឋបាលកូរ៉េខាងត្បូងក៏ម្ដីម្នាចូល
ទៅគោរព។

"សូមថ្វាយការស្វាគមន៍ ចំពោះការយាងមកដល់សាធារណរដ្ឋកូរ៉ែ
យើងខ្ញុំទូលព្រះបង្គំមានសេចក្ដីសង្ឃឹមជាខ្លាំង ថាមិត្តភាពរវាងប្រទេសទាំងពីរ
កាន់តែស្និតល្មួត ក្រាបទូល"

"អរគុណ"

"រឿងសំណើដែលយើងខ្ញុំទូលព្រះបង្គំ ទូលថ្វាយកាលពីសប្តាហ៍មុន មិនជ្រាបថាទ្រង់..."

"តាមមារយាទការទូត យើងមិនត្រូវការចរចានៅវេលានេះ យើងនឹងនិយាយគ្នាជាផ្លូវការនៅខាងក្នុង សង្ឃឹមថាខាងលោកយល់"

មន្ត្រីជាន់ខ្ពស់របស់សាធារណរដ្ឋកូរ៉េថ្លោះទឹកមុខ បរិយាកាសស្ងាគមន៍ដ៏រីករាយទៅជាមានសម្ពាធកើតឡើង មានតែក្មេងៗជាងដប់នាក់ប៉ុណ្ណោះដែលនាំគ្នាគោរពបុរសខ្ពង់ខ្ពស់ ដោយមិនដឹងខ្យល់អី។

"សូមថ្វាយការស្វាគមន៍ចំពោះ ការយាងមកដល់កូរ៉េ"

ក្មេងស្រីវ័យបីឆ្នាំដែលនៅខាងគេឱនគំនាប់សឹងតែកៅសិបដឺក្រេ បើមិនទាស់ត្រង់ថា ដៃទាំងពីរកាន់បាច់ផ្កា ហើយពេលងើបមកវិញក៏សើចស្ទេញចេញធ្មេញដាក់។ កុមារីមាឌល្អិត ប៉ុន្តែបិននិយាយស្តី ហ៊ានប្រសព្វភ្នែកជាមួយ



បុរសខ្ពង់ខ្ពស់ដោយមិនខ្លាចក្រែង ខណៈនោះ សារីហ្វ ក៏ញញឹមដាក់វិញ និង
ហុចដៃទៅរក ទើបកុមារីហុចផ្តាទៅឱ្យ ហើយងើយមុខមកញញឹមម្តងទៀត ជា
ការរង់ចាំការសរសើរ។

ការប៉ះពាល់ចុងម្រាមដៃគ្នា ទោះបន្តិចបន្តួច តែបែរជាធ្វើឱ្យអារម្មណ៍
មាននិស្ស័យកើតឡើងយ៉ាងចម្លែក ទើបគេមិនអាចមើលរំលងបាន។ កែវភ្នែក
ពណ៌បៃតងចាស់ដូចពណ៌ថ្មដ៏មានតម្លៃរបស់នាងតូច ប្រសព្វនឹងកែវភ្នែកមុត
ស្រួចដែលមានពណ៌ដូចគ្នាបេះបិទ និងមុខមាត់ស្អាតដូចម្តាយរបស់គេបេះបិទ
ទើប សារីហ្វ ស្រវាចាប់កដៃតូចនោះជាប់ ព្រមទាំងប្រែមើលផ្នែកខាងមុខ...
មានផ្នត់តកន្លែងដូចគ្នាទៀត ទើបធ្វើឱ្យគេជឿជាក់ភ្លាម ថានាងតូចដែលធ្វើឱ្យ
មនុស្សលំដាប់គេរំជួលចិត្តបានត្រូវតែពាក់ព័ន្ធនឹងឈាមជ័របស់គេ។

សារីហ្វ មើលទៅជុំវិញខ្លួនភ្លាម ដើម្បីប៉ាន់ប្រមាណស្ថានការណ៍ ហើយ
សង្កេតឃើញថាមន្ត្រីសឹងតែគ្រប់គ្នាពាក់គ្រឿងលម្អត្បូងមណីធំខ្លះ តូចខ្លះទៅ

តាមធនធាន អាចដៅបានមិនពិបាកថាពួកគេត្រូវតែមានឈ្មួញស្រីប្រចាំខ្លួនជា
មនុស្សតែម្នាក់។

ពេលនោះឯងដែលគេមានអារម្មណ៍ដល់ទ្រនិចនាឡិកានៅក្នុងបេះដូង
របស់ខ្លួន វាចាប់ផ្តើមដើរម្តងទៀត បន្ទាប់ពីឈប់ដើរអស់រយៈពេលជាច្រើនឆ្នាំ។

ស្រីជើងល្អ ខ្ញុំរកនាងឃើញហើយ!

ពេលឃើញបុរសខ្ពង់ខ្ពស់ក្តាប់ដៃណែន មន្ត្រីជាន់ខ្ពស់គិតថានាងតូច
បង្កបញ្ហា ទើបគិតថាចូលទៅនាំចេញ តែត្រូវគេលើកដៃហាម ព្រមទាំងលុត
ជង្គង់ចុះ ដើម្បីឱ្យខ្សែភ្នែកនៅស្មើនឹងអ្នកទល់មុខ។

មែនហើយ ខ្សែភ្នែកបែបនេះ កាយវិការធ្វើច្រមុះក្របីហិតញីបែបនេះ
ពេលញញឹមមានចង្កុមតូចៗ ដូចគ្នាបេះបិទបែបនេះ ម្តាយរបស់នាងតូចជា
អ្នកណាមិនបាន ក្រៅពីប្រពន្ធជើងល្អ។

"នាងតូចឈ្មោះអី?"



"ខ្ញុំឈ្មោះ បូបូ..."

នាងតូចណែនាំខ្លួនឯងជាភាសាអង់គ្លេសរអិលមាត់ ព្រមទាំងលើកដៃ

គំនាប់បែបទាហាន។

"ខ្ញុំកំពុងរៀនត្រៀមថ្នាក់មត្តេយ្យ បន្ទប់នំខេក"

"ម៉ាក់... នរណាជាម៉ាក់របស់នាងតូច ?"

"បូបូ កូនម៉ាក់ អាលិហ្សា!"

អាលិហ្សា... ឈ្មោះដែលគេស្វែងរកម្ចាស់ឈ្មោះយូរហើយ ប្រើគ្រប់វិធី

គ្រប់បណ្តាញទូទាំងពិភពលោក ដើម្បីតាមរក តែបែរជាបរាជ័យរហូត មិនស្មាន

ថានាងរត់មកពួននៅក្រោមច្រមុះគេបែបនេះសោះ ហើយនាងក៏មានផ្ទៃពោះ។

សារីហ្វ ដកដង្ហើមធំ ស្រវាទាញ បូបូ លើកបីភ្លាម ដែលក្រៅពីមិនខ្លាច

នាងតូចបែរជាសើចចូលចិត្ត លើកដៃម៉ាប់ៗ ទាញគុត្រារបស់គេលេងទៀត។

"ហេតុអីពាក់ស្បែឃ្មុំក្បាល ?"

"យើងលួចនំមកលាក់ មិនឱ្យអ្នកណាដឹង"

គេនិយាយលេងជាមួយ ធ្វើឱ្យ បូបូ សើចកក្អិច។

"លោកពូធ្វើជាប៉ាខ្ញុំបានអត់ ខ្ញុំចង់មានប៉ា"

"ប៉ានាងតូចទៅណា?"

"មិនដឹងទេ ម៉ាក់ប្រាប់ថាធុញប៉ា"

បូបូ រាយការណ៍តាមអ្វីដែលឮបានឮ តែស្តាប់ហើយ ឆ្ងល់ចុងច្រមុះ ភ្លាម។

"ម៉ាក់ប្រាប់ថាប៉ាចិត្តអាក្រក់ ប្តូរប៉ាថ្មីល្អជាង"

ប៉ាចិត្តអាក្រក់ស្តាប់ដោយចិត្តត្រជាក់។

"ហើយម៉ាក់នាងតូចរកប៉ាថ្មីបានហើយនៅ?"

"នៅទេ ទើបខ្ញុំចង់រកឱ្យម៉ាក់ ញ៉ែម៉ាក់ខ្ញុំសាកមើលទេ"

"បានតើ យើងច្បាស់ជាញ៉ែ"



គេញញឹមចុងមាត់ តែពន្លឺភ្នែកមិនញញឹម ព្រោះទីបំផុតរកប្រពន្ធជើងល្អ

ឃើញហើយ។ ស្វាមីនៅដកដង្ហើមឱ្យជ្រងោ ម៉ែចក៏ហ៊ានប្រកាសរកប៉ាថ្មីឱ្យកូន

មិនទាន់បូកបញ្ចូលបំណុលចាស់ដែលមិនទាន់ជម្រះ គេនឹងគិតបញ្ជីពីនាង

ទាំងដើមទាំងការ។

២

អតីតរបស់ អាលិហ្សា

បួនឆ្នាំមុន...

បើមានគេសួរថា ស្រីតូចមុខស្រស់ដូចនាងរៀនចប់ហើយធ្វើការរកស៊ីអី អាលិហ្សា នឹងឆ្លើយថាជាឈ្មួញរកស៊ី ហើយអ្នកសួរនឹងពិចារណាស្រីស្អាតក្នុងឯកសណ្ឋានមហាវិទ្យាល័យ និងគិតថាជាឈ្មួញស្បែកសម៉ត់ខែម្នាក់នេះ ប្រហែលលក់ទំនិញហ្វេសិន មិនអីចឹងក៏គ្រឿងសម្អាង ទើបអ្នកសួរមានអំនួតរបូតមាត់ថាលក់អី ចាំជួយទិញទាំងអស់។

"នេះ៎ថា ស៊ីទ្រីន មកពី ស៊ីឡន កូមែន អាមេធីសត៍ ហ្សឺខន ក៏មាន ត្បូងទទឹមមួយគូនេះធ្វើក្រវិលស្អាតណាស់ ត្បូងកណ្តៀងពណ៌ផ្ទៃមេឃស្រាលមួយ



គ្រាប់នេះ ពន្លឺស្អាតផ្លេកៗ មរកតមួយគ្រាប់ធំនេះ សាស្ត្រាចារ្យផ្នែកទំនាក់ទំនង
កក់យកហើយ"

ឈ្មួញក្រមុំញញឹមពព្រាយ ដែលស្មាមខួចនិងធ្មេញជំពើស មើលគួរឱ្យ
ស្រឡាញ់ ប៉ុន្តែអ្នកសួរដែលកំពុងមើលត្បូងមណីទាំងឡាយបញ្ចេញពន្លឺផ្លេកៗ
ទៅជាភាំង ព្រោះទំនិញដែលនាងលក់គឺត្បូងមណី តម្លៃមានចោកថ្លៃទៅតាម
ទំហំ និងប្រភេទ តែតម្លៃដែលថាចោក វាធ្វើឱ្យអ្នកសួរចង់បះសក់។

"ត្បូងកណ្តៀងពណ៌ផ្ទៃមេឃស្រាលស្អាតព្រិចៗមួយគ្រាប់នេះ តម្លៃ...
ប៉ុណ្ណោះ ចំណែក ស៊ីទ្រីន មួយគ្រាប់តូចនេះ តម្លៃ... ធ្វើបន្តោង ឬចិញ្ចៀនក៏បាន
ស្អាតណាស់"

"ខ្ញុំមិនធ្លាប់ទិញត្បូង ទិញពេជ្រ មិនហ៊ានទិញរបស់ថ្លៃៗ បែបនេះ ពិត
ឬក្លែងក្លាយក៏មិនដឹង"

ទោះត្រូវបដិសេធដោយប្រយោល តែនាងមិនខឹង មានតែអធិប្បាយ

ដោយចិត្តត្រជាក់ ថាមិនបាច់ខ្លាចរបស់ក្លែងក្លាយ ព្រោះត្បូងមណីដែលនាង លក់សុទ្ធតែទាំងអស់ បើចូលចិត្តមួយណា ទៅសុំលិខិតបញ្ជាក់ពីស្ថាប័ន ត្បូងមណីបាន។

"ខ្ញុំលក់ត្បូងតាំងពីឆ្នាំទីមួយ ភ្ញៀវជាសាស្ត្រចារ្យនៅមហាវិទ្យាល័យទាំង អស់ មានហាងធំនៅ ផាហ៊ីរ៉ាត់ សេដ្ឋីប៉ាគីស្ថានហោះហើរមកជាវនៅផ្ទះរបស់ ខ្ញុំដោយផ្ទាល់ បើខ្ញុំលក់របស់ក្លែងក្លាយ មិនស្មោះត្រង់ចំពោះអាជីព ផ្ទះខ្ញុំមិន មែនអាចរកស៊ីមកដល់សព្វថ្ងៃនេះទេ ស្ថាប័នត្បូងមណីនៅក្នុងមហាវិទ្យាល័យ នេះឯង បើចូលចិត្តមួយណា យកទៅពិនិត្យបាន ហើយចាំគិតលុយ"

"តែខ្ញុំមិនផ្លាប់ទិញ...."

"អីចឹងពិសោធទាំងអស់គ្នា រើសគ្រាប់ដែលត្រូវចិត្តជាងគេ ព្រោះយើង ជាអ្នកពាក់ និងអាចកុម្មង់ធ្វើតួចិញ្ចៀន ឬក្រវិលបាន បើធ្វើចិញ្ចៀន ខ្ញុំសុំណែនាំ ឱ្យធ្វើម៉ូតនេះ វានឹងធ្វើឱ្យម្រាមដៃមើលទៅស្អាតសក្តិសម បើធ្វើក្រវិលក៏ស្អាត



ទុកពាក់ចូលរួមកម្មវិធី ឬពាក់មកបង្រៀន សមនឹងក្រណាត់សូត្រណាស់"

ដំបូងអ្នកសួរ គ្រាន់តែចង់សួរលេងប៉ុណ្ណោះ តែបែរជាត្រូវពន្លឺរបស់ត្បូង ទាក់ទាញ គិតតែសម្លឹងមើល អាមេធីសត៍ ពណ៌ស្វាយរូបបេះដូង ទំហំរបស់វា សមល្មម មិនតូចពេក ហើយក៏មិនធំពេក តម្លៃក៏មិនថ្លៃដែរ ព្រោះ អាលិហ្សា មិនបានដាក់តម្លៃថ្លៃ និងបូកតម្លៃផ្សេងៗ ចូល ហើយពេលគណនាថ្លៃធ្វើក្រវិល និងចិញ្ចៀន គឺអាចទទួលយកបាន ទើបពេលនេះអ្នកសួរក៏ក្លាយជាអ្នកទិញ ទាំងមិនយល់ថាត្រូវមន្តសណ្តំមេអ្វីរបស់ឈ្មួញក្រមុំ ទើបអន្ទះអន្ទែងចង់បាន ត្បូងស្អាតៗទាំងអស់នេះ។

"អរគុណដែលជួយជាវ"

អាលិហ្សា ទទួលយកប្រាក់ពីដៃភ្ញៀវ។ និយាយមិនអួតទេ បើនាងបើក តូចលក់ពេលណា ដឹងតែប្រាក់ចូលពេញហោប៉ៅ។

ជំនួញគ្រឿងអលង្ការគ្រួសាររបស់នាង ចាប់ផ្តើមតាំងពីជំនាន់លោកតា

(ខាងឪពុក) មានទីតាំងក្នុងផ្សារទំនើប ដាក់ត្បូងមណីគ្រាប់ធំៗ ក្នុងទូកញ្ចក់ បញ្ចេញពន្លឺព្រិចៗ ទាក់ទាញខ្សែភ្នែកអ្នកមើល ទើប អាលិហ្សា បានស្វែងយល់ ពីការងារទាំងនេះពីចាស់ទុំ។ ពេលអាយុដប់ប្រាំបីឆ្នាំ នាងអាចមើលដឹងថាត្បូង ណាពិត ឬក្លែងក្លាយដោយភ្នែកទទេ អាយុម្ភៃឆ្នាំចេះដាក់តម្លៃ អាយុម្ភៃពីរឆ្នាំ ត្រូវអនុញ្ញាតឱ្យអង្គុយនៅមុខហាង ដាក់ស្លាកប្រកាសទិញត្បូងគ្រប់ប្រភេទ។ នៅលើតុរបស់នាងមានត្បូងគ្រប់ប្រភេទគ្រប់ទំហំរាប់រយគ្រាប់ក្នុងថាស ទើប មានប្រាក់ឆ្លងកាត់ដៃរបស់នាងមួយថ្ងៃៗ ច្រើន។ ទោះត្រឹមជានិស្សិត ចំណាយ ពេលវេលាទំនេរមកជួយមើលហាងឱ្យឪពុក ប៉ុន្តែនាងមិនខ្លាច ព្រោះមាន ប្រព័ន្ធការពារសុវត្ថិភាពពីបុគ្គលដែលអង្គុយមឹះៗ នៅកៀនជញ្ជាំង រួមទាំង កាមេរ៉ាសុវត្ថិភាព។

"សួស្តី លោក ស៊ីន ខានជួបគ្នាយូរ កំពុងនិយាយដើមលោកល្មម"

អាលិហ្សា និយាយដាក់បុរសមាឌធំវ័យកណ្តាល ដែលបើកទ្វារហាងចូលមក។



ចូលហាងគ្រឿងអលង្ការ តែនាងម្ដីម្នាទៅស្វាគមន៍ ព្រោះម្នាក់នេះជាឈ្នួញ កណ្ដាលត្បូងមណី។ ឪពុកទូន្មានថា បើចេះចងមិត្តល្អៗ បើឱកាសក្រោយ គេមានរបស់ល្អនឹងយកមកណែនាំឱ្យយើងមុនគេ។

"សួស្ដីអ្នកនាង អាលិហ្សា ខ្ញុំមានត្បូងទទឹមស្អាតៗ មកលក់"

"ខ្ញុំរង់ចាំលោករាល់ថ្ងៃ"

ឈ្នួញកណ្ដាលញញឹមញញែម ពេលដាក់បង្គុយទល់មុខ។ គេមានចេតនាមកចំពេលដែលថៅកែមិននៅ ព្រោះគិតថាអ្នកនាងមុខមាត់តូចច្រមិចតាមល្បិចឈ្នួញកណ្ដាលមិនទាន់។ គេពាក់អាវធំស៊ុលគយុល មានហោប៉ៅតូចៗ ខោមានហោប៉ៅទាំងមុខទាំងក្រោយ ចង្កេះខោក៏មានហោប៉ៅតូចដាក់ថង់ត្បូងទទឹមច្រើនទំហំ ហើយយករបស់ទាំងនោះឱ្យថៅកែតូចពិចារណា។

អាលិហ្សា សម្រិតសម្រាំងម្ដងមួយថង់ៗ ថង់ណាមិនចាប់អារម្មណ៍ក៏

ហុចឱ្យម្ចាស់ដើមវិញ តែបើចាប់អារម្មណ៍នឹងយកដង្កៀប និងកែវពង្រីកមកឆ្លុះ
មើល ដោយការយកចិត្តទុកដាក់ និងតម្លៃបណ្តើរៗ ខណៈនោះថៅកែធំទើប
ចូលហាង ក៏មិនមករំខាន ចង់ឱ្យកូនស្រីធ្វើការងារនេះទាល់តែចប់ ចំណែក
ថៅកែស្រីកំពុងលួចមើលពីចម្ងាយ ដោយការព្រួយបារម្ភ។

"អូនទៅជួយកូនតម្លៃល្អទេ បង?"

"ទៅធ្វើអី យើញស្មាមចង្កូមមុតស្រួចនោះទេ ហ្នឹងហើយឈ្នួយក្រមុំ
ចង្កូមមុតស្រួចពិត ឥតក្លែងក្លាយ ចាំមើលថ្ងៃដៃថៅកែតូចទៅ"

លោកថៅកែ ឈិន ឆុងតែផឹកយ៉ាងរំតើយ ខណៈដែលកូនស្រីកំពុង
ចរចាទិញលក់ម្តងមួយថង់ៗ ក្នុងចិត្តនាងកំពុងបាញ់ទៅរកត្បូងទទឹមមួយគ្រាប់
ធំ ទឹកល្អនោះហើយ តែធ្វើជាព្រងើយកន្តើយ ថាមិនចង់បាន។

"មួយរយៈនេះស្ងាត់ណាស់ លក់ដូរមិនសូវដាច់ទេ ភ្ញៀវបាត់អស់ ខ្ញុំឱ្យ
ថ្លៃតែប៉ុណ្ណឹងទេ"



"ត្បូងទទឹមប្រភេទនេះកម្ររកបានណាស់ អ្នកនាង ឱ្យចំណេញខ្ញុំបន្តិច
ម៉ោ មួយគ្រាប់នេះទំហំដប់ការ៉ាត់ ម្ចាស់គេលក់មួយការ៉ាត់... មិនថ្លៃទេ"

ឈ្មួញកណ្តាលប្រាប់ តែការពិតទៅគេទិញមកក្នុងតម្លៃថោកជាងដាក់តម្លៃឱ្យ អាលិហ្សា ទៅទៀត។

អាលិហ្សា ញញឹមពព្រាយ តែជ្រឹមភ្នែក បញ្ជាក់ថាដឹងល្បិចឈ្មួញគ្នាឯងព្រោះនាងជាមនុស្សឆ្លាត មិនមែនលូងំឯណា។

"ថ្លៃពេកហើយ ខ្ញុំឱ្យបានតែប៉ុណ្ណឹងទេ"

នាងដឹងថាឈ្មួញកណ្តាលយកត្បូងមកពីអ្នកលក់ គេបានបូកថ្លៃនេះថ្លៃនោះរួចហើយ និងបានចំណេញភាគរយពីអ្នកលក់ទៀត ទើបនាងហ៊ានតថ្លៃខណៈនោះ ស៊ីន ចងវ៉ែក ក៏សុំទៅនិយាយទូរសព្ទនៅខាងក្រៅ ចរចាជាមួយម្ចាស់ដើម ពេលចូលមកវិញក៏ប្រាប់ បើមិនបានដូចតម្លៃដែលដាក់គឺមិនព្រមលក់ទេ ទាំងដែលការពិតគេចង់ចំណេញតម្លៃដែលដាក់លើសសោះ។

"ម្ចាស់គេប្រាប់ថាលក់តម្លៃ..."

"តម្លៃនេះសុំបាយៗ"

នាងបដិសេធ តែបើប្តូរចិត្តលក់ នាងរីករាយទទួលទិញ ហើយពេលគេយកទៅលក់ឱ្យហាងផ្សេង នាងក៏ទូរសព្ទទៅកាត់មុខ។

"ស៊ីន ចងវ៉ុក កំពុងយកត្បូងទទឹមទំហំដប់ការ៉ាត់ទៅលក់ តម្លៃចាប់ផ្តើម ... តែជួយប្រាប់មួយការ៉ាត់តម្លៃ... ឱ្យខ្ញុំផង ខ្ញុំមានថ្លៃកុំម៉្យាងឱ្យពីរភាគរយ តែបើចង់ទិញទុកខ្លួនឯងក៏បាន"

ត្រឹមប៉ុណ្ណឹង ចងវ៉ុក ក៏ជួបតែតម្លៃដូចដែល អាលិហ្សា ដាក់ឱ្យ និងមានកន្លែងខ្លះថោកជាងទៅទៀត ទោះចូលហាងណាក៏សុំទ្បើងថ្លៃមិនបាន មានតែត្រូវបន្ទាបតម្លៃទាបទៅៗ ទើបគេគិតសាថ្មី ព្រមចំណេញតិចតួច តែអាចទទួលយកបាន។

អាលិហ្សា អង្គុយរើសត្បូង ដើម្បីឱ្យជាងច្នៃ ត្បូងទទឹមគ្រាប់ធំៗ បែបនេះ



កម្រែកបាន និងលក់បន្តបានតម្លៃខ្ពស់ ស្រួលមិនស្រួលអាចបានថ្លៃគុណនឹង

ពីរគុណនឹងបីផង តែនាងប្រកាន់គំនិត មិនកេងចំណេញហួសហេតុពេក និង

លក់តែរបស់ពិត របស់សុទ្ធ និងលក់ក្នុងតម្លៃសមរម្យ ទើបមិនបាត់ភ្ញៀវ។

"ត្បូងទទឹមមួយគ្រាប់នោះ មានភ្ញៀវកក់ហើយឬ អាលីស ?"

"មានហើយ ប៉ា គេកុម្ម៉ង់ត្បូងទទឹមទំហំដប់ការ៉ាត់ ខ្ញុំនឹងបូកតម្លៃថែម

មួយការ៉ាត់..."

"មួយរយៈនេះសេដ្ឋកិច្ចមិនសូវល្អ មានអ្នកមានបញ្ហារឿងលុយកាក់

ទើបប្រមូលរបស់លក់ច្រើន ទើបឃ្លាំងរបស់យើងបញ្ចេញទំនិញក្រចេញ កូន

ត្រូវផ្អាកនាំរបស់ថ្មីចូលសិន"

"ខុសហើយប៉ា ពេលវេលាបែបនេះឯង វាមានរបស់ល្អៗ កម្រែកបាន

ត្រូវយកមកលក់ថោកៗ បើយើងរង់ចាំសេដ្ឋកិច្ចល្អប្រសើរ ចាំទិញនោះ តម្លៃវា

នឹងឡើងខ្ពស់"

"អាលីសប៉ាដឹងថាឈាមកូនកំពុងក្តៅតែជឿប៉ាចុះ កាត់បន្ថយទិញចូលសិនទៅ"

អាលិហ្សា យល់ព្រមនឹងសម្តីរបស់ឪពុក តែដល់តែមែនទែនទៅចេះតែភ្លេចខ្លួន ទិញកាន់តែច្រើន ទើបហាងគ្រឿងអលង្ការរបស់គ្រួសារចាប់ផ្តើមខ្វះប្រាក់សុទ្ធបណ្តើរៗ នោះមានន័យថាសែកដែលចេញឱ្យអ្នកយកអីវ៉ាន់មកលក់មុននេះអាចនឹងក្លាយជាសែកខ្មោច ចាត់ទុកថាកំហុសព្រហ្មទណ្ឌ និងឧក្រិដ្ឋពេលនោះឯងដែលនាងត្រូវឪពុកជេរទាំងព្រឹកទាំងល្ងាច ជេរមិនច្រំពាក្យ ជេរន្ទន្ត្រចៀកកើតខ្ទុះ ចំណែកម្តាយក៏ជេរឪពុក ដែលមិនជួយមើលការងារកូនស្រីទើបទាំងឪពុកនិងកូនស្រីប្រញាប់រកភ្ញៀវមកជួយទិញ តែរកមិនបានច្រើន។

"អ៊ូយ! វីរហើយ ទៅរកលុយមកពីណាច្រើនយ៉ាងហ្នឹងឱ្យទាន់ដាច់ខែ"

"រវល់តែឡូឡាទៅហ្នឹងហើយ វាជួយស្អីបាន ឆាប់ទៅរកភ្ញៀវភ្លាមទៅ"

"ប៉ា ថ្ងៃនេះខ្ញុំរត់រកលុយពេញមួយថ្ងៃហើយ សុំញ៉ាំបាយសិន"



នៅវេលានោះ បណ្តាប្រទេសនៅមជ្ឈិមបូព៌ាកំពុងរំភើបនឹងព័ត៌មាន
ដែលហ្សឹក ហ្វារីស អាល់ មីឌីស ព្រមព្រៀងបើកប្រទេស ពួកលោកខាងលិច
កំពុងរកមើលចន្លោះប្រហោងវិនិយោគទុន ប៉ុន្តែទោះព័ត៌មានផ្នែកអន្តរជាតិ
ចាក់ផ្សាយតែបន្តិចបន្តួច មិនលម្អិត ក៏ អាលិហ្សា យកចិត្តស្តាប់ ទើបញញឹម
ភ្នែកឡើងញ័រ ពេលមានគំនិតមួយផុសក្នុងខួរក្បាល។

"កំពុងគិតអីឡប់ៗ ទៀតហើយហ្នឹង"

ថៅកែ ឈិន ខោកក្បាលកូនស្រី។

"អ៎ូយ! អត់មានទេប៉ា ខ្ញុំចេញទៅប្រមូលលុយសិន"

អាលិហ្សា ងើយមុខមើលនាឡិកា គិតថាដល់ពេលទៅតាមការណាត់
ហើយ។ ហាងគ្រឿងអលង្ការរបស់គ្រួសារជាហាងមានអាយុកាលចំណាស់
ដូច្នេះហើយ ទើបមានអ្នកតូចអ្នកធំចូលមកទិញលក់របស់ជាប្រចាំ ជាច្រើនដង
ដែលអ្នកទាំងនោះមានបញ្ហារឿងប្រាក់កាស់ ទើបយកមកផ្ញើឱ្យលក់ តែមិន

ព្រមឱ្យបើកចំហប្រភពថាជាត្បូងរបស់អ្នកណា ដែលធម្មតា នាងមិននិយាយ ស្រាប់ហើយ ឬអ្នកខ្លះយកមកផ្ញើឱ្យលក់ ព្រោះមិនសូវបានពាក់ ឬចង់ដោះដូរយកត្បូងថ្មីៗ តែមិនថាដោយហេតុផលអ្វីក៏ដោយ នាងគិតថ្លៃកម្រៃជើងសាពីរភាគរយតាមតម្លៃលក់ ហើយកាលពីពីរថ្ងៃមុន នាងលក់ក្រវិលត្បូងកណ្តៀងទឹកល្អ ពេលដកថ្លៃកម្រៃជើងសាហើយ ក៏បានចំណេញច្រើន។

នាងនិងភ្ញៀវណាត់គ្នានៅធនាគារ ដើម្បីយកសែកទៅដកលុយ ដែលភ្ញៀវជាមន្ត្រីធំ ពេលរាប់លុយគ្រប់ហើយ ក៏ថែមឱ្យមួយចំនួនទៀត ប្រាប់ថាជាថ្លៃហត់នឿយ។

"ខ្ញុំយកតែថ្លៃកម្រៃជើងសាពីរភាគរយតាមកិច្ចព្រមព្រៀងប៉ុណ្ណោះ មិនយកលើសពីហ្នឹងទេ" នាងនិយាយមួយៗ ដោយទឹកមុខញញឹម។

"ខ្ញុំមិនបានឱ្យលើសទេ"

"យើងព្រមព្រៀងគ្នាតែពីរភាគរយ ក្រែងលលោកស្រីភ្លេច"



"ហើយត្រូវការប៉ុន្មាន ?"

"ពីរភាគរយនៃតម្លៃលក់"

"ខ្ញុំឱ្យប៉ុណ្ណឹង វាគ្រប់គ្រាន់ហើយ ចាត់ទុកថាគ្នាឯង នៅក្មេងសោះអីយក លុយទៅធ្វើអីច្រើនម្ល៉េះ ក្រវិលត្បូងកណ្តៀង ខ្ញុំទិញម៉ោ ហើយលក់វិញមិនបាន បូកកម្រៃអីផង ឱ្យកម្រៃជើងសាដល់ទៅពីរភាគរយ ខ្ញុំខាតស្លាប់ហើយ"

"គ្នាឯងហ្នឹងហើយដែលត្រូវប្រកាន់សច្ចៈ ខ្ញុំលក់ដូរដោយភាពស្មោះត្រង់ មិនកេងចំណេញពីអ្នកណា បើខ្ញុំព្រមយកលុយចំនួន... ពីលោកស្រី ខ្ញុំនឹង ក្លាយជាក្មេងលួង ព្រមឱ្យមនុស្សមិនរក្សាសម្តី មានគំនិតកេងចំណេញញ្ញពី អ្នកដទៃ តើមែនទេ ?"

អាលិហ្សា តបតដោយសំឡេងពីរោះ តែជាការជេរអ្នកទល់មុខត្រង់ៗ មិនចាំបាច់ក្រែងចិត្តមនុស្សដែលគ្មានសច្ចៈ ធ្វើឱ្យលោកស្រីថ្លោះទឹកមុខ និង មើលទៅជុំវិញខ្លួន ឃើញអ្នកដែលកំពុងដើរកាត់ងាកមកមើលក៏ខ្មាស ទើប

រាប់លុយគ្រប់ចំនួន ហុចឱ្យ។

នាងទទួលយកលុយដោយទឹកមុខញញឹម ព្រមទាំងឱនក្បាលបន្តិច ដាក់ ដោយគិតក្នុងចិត្តថាលើកក្រោយ បើលោកស្រីម្នាក់នេះយករបស់ទៅផ្ញើឱ្យលក់ទៀត នឹងទទួលយក តែមិនរត់រកភ្ញៀវឱ្យ។

ពេលបានលុយគ្រប់ចំនួនហើយ នាងក៏ទៅបណ្ណាគារដើម្បីទិញសៀវភៅដែលមានទិន្នន័យរបស់ប្រទេសមិនធ្លាប់ឮឈ្មោះនោះ ប៉ុន្តែបែរជាគ្មានសៀវភៅប្រភេទនោះ។

ចំជាប្រទេសដែលផ្ងាញ់ផ្ងាលអារម្មណ៍មែន!

ពេលត្រូវរកប្រាក់ឱ្យគ្រប់ចំនួនឱ្យទាន់ដាច់ខែ ទើប អាលិហ្សា ចេះតែ គិតដល់ព័ត៌មាននៃការបើកប្រទេសមីឌីស ប្រទេសនៅមជ្ឈិមបូព៌ា ដែលស្តាប់ឈ្មោះហើយ ធ្វើឱ្យនឹកសមុទ្រខ្សាច់សាហារ៉ា រាជវាំងថ្មដ៏ស្តីមស្តែនៅក្រោម



ដើមត្នោត អាទ្បាដាំង និងហិបសម្បត្តិ។ នាងមិនស្គាល់ប្រទេសនេះ តែដឹងថា
រកប្រាក់ពីទីនោះដោយវិធីណា។

"ខ្ញុំនឹងទៅមីឌីស" នាងប្រកាសនៅតុអាហារ ប្រាកដណាស់ថាពេល
គប់គ្រាប់បែកភ្លាម អ្នកម្តាយក៏ធ្វើមុខដូចហិតផ្សែងធូបច្រើនទៅជាពុល ឯឪពុក
វិញទះតុលាន់ផាំង ធ្វើឱ្យចានក្បានខ្ចាតចេញពីតុ។

"លុយរកមិនទាន់គ្រប់ចំនួនផង ចង់គេចទៅដើរលេងទៀត!"

"ខ្ញុំទៅរកលុយ មិនមែនទៅដើរលេងទេ"

អាលិហ្សា រៀបរាប់ផែនការឱ្យឪពុកម្តាយស្តាប់ត្រួសៗ។

"ហ្សឹក ហ្វារីស ប្រមុខប្រទេសមីឌីសទើបតែបើកប្រទេស កាលពីខែមុន
ដែនដីអណ្តូងប្រេងកាតបែបនោះ តែងតែមានសេដ្ឋដែលមានទ្រព្យសម្បត្តិច្រើន
ខាងនោះបើកប្រទេសបែបនេះគឺដូចបើកផ្លូវឱ្យយើងប្រមូលលុយ ទំនិញរបស់
យើងដឹងតែបំពេញចិត្តភ្ញៀវលំដាប់ប្រទេសបានជាមិនខាន"

"ហ្សឹក គឺជាស្អី ?"

"មិនដឹងដូចគ្នា ប៉ា"

"អ៊ុយៗ មិនបានទេ មិនឱ្យទៅ វាប្រថុយគ្រោះថ្នាក់"

"ម៉ាក់នឹងមិនបានឃើញមុខកូនទៀតទេ កូនមិនខ្លាចចោរសមុទ្រខ្សាច់ចាប់ស្រីៗទៅធ្វើទាសកររទេអី ?"

"ប៉ាម៉ាក់ ស្តាប់ខ្ញុំសិន នេះសតវត្សរ៍ទីម្ភៃមួយហើយ ហើយខ្ញុំក៏មិនទៅម្នាក់ឯងដែរ ខ្ញុំទាក់ទងទៅក្រសួងពាណិជ្ជកម្ម សុំទៅជាមួយដែរ បើយើងចង់លក់ទំនិញ គឺត្រូវទៅរកភ្ញៀវដោយផ្ទាល់"

"មិនបានៗ មិនឱ្យទៅ"

ឪពុកបញ្ជាក់បែបនេះ តែចិត្តវិញ្ញាណ អ៊ុនដៀណា ចូនស៍ ចូលសណ្ឋិតអាលិហ្សា រួចទៅហើយ។ នាងបានទាក់ទងទៅក្រុមការងារមើលការខុសត្រូវផ្នែកនាំទំនិញទៅតាំងពិព័រណ៍នៅបរទេស បានទិន្នន័យត្រឹមថាប្រទេសមីឌីស



ធំៗ ដូចជាសហរដ្ឋអាមេរិក កាណាដា អង់គ្លេស រុស្ស៊ី បារាំង ជប៉ុន ចិន តៃវ៉ាន់ កូរ៉េខាងត្បូង ត្រូវបានអញ្ជើញ ចំណែកអ្នកប្រកបរបរឯករាជអស់សិទ្ធិហើយនៅឆ្នាំនេះ ត្រូវរង់ចាំដើមឆ្នាំ ទើបមានការរៀបចំកម្មវិធីធំម្តងទៀត តែនោះសម្រាប់អ្នកផ្សេង ចំណែកកូនស្រីអ្នករកស៊ីដូចនាងគឺខាំមិនព្រមលែងដាច់ខាត។

ចិននិងតៃវ៉ាន់មិនត្រូវគ្នា ដូច្នេះហើយនាងត្រូវសំដៅរកតៃវ៉ាន់ ទោះមានតែស្ថានកុងស៊ុល ក៏មិនមែនបញ្ហាសម្រាប់នាង។ នាងនិយាយភាសាចិនផ្លូវការបានល្អ ព្រោះមានម្តាយជាជនជាតិចិនតៃវ៉ាន់ និងភាសាអង់គ្លេសស្ទាត់ជំនាញ ទើបស្គាល់មន្ត្រីនៅតៃវ៉ាន់ច្រើនរូប ព្រោះជាភ្ញៀវទិញលក់ត្បូងមណីជាមួយគ្នានិងច្រើនដងហើយ ដែលនាងបានចេញចូលអគារសេដ្ឋកិច្ចនិងវប្បធម៌តៃប៉ិ ប្រចាំសាធារណរដ្ឋកូរ៉េក្នុងឋាន:ជាឈ្មួញត្បូងមណី គួបតំណែងម្ចាស់បំណុល។ ថ្ងៃនេះនាងនាំយកគំរូទំនិញដែលត្រូវយកទៅតាំងពិព័រណ៍មកជាមួយ ហើយ

បុគ្គលដែលត្រូវមកជួបគឺប្រធានពាណិជ្ជកម្ម មីស្ទ័រ ស្ទឺ។

"នាងខ្ញុំដឹងថាខាងតៃវ៉ាន់ក៏មានឈ្មោះបោះសំឡេងផ្នែកគ្រឿងអលង្ការដែរ តែឆ្នាំនេះមិនទាន់នាំទំនិញប្រភេទនេះចេញទៅទេ ទើបនាងខ្ញុំសុំធ្វើជាតំណាងនាំទៅក្នុងនាមតៃវ៉ាន់"

"ក្រែងថាខ្ញុំមិនអាចជួយអ្នកនាងបាន រឿងនាំទំនិញដាក់តាំងពិព័រណ៍ជាទំនួលខុសត្រូវរបស់ការិយាល័យកណ្តាល ខ្ញុំគ្មានសិទ្ធិចូលទៅជៀតជ្រែកទេ"

"នាងខ្ញុំបានឮថា ចិនប្រើឥទ្ធិពលបង្គាប់បង្ខំឱ្យតៃវ៉ាបានទីតាំងមិនល្អភ្ញៀវដែលចូលទៅទស្សនាមិនទាំងដឹងផងថា មានបញ្ជររបស់តៃវ៉ាន់ ថ្ងៃនេះជាថ្ងៃទីបួនហើយ សល់ដប់ថ្ងៃទៀត គឺអាចគ្មានភ្ញៀវមែនក៏ថាបាន តើមែនទេ?"

អាលិហ្សា ចូលចំចំណុចតែម្តង ទោះមីស្ទ័រ ស្ទឺ មិនតបត តែនាងដឹងថាគេកំពុងយកចិត្តទុកដាក់ស្តាប់។

"បើនាងខ្ញុំអាចហៅភ្ញៀវឱ្យចូលមកទស្សនានៅបញ្ជរតៃវ៉ាន់បាន នាងខ្ញុំ



សុំទីតាំងតែប្រាំមួយម៉ែត្រការ៉េប៉ុណ្ណោះ បើខាងលោកឃើញថានាងខ្ញុំធ្វើមិន
បានតាមការស្នើសុំ ឬធ្វើអ្វីឱ្យខូចខាតដល់ផលប្រយោជន៍របស់តៃវ៉ាន់ នាងខ្ញុំ
រីករាយធ្វើតាមការសម្រេចរបស់អ្នកមើលការខុសត្រូវ ដោយគ្មានលក្ខខណ្ឌ បើ
នាងខ្ញុំធ្វើបានល្អ នោះគឺជាការត្រួសត្រាយផ្លូវឱ្យជំនួញត្បូងមណីរបស់តៃវ៉ាន់"

មីស្ស័រ ស្វីអង្អែលចង្កាដោយការសញ្ជឹងគិត។បញ្ហារបស់ប្រទេសនីមួយៗ
មានផ្ទៃក្រឡាជិតពីររយម៉ែត្រការ៉ េ សុទ្ធតែធ្វើការប្រកួតប្រជែងគ្នាយ៉ាងក្តៅគគុក
ជាពិសេសចិន និងសហរដ្ឋអាមេរិក អាចនិយាយថាលេចធ្លោជាងគេជាងឯង
ទើបធ្វើឱ្យបញ្ហារប្រទេសផ្សេងអាប់រស្មី ចំណែកបញ្ហារបស់តៃវ៉ាន់កាន់តែស្ងាត់
ព្រោះត្រូវអនុញ្ញាតឱ្យមានទីតាំងនៅឆ្ងាយពីចំណុចសំខាន់ៗ ទោះទំនិញមាន
ភាពទាក់ទាញចំណាប់អារម្មណ៍យ៉ាងណាក៏ដោយ។

មួយសន្ទុះក្រោយមក មីស្ស័រ ស្វី ក៏សុំទៅនិយាយទូរសព្ទ ហើយពេល
ត្រឡប់មកវិញ សម្តីរបស់គេ ធ្វើឱ្យនាងញញឹមបិទមាត់មិនជិត។

"អ្នកនាងអាចធ្វើដំណើរបានពេលណា ?"

"នាងខ្ញុំអាចធ្វើដំណើរបានគ្រប់ពេល"

ទើបយប់នោះ អាលិហ្សា ក៏ចេញដំណើរទៅមីឌីស ដោយមិនបានប្រាប់

អ្នកផ្ទះសូម្បីមួយម៉ាត់។



៣

លក់ដាច់ពេក ទាល់តែបានចូលភ័ង

"សូមស្វាគមន៍អ្នកដំណើរគ្រប់រូប មកកាន់អាកាសយានដ្ឋានអន្តរជាតិ ហ្វារីស ម៉ោងក្នុងតំបន់របស់ប្រទេសមីឌីសនៅវេលានេះគឺម៉ោងដប់ព្រឹក"

បុគ្គលិកនៅលើយន្តហោះប្រកាសពេលយន្តហោះកំពុងបន្ទាបខ្លួនដើម្បីចុះចតនៅក្នុងពេលដប់ប្រាំនាទីខាងមុខ។

អាលិហ្សា គ្រញែងស្មា ដើម្បីបណ្តេញភាពរុករួយ បន្ទាប់ពីចំណាយពេលហោះហើរឆ្លងវេហាអស់រយៈពេលជាច្រើនម៉ោង។ ជនជាតិមជ្ឈិមបូព៌ាដែលធ្វើដំណើរមកជាមួយគ្នា ពេលឆ្លងផុតការត្រួតពិនិត្យហើយ ក៏ទៅផ្លាស់ខោអាវជាឯកសណ្ឋានប្រចាំជាតិ ដែលជាឈុតពណ៌សសម្រុងដល់កជើង ស្បែឃ្លុំក្បាល

សម្រុងដល់ស្មា និងប្រើស្បែឃ្លុំក្បាលនោះក្រាលនឹងកម្រាលពេលលុតជង្គង់
សូត្រមន្តតាមគោលការណ៍សាសនា។

អាកាសយានដ្ឋាននេះមានអាយុកាលចំណាស់ មានស្ពានសម្រាប់ទទួលកាបូបតែមួយប៉ុណ្ណោះ។

អាលិហ្សា មិនចង់ធ្វើខ្លួនឱ្យលេចធ្លោ ទើបតែងខ្លួនមានរបៀប អាវដៃវែងខោជើងវែង ក្រសោបសក់ដាក់ក្នុងស្បែឃ្លុំសក់ តែនាងជាជនជាតិអាស៊ីតែម្នាក់គត់នៅក្នុងជើងហោះហើរនេះ ទើបជួយមិនបានទេដែលទទួលបានការចាប់អារម្មណ៍។

នាងឱបកាបូបជាប់ ពេលតម្រង់ជួរចុះពីយន្តហោះ និងទៅទាក់ទងរឿងសុំលើកលែងការបង់ពន្ធជាករណីពិសេស ដោយប្រើប្រាស់ឯកសារដែលខាងតែវ៉ាន់ផ្តល់ឱ្យ។ ទំនិញដែលនាងយកមកមានខ្សែក ខ្សែដៃ ចិញ្ចៀន ក្រវិលកងដៃ និងត្បូងគ្រប់ប្រភេទគ្រប់ទំហំ ដូចជា ត្បូងកណ្តៀងមួយគ្រាប់មានទំហំ



មួយការ៉ាត់ គុណភាពល្អ មានស្លាកតម្លៃបញ្ជាក់ ស៊ីទ្រីនពណ៌ស្អាតៗពីស៊ីឡន

ទាំងតូចទាំងធំ មានតម្លៃសមរម្យ និងត្បូងលេចធ្លោដែលនាងមានមោទនភាព

ថាត្រូវតែបានថ្លៃគឺត្បូងទទឹម ដែលត្បូងនិងគ្រឿងអលង្ការទាំងអស់មានលិខិត

បញ្ជាក់ពីស្ថាប័នត្បូងមណីដែលត្រូវស្តង់ដាអន្តរជាតិ។

មីឌីស ចំ៎ ឈ្នួញស្រីមកប្រមូលលុយហើយ!

តែពេលឈានជើងចេញពីទ្វារថឺមិណាល់ក៏ជួបធូលី និងខ្សាច់ក្តៅគគុក

តែអាកាសជាតុរងា។

"មីឌីសជាប្រទេសនាំចេញប្រេង និងហ្គាសធម្មជាតិលំដាប់ពិភពលោក

ស្វាគមន៍មកកាន់មីឌីស"

បុរសវ័យចាស់ និយាយភាសាអង់គ្លេសបានល្អ បបួលនិយាយ និង

អញ្ជើញនាងឱ្យប្រើប្រាស់សេវាកម្មតាក់ស៊ីរបស់គេ។

អាលិហ្សា មើលទ្បានចាស់ហើយ មានអារម្មណ៍មិនសូវស្រួល តែពេល

អើតមើលទ្បានផ្សេងហើយ ឃើញថាមានសភាពមិនខុសគ្នា ទើបតថ្លៃ ហើយ
ទ្បើងទ្បានរបស់គេ។

"ខ្ញុំស្មានថាទីនេះរីកចម្រើនជាងនេះតើ"

"យើងបិទប្រទេសយូរហើយ ទើបខួងអណ្តូងប្រេងកាតឱ្យប្រាកដប្រជា
កាលពីជិតដប់ឆ្នាំមុននេះឯង ប្រទេសជាតិមានការអភិវឌ្ឍយឺតយ៉ាវអ្ហ៎! នៅមាន
កុលសម្ព័ន្ធចល័តធ្វើដំណើរតែពីសតែពាសក្នុងសមុទ្រខ្សាច់ ដោយមិនខ្វល់ពី
រឿងព្រំដែន ហ្សឺក ហ្វារីស ប្រកាសបើកប្រទេស និងដាក់ផែនការកែប្រែដ៏ធំ
ប្រហែលពីរបីឆ្នាំទៀត ទើបក្រុងថ្មីរៀបចំរួចរាល់ បានដំណឹងថានឹងកែប្រែឱ្យ
រីកចម្រើនជាងឌូបៃទៅទៀត"

"អស្ចារ្យណាស់"

"ហ្សឺក ហ្វារីស ពូកែណាស់ ទ្រង់ចុះធ្វើការក្នុងឋាន:ជាអ្នកជំនួញ ចរចា
ស្វែងរកផលប្រយោជន៍ឱ្យមីឌីសដោយផ្ចាល់ព្រះអង្គ កសាងមហាវិទ្យាល័យ



កសាងមន្ទីរពេទ្យ រៀបចំប្រព័ន្ធសេវាសាធារណៈថ្មីទាំងអស់ ហើយកែប្រែ

សារមន្ទីរទូទាំងពិភពលោក ចាត់ទុកថាទ្រង់សំណាងល្អដែលមានហ្សឺក សារីហ្វ

ព្រះអនុជជាដៃស្តាំ មើលការខុសត្រូវការខួងប្រេងកាត និងការនាំចេញ"

អំតាក់សីព្រោកប្រាជ្ញកាន់តែវែងឆ្ងាយ អាលិហ្សា ស្តាប់ខ្លះ មិនស្តាប់ខ្លះ

ដោយមិនសូវយកចិត្តទុកដាក់ប៉ុន្មាន បានឮត្រឹមថាហ្សឺកព្រះរៀមជាមនុស្សកាច

ចំណែកហ្សឺកដែលជាព្រះអនុជកាចស្ងួយគុណ ពីរនាក់បងប្អូនបែងចែកទឹកដី

ដើម្បីគ្រប់គ្រងដែលតំបន់ហ្វេសសានជាប្រភពខួងយកប្រេងពាលជាងរាជធានី

ឆ្ងាយណាស់។

"បើចង់យកទំនិញទៅលក់ក្នុងវាំង ត្រូវទៅជាមួយអ្នកណាដែរ អ៊ំ?"

"ណូៗ បើរាជវង្សានុវង្សនៅក្នុងវាំងមិនហៅ កុំសង្ឃឹមថាបានបៀតរបង

វាំងឱ្យសោះ"

បញ្ជាក់ថាបើអ្នកទិញមិនស្គាល់អ្នកលក់គឺចប់ជាស្ថាពរ!

ឈ្មោះក្នុងស្រទាប់អភិជន សុំពេលគិតបន្តិចសិន តែពេលនេះនាងនិងអ៊ំតាក់ស៊ី

ព្រោកប្រាជ្ញជិតមួយម៉ោងហើយ តែឡានមិនព្រមរត់ចូលក្នុងក្រុងសោះ។

"យូរទេ ទម្រាំដល់សណ្ឋាគារ អ៊ំ?"

"ពីរម៉ោងទៀត ប្រហែលដល់"

"ហ៉ា! ខ្ញុំហោះឆ្លងទឹកឆ្លងសមុទ្ររាប់ពាន់គីឡូម៉ែត្រ ចំណាយពេល

រាប់សិបម៉ោង តែត្រូវចំណាយពេលបីម៉ោងដើម្បីចូលក្រុងឬ អ៊ំ?"

"ឱ្យធ្វើម៉េចចុះ បើផ្លូវត្រូវបិទ ដើម្បីជួសជុល ផ្លូវមួយទៀតកំពុងសាងសង់

ផ្លូវរថភ្លើង ចំណែកផ្លូវខាងនុះកំពុងសាងសង់ផ្លូវលឿន នេះផ្លូវកាត់ដែលជិត

ជាងគេហើយ"

អ៊ំតាក់ស៊ីរៀបរាប់ដោយការងឿងឆ្ងល់ថា គ្រាន់តែស្នះផ្លូវប៉ុណ្ណឹង ឡូឡា

ធ្វើអី។



ពេលជួបនឹងមន្ត្រីប្រចាំកន្លែងទទួលអ្នកដំណើរដែលសោះកក្រោះ នាង
មិនសូវមួម៉ៅប៉ុន្មាន តែពេលមកជួបនឹងស្ថានការណ៍ចរាចរណ៍កកស្ទះធ្ងន់ធ្ងរ វា
ធ្វើឱ្យនាងចង់ឆ្កួតតែម្តង។ ផ្លូវថ្នល់នៅរាជធានីចាត់ទុកថាធំទូលាយ តែចំនួន
យានយន្ត ផ្លូវថ្នល់មិនអាចទ្រទ្រង់រួច ទ្បាននីមួយៗ វ៉ាឆ្វេងវ៉ាស្តាំដោយមិនខ្វល់
ពីគំនូសបែងចែកផ្លូវ អ្នកឆ្លងផ្លូវក៏ខ្លាំងដៃណាស់ដែរ ឆ្លងផ្លូវគ្រប់ពេលគ្រប់វេលា
ដោយមិនខ្វល់ភ្លើងបៃតង ឬភ្លើងក្រហម មិនចាប់អារម្មណ៍ផ្លូវថ្មើរជើង និងមិន
ខ្លាចត្រូវទ្បានបុក។ ទោះស្ថានការណ៍ចរាចរណ៍គួរឱ្យមួម៉ៅប៉ុនណា ប៉ុន្តែបែរជា
គ្មានអ្នកណាទ្បូទ្បា រករឿងជេរបញ្ជោរឱ្យខូចបរិយាកាស រួមទាំងគ្មានសំឡេង
ចុចស៊ីហ្គេឱ្យថ្លង់ដូចនៅប្រទេសមួយចំនួន។

នៅតាមផ្លូវ មើលឃើញអគារផ្សាយសំឡេង និងអគារមានដំបូលកោង
របស់វិហារអ៊ីស្លាមពេញទីក្រុង ដែលវិហារខ្លះមានទំហំតូច នៅលាយឡំក្នុង
ទីប្រជុំជន វិហារខ្លះមានទំហំធំមានទ្វារកោង ឬកញ្ចក់ដ៏វិចិត្រ។ សំឡេងប្រកាស

ឱ្យសូត្រធម៌ថ្វាយបង្គំព្រះពីក្បាលមេក្រូឮពេញទីក្រុង ដែលមិនទាន់សុំ ទើប
មានអារម្មណ៍ប្លែកៗ។

អ្នកនៅទីនេះមិនបង្ហាញសាច់បង្ហាញឈាមនៅទីសាធារណៈដាច់ខាត
មិនដូច្នោះនឹងត្រូវចាត់ទុកថាមានកំហុស បើជាបុរសត្រូវពាក់អាវដៃវែង សម្រុង
ដល់កជើង ពាក់មួកវាងមូលពីលើស្បែឃ្មុំក្បាល ចងដោយខ្សែខ្មៅ ចំណែកស្ត្រី
ពាក់ស្បែឃ្មុំក្បាលពណ៌ស្រស់ និងពាក់អាវវែង តែនាងជឿថានៅក្រោមក្រណាត់
វែងៗ ទាំងនោះ ស្រីៗទាំងនោះតែងខ្លួនតាមហ្វេសិន និងផាត់មុខផាត់មាត់
ដោយគ្រឿងសម្អាង។

"មីឌីសស្ថិតនៅចន្លោះរវាងអាស៊ីនិងអឺរ៉ុប ទើបប្រជាជនមានចម្រុះពណ៌
សម្បុរ ច្រើនជាតិសាសន៍"

អំតាក់ស៊ីមានទឹកចិត្តបើកកាត់បាសារ៍ ឬផ្សារ ដែលជាប្រភពនៃការ
ជួញដូរ ប្រមូលផ្តុំទៅដោយមនុស្សម្នាមកពីទូទាំងពិភពលោក របស់របរដែល



ដាក់លក់មានទាំងគ្រឿងទេស របស់ស្រស់ៗ សម្លៀកបំពាក់ សម្ភារក្នុងផ្ទះបាយ

របស់របរតុបតែងផ្ទះ ដែលភាគច្រើនជារបស់ក្នុងតំបន់ និងនាំចូលមកពីប្រទេស

ជិតខាង ហើយបើទិញរបស់ដែលមានម៉ាកមកពីលោកខាងលិចគឺត្រូវទិញនៅ

ហាងទំនិញរបស់រដ្ឋបាលប៉ុណ្ណោះ។

មីឌីសទើបតែបើកប្រទេស ទើបមានរឿងជាច្រើនដែលត្រូវកែប្រែ និង

ពង្រីក នាពេលអនាគតនឹងបើកទីផ្សារសេរី ដែលជាការបើកឱកាសឱ្យមាន

ជំនួញមហាសាល ហើយប្រាកដណាស់ថានៅបាសារ៍ស្ទះផ្លូវណាស់ តើអ៊ំជិះ

កាត់ធ្វើអី?។

សុខៗទ្វារឡានក៏ត្រូវអ្នកណាមិនដឹងបើក ហើយមានបុរសពីរនាក់ចូល

មកអង្គុយ ព្រមទាំងរាក់ទាក់ hello where are you come from? ដែល

ធ្វើឱ្យនាងបុកពោះ ព្រោះអីវ៉ាន់ដែលខំដឹកជញ្ជូនមកមានតម្លៃមហាសាល ទើប

អង្គុយរឹងខ្លួនស្អក រិះរកផ្លូវរត់ ប៉ុន្តែពេលឡានលូនចេញទៅបានពីរផ្លូវ បុរសពីរ

នាក់នោះក៏ឱ្យលុយអំតាក់ស៊ី ហើយបើកទ្វារចុះ បន្ទាប់មកក៏មានពីរនាក់ម្តាយ
កូនចូលមកជំនួស ទើបនាងបានយល់ដឹងថាតាក់ស៊ីនៅទីនេះអាចដាក់ភ្ញៀវនៅ
តាមផ្លូវបាន ក្នុងករណីទៅផ្លូវស្រប ទើបមានមនុស្សឡើងចុះជាហូរហែ។

"ហេតុអីឡានមិនកម្រើកអីចឹងអ៊ំ ?"

"គេបិទផ្លូវ មានក្បួនរបស់រាជវង្ស ឮថាជា ហ្សឹក សារីហ្វ"

ហ៊ឺយ!

នាងចង់ខ្ចៅមុខនរណាម្នាក់ ប៉ុន្តែយ៉ាងណាបានជាជិះឡានអ៊ំយូរសឹង
តែកើតបបូសគូទទៅហើយ ទើបប្រាប់ឱ្យគេជូនទៅហាងគ្រឿងអលង្ការដែលធំ
បំផុតនៅក្នុងក្រុង។

"នុះ!"

"ឯណា មានតែហាងលក់ខោអាវ"

"ហាងលក់ខោអាវហ្នឹងហើយ គេលក់ពេជ្រលក់ត្បូងដែរ សុទ្ធ ឬមិនសុទ្ធ



គឺត្រូវពឹងរាសីខ្លួនឯង"

អាលិហ្សា មើលតាមចង្កុលដៃរបស់អ៊ំតាក់ស៊ី ឃើញតែអគារពណ៌ដី ដែលលក់របស់របរច្រើន ហើយពេលសង្កេតឱ្យច្បាស់ទើបឃើញស្លាកហាង ទើបនាងប្រមូលទិន្នន័យជាបន្តបន្ទាប់ថា មិនធ្លាប់មានក្រុមហ៊ុនរឿងអលង្ការអន្តរជាតិមកបើកនៅទីនេះ ពេលចង់លក់ចង់ដូរគឺត្រូវហោះហើរទៅបរទេស នោះមានន័យថាទីនេះសំបូរទៅដោយឱកាសធ្វើជំនួញ ទើបចិត្តវិញ្ញាណកូនស្រីរបស់អ្នកលក់ដូរធ្វើការភ្លាម។

"ស៊ុប-ប៉ា-មេហ៍ អរុណសួស្តី"

អ៊ំនៅទំនេរៗ ទើបបង្រៀនពាក្យរាក់ទាក់សាមញ្ញៗ ឱ្យចេះ ប៉ុន្តែនាងបញ្ចេញសំឡេងតាមពិបាក បើចង់រាក់ទាក់បែបមិនរើសភេទ ឬពេលវេលា ត្រូវប្រើពាក្យថា ***សា-ឡាម*** នោះមិត្តភាពពីជនជាតិមីឌីសនឹងហូរចូលមកមិនដាច់ខ្សែ ហើយអ៊ំក៏បន្តដោយពាក្យថា ***មេក-ស៊ី*** ប្រែថា ***អរគុណ*** កម្ចីភាសាបារាំង។

ពេលមកដល់សណ្ឋាគារ មុនពេលដើរញ័រជើងទៅឆែកអ៊ីន អាលិហ្សា ក៏ពិចារណាធនធានរបស់អ្នកនៅទីនេះ នៅវេលានេះ ពេលឃើញឡានដែលដូចកម្ទេចដែករត់ពេញផ្លូវថ្នល់ឈ្នួញក្រមុំក៏ស្រងាកចិត្តព្រោះបើខាតទុនត្រឡប់ទៅផ្ទះវិញ ត្រូវឪពុកជេរបីថ្ងៃបីយប់មិនខាន ប៉ុន្តែពេលឃើញអ្នកដើរទិញអីវ៉ាន់ហូតលុយពីកាបូបដូចហូតក្រដាស នាងក៏បើកភ្នែកធំៗ យល់ហើយថាហេតុអ្វីបានជាពិភពលោកចាប់អារម្មណ៍គជ់នៃមជ្ឈិមបូព៌ាមួយគ្រាប់នេះ ដែលអត្រានៃភាពរីកចម្រើនរបស់ប្រទេសមីឌីស អាចនិយាយបានថាគួរឱ្យស្ងើចសរសើរ។

សណ្ឋាគារដែលនាងស្នាក់នៅស្ថិតនៅតំបន់សេដ្ឋកិច្ច និងជិតកន្លែងតាំងពិព័រណ៍ទំនិញអន្តរជាតិ ទិដ្ឋភាពក៏ល្អណាស់ដែរ ពេលបើកវាំងននក៏មើលឃើញជញ្ជាំង ដែលខាងសណ្ឋាគារគូររូបសមុទ្រខ្សាច់ និងអូដ្ឋ ទុកឱ្យភ្ញៀវធ្វើការស្រមើស្រមៃ។ កម្មវិធីទូរទស្សន៍មានតែព័ត៌មាន និងឯកសារ ដែលទាញ



យកស៊ីញ្ជាល់មកពីប្រទេសលីបង់ ចំណែកកម្មវិធីដែលផិតដោយហូលីវូដ និង
កម្មវិធីដែលមានខ្លឹមសារហិង្សា និងផ្លូវភេទ ចាត់ទុកថាជារឿងហាមប្រាម។

ពេលគ្មានអ្វីឱ្យមើលបែបនេះ ទើប អាលិហ្សា ម្ដីម្នាចូលងូតទឹក និងធ្វើ
ការហ្វឹកហាត់ភាសាព័រសៀ ពាក្យសាមញ្ញៗ ពីរបីប្រយោគ ហើយចូលដេក។

បន្ទាប់ពីសម្រាកគ្រប់គ្រាន់ និងទទួលទានអាហារពេលព្រឹកបែបអឺរ៉ុប
នៅសណ្ឋាគាររួចរាល់ មនុស្សរបស់រដ្ឋបាលតៃវ៉ាន់ដែលមកទទួល និងណែនាំ
ថាឈ្មោះមីស្ទ័រ វ៉ាង និងជាអ្នកសម្របសម្រួលឱ្យនាងតាំងពីថ្ងៃនេះ រហូតដល់
ថ្ងៃចប់កម្មវិធី។

"រីករាយដែលបានស្គាល់ មិស ឈិន"

គេចាប់ដៃរាក់ទាក់ ណែនាំ និងហៅនាងតាមនាមត្រកូលដែលបង្ហាញ
ក្នុងលិខិតឆ្លងដែន ហើយអញ្ជើញនាងឡើងឡានធំ ផ្តល់កិត្តិយសក្នុងហាន:ជា
បុគ្គលដែលការិយាល័យកណ្តាលណែនាំ ប៉ុន្តែពេលសួរនាំត្រួសៗ ទើបដឹងថា

ទើបកាយវិការរបស់គេដែលមានចំពោះនាងមានភាពប្រែប្រួល។

"សង្ឃឹមថាមិសនឹងមានវិធីដោះស្រាយបញ្ហារបស់យើងបាន"

"ប្រាកដណាស់"

អាលិហ្សា សុភាពរាបសារ តែងខ្លួនដោយអាវដៃវែងពណ៌បៃតងខ្ចី ពាក់អាវគ្រែរហ្សេពណ៌ស ស្លៀកខោជើងវែង ពាក់ស្បែកជើងខឺតស៊ូពណ៌ដី មើលទៅថ្លៃថ្នូរ ពាក់ស្បែឃ្មុំសក់មានរបៀបជាផ្លូវការ និងព្យួរកាតបុគ្គលិករបស់តៃវ៉ាន់ជាប់នឹង.ក ហើយបន្ទាប់ពីនោះគឺការទៅប្រឈមមុខនឹងសង្គ្រាមពាណិជ្ជកម្មដែលនាងជឿថាត្រូវតែឈ្នះ។

បញ្ជររបស់តៃវ៉ាន់ស្ទើរតែគ្មានមនុស្សដើរកាត់ ព្រោះត្រូវរៀបចំឱ្យនៅឆ្ងាយពីកន្លែងសំខាន់ ហើយទំនិញទាំងឡាយក៏ត្រូវខាងប្រទេសចិន និងជប៉ុនបិទផ្លូវ ទើបបរិយាកាសស្ងប់ស្ងាត់ និងកណ្តោចកណ្តែង។ មនុស្សរបស់តៃវ៉ាន់



អន្ទះអន្ទែងខ្លាំងណាស់ ព្រោះមិនដឹងថាដោះស្រាយបញ្ហាដោយវិធីណា គ្រប់

គ្នាមើលមកនាងដែលត្រូវប្រគល់តួនាទីហៅភ្ញៀវចូលបញ្ជរ ខណៈនោះបាន

ពិចារណាហើយថា ស្រីស្អាតម្នាក់នោះប្រហែលប្រើរូបសម្រស់ទាក់ទាញភ្ញៀវ

ប៉ុន្តែខាងគេក៏មានក្រុមស្រីស្អាតចាំចាត់ការរឿងនេះរួចហើយ ទើបគិតមិនចេញ

ថា អាលិហ្សា នឹងចាត់ការយ៉ាងណា។

"របស់ដែលកុម៉្មង់ឱ្យធ្វើ បានហើយមែនទេ ?"

"បាទ"

"អីចឹងសម្រុកចូល"

នាងផ្ចាត់ម្រាមដៃជាសញ្ញានៃការធ្វើការ។ វិធីសាស្ត្រសាមញ្ញៗដែល

នាងប្រើគឺកុម៉្មង់ឱ្យធ្វើកាក់មាសពណ៌លឿងតូចៗ ជាច្រើន ហើយយកទៅចែក

ចាយតាមទីតាំងនានា មនុស្សម្នាដែលដើរកាត់ ឃើញកាក់មាសចាំងពន្លឺ និង

ចូលមកយក និងមើលឃើញការប្រកាសថា បើនរណាមានកាក់នេះ គឺអាច

យកទៅដូររង្វាន់នៅបញ្ជរតែវ៉ាន់បាន ដែលលទ្ធផលគឺបញ្ជរមានមនុស្សច្រើន។

រង្វាន់ដែលថានោះ គឺបន្តោងសោអនុស្សាវរីយមានពាក្យថា **កាលីម៉ា សាដាហាហ៍** (*ពាក្យស្រង់ចេញពីព្រះគម្ពីរអាល់គុរអាន ជាការប្រណិធានចំពោះខ្លួនឯងយកសាសនាអ៊ីស្លាមជាសាសនារបស់ខ្លួន*) ដែលមូស្លីមចូលចិត្តខ្លាំង ទើបមានមនុស្សម្នាសំដៅមកបញ្ជរតែវ៉ាន់ស្ទូកទឹកស្ទូកដី ធ្វើឱ្យបញ្ជរដែលគ្មានអ្នកណាស្គាល់ គ្មានអ្នកណាចាប់អារម្មណ៍ មានមនុស្សច្រើនកុះករ ចំនួននៃការលក់ក៏កើនទ្បើង ហើយប្រាកដណាស់ថា អាលិហ្សា ដំណើរការផែនការវគ្គបន្ត ព្រោះនាងចង់ឱ្យភ្ញៀវដែលទិញគ្រឿងអលង្ការត្រូវនឹកដល់នាងមុនគេ ដែលវិធីរបស់នាងមិនពិបាក ឬស្មុគស្មាញ ត្រឹមប្រើកលយុទ្ធខ្លីដាវសម្លាប់មនុស្សធម្មតាៗ ដោយការឱ្យភ្ញៀវ លគ្រឿងអលង្ការស្អាតៗ ថតរូបបង្ហោះតាមបណ្តាញសង្គម។

បណ្តាភរិយាមហាសេដ្ឋីក្នុងសង្គមដែលបិតទ្វារយូរមកហើយ ឃើញផែនការទីផ្សារបែបនេះហើយ គឺគ្មានអ្នកណាព្រមចាញ់អ្នកណា ប្រញាប់មករក



វប្បធម៌របស់គ្រួសារមូស្លីម ដែលមានភរិយាដល់ទៅបួននាក់ បើភរិយាម្នាក់ណា ចង់បានអ្វីហើយ ស្វាមីគឺត្រូវតែទិញឱ្យគ្រប់បួន ដើម្បីឱ្យស្មើភាពគ្នា ដែលធ្វើឱ្យ ចំនួននៃការលក់របស់នាងគុណនឹងបួនដង លក់របស់ដាច់ដូចចាក់ទឹកចោល ហើយស្មៀតសំខាន់របស់នាងគឺ...

"ខូ-ដា-ហា-ហ្វេស"

អំតាក់ស៊ីជាអ្នកបង្រៀនពាក្យនេះដល់នាង ពាក្យលាទូទៅ ឬប្រើពាក្យ បាយៗ ក៏បាន ប៉ុន្តែបើចង់ឱ្យជនជាតិមីឌីសស្តាប់ហើយត្រូវចិត្តត្រូវថ្លើម ដល់ ថ្នាក់អាឡោះអាល័យ គឺត្រូវតែប្រើពាក្យ *ខូ-ដា-ហា-ហ្វេស* ភ្ញៀវមួយរយទាំង មួយរយស្តាប់ហើយក៏បានលទ្ធផល ទិញអីវ៉ាន់ម្តងហើយ ក៏ត្រឡប់មកទិញ ម្តងទៀត ដង្ហែគ្នាមករក ដល់ថ្នាក់ឈ្មួញក្រមុំរកពេលញ៉ាំបាយញ៉ាំទឹកគ្មាន។

នៅមុខបញ្ជរលក់គ្រឿងអលង្ការតូចតាចរបស់ អាលិហ្សា ពេលនេះមាន

កូនស្រីមហាសេដ្ឋីនៃមីឌីសក៏មានដែរ ពួកនាងជាភ្ញៀវវីអាយភី អ្នកខ្លះដើរមក សម្លឹងត្បូងមណី ដោយមិននិយាយ មិនសួរនាំ មិនតថ្លៃមួយម៉ាត់ តែចង្អុលប្រាប់ និងពេលគិតលុយរួចក៏ដើរចេញទៅ ដែលធ្វើឱ្យអ្នកលក់ឆ្ងល់។

ពេលនេះនាងឈប់ស្តែសរឿងលុយហើយ តែស្តែសរឿងរបស់មានមិនគ្រប់លក់ ព្រោះត្រឹមដាក់លក់ថ្ងៃដំបូងក៏ត្រូវព្យរស្លាកប្រកាសថាអស់ទំនិញ។ នាងអាចដាក់តម្លៃលក់ បានកម្រៃច្រើន និងមានប៉ុនណាក៏មិនគ្រប់លក់ ថ្ងៃបន្ទាប់មកក៏ប្រមូលបានការកុម្ម៉ង់ច្រើនទៀត ម្តងនេះឪពុកមិនជេររឿងខ្វះលុយទេ តែជេរថាកុំទទួលការកុម្ម៉ង់ច្រើនពេក ជាងធ្វើមិនទាន់។

ពេលលក់ដាច់បែបនេះ នាងក៏កើតគំនិតចង់បើកហាងនៅមីឌីសតែម្តង ទើបពិភាក្សាជាមួយមីស្ទ័រ ស្វី ដើម្បីរកច្រក។

"មិនបានទេ បើជនជាតិបរទេសត្រូវការធ្វើការរកស៊ី គឺត្រូវទទួលបាន



ការអនុញ្ញាតពីក្នុងវាំងជាមុន ដែលទម្រាំរត់ការបានត្រូវឆ្លងកាត់ច្រើនដំណាក់ ណាស់ ទម្រាំបានត្រាប្រថាប់ ចំណាយពេលជិតកន្លះឆ្នាំ"

មីស្ទ័រ ស្វី និយាយមិនទាន់ដាច់ពីមាត់ផង មនុស្សមកពីក្នុងវាំងក៏ត្រសុលចូលមកសុំជួប មិស ឈិន។

"សម្តេចព្រះមាតារបស់ហ្សឺក ហ្វារីស សព្វព្រះទ័យជាងត្បូងពី មិស ឈិន មិនដឹងថាអាចចូលគាល់ទ្រង់ឥឡូវនេះបានទេ ?"

"នាងខ្ញុំចូលបាន ចូលបានមួយទំហឹង"

មីស្ទ័រ ស្វី ចំហាមាត់ធ្លុង ខណៈដែល អាលិហ្សា ឱនក្បាលគំនាប់ដោយក្តីរីករាយ។ ភ្ញៀវដែលនាងត្រូវការលក់ដូរពិតប្រាកដគឺព្រះញាតិវង្ស ព្រោះដឹងថាក្រុមស្ត្រីជាន់ខ្ពស់តែងតែទៅមករកគ្នា បើស្ត្រីក្នុងវាំងមានចំណង់ចំណូលចិត្តបែបណាហើយ គឺស្ត្រីនៅក្រៅវាំងត្រូវតែចូលចិត្តតាមដែរ ហើយបើបណ្តាភរិយារបស់អ្នកធំៗ ចូលចិត្តរបស់ណា គឺតែងតែមានឥទ្ធិពលទៅដល់ក្នុងវាំងដូចគ្នា

ពេលដឹងពីគោលការណ៍នេះហើយ ការដុតភ្លើងឱ្យត្រូវចំណុចគឺមិនមែនជារឿង
លំបាកទេ។

គោលដៅដែលនាងកំណត់ទុកមករកលឿងជាងការគិត ទើបត្រៀម
របស់ល្អៗទុក ដែលធានាថាបើដាក់លក់ក្នុងបញ្ជរ ភ្ញៀវទាំងឡាយនឹងបើកភ្នែក
ធំៗ ស្រែកវ៉ាវៗ មិនដាច់ពីមាត់។

អាលិហ្សា តែងតែដាក់ផែនការជាដំណាក់កាល បើអ្នកជំនួញផ្សេងអាច
គិតមិនចេញថាមកដល់ប៉ុប បានចូលវាំងប៉ាប់ តែឈ្មួញក្រមុំតូចម្នាក់នេះគិត
ចេញ។

ហើយនោះគឺជាថ្ងៃដំបូងដែលនាងជួប ហ្សឺក សារីហ្វ អាល់ មីឌីស វ៉ាលី
នៃហ្វេសសាន ព្រះអនុជនៃ ហ្សឺក ហ្វារីស អាល់ មីឌីស។



៤

ចូលភំងថ្មភក់

ផ្លូវដែលឡានលីម៉ូស៊ីនរត់កាត់ ជាផ្លូវដែលមានផែនទីក្រុងតាំងខាងជើង ដល់ខាងត្បូង មានដើមឈើធំៗ អមសងខាងផ្លូវ ទង់រាជវាំងដែលដោតលើ កាប៉ូលឡានទាំងសងខាង ធ្វើឱ្យផ្លូវស្រឡះល្អ ដោយមិនគួរឱ្យជឿ។ រាជវាំងជា កន្លែងធ្វើការរបស់មន្ត្រីរាជការ ដែលនាងជាប់ចិត្តនឹងចតុរស្សធំនៅកណ្តាល ក្រុងដែលកសាង ដើម្បីជាសារមន្ទីរ និងតំបន់ទេសចរណ៍នាពេលអនាគត អគារផ្ទះសម្បែងមានភាពទាន់សម័យ អគារខ្ពស់ៗ ថ្មីៗ ជាច្រើនកន្លែងនឹងត្រូវ បើកទ្វារឱ្យជនជាតិបរទេសចូលមកធ្វើជំនួញ ខុសពីក្រុងចាស់ដែលនៅតែរក្សា សិល្បៈរចនាបថព័រសៀ និងមិនសូវមានសណ្តាប់ធ្នាប់ប៉ុន្មាន។

មិនយូរប៉ុន្មាន ឡានទំនើបក៏នាំឈ្មួញក្រមុំមកដល់គោលដៅ ស្លាកស្អាត នៅចំពោះមុខសរសេរពាក្យថា នាងមិនច្បាស់ទេ ព្រោះមិនសូវចេះ តែដែលច្បាស់គឺមានទាហានយាមប៉មតាមជ្រុងកំផែងខ្ពស់ៗ ទាហានការពារពាក់ឈុតក្រោះការពារគ្រាប់ និងមួកពេរពណ៌ក្រហម ជើងខោញាត់ចូលស្បែកជើងប៊ូតមានពុកមាត់ពុកចង្កា និងមានអាវុធប្រចាំខ្លួន។

ពេលបើកឡានកាត់ទ្វារបីជាន់ នាងក៏មើលឃើញវាំងថ្មភក់ដែលធ្លាប់អានជួបក្នុងរឿងនិទានអារ៉ាប់ វាពិតជាមានមែន។

ទ្វារឡានត្រូវបើក ចុងជើងរបស់នាងជាន់លើព្រំរោមចៀមដែលក្រាស់និងទន់ល្មើយ តា្បញដោយក្បូរក្បាច់ព័រសៀ ក្រាសវែងអន្លាយចូលទៅដល់តួអគារ ដែលទីនេះជាដំណាក់របស់ ហ្សឺក សារីហ្វ អាល់ មីឌីស។

ដំណាក់ថ្មភក់ ចំណុចលេចធ្លោរបស់វាគឺតួអគារមានពណ៌សស្អាត និងមានទំហំធំល្វឹងល្វើយ ទំនើបប្រណិត ខាងក្រៅជាអគារកម្ពស់បីជាន់ មើលទៅ



សាមញ្ញ មានប៉មខ្ពស់ស្រួចរលែម ដែលខ្ពស់ជាងគេជាងឯងគឺប៉មបឺតខ្យល់ ឬ Window Tower មានតួនាទីប្រៀបដូចខ្យល់អាកាសធម្មជាតិ។ នេះជាភាពឆ្លៀវឆ្លាតរបស់វិស្វកររសម័យបុរាណ ដែលចេះវិធីបង្កើតប្រព័ន្ធបង្វិលខ្យល់ ឱ្យគ្រប់បន្ទប់ទាំងអស់មានខ្យល់អាកាសត្រជាក់ស្រួល ដោយមិនចាំបាច់ចំណាយថាមពលអគ្គិសនីយ។

ពេលដើរកាត់ទ្វារចូលទៅ ក៏ឃើញសាលធំ តុបតែងយ៉ាងប្រណិតដោយឈើស្រល់ និងឈើស៊ីដារ៍ ពិតានខ្ពស់ស្រឡះ នៅជុំវិញបន្ទប់មានបន្ទប់ទទួលភ្ញៀវជាច្រើន តែបិទទ្វារ ដើម្បីសុវត្ថិភាព។

អាលិហ្សា ដើរតាមព្រំដែលមានក្បូរក្បាច់វិចិត្រ និងមានឱកាសបានយល់សោភណ្ឌភាពបល្ល័ង្ក តុបតែងដោយមាស និងត្បូងមណីចម្រុះប្រភេទដែលមានក្បូរក្បាច់ស្អាតលេចធ្លោ មានទ្រង់ទ្រាយដូចត្រែ មានជណ្តើរបីកាំធ្វើពីមាស។ ព្រះហស្តនៃព្រះម៉ែ ហ្វាទិម៉ា កាលពីអតីត អ្នកគ្រប់គ្រងមីឌីសធ្លាប់

ប្រើប្រាស់ពេលធ្វើការ តែបច្ចុប្បន្នយកទៅដាក់នៅអគារទាន់សម័យហើយ ទើប

ទីនេះត្រូវយកធ្វើជាបន្ទប់ទទួលភ្ញៀវ ចំណែកកន្លែងអាស្រ័យនៅមែនទែនគឺនៅ

ខាងក្នុងជ្រៅ មានទ្វារពីរបែងចែកជាទ្វារស្ត្រី និងទ្វារបុរស។ បុរសស្ត្រីប្រើប្រាស់

ទ្វារផ្សេងគ្នា ចេញពីអគារខុសគ្នា។

ទោះគ្មានអ្នកយាមទ្វារ តែនាងដឹងថាមានខ្សែភ្នែកកំពុងសម្លឹងមើលមក

ពីកន្លែងណាមួយ។

ខណៈនោះនៅជ្រុងមួយទៀតរបស់សាលធំ ហ្សឺក សារីហ្វ អាល់ មីឌីស

កំពុងឈរក្រពាត់ដៃយ៉ាងរំភើយ។ មុននេះគេកំពុងដើរទៅកន្លែងមួយ និងកំពុង

ទៅជួប អ៊ុឡាម៉ា (ប្រមុខសាសនាអ៊ីស្លាម) តាមការណាត់ តែគ្រប់យ៉ាងត្រូវ

ផ្អាកទាំងគំហុក ពេល អាលិហ្សា ដើរចូលមកក្នុងដំណាក់របស់គេ។

ពេលទ្វារត្រូវបើក ខ្យល់ក៏បក់ចូលមកត្រសៀកៗ នាំស្រីមាឌល្អិតមក

ជាមួយ។ នាងស្រស់ស្រាយ បញ្ចេញរស្មី ព្រោះពន្លឺព្រះអាទិត្យក្តៅតិចៗស្រោច



លើស្បែកសខ្ចី ស្អាតដល់ថ្នាក់គេដកខ្សែភ្នែកចេញមិនបាន។

អ៎ ព្រះអាទិត្យ! មិនធ្លាប់ឃើញស្រីណាទាក់ចិត្តទាក់ភ្នែកដូចស្រីម្នាក់នេះ!

បុរសខ្ពង់ខ្ពស់ត្រូវផ្អាកដំណើរ ដើម្បីឈរមើល ធ្វើឱ្យបណ្តាអ្នកហែហម
នាំគ្នាងឿងឆ្ងល់។

"ស្រីបរទេសម្នាក់នោះជានរណា?"

អ្នកហែហមស្វែងរកទិន្នន័យមកមើល មិនយូរប៉ុន្មានក៏បានចម្លើយ។

"នាងឈ្មោះ មិស ឈិន ជាបុគ្គលិកហាងគ្រឿងអលង្ការមកពីតៃវ៉ាន់
មកចូលគាល់សម្តេចព្រះមាតា ក្រាបទូល"

កែវភ្នែកមុតដូចស្នាំងតាមមើលស្រីស្អាត គួរឱ្យស្រឡាញ់ សក់ខ្មៅ
មុខមាត់ស្អាតគ្មានអ្វីឱ្យទាស់ កែវភ្នែកមើលទៅរបិលរប៉ូច និងរឹងទទឹង ស្បែក
របស់នាងស្អាតផូរផង់ ពេលពាក់អាវសឺមីពណ៌បៃតងខ្ចី ពាក់អាវគ្រែរហ្សពណ៌
ស មើលទៅកាន់តែសមឥតខ្ចោះ ទោះខោជើងវែងដល់កជើង មិនបង្ហាញសាច់

តែរឹបរាងឱ្យឃើញជើងស្រឡូន បើឱ្យសន្និដ្ឋាន មនុស្សស្រីរាងស្រឡូនដូចនាង ប្រហែលមានកម្ពស់ត្រឹមចង្ការរបស់គេ ដែលគេអាចថើបថ្ងាសរបស់នាងបានស្រួល។

នាងដើរចូលមកជាមួយកាបូបនិរភ័យដាក់របស់មានតម្លៃ ហើយខ្សែភ្នែកមុតស្រួចរបស់គេសង្កេតឃើញថានាងដកដង្ហើមចូលឱ្យពេញសួត ដើម្បីកាត់បន្ថយអារម្មណ៍ភាពញាប់ញ័រ ដើមទ្រូងទន់ល្មើយធ្វើចលនាតាមចង្វាក់នៃការដកដង្ហើម។ ពេលមន្ត្រីរាជវាំងចូលមកទូលថ្វាយថាសម្តេចព្រះមាតារបស់គេសព្វព្រះទ័យឱ្យចូលគាល់ ទឹកមុខ និងពន្លឺភ្នែករបស់នាងក៏ប្រែប្រួលទៅជានឹងធឹង ដែលអាចហៅបានថាស្អាតល្អដូចពេជ្រទឹកល្អ ដែលលាក់នៅក្នុងខ្សាច់រង់ចាំថ្ងៃបញ្ចេញពន្លឺ។ គេជឿថានាងជាស្ត្រីក្លាហាន និងចិត្តដាច់ម្នាក់។

សារីហ្វ ឈរមើលទាល់តែនាងដើរចូលទ្វារស្ត្រី ទើបធ្វើដំណើរបន្តដើម្បីទៅធ្វើធុរៈរបស់ខ្លួន និងជឿថាបន្តិចទៀតគេនឹងភ្លេច ដូចពេលជួបស្រីស្អាតជា



ច្រើន ហើយក៏ភ្លេចពួកនាងអស់រលីង។

គេមិនបាននឹកភ្នកអីបន្តិចថាស្រីម្នាក់នោះ នឹងក្លាយជាមនុស្សស្រីតែ

ម្នាក់នៅក្នុងចិត្ត ជាម្តាយរបស់កូនៗ និងជាពន្លឺចែងចាំងដែលគេតាមរកមួយ

ជីវិតហើយ។

អាលិហ្សា លួចផ្តុំខ្យល់ដង្ហើមនៃភាពញាប់ញ័រចេញតាមមាត់ ពេលដើរ

ចូលទ្វារស្ត្រី បន្ទាប់មកក៏ត្រូវនាំចូលដំណាក់របស់សម្តេចព្រះមាតា ឌីណា

ព្រះមាតារបស់ ហ្សឺក ហ្វារីស។

ដំណាក់របស់សម្តេចព្រះមាតា ឌីណា តុបតែងជញ្ជាំងបន្ទប់ដោយឈើ

ដែលមានក្បរក្បាច់រចនាវិចិត្រតាមសិល្បៈអ៊ីស្លាម ពិតានលម្អដោយកញ្ចក់ថ្លា

កាត់ជាជ្រុងៗ ពេលពន្លឺបញ្ចាំងចំនឹងបញ្ចេញពន្លឺផ្លេកៗដូចពេជ្រ ទាំងនោះជា

ស្នាដៃរបស់ជាងដៃឯក ចំណែកខាងក្រោមជា*ព្រះទីនង់ភោជនីយ* (**បន្ទប់ទទួល**

ទានអាហារ) ផ្ទាល់ព្រះអង្គ មានរូបថតកាលតាំងពីអតីតដល់បច្ចុប្បន្ន ទាំង

រូបថតកាលទើបចាប់សាងសង់រាជវាំង រូបថតអតីតប្រមុខរាជវង្សដែលធ្លាប់គង់

ប្រថាប់នៅទីនេះ រួមទាំងភ្ញៀវសំខាន់ៗពីក្រុមមនុស្សអារ៉ាប់ដែលធ្លាប់មកលេង

ទើប អាលិហ្សា មានអារម្មណ៍ដូចធ្លាយចូលមកក្នុងពិភពមួយទៀត ដែលមិន

ធ្លាប់ស្គាល់។

"សូមសង្រួមឥរិយាបថ" មន្ត្រីរាជវាំងជាស់តឿន ពេលបើកទ្វារគូធ្វើពី

ឈើស៊ីដារ៍ចូលទៅខាងក្នុង ហើយឱនគំនាប់នាងដោយការគោរព។

បន្ទប់ដែលនាងដើរចូលទៅជាសាលធំ តុបតែងយ៉ាងវិចិត្រ មានក្លិន

ក្រអូបផ្អែមពីគ្រឿងក្រអូបដែលដុតក្នុងផើង ហើយសម្តេចព្រះមាតា ឌីណា

ដែលជាម្ចាស់ដំណាក់គង់នៅទីខ្ពស់ ក្រាលព្រំក្រាស់ទន់ល្មើយលាតសន្ធឹងផុត

សាលធំ។ ទ្រង់ស្ថិតនៅចំកណ្តាលខ្នើយទាំងឡាយដែលប៉ាក់ក្បាច់ព័រសៀមាន

ពណ៌ឆើតឆាយ។ ទ្រង់ជាស្ត្រីវ័យជាងហាសិបឆ្នាំដែលមានសម្រស់ស្រស់ស្អាត



និងមានក្តីមេត្តា សែ្បឃ្លុំក្បាលរបស់ទ្រង់លម្អដោយពេជ្រគ្រាប់ធំៗ និងទោះ
ឥរិយាបថអង្គុយបែបរំភើយៗ និងមានទឹកមុខល្វើយ ប៉ុន្តែសម្រស់នៅតែស្អាត
ពន្លឺភ្នែកដាច់ខាតសមជាឈាមជ័រម្ចាស់សមុទ្រខ្សាច់។

អាលិហ្សា ទទួលបានការអប់រំរួចហើយថាត្រូវដើរតាមព្រំវែង និងថើប
ថ្ពាល់ទាំងសងខាងរបស់ទ្រង់ ហើយទទួលបានការស្វាគមន៍បែបនោះដូចគ្នាពី
ទ្រង់វិញ និងបន្ថែមដោយស្នាមញញឹមរបស់ទ្រង់។

"អាស្លាម មុអាល់លៃគុម សេចក្តីសុខចូរកើតមានចំពោះអ្នក"

"វ៉ា អាល់លៃគុម មុសសាឡាម សេចក្តីសុខ សូមកើតមានចំពោះទ្រង់
ដូចគ្នា ព្រះម៉ែម្ចាស់"

នាងតបតវិញ តែសំឡេងប៉ែឡាំៗ ដែលសម្តេចព្រះមាតាស្តាប់ហើយក៏
អស់សំណើចតិចៗ បន្ទាប់មកឱ្យមន្ត្រីរាជវាំងយកកាហ្វេនិងនំចំណីមកទទួល។

អាលិហ្សាមិនមែនជាភ្ញៀវតែម្នាក់គត់របស់ទ្រង់នៅមានស្ត្រីវ័យកណ្តាល

ជនជាតិអារ៉ាប់អង្គុយជាមួយដែរ មុខមាត់មើលទៅកាចឆ្នាស និងណែនាំខ្លួនថា

ជាអ្នកជំនាញពាក់ព័ន្ធនឹងគ្រឿងអលង្ការ ឈ្មោះ ហាន់ណា។

"យើងបានឮពីកេរ្តិ៍ឈ្មោះរបស់នាង និងបានយើញគ្រឿងអលង្ការ យើញ

ថារចនាបានល្អណាស់ ទើបយើងចង់ជួបឱ្យបានម្តង"

"ជាមហាកិត្តិយសរបស់ខ្ញុំម្ចាស់ណាស់ ព្រះម៉ែម្ចាស់ គ្រឿងអលង្ការទាំង

នេះជាស្នាដៃរបស់ជាងលំដាប់ ចំណែកក្បូរក្បាច់រចនាជាសិល្បៈសម័យបុរាណ

ព្រះម៉ែម្ចាស់"

នាងរៀបរាប់ ខណៈនោះក៏មានអ្នកបម្រើជាយុវតី ពាក់ឈុតវែងពណ៌

ស្វាយជាឯកសណ្ឋានកាន់ថាសដើរចូលមក ជាដាល់ឡាហ៍ ឬកាហ្វេបែបអារ៉ាប់

ដែលខុសពីកាហ្វេទូទៅ ថែមទាំងមានកាកសើមបុកៗ ដូចភក់ដែលជាល្បាយ

នៅបាតពែង។ ពួកនាងចាក់កាហ្វេនោះពីថូដាក់ពែងស្អាត ហើយពេលលើក

ភ្លក្សគឺវិះតែឈ្លក់ ព្រោះដាក់ក្រវាញក្នុងនោះដែរ ទើបប្រញាប់ដួសខេកផ្លែឈើ



ជាក់ចូលមាត់ ដែលនាងចូលចិត្តរសជាតិផ្អែមរបស់ផ្លែម៉ើដែលជាក់ក្នុងខេក
មែនទែន។

"យើងត្រូវការទិញត្បូងមណី ដើម្បីធ្វើគ្រឿងអលង្ការជាអំណោយដល់
កូនប្រុសទាំងពីរ"

សម្តេចព្រះមាតាមានន័យដល់ ហ្សឺក ហ្វារីស និង ហ្សឺក សារីហ្វ។ តាម
ទំនៀមទម្លាប់ ខាងប្រុសត្រូវប្រគល់គ្រឿងពេជ្រជាជំនូន និងជាអំណោយនៅថ្ងៃ
ដំបូងបន្ទាប់ពីរៀបការរួចបានមួយថ្ងៃ ដែលមានន័យថាត្រូវត្រៀមគ្រឿងលម្អមិន
តិចជាងដប់សម្រាប់ទុកឱ្យហើយ។

ហាន់ណា មើលមកនាងដោយទឹកមុខមិនរាប់ញាតិ ហើយស្នាមញញឹម
នោះមានភាពក្រអឺតក្រទម ព្រោះត្រូវអនុញ្ញាតឱ្យចូលមកលក់ដូរក្នុងវាំងច្រើន
ឆ្នាំហើយ និងជឿថាសម្តេចព្រះមាតាត្រូវតែគាំទ្រទំនិញពីក្រុមគ្រួសារមូស្លីមដូច
គ្នា។

ពេលចប់ពិធីទទួលសាមញ្ញៗហើយ អាលិហ្សា ក៏សាកសួរសម្តេច ត្រួសៗ ថាចាប់អារម្មណ៍ចង់បានត្បូងប្រភេទណាជាពិសេស បើមាន នាងនឹងយកមកឱ្យជ្រើសរើស។

"សារីហ្វ ចូលចិត្តពាក់ចិញ្ចៀនត្បូងកណ្តៀងពណ៌ខៀវចាស់ម៉ូតបួនជ្រុងទំហំប៉ុននេះ... នាងអាចរកត្បូងកណ្តៀងស្អាតៗ ពណ៌ដូចគ្នា ទំហំប៉ុនគ្នាៗ បួនដប់គ្រាប់ឱ្យយើងធ្វើគ្រឿងលម្អសម្រាប់ជាអំណោយដល់អនាគតព្រះជាយា បានឬអត់ ?"

នាងចង់សួរថាហ្សឹកនៅលីវឬ តែចេះទប់មាត់ទាន់ ព្រោះដឹងថាជារឿងគ្មានមារយាទទាល់តែសោះ។ មនុស្សស្រីនៅលីវក្លាហានពេកហើយដែលសួរនាំពីកូនប្រុសរបស់គេបែបនោះ។

ទោះសុខៗមានការកុម្ម៉ង់ធំឱ្យតាមរកកណ្តៀងស្អាតៗ បួនដប់គ្រាប់ក៏ដោយ តែនាងបែរជាមិនសប្បាយចិត្ត ទើបត្រូវទូលតាមទ្រង់។



"បើសម្តេចព្រះមាតាចេញរាជបញ្ជាឱ្យខ្ញុំម្ចាស់រកពេជ្រ ដែលមានទំហំ និងគុណភាពដូចគ្នាចំនួនដប់គ្រាប់ ខ្ញុំម្ចាស់អាចរកបាន ព្រះម៉ែម្ចាស់ តែបើជាត្បូង នោះជារឿងលំបាកណាស់ ព្រោះត្បូងមួយគ្រាប់ៗ មានភិនភាគខុសគ្នា ទាំងទំហំ ទាំងពណ៌ ទាំងទឹក ពន្លឺ និងគុណវិបត្តិ ខ្ញុំម្ចាស់មិនអាចសន្យាបានទេ ថាអាចរកបានក្នុងពេលដ៏ខ្លី ព្រះម៉ែម្ចាស់"

"ខ្ញុំម្ចាស់អាចចាត់ការបានក្នុងរយៈពេលមួយខែ ព្រះម៉ែម្ចាស់ ខ្ញុំម្ចាស់មានពេជ្រពណ៌សព្រលាំផ្ទៃមេឃទៀត ជានាថាសមនឹងត្បូងកណ្តៀង ដោយគ្មានអ្វីឱ្យទាស់ ព្រះម៉ែម្ចាស់ ខ្ញុំម្ចាស់នឹងឱ្យកូនប្រុសច្នៃម៉ូតគ្រឿងពេជ្រថ្វាយទ្រង់ជ្រើសរើស គ្រប់ម៉ូតផ្តោតសំខាន់ទៅលើភាពប្រណិតមិនអាចកាត់ថ្លៃបាន ថ្លៃថ្នូរខ្ពង់ខ្ពស់សមនឹងព្រះកិត្តិយស ព្រះម៉ែម្ចាស់"

ហាន់ណា យកត្បូងមណីមួយចំនួនចេញមក ទាំងត្បូងទទឹម ត្បូងកណ្តៀង តូប៉ាស ស៊ីទ្រីន ពេជ្រ និងត្បូងប្រភេទផ្សេងទៀត និងមានច្រើនពណ៌

ពួកវាកំពុងបញ្ចេញពន្លឺផ្លេកៗ ប្រដេញគ្នា។ ឈ្មួញស្រីរៀបរាប់ថាខ្លួនមានត្បូង
ពេជ្រស្អាតៗ ច្រើនណាស់ស្តុកទុក ត្រឹមត្បូងកណ្តៀងដប់គ្រាប់មិនមែនជារឿង
លំបាក ហើយត្បូងដែលនាំមកជាមួយជារបស់ល្អ ទើបលក់ឱ្យសម្តេចនៅក្នុង
តម្លៃខ្ពស់ ខណៈនោះសម្តេចបណ្តោយឱ្យស្ត្រីវ័យចាស់រៀបរាប់ទំនិញរបស់ខ្លួន
ដោយមិនរំខាន ចំណែក អាលិហ្សា ជាមនុស្សឆ្លៀវឆ្លាត ទើបមិនមាត់មិន.ក
ព្រោះជ្រូកត្រូវលើកសែងទៅហើយ តើយកស្នែងមួយទៀតទៅបង្អាកធ្វើអី។

"នេះជាស្តី អ្នកនាងស្គាល់មែនទេ អ្នកនាងគិតថាវាថ្លៃប៉ុន្មាន ?"

ហាន់ណា និយាយជាភាសាអង់គ្លេសប៉ែឡាំ ដោយសំនៀងកាចជាការ
បង្ក្រាបនាង ដៃម៉ាប់ៗ ក៏លើកត្បូងពណ៌ក្រហមស្រស់ទំហំប៉ុនពងក្រួច ទឹកល្អ
មកអួត និងប្រាប់ថាទិញត្បូងទទឹមនេះមកពីភូមា បន្ទាប់មកយកតូប៉ាសពណ៌
ពងមាន់មកណែនាំជាភាសាព័រសៀ។

អាលិហ្សា លួចមើលហើយ វាយតម្លៃនៅក្នុងចិត្តរួចរាល់ ដោយសារជា



ជនជាតិបរទេស ទើបមិនមាត់មិនក។

"មិស ឈិន គិតយ៉ាងម៉េចដែរ យើងគួរទិញត្បូងទទឹមនេះទេ ?"

ទ្រង់សួរ ព្រោះសង្កេតឃើញថាឈ្មួញក្រមុំមិនចាប់អារម្មណ៍ត្បូងទទឹម

របស់ ហាន់ណា។

"ខ្ញុំម្ចាស់មិនហ៊ានបញ្ចេញយោបល់ទេ ព្រះម៉ែម្ចាស់"

"និយាយម៉ោ យើងត្រូវការស្តាប់យោបល់របស់នាង"

សម្តេចឯក់ក្បាលជាការអនុញ្ញាតឱ្យបញ្ចេញយោបល់ ទើបនាងអែនអន

តែមិនឱ្យមើលទៅមិនល្អមើល ហើយនិយាយសាច់ការភ្លាម។

"ពេលខ្ញុំម្ចាស់លក់ទំនិញ ត្បូងប្រភេទខ្លះ ទាំងស្អាត ទាំងល្អ តែភ្ញៀវ

មិនចាប់អារម្មណ៍ បែរជារើសយកត្បូងដែលអន់ជាង ដែលគ្រប់យ៉ាងស្ថិតលើ

ចំណង់ចំណូលចិត្តរបស់ភ្ញៀវ ព្រះម៉ែម្ចាស់ ដូច្នេះហើយបើសម្តេចព្រះមាតា

សព្វព្រះទ័យគឺអាចទិញទុកបាន ចំណែករឿងតម្លៃ... ខ្ញុំម្ចាស់មានយោបល់ថា

ត្បូងពណ៌ក្រហមមួយគ្រាប់នោះ ខ្ញុំម្ចាស់ឱ្យតម្លៃបីដុល្លារ ព្រះម៉ែម្ចាស់"

"បីដុល្លារ! ហេតុអី?"

"ត្បូងមួយគ្រាប់នេះជាកូមែនលាបពណ៌ មិនមែនត្បូងទទឹម ខ្ញុំម្ចាស់មិនជួញត្បូងគុណភាពនេះទេ ព្រះម៉ែម្ចាស់"

អាលិហ្សា ប្រាប់ត្រង់ៗ ដោយមិនយកភ្នែកមើលត្បូងចម្រុះពណ៌ដែលដាក់តម្រៀបគ្នានៅចំពោះមុខ ព្រោះដឹងថាជាត្បូងគុណភាពទាប អាចប្រើបានតែក្នុងទូត្រីលម្អប៉ុណ្ណោះ ខណៈនោះធ្វើឱ្យឈ្មួញវ័យចាស់ចងចិញ្ចើម និយាយរអ៊ូៗជាភាសាព័រសៀថា *ស្រីបរទេសនេះកុហក មិនចេះមើលរបស់*។

បន្ទាប់មក ហាណា ក៏យកស៊ីទ្រីនទំហំធំមកបញ្ចុះបញ្ចូលសម្តេច វាស្អាត ត្រូវឆ្មៃជាម៉ូតមុខផ្កាកុលាប ចំណែកបាតជាម៉ូតបួនជ្រុង ហើយពេលឈ្មួញក្រមុំពាក់ស្រោមដៃ យកដង្កៀបកៀបត្បូងនោះទៅបញ្ចាំងមើលពន្លឺ ទើបប្រញាប់ប្រាប់។



"តូប៉ាសមួយគ្រាប់នេះពិបាកថ្នែណាស់"

"វាជាស៊ីទ្រីន មិនមែនតូប៉ាស ហើយបាតក្រោមថ្នែជាម៉ូតបួនជ្រុង ដើម្បី ឱ្យត្បូងមិនអាប់រស្មី ម៉ូតសាមញ្ញៗបែបនេះ ពិបាកត្រង់ណាឬ?"

ពេល អាលិហ្សា និយាយបែបនេះ ហាណា ក៏ឆ្លងចុងច្រមុះ។

"អ្នកលក់ដូចគ្នា តែលាបពណ៌គ្នាឯងឱ្យហ្មងសៅបែបនេះ មិនល្អទេ ខ្ញុំ ជាអ្នកជំនាញត្បូងមណីដែលទទួលបានការបណ្តុះបណ្តាលពីស្ថាប័ន GIA"

"សុំមើលលិខិតជានាពីស្ថាប័ន GIA បន្តិចម៉ោ"

"ខ្ញុំជាអ្នកជំនាញត្បូងមណី ដែលទទួលបានការបណ្តុះបណ្តាលពី ស្ថាប័ន GIA" ហាណា បញ្ជាក់ដោយទឹកមុខមាំ ទើប អាលិហ្សា ជញ្ជក់មាត់ ជាក់។

"អ្នកនៅក្នុងវិស័យត្បូងមនីពិតប្រាកដ បើមានអ្នកណាសុំមើលលិខិត ជានាគុណភាពត្បូង គឺតែងតែយកមកឱ្យមើលដោយការពេញចិត្ត ត្រូវតែជា

លិខិតជានាពិតប្រាកដ មិនមែនរបស់ក្លែងក្លាយ ឬតំណាងអីទាំងអស់ ប្រព័ន្ធ GIA កំណត់គុណភាពពណ៌ពេជ្រដោយតួអក្សរ និងតួលេខ មានសេចក្តីលម្អិត ពេលដែលអ្នកនិយាយថា ពេជ្រពណ៌សព្រលាំផ្ទៃមេឃ ខ្ញុំក៏ដឹងទៅហើយថា អ្នកជាជនចោកប្រាស់"

"ផ្តេសផ្តាស! ផ្តេសផ្តាសណាស់ ស្រីម្នាក់នេះមានចេតនាលាបពណ៌ឱ្យ ខ្ញុំម្ចាស់ សម្តេចព្រះមាតា នាងមានចេតនាចោទប្រកាន់ខ្ញុំម្ចាស់ ដើម្បីដណ្តើមលក់របស់ ព្រះម៉ែម្ចាស់"

"រឿងបែបនេះពិសោធន៍ងាយដូចបកចេកហ៊ានបញ្ជូនត្បូងទាំងអស់នេះ ទៅឱ្យស្ថាប័ន GIA ត្រួតពិនិត្យទេ បើជាអ្នកលក់ពិតប្រាកដ មិនថារបស់ចោក ឬរបស់ថ្លៃ គឺត្រូវតែស្មោះត្រង់ ល្អប្រាប់ថាល្អ មិនល្អប្រាប់ថាមិនល្អ មិនមែនយករបស់មួយមកប្រាប់ថាជារបស់មួយទៀត ទោះលក់បានព្រោះភ្ញៀវមិនដឹង ប៉ុន្តែមិនអាចលក់បានមួយជីវិតទេ"



អាលិហ្សា និយាយដោយមិនទុកមុខ ព្រោះចាត់ថាជាអ្នកជួញដូរត្បូង

ហើយលេងល្បិច ធ្វើឱ្យភ្ញៀវចាត់បង់ទាំងប្រាក់ បង់ទាំងអារម្មណ៍ កើតគំនិត

ប្រឆាំង ឬដែលធ្ងន់ធ្ងរជាងនោះ គឺមិនហ៊ានទិញត្បូងទៀត ចាត់ទុកថាជាការបិទ

ឱកាសឈ្នួញដទៃទៀត ដែលជាអ្នកជួញដូរដោយស្មោះត្រង់ ទើបនាងព្រម

ការពារពេញទី បន្ទាប់មកនាងក៏យក Opal ពណ៌ខ្មៅចាំងស្រមោល មកបៀម

ហើយខ្ចាក់ ធ្វើឱ្យទាំងអស់គ្នាស្រឡាំងកាំង។

"នេះគឺ Opal ពណ៌សលាបពណ៌ត្នោត វាមានប្រតិកម្មប្តូរពណ៌ឱ្យ Opal

មានតម្លៃថ្លៃ ល្បិចទាបពេកហើយ មីសសីស ហាន់ណា"

"ខ្ញុំទិញបន្តមកពីគេទេ ខ្ញុំមិនដឹងអីទេ"

ពេលអ៊ំស្រីដោះសាបែបនេះ ទើបនាងវាយបក។

"អៅ! ក្រែងប្រាប់ថាជាអ្នកត្បូងមនីដែលបានការបណ្តុះបណ្តាលពី

ស្ថាប័នលំដាប់ពិភពលោកនោះអី បើប្រាប់ថាត្រឹមមិនដឹងរឿង ហើយចង់យករួច

ខ្លួន ធ្វើបែបនេះមានចេតនាមិនបរិសុទ្ធតើ"

ហាន់ណា សម្លឹងមុខនាងដោយកំហឹង ហើយប្រញាប់ប្រមូលរបស់របរ ទាំងខាំធ្មេញក្រតៗ។ ទោះនាងចង់សុំថ្វាយបង្គំលា ប៉ុន្តែបើសម្តេចព្រះមាតាមិនអនុញ្ញាត គឺត្រូវតែអាម៉ាស់មុខនៅត្រង់នេះបន្ត។

សម្តេចព្រះមាតាមិនយកភ្នែកមើល ឬស្តាប់ឈ្មួញវ័យចាស់ គ្មានភាពស្មោះត្រង់ម្នាក់នេះ កាយវិការរបស់ទ្រង់ គឺមិនត្រូវការដេញដោលឬមួម៉ៅអីទាំងអស់ ប៉ុន្តែពេញព្រះទ័យជាខ្លាំង ទើប អាលិហ្សា ស្វែងយល់ថា ទ្រង់មិនធ្លាប់ខឹងសម្បារអ្នកណា និងដឹងច្បាស់ថា ហាន់ណា អាស្រ័យព្រះទ័យដ៏ល្អនេះលក់របស់ក្លែងក្លាយ ទ្រង់ក៏មិននិយាយអី តែមិនហៅមកជួបទៀត មកដល់ថ្ងៃនេះ ទ្រង់ត្រូវការធ្វើតេស្ត អាលិហ្សា ទើបបញ្ជាឱ្យតាម ហាន់ណា មកចូលគាល់ ហើយ អាលិហ្សា ក៏មិនធ្វើឱ្យទ្រង់ខកព្រះទ័យ។ ក្មេងស្រីម្នាក់នេះខុសពីឈ្មួញត្បូងពេជ្រដែលទ្រង់ធ្លាប់ស្គាល់ នាងមានចំណេះដឹងផ្នែកត្បូងមនីមិន



តិចនោះទេ គួរឱ្យជឿទុកចិត្តបាន និងមិនចេះតែលក់របស់ផ្តេសផ្តាស ទើបទ្រង់ប្រគល់ការទុកចិត្តនេះទៅឱ្យនាងធ្វើការរឿងមួយ។

"យើងមានរបស់មួយចង់ឱ្យនាងមើល"

ទ្រង់ទះដៃ មិនប៉ុន្មានដង្ហើមក្រោយមក ខ្ញុំបម្រើពីរនាក់ក៏ជួយលើកហិបមួយចេញមក ហើយពេលបើកគម្រប ឃើញថានៅខាងក្នុងសុទ្ធតែជាត្បូងមនីច្រើនគគោក ប៉ុន្តែរបស់ដែលទ្រង់យកចេញមក គឺជាប្រអប់មាស មានក្បូរក្បាច់រចនាតូចមួយ ដែលមើលភ្លាមក៏ដឹងថាជារបស់សំខាន់។

"នេះជាចិញ្ចៀនដែលព្រះស្វាមីរបស់យើងឱ្យជាអំណោយមង្គលការ"

អ្វីដែលស្ថិតនៅចំពោះមុខ គឺចិញ្ចៀនពេជ្រគ្រាប់ធំ ថ្មៃជាម៉ូតជ្រុងកុលាបមើលទៅគ្មានតម្លៃជាសាច់ប្រាក់ប៉ុន្មាន ព្រោះតួចិញ្ចៀន ជាមាសទឹកអន់ ហើយពេលនាងយកចិញ្ចៀនមកឆ្លុះនឹងភ្លើង មើលយ៉ាងលម្អិត ឃើញថាសាច់ពេជ្រមានគុណវិបត្តិច្រើនណាស់ ដល់ថ្នាក់មើលឃើញដោយភ្នែកទទេ ហើយពណ៌ក៏

អាប់ដែរ មិនសតាមការគួរ កន្លែងខ្លះក៏បាក់ ទើបនាងយល់ភ្លាមថា តម្លៃរបស់ចិញ្ចៀនេះ មិនស្ថិតនៅលើទឹកប្រាក់ តែស្ថិតនៅលើផ្លូវចិត្ត។

"កាលពីរាប់សិបឆ្នាំមុន មីឌីស ក្រីក្រមិនទាន់មានស្អីទេ ស្វាមីរបស់យើង គ្រាន់តែជាអ្នកចម្បាំងសមុទ្រខ្សាច់ដែលគ្មានបល្ល័ង្កប៉ុន្តែទ្រង់ព្រមលក់បសុសត្វ ដែលមានទាំងអស់ដើម្បីទិញចិញ្ចៀនមួយវង់នេះឱ្យយើង"

"រ៉ូមែនទិចមែនទែនព្រះម៉ែម្ចាស់ ទ្រង់ត្រូវការឱ្យកែកុនចិញ្ចៀនមួយវង់នេះឬព្រះម៉ែម្ចាស់"

"ត្រឹមត្រូវចិញ្ចៀនមួយវង់នេះជាអនុស្សាវរីយយើងត្រូវការឱ្យវាស្អាតមានពន្លឺម្តងទៀត ប្រើមាសសជំនួសរបស់ចាស់ យើងនឹងឱ្យថ្លៃឈ្នួល សមរម្យ ហើយប្រាកដណាស់ថានឹងម៉ៅយកត្បូងរបស់នាងទាំងអស់ដែរ"

បេះដូងរបស់ អាលិហ្សា រីកមាឌដោយការសប្បាយចិត្តដែលសម្តេចព្រះមាតាប្រគល់ការទុកចិត្តនេះឱ្យនាង។

"ខ្ញុំម្ចាស់មិនមែនជាជាង និងគ្មានចំណេះដឹងផ្នែកនេះ ក្រែងថានាំយក
ចិញ្ចៀនមួយវង់នេះទៅជាមួយមិនបាន"

"យើងយល់ ប៉ុន្តែសុំឱ្យរួចរាល់ឆាប់បំផុតតាមដែលអាចធ្វើបាន យើង
មានជំងឺរោគបេះដូង ខ្លាចថាមិនអាចរស់នៅបានយូរ អ្វីដែលមិនទាន់ជម្រះ
យើងចង់ធ្វើឱ្យវាឆាប់ចប់មុនពេលវេលា"

"វេជ្ជសាស្ត្រឥឡូវទាន់សម័យនិងរីកចម្រើនណាស់ ខ្ញុំម្ចាស់គិតថា..."

"យើងដឹងខ្លួនឯងច្បាស់"

"ប្រយ័ត្នត្រូវដូរពេជ្រ ព្រះម៉ែម្ចាស់"

ហាន់ណា នៅតែមិនព្រមបិទមាត់ ឆ្លៀតឱកាសញុះញង់សម្តេចព្រះមាតា
ឱ្យមានការប្រុងប្រយ័ត្ន តែ អាលិហ្សា បែរជាញញឹមស្រស់ ដោយក្នុងចិត្តចង់
យកត្បូងទាំងឡាយរបស់អ៊ំស្រី ទះមុខចាស់នោះ ទះឆ្វេងទះស្តាំមែនទែន។

"បើនាងជំនាញឱ្យបានមួយជំនិតដែលនាងអួតអាង នាងគួរតែដឹងថា

ពេជ្រក្បាច់កុលាបជាពេជ្រតម្លៃថោក និងមិនត្រូវបាននិយម បើប្រៀបធៀបនឹង

ពេជ្រក្បាច់កេសរ ពន្លឺផ្លេកៗ ស្អាត ខុសគ្នាឆ្ងាយណាស់ ហើយពេជ្រមានគុណ

វិបត្តិពណ៌លឿងដូចពណ៌ប្រេងកាតបែបនេះ វាត្រូវតែថោកជាងពេជ្រគ្មានពណ៌

ឆ្ងាយណាស់ ដូច្នេះហើយ គ្មានហេតុផលអីដែល មីស ឈិន ដោះដូរយកទេ

នាងគួរពិចារណាកំហុសខ្លួនឯងមិនមែនលូកមាត់ដោយយើងមិនអនុញ្ញាត"

ទោះទ្រង់មានព្រះទ័យល្អ ត្រជាក់ដូចទឹក តែចរិតរបស់ទ្រង់ គឺដាច់ខាត

ខ្លាំងណាស់ ធ្វើឱ្យស្ត្រីវ័យចាស់បិទមាត់នៅស្ងៀមស្ងាម ចំណែក អាលិហ្សា ទះ

ដៃឮប្រាវៗនៅក្នុងចិត្ត។ តាមពិតទៅ សម្តេចព្រះមាតាគឺជាអ្នកជំនាញម្នាក់នោះ

ឯង ទ្រង់ដឹងថារបស់ណាល្អ របស់ណាមានគុណវិបត្តិ តែបែរជាមិនមាត់មិនក

ដើម្បីមិនឱ្យអ្នកខ្លះអាម៉ាស់មុខ។

"ខ្ញុំម្ចាស់នឹងយកចិញ្ចៀនពេជ្រមួយវង់នេះត្រឡប់ទៅជាមួយ ដើម្បីប្តូរតួ

តាមព្រះរាជបំណង ពេលការងារចប់រួចរាល់ ខ្ញុំម្ចាស់នឹងយកមកថ្វាយទ្រង់វិញ



រួមទាំងតម្លៃសរុបទាំងអស់ព្រះម៉ែម្ចាស់ អ៊ីនធា អាឡាស"

អ៊ីនធាអាឡាស = បើព្រះអាឡាទ្រង់មេត្តា

អាលិហ្សា ប្រគល់ត្បូងនិងលិខិតជានាដែលនាងយកមកទាំងអស់ រួមទាំងវិកយបត្រ ហើយថើបខ្នងដៃរបស់ទ្រង់ ជាការធ្វើកិច្ចសន្យាដោយកិត្តិយសបន្ទាប់មកក៏លា ដោយទ្រង់បញ្ជាក់ថា លើកក្រោយឱ្យយកត្បូងល្អៗ មកឱ្យជ្រើសរើសបន្ថែមផង។

"ខ្ញុំម្ចាស់មិនធ្វើឱ្យទ្រង់ខកព្រះទ័យទ ព្រះម៉ែម្ចាស់"

អាលិហ្សា ដើរចេញទៅហើយ ខណៈនោះ ហាន់ណា ក៏តាមមើលដោយការស្អប់ខ្ពើមបន្ទាប់មកក៏ដកដង្ហើមមិនពេញពោះពេលងាកមកឃើញព្រះនេត្ររឹងកំព្រឹស។ គតិរបស់ព្រះរាជវង្សគឺកិត្តិយស ហើយគ្មានថ្ងៃអភ័យឱ្យជនបោកប្រាស់ នាងក៏ដឹងខ្លួនថាបានធ្វើរឿងខុសដ៏ធ្ងន់ យកត្បូងមនីដែលមានគុណភាពអន់បំផុតមកលក់អស់រយៈពេលជាច្រើនឆ្នាំ រឿងប្រហែលមិនចប់ ត្រឹមប្រគល់

លុយឱ្យវិញនោះទេ ស្រួលមិនស្រួល មុខជំនួញរបស់នាងនិងកូនប្រុស អាចនឹង

ខ្ចាតចេញពី មិឌីស ក៏ថាបាន ទើបរិះរកវិធីយករួចខ្លួន ប៉ុន្តែពេលឃើញសម្តេច

ព្រះមាតាចងចិញ្ចើម លើកដៃម្ខាងក្តោបដើមទ្រូងដើមឆ្វេងដោយការឈឺចាប់

បន្ទាប់មកក៏ដួលខ្ពោក សន្លប់ នាងក៏ភ័យ មើលឆ្វេងមើលស្តាំដោយភាពឆ្លៀវឆ្លា

ព្រោះនៅក្នុងបន្ទប់នេះ គ្មានអ្នកណាផ្សេងក្រៅពីនាង នាងខ្លាចឡើងញ័រខ្លួន

ព្រោះលូកដៃទៅអង្រួនទ្រង់ហើយក៏មិនព្រមកម្រើក មិនដឹងថាស្លាប់ឬរស់។

នេះជាឱកាសល្អ!

លឿនដូចការគិត ស្ត្រីវ័យចាស់មិនរង់ចាំយូរ ប្រញាប់ប្រមូលត្បូងល្អៗ

របស់ អាលិហ្សា ដែលលក់ឱ្យសម្តេចព្រះមាតាដាក់ចូលកាបូបរបស់ខ្លួនឯង

និងរង់ចាំទាល់តែទ្រង់ដាច់ខ្យល់នោះឯង ទើបស្រែកចេចចាច។

"ជួយផង! ជួយផង ចោរ! វាធ្វើបាបសម្តេចព្រះមាតា ហើយលួចចិញ្ចៀន

ពេជ្ររត់ទៅបាត់!"



៥

យល់ច្រឡំ

សំឡេងចេចចាចទាមទារការចាប់អារម្មណ៍ពីអ្នកនៅក្នុងវាំង ត្រឹមមួយប៉ព្រិចភ្នែកក៏មានភាពចលាចលកើតឡើង ហាន់ណា យំយែកបោកខ្លួនបោកប្រាណ និយាយដដែលៗថា ស្រីបរទេសម្នាក់នោះមិនឈប់ ហើយអាស្រ័យភាពចលាចលនោះ រកផ្លូវគេចចេញ ខណៈនោះក៏ទូរសព្ទទៅរកកូនប្រុស ដែលរង់ចាំនៅក្រោយវាំង។

"បើឃើញស្រីបរទេសសម្បុរសមាឌល្អិត បាញ់វាចោលទៅ វាជាចោរ"

(ហេតុអីម៉ាក់?)

"ធ្វើតាមម៉ាក់ប្រាប់ឱ្យបាន មិនអីចឹងឯង..."

ហាន់ណា មានអារម្មណ៍ថាមានស្រមោលមួយឈរនៅចំពោះមុខ ទើប

ងើយមុខមើល ហើយក៏ឃើញកែវភ្នែកកាចមើលមក ដែលធ្វើឱ្យនាងស្លេកមុខ

និយាយអីមិនចេញ។

"ហ្សឹក សារីហ្វ..."

"ពេលចូលគាល់ មានអីកើតឡើងចំពោះសម្តេចព្រះមាតា ?"

"ទ្រង់...ទ្រង់ត្រូវធ្វើបាបព្រះពរ ឆាប់...ឆាប់តាមស្រីបរទេសម្នាក់នោះ

មកវិញម៉ោ នាងជាចោរ ស្រីម្នាក់នោះលួចចិញ្ចៀនពេជ្រដ៏សំខាន់ ហើយរុញ

សម្តេចព្រះមាតាឱ្យដួល ហើយ...ហើយ...មានអារុធ"

អណ្តាតរបស់នាងចង់ព័ន្ធគ្នាទៅហើយ និងបន់ស្រន់ឱ្យកូនប្រុសសម្លាប់

អាលិហ្សាបានមុនពេលរឿងរបស់ខ្លួនត្រូវលាតត្រដាង ខណៈនោះខ្សែភ្នែករបស់

បុរសខ្ពង់ខ្ពស់ក៏ពោរពេញទៅដោយទោស: ទើបនាងប្រឹងអត់ដង្ហើមទប់ការភ័យ

ខ្លាច ខណៈនោះ ហ្សឹក សារីហ្វ ក៏រលាស់កដៃ បញ្ជាអង្គរក្ស។



"ចាប់អ្នកដែលចូលក្នុងដំណាក់របស់សម្តេចព្រះមាតាទាំងអស់ ដរាប ណាដែលរកការពិតមិនទាន់ឃើញ គ្មានអ្នកណាអាចចេញពីទីនេះបាន"

"ក្រាបទូល"

អាលិហ្សាឡើងឡានដែលចតចាំនៅមុខអគារពណ៌គុជខ្យងហើយចេញទៅក្រៅកំផែងវាំង ប៉ុន្តែមើលឃើញភាពមិនប្រក្រតី គឺបានឮសំឡេងស៊ីរ៉ែនរបស់ឡានសង្គ្រោះបន្ទាន់និងមនុស្សម្នាស្រែកឮរងំឮពីខាងក្នុងទើបនាងប្រាប់ឱ្យបើកបរជួយចត ព្រោះនឹកបារម្ភពីសម្តេចព្រះមាតាដែលមើលទៅទ្រង់ហត់នឿយណាស់កំឡុងពេលនិយាយគ្នា ហើយខណៈដែលកំពុងតែរារែកថាគួរទៅមុខបន្ត ឬត្រឡប់ក្រោយ វិនាទីនោះ ទ្វារឡានក៏ត្រូវចាប់ទាញបើកទាំងកំរោល។ ដៃដ៏រឹងមាំម្ខាងរបស់មនុស្សប្រុស លូកមកក្រសោបចង្កេះរបស់នាង ហើយអូសចុះពីឡាន ជើងទាំងពីររបស់នាងហើបផុតពីដី ធ្វើឱ្យនាងភ័យបុកពោះ និងដោយសារភ័យនោះឯង ទើបនាងថយកែងដៃដាក់ម្នាក់នោះតាម

សញ្ជាតិញ្ញាណនៃការការពារខ្លួន។

"ខ្លាំងដែណាស់នាង" គេការពារបានទាន់ ដោយការចាប់ច្របាច់កែងដៃ

របស់នាងខ្លាំងៗ "កុរើ ហើយឱ្យចិញ្ចៀនពេជ្រម៉ោ"

"ស្អី...ស្អីគេ"

"ចិញ្ចៀនពេជ្រ ហុចម៉ោ"

ម្ចាស់រង្វង់ដៃម្ខាងនោះ ខ្សឹបប្រាប់ដោយសំឡេងកាច ប៉ុន្តែនាងមិនស្តាប់

បង្គាប់ ហើយអ្វីដែលនាងធ្វើ គឺបោកក្បាលរបស់ខ្លួនទៅក្រោយ បោកនឹងច្រមុះ

របស់ម្នាក់នោះ ខ្លាំងៗ។

ផ្លូស!

"អ៊ូយ! អាឆ្កួត!"

នាងដេរដោយមិនខ្វល់ពីអីទាំងអស់ ព្រមទាំងអង្អែលក្បាលខ្លួនឯង

ចំណែកម្នាក់នោះ ភ្ញាក់ព្រើតតែម្តង ជាងនោះទៅទៀត ក៏ច្របាច់ចង្កេះរបស់នាង



កាន់តែខ្លាំងដោយការមួម៉ៅ និងអូសនាងទៅទាំងបែបនោះ ហើយខ្យល់ដង្ហើម

ក្តៅគគុកដែលស្រោចដាក់ត្រចៀក ធ្វើឱ្យនាងភ័យខ្លឹងរឹងខ្លួនស្លុក គិតអីមិន

ទាន់។

"កុំប៉ះពាល់ខ្លួនខ្ញុំ"

"បិទមាត់!"

សំឡេងរបស់គេកាច ខ្យល់ដង្ហើមក៏ក្តៅស្រោចលើត្រចៀករបស់នាង

ម្តងទៀត ទើបនាងប្រឹងរលាស់ទាល់តែរបូត និងដោយសារការភិតភ័យ និងត្រូ

ការរត់គេចពីបុរសគួរឱ្យខ្លាចម្នាក់នេះទើបនាងរត់ឡើងផ្លូវថ្នល់ដោយមិនបានជា

មើល ឡានចុចស៊ីផ្លេព្យទ្រហឹង អ្នកបើកបរជាន់ហ្វ្រាំងមួយទំហឹង តែមិនទាន់

ប៉ុន្តែវិនាទីនោះ បែរជាមានដៃមួយ ស្រវាចាប់ដើមដៃរបស់នាង ទាញទៅរក

ចិញ្ចើមផ្លូវវិញ ដោយគូទឡានរបស់អ្នកចាប់ហ្វ្រាំងម្នាក់នោះឆាសនាងតែបន្តិច

ប៉ុណ្ណោះ។

សារីហ្វ ស្រវាចាប់ដៃរបស់នាងជាប់ មុខមាំគួរឱ្យខ្លាច។

"គេចទៅណាក៏គេចទៅ ប៉ុន្តែកុំងាប់គេចពីកំហុស មិនបានទេ"

សំឡេងរបស់គេមួម៉ៅ និងច្របាច់ដៃនាងខ្លាំងៗ ធ្វើឱ្យនាងភ័យ ស្រុញ ជើងតែមិននិយាយមិនឡូឡា មិនធ្វើអ្វីទាំងអស់ គេក៏មិននិយាយស្តីអីដែរ ក្រៅពីអូសនាងចូលទៅក្នុងកំផែងវាំងវិញ។

"លែង! លែងខ្ញុំ"

នាងប្រឹងក្រាញ ប៉ុន្តែ សារីហ្វ បញ្ចេញកម្លាំងតែបន្តិចប៉ុណ្ណោះ ក៏អាចអូសនាងចូលទៅជាមួយបាន ហើយនាងប្រុងឡូឡា តែសុខៗក៏ត្រូវគេគ្រវែងឱ្យរមៀលទៅលើផ្លូវថ្នល់ ហើយតាមទៅទ្រាបពីលើដើម្បីការពារ។

ប៉ុង!

គ្រាប់កាំភ្លើងឆាសដំបូលឡានទំនើបតែបន្តិចប៉ុណ្ណោះ សារីហ្វ សម្លឹងមើលវិថីគ្រាប់កាំភ្លើងនោះមិនដាក់ភ្នែក ហើយទាញកាំភ្លើងរបស់ខ្លួនឯងបាញ់



វិញពីរបីគ្រាប់ ខណៈនោះ ទាហានការពាររាប់សិបនាក់ក៏រត់ស្ទុះស្រែរមកចាប់

អ្នកបាញ់ សំឡេងស្បែកជើងប៉ូតទង្គិចនឹងដី ឮខ្លាំងៗ វាមិនគួរឱ្យឈឺក្បាលដូច

ទម្ងន់ខ្លួនរបស់បុរសមាឌធំដែលកំពុងទ្រាបលើនាង ទើបនាងប្រឹងរើបម្រះនៅ

ក្រោមសាច់ដុំហាប់ណែន។

"អ៊ូយៗៗ ចុក ឈឺ..."

"នាងត្រូវគ្រាប់ឬ?"

ដៃក្តៅគគុកស្អាបខ្លួនប្រាណរបស់នាងដោយមិនសុំការអនុញ្ញាត ខណៈ

នោះក៏សង្កត់នាងហាក់ដូចតោសង្គ្រប់ចំណី។

សំឡេងកាំភ្លើងទាក់ទាញចំណាប់អារម្មណ៍មនុស្សម្នា អាលិហ្សា ខឹង

ឡើងព្រិលភ្នែក និងស្រែកកាន់តែឮ ពេលងើយមកឃើញមុខរបស់គេច្បាស់ ថា

ជាបុរសមុខមាត់កាច ពុកមាត់ស្រមូម ស្មារបស់គេធំទូលាយ សាច់ដុំធំៗ ភ្នែក

មុតដូចស្នាំង សណ្តាំអ្នកមើល។ នាងឃើញមុខរបស់គេមិនច្បាស់ ព្រោះពន្លឺព្រះ

ពីដីបែបនេះបាន បញ្ជាក់ថាគេជាមនុស្សដែលមានមាឌធំនិងខ្ពស់ខ្លាំងណាស់ ។

ហើយសុខៗមកគំរាមនាងឱ្យប្រគល់ចិញ្ចៀនរបស់សម្តេចព្រះមាតាបែបនេះ អ្វី

ដំបូងដែលនាងគិតគឺ ចោរ!

"យកចិញ្ចៀនមួយវង់នេះទៅធ្វើអី ឈប់!"

"នាងមិនដឹងពីសារៈសំខាន់របស់វា ឱ្យម៉ោភ្លាម"

"មិនឱ្យ ជួយផងៗ"

បុរសដ៏ខ្ពង់ខ្ពស់មិនខ្វល់ ស្រវាយកកាបូបស្ពាយចំហៀងរបស់នាងបាន

ក៏រើករបស់ដែលត្រូវការ ប៉ុន្តែនាងស៊ូស្លាប់ឱបកាបូបជាប់ ហើយហាមាត់ខាំគេ

ទាល់តែកប់ចង្កូម ដោយមិនខ្វល់ទេថាខាំត្រូវត្រង់ណា ដឹងត្រឹមថាខាំឱ្យដាច់

សាច់របស់គេ។

សារីហ្វ ខឹង ព្រោះមិនស្មានថាស្រីមាឌល្អិតបិនកូនឆ្មាក្លាហានដល់ថ្នាក់



នេះ ខាំបណ្តើរ ស្រែកហ៊ែរៗបណ្តើរ ដូចឆ្កែយ៉ាងអីចឹង។

"បើនាងនៅតែមិនឈប់ធ្វើបាបរាងកាយរបស់យើង ខ្ញុំនឹង..."

គេនិយាយមិនទាន់ចប់ផង នាងក៏ខាំកាន់តែខ្លាំង ដើម្បីប្រកាសថានាងមិនខ្វល់ ដូច្នេះហើយ ទើបគេទះកំប៉ែះគូទរបស់នាងពីរបីដៃខ្លាំងៗ ហើយបានផលល្អណាស់ នាងព្រមហាមាត់ ព្រោះឈឺគូទ។

"នៅមិនឈប់ទៀត"

ផាច់ៗៗ!

"លែង! លែងភ្លាមអាចោរពាល! ជួយផង អ្នកណាក៏បានដែរ ជួយផង"

នាងទាំងស្រែកទាំងរើបម្រះ ត្រង់ណាដែលទះតប់បាន ក៏ទះតប់ខ្លាំងៗ ព្រោះតាំងពីកើតមក យ៉ាងច្រើនត្រូវឪពុកវាយដោយដៃតែអាឆ្កួតនេះជាអ្នកណាមកពីណា ទើបហ៊ានទះកំប៉ែះគូទរបស់នាង។

"បើនៅតែមិនព្រមឆ្កួត ខ្ញុំនឹងដេកសង្កត់នាងនៅលើថ្ម្យល់បែបនេះ"

"មិនបាន!"

នាងស្រែកចាច និងដេរនៅក្នុងចិត្តរាប់រយពាក្យ ហើយប្រឹងស្រែកខ្លាំងៗ

ប៉ុន្តែត្រូវគេទះកំប៉ះគូទទៀត។

ផាច់ៗៗ!

"ស្អាត់!"

"អាឆ្កួត អាកូនអណ្តើកធ្វើបាបមនុស្សស្រី អាចោរចិត្តពាល"

នាងទាំងខឹង ទាំងខ្មាស ស្បថថាគំនុំនេះនឹងចាំទុកដល់ថ្ងៃស្លាប់ ចាំមើលទៅ។ ដោយសារទំហំខ្លួនខុសគ្នាឆ្ងាយ ទើបនាងធ្វើបានត្រឹមតែសម្លក់សម្លឹងគេដោយទឹកមុខក្តៅគគុក ហាក់ដូចព្រះអាទិត្យដែលកំពុងបញ្ចេញកម្តៅនៅលើក្បាល ខណៈដែល សារីហ្វ គ្រវីក្បាល ព្រមទទួលស្គាល់ថាហត់នឿយខ្លាំង ព្រោះនាងឆ្មាសឆ្មើមណាស់ដែរ បើមិនប្រយ័ត្ននឹងត្រូវខាំ ត្រូវខ្ចៅ ឆ្មាសដូចមេខ្លា។



"បើនាងស្រែកជេរខ្ញុំមួយម៉ាត់ទៀត..."

"ម៉េច!"

"ខ្ញុំនឹងប្តូរមកវែីខាងមុខ"

គេប្រាប់ ព្រមទាំងទះកំប៉ែះគូទនាងតិចៗ អាលិហ្សា ក៏បើកភ្នែកធំៗ ខឹង

ឡើងខ្មៅមុខនិងទើបតែឃើញមុខមាំរបស់គេច្បាស់ជាលើកដំបូងបុរសម្នាក់នេះ

មានរូបរាងគួរឱ្យសង្ស័យថាព្រះជាម្ចាស់តុបតែង ឬយ៉ាងណា ចិញ្ចើមក្រាស់ រឹទ្ធ

ឡើងលើ កែវភ្នែកមុតស្រួចគួរឱ្យខ្លាចក្រែងហាក់ដូចពន្លឺភ្នែកតោ រឹងមាំ និងកាច

ប្រភេទថាសត្វតោពិតប្រាកដ សុំខ្លាច។

អាលិហ្សា សម្លក់ថ្មែរ ខ្លួនធំ ហើយយ៉ាងម៉េច ជាមនុស្សប្រុសហើយយ៉ាង

ម៉េច បើគេគិតថាប្រដៅមនុស្សដូចនាងបាន ប្រាប់ឱ្យដឹងទៅថាគិតខុស។

"ជួយផង! ជួយផង! អាចោរពាល ឆ្កួតកាមវាចង់រំលោភខ្ញុំហើយ អ៉ា"

នាងទជាក់មិនឈប់ ទាល់តែរបូត ប៉ុន្តែពេលរត់គេច ក៏ត្រូវដៃក្តៅគគុក

នោះ ស្រវាចាប់ជើងជាប់ ឱ្យដួលម្តងទៀត ហើយអ្នកដែលជិះទ្បានឆ្លងកាត់

នៅម្តុំនោះក៏នាំគ្នាហួចមាត់ អ្នកខ្លះចង្អុលប្រាប់ឱ្យ មុតតាវ៉ា មកជួយចាត់ការ

មុតតាវ៉ា ដែលមានត្រួតត្រាមនុស្សស្រាប់ហើយ ពេលឃើញមនុស្សប្រុសស្រី

កំពុងតែឱបគ្នាប្រមៀលខ្លួននៅលើដី ស្បែឃ្លុំសក់របស់នាងរបូតរបាញ ទើប

មុតតាវ៉ា ចាប់ដំបងនៅក្នុងដៃជាប់ ហើយស្ទុះចូលមក ព្រមទាំងស្រែកបញ្ជា

ដែលធ្វើឱ្យនាងធូរចិត្ត ដែលមានមនុស្សមកជួយ ប៉ុន្តែ មុតតាវ៉ា បែរជាយារដំបង

វ៉ែ។

ផូស!

នាងបិទភ្នែក តែបែរជាគ្មានអារម្មណ៍ឈឺចាប់ ពេលដែលបើកភ្នែកម្តង

ទៀត ទើបឃើញថា គេស្ទុះមកទទួលជំនួសដៃត្រូវវ៉ែទ្ធមួយដំបង ឡើងស្នាម

ក្រហម។

"នាងជាប្រពន្ធរបស់ខ្ញុំ"



សារីហ្វ ស្រែកប្រាប់ជាភាសាព័រសៀ អាលិហ្សា ក៏បើកភ្នែកធំៗ។

"លោកប្រាប់ស្អីគេ"

"ប្រាប់ថានាងជាប្រពន្ធខ្ញុំ ដែលស្រែកឡូឡានេះ ព្រោះប្រចណ្ឌខ្ញុំ"

"អាឆ្កួត អាសម្រាមសង្គម អ្នកណាប្រចណ្ឌអ្នកណា និយាយបែបនេះខ្ញុំ ខូចខាត!" នាងស្រែកគំហក ខណៈនោះ មុតតាវ៉ា នៅតែសម្លឹងមុខ ចាប់កំហុសគេ។ សារីហ្វ ទោះជាព្រះញាតិវង្សដ៏ខ្ពង់ខ្ពស់ តែមិនចង់មានបញ្ហាជាមួយមុតតាវ៉ា ទើបចូលសាច់រឿងភ្លាម។

"ប្រគល់របស់ដែលនាងលួចម៉ោភ្លាម"

"លោកស្រវឹងហើយជៀសចេញទៅ!"

"ស្រវឹង ទីនេះជាប្រទេសម៉ូស្លីម គ្មានអាល់កុល ការដាក់ទោសសម្រាប់ចោរគឺកាត់ដៃស្តាំ ទោសលើកទីពីរកាត់ដៃឆ្វេង លើកទីបីកាត់ជើង នាងលួចប៉ុន្មានដងហើយ"

"ព្រៃផ្សៃបំផុត!"

"ហើយនាងនឹងបានដឹងថាខ្ញុំព្រៃផ្សៃជាងនេះទៅទៀត"

អាលិហ្សា ច្រាល់ឈាមពេញមុខ អាកម្តៅចេញពីរាងកាយរបស់គេ លាយឡំនឹងកម្តៅព្រះអាទិត្យ វាក្តៅគគុក ធ្វើឱ្យនាងព្រិលភ្នែក ហឹងត្រចៀក។ សារីហ្វ ទាញនាងឱ្យងើបឈរ ខណៈនោះឯងដែលនាងរលាស់ដៃ ហើយប្រឹងរត់ដោយមិនខ្វល់ទេថា ស្បែកជើងម្ខាងវារបូតទៅណា ហើយដោះស្បែកជើងម្ខាងទៀត គប់ ព្រមទាំងលៀនអណ្តាតដាក់ ជាការផ្ងាញ់ផ្ងាល បន្ទាប់មកក៏រត់បន្ត ធ្វើឱ្យ សារីហ្វ ភាំង ស្តីដែលមិនធ្លាប់ជួប គឺបានជួបនៅថ្ងៃនេះឯង។

ជើងល្អណាស់!

អាលិហ្សាដកដង្ហើមដង្ហក់ទាំងខ្លាចទាំងខឹងតែប្រឹងរត់ប៉ុន្តែមិនទាន់បាន ទៅដល់ណាផង ខ្សែតីវែង ក៏គ្រវាត់មកចំខ្លួន ធ្វើឱ្យនាងផ្កាប់មុខ ឈឺដល់ថ្នាក់ ស្រែកមិនចេញហើយបុរសមាឌធំដែលចាប់ដើមខ្សែក៏ដើរយឺតៗមកអង្គុញជើង



បន្តិចដោយចិត្តត្រជាក់ ទើបនាងប្រឹងងើប ដើម្បីតស៊ូដោយការជេរប្រទេច ទោះ
គ្មានកម្លាំងកំហែងក៏ដោយ។

"អាចោរព្រៃ អាចោរឆ្កួត អាចោរពាល បើខ្លាំងមែន មួយទល់មួយ ពូកែតែ
ធ្វើបាបមនុស្សស្រី គ្មានការអៀនខ្មាស អាមុខក្រាស់ អាមុខស៊ីម៉ង់ត៍! លែងខ្ញុំ
បានឮទេ"

នាងជេរប្រទេចញាប់មាត់ស្អែក អ្នកដែលកំពុងជួយលើកនាងពដូចកូន
ក្មេង ក៏ខាំធ្មេញក្រតឹៗ ប្រឹងទប់កំហឹង ប៉ុន្តែនាងនៅតែស្រែកជេរមិនឈប់ ធ្វើឱ្យ
ខ្ញុំបម្រើ និងទាហានការពារនាំគ្នាមើលមុខគ្នាឡមឡាម។

"ចិញ្ចៀនរបស់សម្តេចព្រះមាតាជារបស់សំខាន់ ជារបស់អនុស្សាវរីយ
របស់មនុស្សដែលទ្រង់ស្រឡាញ់បំផុតខ្ញុំយកទៅមើលថែទោះស្លាប់ក៏ហាមអ្នក
ណាយកទៅដាច់ខាត!"

នាងគំរាម ទឹកភ្នែកក៏រលីងរលោង ឱបកាបូបជាប់ សារីហ្វ ជានឮហើយ

ក៏ធ្លាក់ថ្លើមក្តុក និងយល់សាច់រឿងបានហើយពេលនេះ ទើបមានអារម្មណ៍ដឹង

ខុស ដែលហិង្សាដាក់នាងដោយមិនសួរនាំជាមុន។

"នាងទទួលបានចិញ្ចៀនមួយវង់នេះពីម្ចាស់ឬ ?"

"មែន ! អាចោរពាល បើចង់មកប្លន់ ខ្ញុំនឹងខាំត្រចៀកឯងឱ្យដាច់ ចាំមើល

ទៅ លែង ! លែង"

"ស្ងាត់ ! បើនាងស្តាប់បង្គាប់ខ្ញុំពេលណា យើងនឹងនិយាយគ្នា"

"ដេកចាំទៅ ឯងគ្មានសិទ្ធិបញ្ជាខ្ញុំទេ អ៊ូយ !"

នាងខាំមាត់ ប្រឹងរើបម្រះ ទាំងដែលចុកស្ទើរស្លាប់ ព្រោះមួយជំហានៗ

របស់បុរសមាឌធំ ស្មាធំរបស់គេ ក៏ទង្គិចនឹងពោះរបស់នាងដែរ សួតរបស់នាង

ទាមទារសុំអុកស៊ីសែន ទោះលំបាកយ៉ាងណា តែនាងមិនព្រមពន្លែងកាបូបឱ្យ

របូតពីដៃ មានតែការពារចិញ្ចៀនរបស់សម្តេចព្រះមាតារបស់គេដោយជីវិត ទើប

សារីហ្វ កាត់បន្ថយភាពកាចសាហាវហើយដាក់នាងចុះ។



"អូខេ ម៉ោះ និយាយគ្នា"

គេនិយាយមិនទាន់ចប់ផង ក៏ត្រូវនាងក្តាបដៃដាល់ ប៉ុន្តែព្រោះគេហ្វឹក ហាត់ខ្លួននៅក្នុងជួរកងទ័ពជិតមួយជីវិតទៅហើយ ហើយបច្ចុប្បន្នក៏ជាអគ្គមេបញ្ជាការជាន់ខ្ពស់ កណ្តាប់ដៃតូចឥតកម្លាំងរបស់នាង តែងតែមិនស្ថិតនៅក្នុងខ្សែភ្នែក ហើយគេក៏អាចគេចពីកណ្តាប់ដៃនោះបានយ៉ាងស្រួល ទាស់ត្រង់ថាបន្តិចក្រោយមកក៏ឈឺគន្លាក់ជើង។

អាលិហ្សា ញញឹមចំអក និងពាក់វិញ្ញាណក្បាច់គុណកុងហ្វូដែលចេះបន្តិចបន្តួច ចាត់ការគេ ហើយការយារកណ្តាប់ដៃអម្បាញ់មិញ វាគ្រាន់តែជាតិចនិចនៅក្នុងការបញ្ឆោតសត្រូវប៉ុណ្ណោះ ទាស់ត្រង់ថា សារីហ្វ ឈឺតែមួយភ្លែត ក៏ចាត់ការនាងវិញ មិនឱ្យរួចពីកណ្តាប់ដៃ។

"បើនិយាយគ្នាស្រួលបួលមិនបាន អីចឹងមិនបាច់និយាយទេ"

"យើងក៏មិនត្រូវការនិយាយជាមួយចោរដូចឯងដែរ"

នាងប្រកែកតវ៉ា ធ្វើឱ្យគេទាំងខឹង ទាំងអស់សំណើច ព្រោះនាងគិតតែលោតកញ្ជ្រោល។ ដំបូងគេគិតថាពន្លែងនាងហើយសុំទោស ប៉ុន្តែពេលនាងមិនចង់បាន ថែមទាំងស្រែកជេរគេជាអាចោរពាល ពេញៗមាត់បែបនេះទេ អីចឹងគេជូនតាមសំណើទៅចុះ។

"ចង់ធ្វើអីខ្ញុំ លែង ជួយផង!"

នាងស្រែក ពេលត្រូវបុរសពុកមាត់ស្រមូមចាប់បោះទៅក្នុងទ្បានទ្បង់រ៉ូវ៉ែរពណ៌ដូចសមុទ្រខ្សាច់ដែលចតនៅជិតគ្នា ប្រើកម្លាំងកំហែងដែលមានខ្លាំងជាងចងដៃរបស់នាងឃុំនៅក្នុងទ្បាន។ អាលិហ្សា ទាំងរើបម្រះ ទាំងប្រឹងខ្ទៅ ថ្នាក់ត្រូវចងដៃ កម្រើកខ្លួនមិនរួច ក៏សម្លក់សម្លឹងគេដោយខ្សែភ្នែកដូចមេខ្លា។ សារីហ្វ យល់មកវិញថា ខ្លួនឯងជាមនុស្សចិត្តត្រជាក់ ប៉ុន្តែពេលជួបនឹងដុចរិតរបស់ក្មេងស្រី ភ្នែកម៉ក់ៗម្នាក់នេះហើយ ឈាមក៏ច្រាល់មកនៅត្រង់សៀតផ្កា ធ្វើឱ្យចង់ផ្ទុះតែម្តង។

ចំមែនក្មេងនេះ!



៦

អាចោរពាល

គេមិនធ្លាប់ខឹង ដោយសារមនុស្សស្រីខ្លាំងយ៉ាងនេះទេ ស្រីមាឌល្អិត ប៉ុនកូនឆ្មា តែឆ្មាសដូចខ្លា ទាំងពាក្យសម្តី ទាំងកាយវិការ ខ្លាំងហួសមាឌ ជេរមិនបាត់មាត់មួយមាត់។

សារីហ្វ គ្រវីក្បាល រលាស់កបំបាត់អាការៈមិងមាំង ខ្លួនប្រាណសុទ្ធតែស្នាមក្រចក ស្នាមធ្មេញ។ នាងខ្វាច នាងខាំ ស្រែកជេរគេក្តែងៗ ថាជាចោរពាលទាំងដែលការពិតគឺនាងហ្នឹងហើយដែលជាឆ្មាពាល។

អាលី មនុស្សរបស់ សារីហ្វា ធ្វើមុខងឿងឆ្ងល់ បន្ទាប់ពីឃើញចៅហ្វាយឱបរឹតជាមួយស្រីស្អាតនៅលើចិញ្ចើមផ្លូវ ចាប់បី ស្រែកគំហកខ្លាំងៗ តែការពារ

នាងពីមុតតារ៉ា។ អាលី មិនហ៊ានហាមាត់សួរ តែប្រញាប់ចូលមករាយការណ៍។

"អាការៈរបស់សម្តេចព្រះមាតា ផុតពីគ្រោះថ្នាក់ហើយ ក្រាបទូល តែ

មិនទាន់ដឹងព្រះកាយ ហ្សឺក ហ្វារីស កំពុងយាងទៅមន្ទីរពេទ្យហើយ"

សារីហ្វ ងក់ក្បាល ហើយងើយក្បាលទៅក្រោយ ដើម្បីស្រូបយកខ្យល់

ចូលសួត រម្ងាប់កំហឹងដែលនៅមាន។

"ចាប់ខ្លួនអ្នកបាញ់បានហើយនៅ?"

"នៅទីនេះហើយ ក្រាបទូល"

ទាហានអង្គរក្ស និងទាហានការពារសន្តិសុខទាត់កូនប្រុស ហាណា ឱ្យ

រមៀលទៅខាងមុខ វាក៏ឈ្លោកមុខឈ្លោកមាត់ ញ័រខ្លួនទទ្រើត ព្រោះដឹងច្បាស់

ថា ហ្សឺក សារីហ្វ អាល់ មីឌីស មិនធ្លាប់ប្រណីមនុស្សអាក្រក់។

"ម៉េចក៏បាញ់ស្រីម្នាក់នោះ?"

"ទូលបង្គំ... ទូលបង្គំគ្រាន់តែ... ចង់ជួយហ្សឺកចាប់ចោរ ក្រានបទូល"



"ឯងមិនបានចូលទៅក្នុងវាំង ម៉េចដឹងថាត្រូវចាប់អ្នកណា ដឹងច្បាស់ផង ថាចោរជាមនុស្សស្រីឬ?"

សារីហ្វ សួរដោយសំឡេងកាច និងឮតិចៗ តែសូម្បីមនុស្សល្ងង់បំផុតក៏ដឹងថាគេកំពុងមួម៉ៅក្តៅក្រហាយ។

"ពិនិត្យកាមេរ៉ាសុវត្ថិភាពក្នុងព្រះទីនាំងប្រថាប់ បើពួកវាម៉ែកូនសមគំនិត គ្នាកុហក បញ្ជូនពួកវាទៅវ៉ៃ ហើយកាត់ក្តី"

"ទទួលរាជបញ្ជា"

"នាំស្រីម្នាក់នោះចូលវាំងសិន ចាំយើងសួរនាំដោយផ្ទាល់"

"ស្រីម្នាក់ណា ក្រាបទូល?"

"គឺម្នាក់នោះ..."

សារីហ្វ ងាកទៅចង្អុលកន្លែងដែលចតឡានឡង់រ៉ូវ័រ ប៉ុន្តែពេលនេះបាត់ទាំងឡាន បាត់ទាំងមនុស្ស ទើបខឹងដល់ថ្នាក់ចេញផ្សែងតាមត្រចៀក។ គេគួរ

តែភ្នកចិត្តថាតេជឫទ្ធិរបស់នាងថាមិនមែនផ្សាំងងាយៗធ្វើឱ្យគេឈឺសព្វសរសៃ
ប្រាសាទ ឈឺមែនទែន ស្រីជើងល្អ។

"តាមប្រមាញ់ឱ្យបាន"

អាលិហ្សា ខះក ក្តៅផ្សាដូចត្រូវស្រុសដោយទឹកពុះ ព្រិលភ្នែក តែប្រឹង
ទប់ស្មារតី បញ្ជាចង្កូតឡានឡង់រ៉ូវ ដែលវាទាំងធ្ងន់ ទាំងមិនស្ទិទ្ធដៃ ទោះធ្លាប់
បើកឡានប្រភេទនេះក៏ដោយ តែវាមិនញឹកញាប់ ទើបវាមិនមែនជារឿងស្រួល
ប៉ុន្មានទេ។

ហ៊ឺះ! អាចោរ កុំគិតថាបានស៊ីកូនស្រីថៅកែ ឈិន ងាយៗ!

ប៉ុស្តិ៍ប៉ូលិស... ប៉ុស្តិ៍ប៉ូលិស...

នាងនឹងប្តឹងប៉ូលិស នាងនឹងអូស.កវាចូលគុក នាងនឹងប្តឹងប៉ាឱ្យហោះ



មកលេងក្បាច់គុងហ្វឺដាក់វា!

អាលិហ្សា និយាយរអ៊ូៗ ដោយការខឹងចិត្ត ហើយបញ្ជាឡានគេចពេញ

ផ្លូវ ព្រោះដូចដឹង ថាអ្នកឆ្លងផ្លូវមិនខ្លាចឡាន។

'ទោសរបស់ចោរគឺត្រូវកាត់ដៃស្តាំ'

សំឡេងឈាមត្រជាក់ឮកងរំពងក្នុងសោត្រប្រសាទ។

អាចោរពុកមាត់មុខកាច!

នាងខាំធ្មេញក្រត គិតថាអ្នកណាឱ្យប្រាកដទៅជាចោរ។

អាចោរចោកទាប ចង់ប្លន់ទ្រព្យពីជនបរិសុទ្ធហើយ នៅហ៊ានទះកំប៉ែះ

គូទនាង ហ៊ានប្រកាសប្រាប់គេឯងទាំងមុខក្រាស់ថានាងជាប្រពន្ធ ហ៊ានព្រួស

ខ្យល់ដង្ហើមក្តៅដាក់ត្រចៀកនាងទៀត អ៊ី! ឆ្អើមណាស់!

អាលិហ្សា ព្រឺសម្បុរខ្លាកៗ ហើយបើមានឱកាសជួបម្តងទៀត នាងនឹង

ខាំមិនរើសកន្លែងខាំទេ ចាំមើលទៅ។

ចរាចរណ៍នៅក្នុងក្រុងកកស្ទះណាស់ទៅហើយ មកធ្វើឱ្យបេះដូងរបស់

នាងលោតឌុកឌាក់ទៀត ដោយសារមានឡានសាវ៉ែនរត់កាត់ ហើយក៏អាន
ស្លាកចរាចរណ៍ដែលសរសេរជាភាសាព័រសៀមិនដាច់ និងពេលកំពុងសម្រេច
ចិត្តថាទៅផ្លូវខាងណា ក៏មានឡានឡង់រ៉ូវ័រម៉ូតដូចគ្នារាប់សិបគ្រឿងបើក នៅ
ឆ្ងាយពីឡានរបស់នាងប្រហែលដប់ឡាន ចំណែកប្រជាជនក៏នាំគ្នាចៀសផ្លូវឱ្យ
ជាបន្ទាន់ តែចំនួនឡានច្រើនពេក ដូច្នេះហើយទើបមនុស្សប្រុសឯកសណ្ឋាន
និងមានអាវុធគ្រប់ដៃនាំគ្នាចុះពីឡាន ដើរសំដៅឡានរបស់នាង។

ពួកគេប្រហែលជាសមត្ថកិច្ច!

អាលិហ្សា ធូរទ្រូងខ្សាក យ៉ាងហោចណាស់ការសុំជំនួយពីរដ្ឋបាលបាន
ជារឿងល្អបំផុត ប៉ុន្តែពេលមើលតាមកញ្ចក់ ឃើញអាចោរពាលចុះពីឡាននោះ
ដែរ និងសម្លឹងចំកញ្ចក់ក្រោយរបស់នាងដែរ ហាក់ដូចដឹង ដោយទឹកមុខកាច
និងចង្កេះមានកាំភ្លើង ទើបនាងចាប់កាបូបស្ពាយជាប់ ព្រោះក្នុងនោះមាន
ចិញ្ចៀនសំខាន់របស់សម្តេចព្រះមាតា ឌីណា ទ្រង់ពឹងពាក់នាងឱ្យមើលថែវា



ហើយមនុស្សតែម្នាក់គត់ដែលនាងនឹងប្រគល់ឱ្យវិញគឺទ្រង់ ទើបនាងត្រូវការពារ

ចិញ្ចៀនមួយវង់នេះឱ្យដល់ទីបំផុត ដូច្នេះហើយដើម្បីយោងអាត្មាឱ្យរស់ ទើប

កាប់ចង្កូតទ្បានចូលចិញ្ចើមផ្លូវ ចូលតាមច្រកតូចៗ ដើម្បីរកផ្លូវគេច ដោយមិន

ដឹងទិសតំបន់ ឆ្ពោះទៅសមុទ្រខ្សាច់។

"តាម!"

សារីហ្វ ខឹងកាន់តែខ្លាំងទៅៗ ចេញបញ្ជាឱ្យកូនចៅឡើងទ្បាន ដេញ

តាម មិនឱ្យបាត់ពីក្រសែភ្នែក។

ខណៈនោះ អាលិហ្សា ប្រឹងបន្ថែមល្បឿន ដីហុយទ្រលោមដោយមិន

គិតជីវិត មាត់ក៏ស្រែកមិនឈប់។ នាងធ្លាប់តែបើកទ្បានទំនើបតូចៗ មិនធ្លាប់

បើកទ្បានទាហាន ទោះប្រព័ន្ធប្រើប្រាស់របស់វាល្អ តែភាពមិនជំនាញក្លាយជា

ឧបសគ្គ ថែមទាំងផ្លូវថ្នល់ដែលឆ្លងចូលសមុទ្រខ្សាច់ មិនមែនផ្លូវល្អ ដូចដែល

ធ្លាប់ឃើញក្នុងភាពយន្ត ខ្សាច់ក៏ប៉ើងតាមខ្យល់ដែលបក់ខ្យល់ៗ មកគរលើ

កញ្ចក់ទ្បានទៀត។

សារីហ្វ បើកទ្បានតាមជាប់ប្រកិត ឃើញទ្បានដែលនាងបើកហោះទៅ ទង្គិចនឹងទួលខ្សាច់ ហោះហើយហោះទៀត ទើបបានតែគ្រវីក្បាល។ គេខំបើក ភ្លើងជាសញ្ញាហើយ គ្រវីដៃដាក់ក៏រួចដែរ តែមើលទៅនាងកំពុងភ័យពេកទេដឹង ទើបគិតតែចោលទៅមុខ។

"ថ្មមទ្បានបន្តិចទៅ អ្នកម្តាយ ឆ្កួតឈាមមែន តិចក្រទ្បាប់ទៅ"

គេនិយាយមិនទាន់ដាច់ពីមាត់ផង ទ្បានដែល អាលិហ្សា បញ្ជាក៏រេចង្កូត ធ្លាក់ពីទួលខ្សាច់ គាំងស្ទេញ ទៅណាមិនបន្តមិនបាន ទើបគេបន្ថែមល្បឿន បើកដេញតាមដោយខ្លួនឯង។ ឃើញបែបនោះហើយ គេប្រាប់ខ្លួនឯងមិនបាន ទេ ថាហេតុអ្វីបានជាស្រៀវក្នុងទ្រូង តែពេលឃើញនាងប្រឹងប្រែងប្រវែប្រវាចេញតាម បង្ហួច មើលទៅនៅសុខសប្បាយ គ្មានរបួស ទើបគេផ្តុំខ្យល់ចេញមកតាមមាត់ ធូរទ្រូងខ្សាក។



ហើយស្រីជើងល្អក៏រត់ចូលសមុទ្រខ្សាច់ដោយមិនគិតជីវិតភ្លាម។

"នាងចង់សម្លាប់ខ្លួនឬយ៉ាងម៉េច"

សារីហ្វ ស្រវាយកវិទ្យុទាក់ទងបញ្ជាការភ្លាម និងខឹងមែនទែនហើយ ព្រោះបើមនុស្សស្រីម្នាក់ចាប់ខ្លួនមិនបាន កេរ្តិ៍ឈ្មោះរបស់គេនឹងស្រុតចុះ ដោយមិនអាចស្រោចស្រង់បានជាមិនខាន។

(ទុកឱ្យពួកទូលបង្គំចាត់ការក៏បាន ក្រាបទូល)

"មិនបាន! គ្រប់គ្នាទៅចាំនៅជំរំ ចាំយើងទៅ ហើយបិទមាត់ឱ្យជិត"

(បញ្ចុះបញ្ចូលឱ្យធ្វើជាអត្តពលកររអូទ្បាំពិករបស់មីឌីសក៏ល្អ ក្រាបទូល រត់លឿនជាងអូដ្ឋទៅទៀត ក្រាបទូល)

អាលី តបតាមវិទ្យុទាក់ទង ដោយមានអារម្មណ៍ល្អ។

(ទតចុះ ក្រាបទូល ទៅដល់នុះហើយ)

"បញ្ជូនទៅចិញ្ចឹមស្វាល្អជាង ស្រីស្អីក៏មិនដឹង ទាំងទាត់ទាំងទះ កាច
ដូចខ្លា"

(មកពីទ្រង់ធ្វើឱ្យនាងខឹង ក្រាបទូល)

"សម្រេចថាឯងកូនចៅអ្នកណា!"

អាលី អស់សំណើចនឹងហ្សឺកកំលោះបដិសេធមិត្តភាពពីស្ត្រីទាំងឡាយ
បែរជាមករវល់ដោយសារស្រីបរទេស ដែលមិនធ្លាប់ស្គាល់ម្នាក់នេះទៅវិញ។
មាត់ប្រាប់ថាមិនចាប់អារម្មណ៍ តែដល់ទៅមែនទែនទៅ បែរជាតាមជាប់ប្រកិត
មិនព្រមដកដៃ ហើយ អាលី គិតថាបើហ្សឺក ហ្វារីស ដឹងថាព្រះអនុជមហា
សោះកក្រោះក្តៅគគុកដូចភ្លើង ព្រោះមនុស្សស្រីធានាថាទ្រង់នឹងសើចរឹងពោះ
មិនខាន តែពេលចៅហ្វាយបញ្ជាឱ្យបិទមាត់ ទើបគ្រប់គ្នាត្រូវប្រតិបត្តិតាម។

(ហ្សឺកចេញរាជបញ្ជាម្តងៗ)

ទាហានម្នាក់ទៀតនិយាយតាមវិទ្យុទាក់ទងជាមួយ អាលី។



"ប្លែកម៉េច ?"

(មិញទ្រង់ធ្លោយហៅស្រីម្នាក់នោះថា អាមិ៉ា)

អាមិ៉ា = ព្រះជាយ៉ា

៧

ឆ្លើយ ឬមិនឆ្លើយ

ខ្សាច់ត្រជាក់ជើងខ្លាំងណាស់!

អាលិហ្សា ប៉ាកជើងឡើងទួលខ្សាច់ពណ៌មាស នៅក្រោមថ្ងៃក្តៅចែសផ្ទៃមេឃពណ៌ខៀវចាស់ គ្មានពពកមួយដុំ អាកាសធាតុដែលគិតថាក្តៅបែរជារងាត្រជាក់។ នាងគិតតែពីរត់ ដោយមិនខ្វល់ពីជើងទទេស្អាត គ្មានស្បែកជើងដឹងត្រឹមថាត្រូវរកកន្លែងពួនឱ្យលឿនបំផុត។

បើមកទេសចរណ៍ នាងនឹងជាប់ចិត្តនឹងវាលខ្សាច់ធំល្វឹងល្វើយ មើលមិនឃើញព្រំដែនសីមា គ្រាប់ខ្សាច់ម៉ដ្ឋខៃត្រូវពន្លឺថ្ងៃដែលកំពុងបណ្តើរកូន ត្រូវលើកដៃបាំង ទើបមើលឃើញផ្លូវ។



នាងទាញស្បែងុំមុខចេញ ហើយងុំសាថ្មី ដើម្បីការពារមុខមាត់ពីរស្មី ក្តៅគគុក បណ្តោយឱ្យសក់ប៉ើងតាមកម្លាំងខ្យល់បក់ចោក រងាដល់ឆ្អឹង។

បានហើយមីឌីស នាងគួរតែជឿឪពុក មិនគួរណារឹងក្បាលមកទីនេះទេ ហ៊ឺៗ!

អាលិហ្សា រត់ទៅសម្ងំនៅក្រោយទួលខ្សាច់ធំមួយ តែមិនទាន់សម្រាក ឱ្យបានដកដង្ហើមស្រួលផង សំឡេងឡានឡង់រ៉ូវ័រក៏ឮទ្រហឹង នៅចម្ងាយមិនដល់ពីររយម៉ែត្រ។

"អ៊ូយ! តាមមករកងាប់អី មនុស្សកំពុងហត់ផង"

នាងខាំធ្មេញ រត់បន្ត តែហត់ពេក ទើបកាន់តែយឺតៗ ហត់ដល់ថ្នាក់ដកដង្ហើមមិនទាន់ មានអារម្មណ៍ដូចមនុស្សជិតស្លាប់ ហើយសុខៗ ទួលខ្សាច់ដែលនាងប្រវែប្រវាឡើងក៏បាក់ហូរចុះទៅក្រោម ទើបដាក់បង្គុយលើខ្សាច់តែម្តង ព្រោះពេលនេះសាច់ដុំឈឺចាប់អស់ហើយត្រូវព្រួតទាត់ជាក់ ចង់តែស្រែកក៏

ស្រែកមិនចេញ។

ទ្បានទ្បង់រ៉ូវែរលុយខ្សាច់ចូលមកចតក្បែរ ហើយចោរពុកមាត់ក៏ទ្រានដៃ
មាត់បង្ខូច ព្រមទាំងហួចយ៉ាងរំតើយដាក់នាង។

"ម៉ែចដែរ បើទៅមុខបន្ត បួនប្រាំរយគីឡូម៉ែត្រទៀតដល់សមុទ្រល្មម"

"បើចង់សម្លាប់ក៏សម្លាប់ម៉ោ មិនបាច់និយាយច្រើនទេ តែចាំទុកសម្តេច
ព្រះមាតា ឪណា នឹងមិនដោះលែងអាចោរពាលឯងទេ ទោះខ្ញុំស្លាប់ក្លាយជា
ខ្មោច ខ្ញុំនឹងតាមទៅដាក់ទំនាយអាញ៉ក់របស់ឯងឱ្យវាស្ងិតងាប់!"

នាងស្រែកគំហកបែបនេះ មិនគួរឱ្យស្រឡាញ់សោះហើយ។

"អីចឹងឱ្យចិញ្ចៀនរបស់សម្តេចព្រះមាតាម៉ោ ហើយចាំយើងជូននាងទៅ
ដល់រាជធានី"

"គ្មានផ្លូវទេ!"

នាងដើរគេច គេក៏បើកទ្បានតាមជារឿយៗ ដូចកំលោះជំនាន់មុនតាម



ញ៉ែស្រី។ សារីហ្វ នឹកអស់សំណើច ព្រមទទួលថាជាប់ចិត្តនឹងកាយវិការរបស់

នាង ថ្ពាល់ក្រហម បបូរមាត់ស្អាតចូលចិត្តព្រួសពាក្យឆ្នាសៗជាក់ ជាប់ចិត្តគេ

កែវភ្នែកមូលក្តុំពណ៌ខ្មៅមើលទៅស្រទន់ តែមិនទន់ជ្រាយ កាន់តែធ្វើឱ្យសក់

ពណ៌ខ្មៅបញ្ចេញពន្លឺរលោង។ រំពេចនោះគេនឹកចង់ចាប់នាងយកទៅលាក់ពី

មនុស្សលោក លាក់នាងពីក្រសែភ្នែកមនុស្សប្រុសគ្រប់រូប លើកលែងគេម្នាក់

និងប្រដៅឱ្យនាងក្តៅគគុកដូចភ្លើងនៅក្នុងរង្វង់ដៃមាំមួន មិនឱ្យច្រត់ចង្កេះ តវ៉ា

ច្រែតៗ បែបនេះទេ។

"កាបូបបាត់ទៅណា យកចិញ្ចៀនទៅលាក់នៅឯណា?"

"នៅម្តុំៗនេះឯង ចង់បានទៅរកដោយខ្លួនឯងទៅ ខ្ញុំមិនប្រាប់ទេ"

សារីហ្វ ចុះពីឡាន បិទទ្វារលាន់គ្រាំង ហើយដើរមកចាត់ការដំណាក់

កាលដាច់ខាត ខណៈដែល អាលិហ្សា ស៊ូមិនរាថយ ប៉ុន្តែមិនអាចតតាំងនឹង

កម្លាំងដែលមានច្រើនជាងបាន ត្រូវគេក្រសោបដោយដៃម្ខាង និងចងណែន

ម្តងទៀត ថែមទាំងត្រូវញ៉ុកមាត់ជិតទៀត មិនអាចនិយាយអ្វីបាន ក្រៅពីស្រែក ឮក្ហរៗ និងរើបម្រះ បន្ទាប់មកក៏ត្រូវលើកដាក់លើស្មា ទៅបោះក្នុងឡាន បើក ត្រឡប់ទៅជំរំដែលនៅឆ្ងាយ។

"លែងខ្ញុំអាឆ្កួត ឯងគ្មានសិទ្ធិធ្វើបែបនេះទេ!"

ពេលប្រឹងខ្ជាក់ក្រណាត់ចេញពីក្នុងមាត់បានសម្រេច ការនាងក៏ព្រួសពាក្យអសុរោះដាក់ភ្លាម ព្រមទាំងទះតប់មិនសំចៃដៃ ប៉ុន្តែគេមិនស្តៀបខ្លួនអីបន្តិច។

"តាមធម្មតាខ្ញុំជាមនុស្សមានអារម្មណ៍ល្អ ប៉ុន្តែប្រហែលជាមិនល្អទេ បើនាងនៅតែប្រទូសរ៉ាយមិនឈប់បែបនេះ"

ក្រមុំកូនកាត់ធ្វើមុខខ្ជូរ បន្ទាប់មកក៏បើកភ្នែកធំៗពេលត្រូវគេនាំមកដល់ជំរំនៅកណ្តាលសមុទ្រខ្សាច់ មានតង់ធំពណ៌ដីឥដ្ឋនៅចំកណ្តាល ឡោមព័ទ្ធដោយតង់តូចៗ។ ផ្លូវថ្នល់មិនមែនជាកៅស៊ូ ឬបេតុង ទើបដីហុយទ្រលោមគ្រប់



ពេលវេលា ហើយនៅទីនេះនៅតែមានជំនឿសាសនាយ៉ាងងប់ងល់ជាងទីក្រុង
មនុស្សស្រីគ្រប់រូបត្រូវពាក់ឈុតវែងពណ៌ខ្មៅ ដែលហៅថា *អាបាយ៉ា* បិទបាំង
តាំងពីក្បាលដល់ចុងជើង។ អ្នកនៅទីនេះមានចម្រុះជាតិសាសន៍ មានមុខរបរ
រៀងខ្លួន ជាកម្មករធ្វើផ្លូវ កម្មករសំណង់ ដាក់ប្រព័ន្ធសេវាសាធារណៈ បំពាក់
សូឡាស៊ែល ដាក់បណ្តាញផ្សព្វផ្សាយ សាងសង់រោងចក្រនិងមន្ទីរពេទ្យ មាន
ទាំងវិស្វករ ធរណីវិទូ អ្នកត្រួតពិនិត្យពិត្រូគីមី និងវេជ្ជបណ្ឌិត។ ពួកគេត្រូវប្រឈម
នឹងធូលីដី មូសនិងពន្លឺថ្ងៃក្តៅចង់ខ្លោច ដើម្បីឱ្យមីឌីសមានភាពរីកចម្រើន។

អាលិហ្សា ស្ទើរតែស្រែករាល់ ៣វិនាទីម្តង ព្រោះមានអារម្មណ៍ថាមាន
គ្រាប់ខ្សាច់ខ្ចាត់ចូលរន្ធរោម អាកាសធាតុរងា តែស្ងួត ខ្យល់ដែលបក់បោកនាំ
ធូលីដីមកជាមួយនៅពេលថ្ងៃ ធ្វើឱ្យនាងចង់ឆ្កួតម្តងៗ។

សារីហ្វ នាំនាងចូលបន្ទាយទាហាន មានតង់ធ្វើពីស្បែកសត្វរាងខ្ពស់
បែបបុរាណ សំឡេងអូដ្ឋស្រែកបន្ទរដោយសំឡេងកណ្តឹងដែលព្យួរជាប់ករបស់វា

ធ្វើឱ្យនាងងឿងឆ្ងល់ ហើយពេលឃើញពួកក្រណាត់សូត្រក្បរក្បាច់ព័រសៀ បូរាណ កែវដ៏ប្រណិតដាក់ក្បែរថូទឹកមានក្បរក្បាច់ប្លែកភ្នែកដូចធ្លាប់ឃើញក្នុងសារមន្ទីរ គ្រាន់តែវាជារបស់ថ្មី។

ក្នុងបន្ទាយទាហានមានមនុស្សប្រុសមាឌធំៗ ប្រហែលមួយរយនាក់ទេដឹង មានកំសៀវឆុងកាហ្វេបែបអ្នកស្រុកនៅលើដែកជើងបីបន្តប់លើត្នក់ភ្លើង។ អាហារចំណីនៅទីនេះអន់ខ្លាំងណាស់ ពេលយប់ស្ទើរតែគ្មានរឿងសប្បាយរីករាយឱ្យធ្វើ ហើយពេលមានស្រីស្អាតខាបព្រលឹង ដំណើរល្វត់ល្វន់គួរឱ្យស្រឡាញ់ដូចនាងធ្លាយចូលមក គ្រប់គ្នាក៏មើលមកដោយក្រសែភ្នែកស្រេកឃ្លាន នោះហើយដែលធ្វើឱ្យនាងឡើងញ័រខ្លួន។

គ្រប់គ្នាមើលមកនាងមិនដាក់ភ្នែក ខណៈនោះអ្នកដែលចាប់ខ្លួននាងមកក៏និយាយជាមួយពួកនោះជាភាសាព័រសៀ ដែលគេនិយាយមួយម៉ាត់ប៉ុណ្ណោះ ទាហានទាំងឡាយ ដែលមានអាវុធគ្រប់ដៃប្រញាប់ប្រតិបត្តិការតាម



ភ្លាម ដែលធ្វើឱ្យនាងស្លេកមុខសឹងតែដូចក្រដាស ព្រោះនេះជាសម្បុកចោរ
ច្បាស់ណាស់។

"នែ៎! នាំខ្ញុំមកលក់ជាទាសកររឬ ខ្ញុំមិនព្រមទេ"

"បើនាងធ្លាប់រៀនសូត្រខ្លះ គួរតែដឹងថារបបទាសករ វាចប់សម័យរាប់
រយឆ្នាំទៅហើយ"

ពេលបានឱកាស ក៏ជេរភ្លាម អាចោរពាលនេះ!

"កំពុងជេរខ្ញុំហើយ មុខហ្នឹង"

"ម៉េច! ជេរនៅក្នុងចិត្តមិនបានទេក៏អី!"

មួយម៉ាត់មិនធ្លាក់ដល់ដីសោះហើយ!

សារីហ្វ ទម្លាក់ភ្នែកចុះបន្តិច តែមិនឆ្លើយសំណួររបស់ស្រីបានសម្តីដែល
ទើបតែគ្រវែងទៅលើដីស្មោកគ្រោក ខណៈនោះនាងក៏មើលទៅជុំវិញខ្លួន និងធុំ
ក្លិនគ្រឿងក្រអូបឆួលច្រមុះតែម្តង បន្ទាប់មកក៏ស្រែកភ្លាត់មាត់ ព្រោះមានសត្វ

ល្អិតធំវារលើជើង ទើបប្រឹងរើបម្រះ តែមិនបានសម្រេច។

"រីករាយដែលបានស្គាល់ នាងគួរប្រាប់ឈ្មោះខ្លួនឯងឱ្យយើងដឹង ប្រាប់មកថានាងជាអ្នកណា"

"ឆឺះ!"

ខ្សែតីស្បែកគោត្រូវវាត់លាន់សំឡេងនៅក្បែរខ្លួន ឱ្យនាងស្រែកភ្លាត់មាត់ម្តងទៀត។

"អាមនុស្សពាល ចាំទុក!"

"បើមិនរឹងក្បាល ខ្ញុំមិនវើនាងទេ ល្អទេ"

ហ្សឹក សារីហ្វ អាល់ មីឌីស វ៉ាលីនៃហ្វេសសានដាក់បង្គុយលើពូក បែរមុខមករកឈ្លើយក្រមុំ ហើយធ្វើការសួរចម្លើយ។ កំលោះក្រមុំសម្លឹងមុខគ្នាមិនដាក់ភ្នែក នឹងធ្វើការប្រយុទ្ធគ្នាយ៉ាងកាចសាហាវតាមរយៈក្រសែភ្នែក ប៉ុន្តែហ្សឹកកំលោះក្រៅពីមិនញញើត និងញញឹមត្រជាក់ដែលវាខុសពីកែវភ្នែកមុតស្រួច



មួយគូនោះមែនទែន ហើយនៅជិបកាហ្វេយ៉ាងរំភើយ បន្ទាប់មកទាញកាំបិតខ្លី ដែលលម្អដោយត្បូងពេជ្រប្រដេញពន្លឺផ្លេកៗ មកប៉ាតបាតដៃ ពេលកំពុងរង់ចាំចម្លើយ។

"អូខេ យើងនិយាយគ្នាស្រួលបួលទៅ យើងដឹងថានាងហត់នឿយពេញបន្ទុកហើយ... នាងជាអ្នកណា ចិញ្ចឹនពេជ្រនៅឯណា ?" គេសួរដោយសំឡេងស្មើ ប៉ុន្តែម៉ឺងម៉ាត់ ទើបនាងព្រមងាកយឺតៗមករក តែប្រសព្វភ្នែកជាមួយដោយការរកឿង។

"សុខៗក៏មកចាប់ជំរិតគេ ចាប់ចងដូចជ្រូក ហើយនៅមានមុខមកសួរនេះសួរនោះទៀត"

សំឡេងខ្សែតីត្រូវរាត់លាន់ខ្ទាប់បន្តឹឡឹងម្តងទៀត ដែលម្តងនេះវានៅឆ្ងាយត្រឹមមួយសរសៃសក់ ទើបនាងប្រញាប់បិទភ្នែកជាបន្ទាន់ ហើយនិយាយដោយសំឡេងញ័រៗ។

"គឺ... គឺ... ខ្ញុំឈឺ ចង់ចូលបន្ទប់ទឹក ជួយស្រាយចំណងឱ្យសិនបានទេ ហើយចាំនិយាយគ្នា ណ៎ះ!"

អាលិហ្សា ហុចដៃទាំងពីរដែលជាប់ចំណងទៅឱ្យ ព្រមទាំងសួរដោយភ្នែកព្រិចៗគួរឱ្យអាណិតដាក់ទៀត ប៉ុន្តែត្រូវបដិសេធ។

"ហឺៗ គិតឬថាល្បិចអស់នេះបោកយើងបាន ឆ្លើយសំណួរសិនមកថា នាងជាអ្នកណា ហើយចូលគាល់សម្តេចព្រះមាតា ឪណា ក្នុងគោលបំណងអី បើមិនឆ្លើយយប់នេះដេកក្នុងគុកនេះហើយ"

"ខ្ញុំ... ខ្ញុំឈឺពោះពិតមែន ហឺក! មិនបានកុហក មេត្តាផងទៅ"

គេងើបទៅទាត់កន្ទោរធំឱ្យនាងដោះទុក្ខសត្វនៅចំពោះមុខ ព្រមទាំងនឹកអស់សំណើចថានាងប្រហែលជាអៀនខ្លាំងមិនហ៊ានធ្វើបែបនោះទេ ប៉ុន្តែគេគិតខុស ព្រោះនាងងើបឈរយឺតៗ ព្រមទាំងយំអណ្តឺតអណ្តក ខណៈនោះក៏ទាញចង្កេះខោទម្លាក់។



"ឈប់សិន! ជាមនុស្សស្រីប្រភេទអីហ្នឹង"

"នេះនែ៎!"

អាលិហ្សា លើកជើងទាត់ថ្ងាសក្រោមរបស់គេភ្លាមពេលមានឱកាស ធ្វើ

ឱ្យបុរសមាឌធំដួលខ្ពោក មុខទ្បើងខ្មៅប៉ែ បន្ទាប់មកនាងក៏ផ្តួលខ្លួន អារចំណង

នឹងកាំបិតមុតស្រួចទាល់តែដាច់ ប៉ុន្តែស្រមោលដែលឃើញនៅលើជញ្ជាំងតង់

ធ្វើឱ្យ អាលី មនុស្សជំនិតរបស់ហ្សឺក សារីហ្វ មើលឃើញថាកំលោះក្រមុំកំពុង

នេះនោះគ្នា។

"លែងភ្លាម! អ្ហឺ!"

គេគ្រហឹមដោយកំហឹង ពេលត្រូវនាងយកក្រណាត់ជូតជើងញាត់មាត់

បន្ទាប់មកក៏ហុកមកច្រកកៀវលើរាងកាយ ដើម្បីចងកដៃនឹងបង្គោលតង់ជាការ

សងសឹក និងដើម្បីជាការតបស្នងឱ្យដល់ចិត្ត ក៏ដាល់ពោះរបស់គេពីរបីដៃ។

នេះនែ៎ៗ ងាប់ទៅអាចោរពុកមាត់!

"ហាសហា ចាំទុកអាចោរឆ្កួតកាម កុំធ្វើបែបនេះដាក់ខ្ញុំទៀត"

អាលិហ្សា លើកដៃម្ខាងច្រត់ចង្កេះ ម្ខាងទៀតលើកចាក់ថ្ងាសរបស់គេ ចង់ចាក់ឱ្យធ្លុះដល់ខួរក្បាល។

"ចាំទុក កុំធ្វើបាបមនុស្សស្រី កុំធ្វើខ្លួនអន់ចរិត មិនអីចឹងខ្ញុំនឹងប្តឹងប៉ាឱ្យមកចាត់ការធ្ងន់ជាងនេះ អាចោរល្ងីល្ងើ"

នាងលៀនអណ្តាតព្រមទាំងជ្រួញច្រមុះដាក់ ហើយរៀបចំខ្លួនប្រាណឱ្យមានរបៀប ស្រវាយកស្រោមកាំបិតលម្អដោយត្បូងពេជ្រ ទុកធ្វើជាអាវុធឱ្យអ្នកនៅខាងក្រៅបើកផ្លូវឱ្យ ប៉ុន្តែនាងឈានជើងមិនទាន់ដល់ទ្វារផង សុខៗតង់ស្បែកគោក៏បាក់ប្រាវតាមកម្លាំងអង្រួនរបស់ បុរសមាឌធំដែលត្រូវចងដៃជាប់នឹងបង្គោល ហើយពួកនាងក៏ស្ថិតនៅក្រោមស្បែកជាមួយគ្នា និងបានឮតែសំឡេងស្រែករបស់នាង។

ខណៈនោះទាហានការពារសន្តិសុខក៏នាំគ្នាស្រែកឆោឡោ និងជួយ



លើកបង្គោលបញ្ឈរឡើងវិញ ហើយពេលទាញស្បែកគោត្រឡប់ឡើងលើវិញ

ក៏នាំគ្នាបែរខ្នងជាបន្ទាន់ ព្រោះបុរសដ៏ខ្ពង់ខ្ពស់កំពុងឱបរឹតស្រីស្អាត ខោអាវ
របូតរបាញ ទាំងដែល អាលិហ្សា ប្រឹងរើបម្រះ ប៉ុន្តែការធ្វើបែបនោះមានតែធ្វើឱ្យ
នាងចាញ់ប្រៀប។

"បើមិនឆាប់លែង ខ្ញុំនឹងខាំឱ្យដាច់សាច់ ចាំមើលទៅអាឆ្កួត លែងទៅ
អាចោរពាល ធ្វើបែបនេះ វាចូលបទល្មើសបៀតបៀនផ្លូវភេទវើយ!"

"នាងក៏បៀតបៀនសរសៃប្រសាទរបស់ខ្ញុំដែរ អូខេ រើឱ្យខ្លាំងជាងនេះ
ទៅ ន្លាលខ្ញុំហែកខោអាវរបស់នាងឱ្យរហែកអស់"

ម្ចាស់រាងកាយតូចច្រឡឹងនៅក្នុងរង្វង់ដៃមាំមួននៅស្ងៀមភ្លាម និងប្រឹង
ទប់ទឹកភ្នែក ពេលច្រមុះស្រួចអូសមកជិតគល់ទ្រូង ដៃទាំងពីរត្រូវលើកទៅ
សង្កត់លើក្បាល មានរាងកាយមាំមួនសង្កត់ពីលើ ដោយគ្មានចន្លោះប្រហោង
ឱ្យខ្យល់ចេញចូល និងពេលបានឃើញច្បាស់ថាខ្លាប្រុងហែកហួរក្តាន់ ទើបនាង

មើលទៅជុំវិញខ្លួន ដើម្បីសុំជំនួយ។

"ជួយផង ជួយខ្ញុំផង"

ពេលនោះឯងដែលថ្ពាល់របស់ហ្សឺកកំលោះទៅជាក្រហមងាំង ព្រោះនឹកឃើញថាមិនមែននៅតែពីរនាក់ ទើបពន្លែងខ្លួននាងភ្លាម ហើយស្រែកបញ្ជាឱ្យបោះបង្គោលតង់សាថ្មី។ សារីហ្វ ដឹងពីតេជឫទ្ធិរបស់ស្រីម្នាក់នេះ ទើបយកខ្សែស្បែកមកចងដៃចងជើង ដោយមិនអាណិតអីបន្តិច។

អាលិហ្សា ងើយមើលផ្ទៃមេឃ ហើយត្អូញត្អែរនៅក្នុងចិត្តថាលក់ត្បូងលក់ពេជ្រ តែងខ្លួនស្អាត នៅសុខៗសោះ ហេតុអីក្លាយជាទាសករកណ្តាលសមុទ្រខ្សាច់បែបនេះទៅកើត។

"អាចោរឆ្កួត អាចោរអន់ចរិត អ្នកមនុស្សជិះគាន់កៀបសង្កត់មនុស្សស្រី បើខ្លាំងមែនមួយតទល់ទេ មនុស្សស្អីមុខក្រាស់ មិនចេះខ្មាសគេ អន់ចរិត អ៊ុយៗ នាំគ្នាមកមើលឱ្យឆាប់ឡើង"



ដោយមិនប្រណីហាន:យសស័ក្តិ ធ្វើឱ្យ អាលី និងទាហានទាំងឡាយមើលមុខ

គ្នា ធ្វើភ្នែកឡេមឡាម ដកដង្ហើមមិនពេញពោះ ព្រោះដៅអារម្មណ៍ចៅហ្វាយ

មិនត្រូវ ពេលឃើញទ្រង់កំពុងញញឹម អាលី ក៏ញញឹម តែពេលសង្កេតឱ្យច្បាស់

ទើបឃើញកែវភ្នែកមុតស្រួចមួយគូនោះកំពុងឆាបឆេះដោយអណ្តាតភ្លើង។

កំពុងឆេះដុំតើនេ៎ះ!

...

ពេលនេះជិតម៉ោងប្រាំល្ងាចហើយ អាលិហ្សា ត្រូវចាប់ចងប្រមៀលខ្លួន

នៅលើដី និងមានមនុស្សរបស់ហ្ស៊ឺកចូលមកបំពាក់ភ្លើងឱ្យ ពេលរួចរាល់ក៏ដើរ

ចេញទៅវិញ ដោយមិនខ្វល់ពីសំឡេងស្រែកសុំជំនួយ ចំណែកនៅខាងក្រៅ

មានតែសំឡេងនិយាយគ្នាជាភាសាព័រសៀ មានការដើរល្បាតយ៉ាងតឹងរ៉ឹង។

អាលិហ្សា ដកដង្ហើមធំ ពេលគ្មានអ្នកណាជួយ ទើបប្រឹងជួយខ្លួនឯង

ទាំងខាំ ទាំងទាញខ្សែស្បែកស្ងិត តែពេលមិនបានសម្រេច ក៏ដកដង្ហើមជំម្តង ទៀត ដេកស្តាប់សំឡេងភ្លើងបែកផ្កាព្មម្តងៗ ដែលយ៉ាងហោចណាស់ចំហាយ ក្តៅរបស់អណ្តាតភ្លើងក៏ធ្វើឱ្យបាតដៃត្រជាក់ឱ្យមានពណ៌ឈាមឡើងវិញ។

ម្ចាស់តង់ចេញទៅបាត់យូរសែនយូរ នាងក៏ប្រឹងអើត.ករកមើល ហើយ ពេលត្រឡប់មកវិញ ក៏មានរបស់មកជាមួយ គឺថ្នាំលាងរបួស តែអ្នកទោសក្រមុំ ហត់ពេក ដេកលក់ទៅហើយ ដែលកាយវិការនេះគួរឱ្យអាណិត ធ្វើឱ្យគេទន់ចិត្ត ល្អក ហើយពេលឃើញខ្លួនប្រាណមាន កដៃ កជើង មានរបួសសើស្បែក គឺ កាន់តែមួម៉ៅក្តៅក្រហាយ។



សារីហ្វ ចូលមកជិត ដើម្បីពិចារណាស្រីម្នាក់នេះឱ្យម៉ត់ចត់។ នាងស្អាត គួរឱ្យស្រឡាញ់ ស្បែកសម៉ត់ខៃ បបូរមាត់ក្រហមតូចច្រមិច ខ្លួនតូចតែមួយ តែ មានរាងមានវៅគួរឱ្យមើល ធ្វើឱ្យនឹកដល់ព្រះនាងក្នុងរឿងព្រេងនិទាន ទាស់ ត្រង់ស្រីសាច់សម្នាក់នេះហែកច្បាប់របស់កុលស្ត្រី ពូកែឡូឡា ពូកែស្រែក បើ



មាននរណាប្រាប់ថាមនុស្សស្រីជាភេទទន់ជ្រាយ គេសុំប្រកែកតវ៉ាដាច់ក្បាលចោល។

ចង្វាក់ដង្ហើមរបស់នាងថេរ ទើបគេដាក់បង្គុយក្បែរ ហើយយកថ្នាំកាត់បន្ថយអាការៈហើមជាំ និងថ្នាំលាបរបួសមកដាក់ជិត ប៉ាតថ្នាំនឹងម្រាមដៃហើយប្រុងលាបលើស្បែកសម៉ដ្ឋខៃ តែបែរជាឱនមុខសង្ហាទៅរកថ្ពាល់រលោងទៅវិញ ទាស់ត្រង់ថាពេលនោះភ្ញាក់ស្មារតី ទើបសម្រេចចិត្តមិនប៉ះពាល់នាង ព្រោះមិនចង់ធ្វើជាមនុស្សប្រុសកេងចំណេញលើមនុស្សស្រីដែលកំពុងដេកលក់។

"ពេលដេកលក់មើលទៅដូចក្មេងស្រីសុភាពរាបសា"

"ពេលភ្ញាក់ក៏គួរឱ្យស្រឡាញ់វើយ!"

នាងបើកភ្នែកគ្រលួងៗ ញេញចង្អុម គ្រហឹមដាក់ ទើបគេដឹងថានាងចង់ខាំកដៃរបស់នាង គួរឱ្យចាប់កាច់កមែនទែន បែបនេះ។

អាលិហ្សា សម្លក់សម្លឹងគេ ខ្ជឹបបបូរមាត់ណែន ថ្ពាល់ទាំងសងខាង

ក្រហមងាំង មើលក៏ដឹងថានាងកំពុងខ្លាចខ្លាំង។ សុខៗ គេនឹកចង់លួងលោម

នាង ទើបឱនទៅរក ឱ្យមុខទាំងពីរនៅជិតគ្នាបង្កើយ ជិតដល់ថ្នាក់ទទួលបាន

ខ្យល់ដង្ហើមក្តៅៗរបស់គ្នា។ នាងងាកមុខចេញ ដែលធ្វើឱ្យប៉ះចុងច្រមុះរបស់គេ

ទើបបិទភ្នែកភ្លាម ព្រមទាំងស្រែកឡូឡា។

"ធ្វើអី!"

"មុខឆ្នាស មាត់ដាចបែបនេះ អ្នកណាទៅធ្វើអីកើតទៅ ពេលរសៀល

អាកាសធាតុនៅសមុទ្រខ្សាច់ចាប់ផ្តើមរងា ចាំរកខោអាវក្រាស់ៗឱ្យពាក់ ឱ្យចេះ

ដឹងគុណផង"

មនុស្សស្អីពូកែទារសគុណ ពូកែតាម គួរបញ្ចុះបញ្ចូលឱ្យទៅធ្វើជាអ្នក

តាមទារបំណុល!

ពេលគេងាកទៅដោះអាវ ឱ្យឃើញសាច់ដុំ ទើបនាងត្រៀមប្រយុទ្ធដោយ



មិនខ្លាចងាប់ ធ្វើឱ្យគេគ្រវីក្បាលដោយការនឿយណាយចិត្ត ព្រោះថ្នាក់ត្រូវចង

ដៃចងជើងហើយ ទឹកមុខនៅតែឆ្មាសឆ្មើម មិនព្រមលន់តួ។

សារីហ្វ យកនេះ រើនោះ ពេលបានហើយក៏បោះអាវរងាក្រាស់ឱ្យ តែ
នាងប្រឹងរំកិលខ្លួនថយ និងបិទភ្នែកភ្លាម ព្រោះមិនចូលចិត្តក្លិនញើសរបស់
មនុស្សពុកមាត់ស្រមូប។

"ខ្ញុំ... រងាជើង ឈឺដៃរ"

"អ្នកណាប្រើឱ្យដោះស្បែកជើងគប់គេ"

"អ៊ុំ!"

"នៅឱ្យស្ងៀម មើលរបួសឱ្យ"

គេដើរមកដាក់បង្គុយក្បែរ ចាប់កជើងដែលមានរបួសប្រែចុះប្រែឡើង
ដើម្បីពិនិត្យ ហើយអូសខ្សែភ្នែកទៅសម្លឹងដើមទ្រូង ទំហំរបស់វាធំជាងប្រអប់ដៃ
របស់គេទៅទៀត មូលក្តុំ ណែនក្បាំ ទើបប្រញាប់ទាញខ្សែភ្នែកមកវិញ និងទាញ
ចំណាប់អារម្មណ៍ដោយការយកសេរ៉ូមប្រែសម្រាប់លាងរបួសចាក់ទៅលើ និង

ជូតដោយថ្នាំលាងរបួស។ ដៃរបស់គេធំ ចាប់កជើងរបស់គេបានស្រួល តែចាប់

ដោយការប្រុងប្រយ័ត្ន។

"ជើងតូចមួយក្តាប់ តែរត់យីពីលឿន"

គេរអ៊ូៗ ដូចនិយាយដាក់ខ្លួនឯង ដែលធ្វើឱ្យមុខរបស់នាងក្រហម និង

ប្រញាប់ដកជើងចេញ ខណៈនោះខ្សែភ្នែកពីគូក៏ប្រសព្វគ្នា និងភាំងមួយដង្ហើម

ឱ្យនាងមើលពន្លឺភ្នែកសប្បាយចិត្តផង ស្អាក់ស្ទើរផងនៅក្នុងកែវភ្នែកមួយគូនោះ

តែនាងទៅជានិយាយអីមិនចេញ។

"ឡូឡាមួយថ្ងៃហើយ ឃ្លានហើយនៅ?"

គេសួរដោយសំឡេងកាច ទើបត្រូវនាងធ្វើឆើយដាក់ សក់ពណ៌ខ្មៅចាស់

វែងទាំងស្អាត ទាំងរលើបរលោងរលាស់តាម ទើបគេដកដង្ហើមធំចំអកខ្លួនឯង។

អ្ហឺ ណ៎! ស្រីស្អាតសុភាពរាបសាមានពេញនគរមិនធ្លាប់ចាប់អារម្មណ៍

បែរជាគោចរមកជួបស្រីគួរឱ្យស្រឡាញ់បែបឆ្នាសឆ្មើម ហើយពេលនាងធ្វើមុខ



ខ្ញុរ ទាំងដែលពោះកំពុងកូរក្រូកៗ ក៏ចង់ធ្វើបាប។

"សំឡេងស្អកបែបនេះ ស្រែកទឹកហើយហ្នឹង"

មនុស្សដូចគេចាត់ទុកជាបិសាចឈាមត្រជាក់ អាចនិយាយស្តីកូរវឹក សរសៃប្រសាទអ្នកដទាំបានទាំងដែលកំពុងញញឹមស្រស់ ធ្វើឱ្យនាងឈឺចិត្ត មិនចង់ព្រមចាញ់មនុស្សប្រភេទនេះទេ។

"មែន តែទោះខ្ញុំស្រែកទឹកងាប់ ក៏មិនប្រាប់ស្អីទាំងអស់"

"ហេតុអីហួងហែងចិញ្ចៀនដែលមិនមែនជារបស់ខ្លួនឯងបែបនេះ"

"ព្រោះមិនមែនជាចិញ្ចៀនធម្មតា វាមានតម្លៃផ្នែកផ្លូវចិត្ត ចោរដូចលោក ស្គាល់ទេ ដឹងអត់ថាអតីតហ្សីកដែលលង់លក់ទៅហើយប្រគល់ក្តីស្រឡាញ់ របស់ទ្រង់ឱ្យសម្តេចព្រះមាតា ឌីណា អស់ពីបេះដូង ភស្តុតាងគឺចិញ្ចៀនមួយ វង់នោះ ខ្ញុំមានតួនាទីមើលថែការពារអីវ៉ាន់របស់ភ្ញៀវ នេះជាក្រមសីលធម៌របស់ ឈ្មួញ ខ្ញុំមិនដឹងថាចោរដូចលោកយកចិញ្ចៀនទៅធ្វើអីទេ តែខ្ញុំមិនព្រមឱ្យទេ"

"ចិញ្ចៀនមួយវង់នោះជារបស់យើង"

"អ៊ុំ! អីចឹងសាកប្រាប់ភិនភាគវាម៉ោមើល៍"

"យើងដឹងត្រឹមថាជាចិញ្ចៀនពេជ្រអាប់រស្មី ពេជ្រគ្រាប់តូចៗ"

"អៅៗ ចាប់មនុស្សកុហកបានម្នាក់ហើយ គិតថាបោកមនុស្សដូចខ្ញុំបាន ងាយឬ ប្រាប់ឱ្យដឹងថាគីឡូខុសគ្នា មើលៗ មើលមេដៃខ្ញុំនេះ ពេជ្រធំជាងមេដៃទៅទៀត យើញទេ បោកគេច្បាស់ណាស់"

នាងលើកមេដៃបង្ហាញ ព្រមទាំងសម្លក់សម្លឹង ទើបគេធ្វើភ្នែកឡេមឡាម មើលលើ។

"នាងគិតថាមេដៃរបស់នាងធំ ប៉ុន្តែសម្រាប់ខ្ញុំ មេដៃរបស់នាងតូច"

ពួកគេសម្លឹងសម្លក់គ្នាទាល់តែកើតមានផ្កាភ្លើងផ្ទុះ សំឡេងលាន់ព្រៀកៗ ក្នុងលម្ហ បរិយាកាសឱ្យអារម្មណ៍ក្តៅគគុក ធ្វើឱ្យទាហានដែលកំពុងឈរយាម នៅខាងក្រៅស្រៀវឆ្អឹងខ្នង។



"ទីនេះជាសម្បុកចោរ ទើបមានទាហានមានអាវុធគ្រប់ដៃ គិតតែបង្កសង្គ្រាម ទាំងដែលជាដែនដីសន្តិភាព ឃោរឃៅជួជាតិមែន ហ៊ឹះ!"

ខួរក្បាលខួរក្បុងក្រឡកអស់ហើយនាងស្រី ក្រៅពីពូកែឡូឡា ពូកែស្រែក ពេលនេះពូកែអូសសណ្តោងទៀត ធ្វើឱ្យគេចង់តែដោះទង់*អាសាដុលឡោះ* (*សីហៈនៃព្រះអាឡា ជារហស្សនាមរបស់ សារីហ្វ*) មកឱ្យនាងមើលបណ្តើរ ទះកំប៉ែះគូទនោះបណ្តើរ ព្រោះមេបញ្ជាការកងទ័ពលំដាប់គេក្លាយជាមេចោរ ងខ្សែភ្នែករបស់នាងទៅហើយ។

"តាងនាមព្រះជាម្ចាស់ ទ្រង់មេត្តា ទ្រង់ប្រណីជានិច្ច ពាក្យថាសន្តិភាព មិនមែនមានន័យថាគ្មានសង្គ្រាម វិថីជីវិតដែលត្រូវពឹងផ្អែកធម្មជាតិធ្វើឱ្យកុលសម្ព័នទាំងឡាយដណ្តើមវាលស្មៅគ្នាដើម្បីចិញ្ចឹមសត្វ ភាពប្រទាញប្រទង់គ្នាក្នុងដែនដីនេះគឺជារឿងធម្មតាសាមញ្ញ កុំប្រើខ្សែភ្នែកពីវប្បធម៌ផ្សេងមកមើលហើយកាត់ក្តីវប្បធម៌យើង"

"តែសន្តិភាពគឺជារឿងសំខាន់"

"មែន រាល់ពេលកើតមានការប្រទាញប្រទង់គ្នា ការចរចានឹងកើតឡើង បើជាបំណងរបស់ព្រះអាទ្បា សន្តិភាពតែងតែបើកទ្វាឆ្ពោះទៅកាន់ឱកាសគ្រប់ឱកាស គ្រប់ស្ថានការណ៍ ដូចជា ចាប់ផ្តើមពីការ... បើយល់ព្រមនិយាយគ្នាស្រួលបួល នាងនឹងទទួលបានការស្វាគមន៍"

បុរសសង្ហាទះដៃបីដង បន្ទាប់មកក៏មានមនុស្សលើកអាហារ ដើរចូលមក ហើយនាងក៏បើកភ្នែកធំៗ ពេលឃើញបន្លែស្រស់ពេញកញ្រែង ព្រោះមិនចង់ជឿថាដែនដីសមុទ្រខ្សាច់ មានបន្លែស្រស់គួរឱ្យទទួលទានបែបនេះ ដែលពេលក្រោយមកទើបនាងដឹងថា កំពុងអភិវឌ្ឍសមុទ្រខ្សាច់ឱ្យក្លាយជាប្រភពកសិកម្មទាន់សម័យ។ ល្បីថាដីនៅទីនេះល្អមែនទែន ត្រឹមមានភ្លៀងធ្លាក់ ទោះមួយគ្រាប់ក៏ដោយ វានឹងធ្វើអោយគ្រាប់ពូជដុះពន្លក ហើយក្រៅពីបន្លែស្រស់នៅមាននំម្សៅណាន និងយ៉ាអួ មួយចានធំទៀត។



ក្រមុំកូនកាត់ងឿងឆ្ងល់មិនយល់ថាពួកគេទទួលទានដោយរបៀបណា។

តាំងពីមកដល់ប្រទេសនេះ នាងពឹងពាក់ផ្ទះបាយរបស់សណ្ឋាគាររហូត មិន

ធ្លាប់សាកល្បងអាហារប្រពៃណី។

"បើសន្យាថាមិនរត់ ខ្ញុំនឹងស្រាយចំណងឱ្យ យល់ព្រមទេ?"

ពេលឃើញនាងតាមមើលអាហារទាំងនោះ ដោយខ្សែភ្នែកស្រេកឃ្លាន

សារីហ្វ ក៏ដាក់សំណើ។

"ក៏បាន"

"សន្យាទេ?"

"អ៎ុយ! ចង់និយាយយូរទៀតទេ ខ្ញុំខះកចង់ងាប់ហើយ"

ពេលមានសេរីភាព នាងក៏លើកពែងតែផ្អែមៗ ផឹកព្រោះស្រេកខ្លាំង តែ

រសជាតិផ្អែមត្រជាក់ ឱ្យអារម្មណ៍ដូចបានកើតថ្មី បន្ទាប់មកក៏សង្កេតអ្នកអង្គុយ

ទល់មុខ ឃើញគេទទួលទានមើលទៅទំនងធ្លាញ់ណាស់ វិធីទទួលទានក៏មិន

លំបាក គ្រាន់តែបៀកម្សៅដែលរាងស្អិតទំហំមួយម៉ាត់ បន្ទាប់មកក៏ដួលយ៉ាអួ ស្រោចពីលើ ខ្ចប់វាដូចគាវហើយដាក់ចូលមាត់ ដែលគេទទួលទានត្រឹមមួយ ភ្លែតប៉ុណ្ណោះ នំម្សៅណានមួយគំនរធំក៏រលស់អស់។

"ឆ្ងាញ់ ភ្លក្សទេ ?"

គេហុចនំម្សៅណានខ្ចប់យ៉ាអួឱ្យភ្លក្ស ដោយមិនញញើតដែលរាងកាយ ល្វែងលើរបស់ខ្លួនគ្មានអីបិទបាំង និងលួចញញឹមដែលបានបេះបួយស្រីជើង ល្អ ព្រោះពេលនេះមុខរបស់នាងឡើងក្រមូវ មិនហ៊ានមើលគេចំៗ។

"ម៉េចចាំបាច់ដោះអាវ ?"

"មិនបាច់ធ្វើមុខដូចតួស្រីរឿងប្រលោមលោក ប្រាប់ឱ្យដឹងមុន បើក្នុង លោកនេះ លែងមានមនុស្សស្រីនៅសល់ ទើបយើងរើសយកនាង"

មនុស្សប្រុសស្អី សម្តីមិនគួរឱ្យស្រឡាញ់សោះហើយ!

"សួរខ្ញុំសិនទៅ បើដល់ពេលនោះ ខ្ញុំរើសលោកឬអត់ អាមនុស្សលង់ខ្លួន



ងងឹ"

នាងជូតទឹកភ្នែកដូចកូនក្មេង ហើយបែរខ្នងដាក់ ព្រោះខឹង។

"មិនញ៉ាំទេអី?"

"ញ៉ាំ"

អាលិហ្សា ញុកនំម្សៅចូលមាត់ ញ៉ាំបានកន្លះបន្ទះ ក៏ទៅលែងរួច ព្រោះអួល ហើយយ៉ាអួពណ៌សក៏ជូរម៉ែអាជូរទៀត ពេលងាកទៅរកបន្លែសាឡាត់ វាសុទ្ធតែបន្លែមែន មានប៉េងប៉ោះ ត្រសក់ និងបន្លែស្លឹក គ្មានទឹកជ្រលក់ឱ្យចុចហើយពេលដៀងមើលគេ ក៏ភ្លាក់ផ្អើល ព្រោះគេញ៉ាំអស់ពីចាន មិននៅសល់សូម្បីតែបន្លែផៅមួយទង ពូកែញ៉ាំដូចគោស៊ីស្មៅ។

សារីហ្វ ទ្រានដៃមើលស្រីសាច់ស ដែលញ៉ាំបណ្តើរ ធ្វើមុខដូចយំបណ្តើរ ទើបគេកុម្ម៉ង់អាហារថ្មីឱ្យ ម្តងនេះនាងញ៉ាំអស់រលីង។

អាលិហ្សា យកសាច់អាំងមកញ៉ាំមួយៗ និងរង់ចាំឱ្យបាត់ក្តៅ ហើយញ៉ាំ

ជាមួយសាទ្បាដយ៉ាងឆ្ងាញ់មាត់ ទើប សារីហ្វ ប្រគល់សាច់អាំងទាំងអស់ឱ្យ។

"ឆ្ងាញ់ដល់ហើយ នេះសាច់អី?"

"សាច់បង្គួយ សំណាងដែលចាប់បានអាធំ មិនគិតថានាងចូលចិត្ត"

អាឆ្កួតអីយ!

អាលិហ្សា ឈប់ញ៉ាំភ្លាម និងកំពុងអន្ទឹមអន្ទម ជេរគេនៅក្នុងចិត្តមិនដក មាត់ ខណៈដែល សារីហ្វ ធ្វើមុខមាំ តែពន្លឺភ្នែកញ័រ ព្រោះកំពុងអស់សំណើច។ ពេលបានបេះបួយហើយ ក៏ធ្វើឱ្យគេសើចចូលចិត្ត បន្ទាប់មកទើបបកស្រាយ។

"វាជាសត្វចៀម ប្រឡាក់គ្រឿងទេស អាំងលើភ្លើងតិចៗ បើមានអារម្មណ៍ ល្អវិញហើយ គួរជួយសហការផង"

"អីចឹងប្រាប់សិនម៉ោ ថាត្រូវការចិញ្ចៀនសម្តេចព្រះមាតា ឪណា ធ្វើអី?

"យើងមិនចាំបាច់ប្រាប់នាង ឱ្យចិញ្ចៀនម៉ោ កុំឱ្យយើងអស់ការអត់ធ្មត់ ទាន់ យើងដឹងហើយថានាងជាតំណាងរបស់តែវ៉ាន់ មើលខុសត្រូវត្បូងមណី



ដែលនាំយកមកលក់ក្នុងពិធីតាំងពិព័រណ៍ ហើយពេលនេះយើងបញ្ជាឱ្យនាង ប្រគល់ចិញ្ចៀនពេជ្រនោះមកវិញ យើងប្រើកិត្តិយសរបស់ខ្លួនជានាថានាងត្រូវតែមានសុវត្ថិភាព"

និយាយមិនទាន់ចប់ផង ស្រីមាឌល្អិតក៏ផឹកទឹកតែទាល់តែឆ្អែត ហើយងើបឈរយឺតៗ ទឹកមុខក៏ស្មើ ទើបគេរង់ចាំចម្លើយដោយការអត់ធ្មត់ តែត្រឹមមួយប៉ប្រិចភ្នែកប៉ុណ្ណោះ នាងក៏រត់ចេញពីតង់ កាត់ក្រុមទាហានដែលកំពុងឈរយាមកាមបានយ៉ាងងាយ ព្រមទាំងស្រែកដាក់។

"មនុស្សដូចខ្ញុំមិនចរចាជាមួយចោរទេវើយ!"

ឃើញបែបនេះ សារីហ្វ ចំហមាត់ធ្លុង។

អ៊ូហ៎! ម្ចាស់ថ្លៃ ឆ្នាសឡើងព្រឺសម្បុរ!

គេត្រូវដកដង្ហើមចូលឱ្យពេញសួត ដើម្បីរម្ងាប់អារម្មណ៍ មើលទៅគេត្រូវចាប់នាងទះកំប៉ែះគូទម្តងទៀតហើយទេដឹង ទើបនាងរាងចាល។

...

ថ្ងៃនេះរត់ម៉ារ៉ាតុងប៉ុន្មានគីឡូម៉ែត្រហើយក៏មិនច្បាស់ តែដែលច្បាស់គឺ
នាងរត់សំដៅទ្បានឡង់រ៉ូវ៉ែរដែលចតនៅជិត និងសម្លឹងឃើញវាតាំងពីត្រូវគេនាំ
ចូលមកក្នុងសម្បុកចោរនេះម្ល៉េះ ហើយចំណាយពេលតែបន្តិចក៏បញ្ឆេះម៉ាស៊ីន
បាន និងជាន់ហ្គែរកប់ជើងតែម្តង ចោលសម្រុកចេញពីបន្ទាយ ឱ្យទាហានទាំង
ទ្បាយលោតគេចព្រោងព្រាត។

"លាដល់ជាតិក្រោយ អាពួកចោរ ហាសហា"

"តូចតែខ្លាំង ក្រាបទូល ដូចផ្លាយចេញមកពីកុនសង្គ្រាម បើបំពាក់អាកា
បាញ់រះទៀតនេ៎ះ ដឹងតែមែន"

អាលី អស់សំណើចមុខឡើងក្រហម តែបុរសខ្ពង់ខ្ពស់មិនសើចជាមួយ
គិតតែប្រញាប់តែងខ្លួនពាក់កណ្តាលជាឯកសណ្ឋានទាហាន ទាញអាវុធ និង
ខ្សែធំៗសម្រាប់ចងអូដ្ឋ មុខមាំឡើងក្រហមងាំងដោយកំហឹង ពេលដើរឡើង



ឡានមួយទៀត ដោយមាន អាលី លោតឡើងតាម តែត្រូវបណ្តេញចុះ ទើប
កូនចៅជំនិតយល់ហើយ ថានេះជាកិត្តិយសរបស់*អាសាដុលឡោះ* និង *អាមីរ*
ក្រមុំតូចថ្លើមធំ។

"ព្យុះខ្សាច់បង្កើរូបរាងហើយ សូមប្រុងប្រយ័ត្នផង ក្រាបទូល"

"មិនលើសពីដប់នាទីក៏រួចរាល់ហើយ រៀបចំអីវ៉ាន់គេចពីព្យុះមុនទៅ
ហើយត្រៀមទ្រុងឱ្យយើងផង"

៨

សមុទ្រសាច់

អាលិហ្សា បើកឡានលុយខ្សាច់តាមស្នាមកង់ឡាន ត្រឡប់ទៅកាន់កន្លែងទុកឡានចោល គោលបំណងគឺជីកយកកាបូបដែលលាក់ទុក ហើយប្រញាប់រត់ចូលវាំង ទៅដំណាក់សម្តេចព្រះមាតា ឪណា តែស្ថានភាពដូចមិនសូវស្រួលហើយពលនេះ ព្រោះនៅខាងក្រោយមានខ្យល់គួចដីខ្សាច់ ដែលមិនបាច់ងាកទៅមើលថាជាម្ចាស់កម្មពៀរពុកមាត់ស្រមូមនោះឯង ទើបធ្វើឱ្យនាងនឹកខឹងអាចោរស្រមូមនោះ ថាចង់តាមដូចតុកកែកូនខ្ចីឬយ៉ាងម៉េច។

ពេលមកដល់កន្លែងដែលឡានឡង់រ៉ូវែរជាប់អន្លង់ខ្សាច់ នាងក៏ប្រញាប់ចុះទៅកាយខ្សាច់ខាងទ្វារអ្នកបើកបរ យកងាប់យករស់ ទាល់តែឃើញកាបូប



តែពេលងាកមកវិញ ដើម្បីដើរទៅឡើងឡាន សារីហ្វ ក៏មកដល់ល្មម ហើយគេ

ក៏បាញ់កង់ឡានទាល់តែសំប៉ែតក្នុងពេលមួយប៉ប្រិច ដើម្បីបិទច្រករត់គេច ទើប

នាងស្រែកចង់ដាច់កន្លើត ស្រែកជេរប្រទេច។

នេះវាដូចនាងនាំផ្លូវចោរមកឱ្យប្លន់ចិញ្ចៀនឱ្យសុទ្ធៗ!

"ឡើងឡាន យើងត្រូវចេញពីទីនេះហើយ ឱ្យឆាប់ឡើង"

"មិនទៅ!"

"ឡើងឡាន! ខ្ញុំមិនធ្វើអីនាងទេ"

"ម៉េចជឿបានទៅ ថាទុកចិត្តលោកបាន?"

អាលិហ្សា ឱបកាបូបជាប់ ពេលដើរចេញ ទើបគេគ្រវីក្បាល ហួសចិត្ត

នឹងស្រីក្បាលរឹងគ្មានគូប្រៀប ហើយមើលទៅខាងមុខ ដើម្បីរម្ងាប់អារម្មណ៍

ខឹងសម្បាបន្ទាប់មកក៏លោតចុះពីឡានទៅអូសនាងមកវិញតែនាងមិនព្រមដើរ

តាម គិតតែក្រាញ។

"ឈប់ភ្លាម នាងធ្វើឱ្យខ្ញុំខាចពេល ត្រឹមចិញ្ចៀនមួយវង់ ឱ្យម៉ោ កញ្ញា"

"អីចឹងឬ! ហើយអ្នកណាប្រើឱ្យមកខាតពេលនៅទីនេះ ទាល់តែមាន បញ្ជាពីសម្តេចព្រះមាតា ឌីណា ទើបខ្ញុំព្រមឱ្យ អ្នកផ្សេងកុំសង្ឃឹម អ៊ូ! កុំប្រាប់ ថាដែលខំតាមមកដណ្តើមចិញ្ចៀន ព្រោះចង់យកទៅគំរាមរឹបអូសអំណាចដូច នៅក្នុងកុន អ៉ាៗៗ"

"សរសៃប្រសាទហើយ កញ្ញា"

"អឺ! សរសៃប្រសាទ មានបញ្ហាអីទេ!"

នាងខាំមាត់ ប្រឹងដើរបន្ត គេក៏ដើរតាម និងអាស្រ័យជើងដែលវែងជាង ដើរមកស្ទាក់មុខស្ទាក់ក្រោយ ទើបនាងសង្កៀតធ្មេញ គ្រហឹមដាក់ ហើយគេច ចេញ ទើបពេលនេះពួកនាងត្រូវកៀងគ្នាជុំវិញឡាន។

"ខ្ញុំប្រាប់ថាឱ្យឈប់!"

"មិនឈប់! ហ៊ានតែចូលមកជិតមើល៍ ខ្ញុំនឹងខាំស្លឹកត្រចៀកឱ្យដាច់"



សារីហ្វ ខឹង និងដាក់ទោសនាងច្រើនណាស់ ហើយពេលវេលាដែលកាន់តែកៀក ធ្វើឱ្យគេសម្រេចលោតទៅសង្គ្រប់ចង្កេះតូចស្តើងភ្លាម។

"អ៉ា!"

នាងស្រែកអស់សំឡេង ខណៈនោះក៏ភ្លាត់ជើង រមៀលធ្លាក់ពីទួលខ្សាច់ទាំងពីរនាក់ ប៉ុន្តែគេយកខ្លួនឯងរងការប៉ះទង្គិចចំពោះនាងជានិច្ច តែយ៉ាងណានាងទាំងភ័យ ទាំងចុកពោះ និងរឹះតែស្រែកម្តងទៀត ពេលឃើញអ្វីម៉្យាងនៅចំពោះមុខ។

"ហ្វ!"

ពស់ខ្មៅស្តើលទាំងធំ ទាំងវែង កំពុងអើត.ក បើកពពារនៅឆ្ងាយពីពួកនាងមិនប៉ុន្មានម៉ែត្រ។

"អ៊ី! ពស់ ជួយផងៗ"

"ស្ងៀម!"

សារីហ្វ សម្លឹងវាមិនដាក់ភ្នែក ខណៈនោះក៏ឱបស្រីមាឌល្អិត តែស្រែកឮ ឱ្យនៅក្រោមរាងកាយដោយដៃម្ខាង ដៃម្ខាងទៀតទាញកាំបិតខ្លីចេញពីស្រោមដែលសៀតនឹងចង្កេះ ដើម្បីត្រៀមខ្លួនទប់ទល់ជាមួយវា តែសំណាងល្អដែលពស់បែបធុញទ្រាន់ទេដឹង ទើបលូនចេញទៅតាមផ្លូវរបស់វា ទុកឱ្យពួកគេបានដកដង្ហើមធូរទ្រូងជាមួយគ្នា។

តាមធម្មតាគេហត់នឿយជាមួយមនុស្សស្រីនៅលើគ្រែ មិនធ្លាប់មានទេបែកញើសដោយសារស្រីខ្ចីញ្ញេញជើងល្អ។ ទាំងដែលរមៀលមកឆ្វាយយ៉ាងនេះហើយ នាងនៅតែមិនព្រមឈប់រើ ទើបគ្រហឹមនៅដើម.ក ហើយប្រើកម្លាំងកំហែងក្រសោបកដៃទាំងពីរដាក់ទៅលើក្បាល ដើម្បីចង តែខ្សែភ្នែកបែរជាជាប់ឆ្កឹង គិតតែសម្លឹងបែបនោះ ទើបនាងឈប់រើ ដោយការសង្ស័យថាគេមើលអ្វី។

"អា... អា..."



និងជំពប់ខ្យល់ដង្ហើមដោយការខ្មាសអៀន ព្រោះអាវសឺមី វាគ្មានរបៀនរៀបរយ គិតថាប្រហែលរបូតពេលត្រូវគេក្រសោបចង្កេះ រអិលជើងដួល រមៀលនោះឯង ឡេវអាវដាច់អស់ ដៃអាវត្រូវទាញឱ្យរហែកចំស្មា ឱ្យសាច់សខ្ចីនៅកណ្តាលវាល រញ្ជួយដល់ហ្ស៊ឹកសោះកក្រោះឱ្យមើលមិនដាក់ភ្នែក។

"ចង់មើលយូរទៀតទេ អាឆ្កួត"

"កាន់តែរើ កាន់តែឃើញ"

ពេលគេញញឹមបេះបួយបែបនេះ នាងក៏សង្កៀតធ្មេញ គ្រហឹមកាន់តែព្ម និងឈប់រើបម្រះ ប៉ុន្តែក្រៅពីគេមិនព្រមងើបចេញ បែរជាឱនមកសម្លឹងនៅជិត ទើបម្តងនេះនាងរើបម្រះមួយទំហឹងតែម្តង ដែលអាវក្នុងស្ទើរតែឱបក្រសោបដើមទ្រូងណែនក្បាំលែងជាប់ វាចេះតែដោលឡើងលើ។

ទាំងដែលធ្លាប់ឃើញស្រីក្នុងហារែម និងស្រីរបាំប្រើប្រាស់រូបភាពជា

ច្រើនដើម្បីទាក់ទាញ ប៉ុន្តែពេលបានឃើញសាច់សខ្ចី អារម្មណ៍ពុះកញ្ជ្រោល
របស់មនុស្សប្រុសដែលឆ្លងកាត់សង្គ្រាមតណ្ហាជោកជាំ បែរជាត្រូវដុតឱ្យឆេះ
បានយ៉ាងងាយ។

"ទោះស្រមេកស្រមកបបន្តិច តែស្អាតផស់គេ ថែមទាំងចំហឱ្យមើល
មិនគិតលុយទៀត"

"កុំមើល លែងខ្ញុំអាឆ្កួត អាថោក! តិចចាក់ធ្លុះគ្រាប់ភ្នែក!"

សាច់នាងសខ្ចីស្រាប់ហើយពេលខោអាវបិទបាំងមិនជិត ហើយពេល
បានឃើញសាច់ដែលនៅក្នុងខោអាវបែបនេះ គឺដូចបណ្តូលចេក ដើមទ្រូងជំ
ជាងដងខ្លួនទ្រលុកទ្រលន់គួរឱ្យមើល ពោះរាបស្មើ មានរន្ធផ្ចិតតូច មើលទៅគួរ
ឱ្យស្រឡាញ់កាន់តែទាក់ទាញចិត្តអារម្មណ៍។ សារីហ្វ ដកដង្ហើមចូលឮខ្លាំងៗ
ជីពចរលោតញាប់ ធ្វើឱ្យភ្នែកខ្លះនៃរាងកាយឡើងរឹងកំព្រឹស ព្រោះនាងស្អាត
គ្រប់កន្លែង ទាស់បន្តិចគឺជេរឈ្មុយណាស់ ហើយជង្គង់តូចនោះក៏លើកអុក



ចំណុចយុទ្ធសាស្ត្ររបស់គេខ្លាំងៗ ទៀត ធ្វើឱ្យមុខរបស់គេឡើងខ្មៅប៉ែ។

"នាង... នាងជាមនុស្សស្រីចុងក្រោយដែលខ្ញុំមើល... ចាំទុក!"

គេសង្កៀតធ្មេញដាក់ ទម្លាក់ខ្លួនផ្ងារក្រោយ ព្រោះចុករមួលអស់ហើយ ពេលនេះ និងនិយាយរអ៊ូៗ។

"សមមុខ អ្នកណាប្រើឱ្យធ្វើខ្លួនគ្មានមារយាទដាក់គេមុន"

នាងក្រសោបជាយអាវចងគ្នា និងឱបកាបូបណែនដៃ។ ពេលនេះទាំងហត់ ទាំងក្តៅ ទើបមិនបានជាសង្កេតសំឡេងខ្យល់ដែលកំពុងបក់បោកខ្លាំងនិងកាន់តែខ្លាំងៗ ទៅឱ្យសក់គ្រវីគ្រវាត់តាម កាបូបក៏ប៉ោងតាមដែរ ពពកប្រែពណ៌ បិទបាំងពន្លឺថ្ងៃ។

"កាបូប!"

"តាមតែវាទៅ ឡើងឡាន!"

ម្តងនេះ អាលិហ្សា មិនបដិសេធ ប្រញាប់លោតឡើងឡាន ដោយការ

ភ័យខ្លាច ខណៈនោះក៏ដឹងខ្លួនថាកំពុងប្រឈមមុខគ្រោះធម្មជាតិ គ្រប់យ៉ាង បង្ករបរាងលឿនណាស់ ខ្យល់បក់ចោកដីខ្សាច់ឱ្យវិលខ្ទាល់ មេឃទៅជាខ្មៅ និង គ្រោះថ្នាក់មិនអាចបើកឡានបាន។

សារីហ្វ ចេញបញ្ជាតាមវិទ្យុទាក់ទងឱ្យមនុស្សរបស់ខ្លួន ដកថយទៅរក កន្លែងគេចពីព្យុះ បន្ទាប់មកក៏សម្រួលកៅអីឡានរបស់ខ្លួនឯងនិងនាងឱ្យដេក រាប យកឡានឡង់រ៉ូវ័រធំនេះធ្វើជាគ្រោះការពារបណ្តោះអាសន្ន។

"រុំស្បៃឱ្យជាប់ បិទមុខបិទមាត់ឱ្យជិត ហើយក្រាបចុះ"

គេបញ្ជា ហើយផ្តួលខ្លួនដេក និងទៅជាភាំង ពេលឃើញនាងញ័រខ្លួន និងកំពុងយំ។

"កុំខ្លាច នាងមានខ្ញុំ"

"ព្យុះយូរទេ ?"

"មិនយូរទេ មិនប៉ុន្មានម៉ោងប៉ុណ្ណោះ"



គេកុហក ព្រោះមិនចង់ឱ្យនាងភ័យខ្លាចជាងនេះ ព្រោះព្យុះសមុទ្រខ្សាច់
កើតទ្បើងញឹកញាប់ និងព្យុះពេញមួយថ្ងៃ ឬជួនកាលច្រើនថ្ងៃ។

ខ្សាច់ដែលត្រូវព្យុះបក់នាំមកក៏កើនកម្ពស់មកនៅចំហៀងឡាន ខ្យល់
បក់ចោកខ្លាំង ធ្វើឱ្យរញ្ជួយដូចយក្សអង្រួន កញ្ចក់បង្អួចក៏ប្រេះ ហើយពេលនោះ
ឯងដែលនាងព្រមឱ្យបសារភាពការពិត។

"ខ្ញុំខ្លាច"

ធ្វើខ្លួនគួរឱ្យស្រឡាញ់ក៏ចេះដែរតើ!

សារីហ្វ គិតនៅក្នុងចិត្ត និងសម្លឹងមើលមុខនាង ដោយមិននិយាយអ្វី
ត្រឹមលូកដៃទៅដាក់លើក្បាល ជាការប្រាប់ដោយកាយវិការថានាងនឹងមាន
សុវត្ថិភាព។ នាងប្រសព្វភ្នែកជាមួយគេយ៉ាងយូរ ហើយងាកចេញ អង្គុញ់ជើង
រួញខ្លួននៅលើពូកកៅអី ថ្ពាល់រលោងផ្អឹបនឹងពូកស្បែកពណ៌ខ្មៅ តែគេបាន
ចងចាំកែវភ្នែកពណ៌ខ្មៅ មានពន្លឺផ្លេកៗនោះ ទុកក្នុងបេះដូងរួចហើយ ចងចាំ

ដោយមិនដឹងខ្លួន ហើយពេលនោះឯងដែលសង្កេតឃើញចិញ្ចៀនរបស់សម្តេច
ព្រះមាតានៅនឹងម្រាមដៃស្រឡូន។

មើលទៅនាងដឹងហើយថាត្រូវគេសម្លឹង ទើបប្រញាប់ដកដៃម្ខាងនោះ
ទៅលាក់ និងសម្លឹងគេវិញដោយខ្សែភ្នែកដូចខ្លាញីដែលកំពុងត្រៀមខ្លួនប្រយុទ្ធ
ជាមួយស្តេចតោមហាកម្លាំង។ នៅវេលានេះ ពិភពលោកទាំងមូលមានតែគេ
និងនាងពីរនាក់ប៉ុណ្ណោះ នៅឆ្ងាយពីគ្នាត្រឹមឈោងដៃដល់ ខ្សែភ្នែកពីរគូដែល
ប៉ះគ្នាក្លាយជាកម្តៅប្លែកៗ។

"ខ្ញុំស្មានថាវាទៅបាត់ជាមួយកាបូបតើ"

"បង្កាអ្នកខ្លះមានគំនិតដណ្តើមយកចិញ្ចៀន ខ្ញុំនឹងបោះកាបូបនោះ
ចោល បញ្ឆោតថាចិញ្ចៀននោះក្នុងនោះដែរ"

"ល្បិចច្រើនណាស់"

"ល្អជាងមនុស្សមុខក្រាស់ មិនចេះខ្មាសគេដែរ"



គេបានសម្លឹងមើលរាងរៅតូចច្រឡឹងស្រួលបន្តិច ហើយអត់មិនបាននឹងគិត ដល់ការប៉ះពាល់ទន់ល្មើយ ពេលទះកំប៉ះគូទរបស់នាង ជាងនោះទៅទៀត ស្បែកស ម៉ដ្ឋខែ ទ្រលុកទ្រលន់ដែលទង្គិចភ្នែក ជាចំណីអាហារឆ្ងាញ់មែនទែន កាន់តែមើល កាន់តែគួរឱ្យស្រឡាញ់ គួរឱ្យអង្អែល គួរឱ្យស្វែងរក ទោះត្រូវខាំ ត្រូវទាត់ម្តងទៀត ហើយបានមើលម្តងទៀតក៏ចាត់ទុកថាសមាមាត្រ ទើបធ្វើឱ្យ អារម្មណ៍ដែលទាំងខឹង ទាំងសម្បាក្លាយជាអារម្មណ៍ល្អមួយរំពេច។

"មិនឈ្លោះគ្នាបន្តទេអ្ហែ ?" គេសួរព្រលយចោល មិនដឹងខ្លួនថាចូលចិត្ត តវ៉ាមាត់តសម្តីជាមួយនាងតាំងពីពេលណា។

"សម្រាកសិន ព្យុះស្ងប់ពេលណា ចាំនិយាយគ្នា"

នាងដកដង្ហើមធំ ស្រាប់តែពេលនោះមានដុំថ្មមួយហោះមកប៉ះកញ្ចក់ ខាងខ្លួនមួយទំហឹង ធ្វើឱ្យភ្ញាក់ព្រើត ប្រញាប់បែរមុខមករក ស្រវាដៃរបស់គេ

ឱបណែនបៀតនឹងដើមទ្រូងទន់ល្មើយ ដោយម្ចាស់វាមិនដឹងខ្លួន មិនបានជា ប្រយ័ត្ន ព្រោះរវល់តែបិទភ្នែក ដោយការភ័យខ្លាច។

"ក្រែងជេរខ្ញុំច្រែតៗ ថាជាចោរ ហើយមកឱបដៃចោរធ្វើអី"

"បិទមាត់ទៅ ខ្ញុំកំពុងស្រមើស្រមៃដល់មុខតួប្រុស"

ព្រះអាទិត្យ ស្តាប់នាងនិយាយ!

សារីហ្វ ប្រញាប់ដកភ្នែកចេញ លើកដៃម្ខាងទៀតទ្រក្បាល សន្ធឹងខ្លួនកាត់បន្ថយភាពតាងតឹង។ ខ្លួនគេទាំងធំ ទាំងវែង តែកៅអីទ្បានតូចពេក ទើបដេកមិនស្រួល ហើយចុះឡើងៗ ក៏អត់មិនបាននឹងងាកទៅមើលអ្នកដេកក្បែរ។

គេមើលឃើញរូបភាពខ្លួនឯងឱបក្រសោបនាង ថើបជញ្ជក់ដោយភាពក្តៅគគុក គ្រវាសអណ្តាត រឹតរួតអណ្តាតរបស់នាង ហាក់ដូចសត្វកំណាចដែលរបូតចេញពីទ្រង់ តែពេលព្រិចភ្នែកម្តងទៀត វាគ្រាន់តែយល់សប្តិឆ្កួតៗ របស់ខ្លួនប៉ុណ្ណោះ។



"ជាប់នៅកណ្តាលព្យុះក្នុងសភាពបែបនេះ មិនខ្លាចត្រូវរំលោភទេអ្ហែ"

"សាកមើលទៅ ខ្ញុំនឹងនោមដាក់ឱ្យឆ្អេះងោង កំពុងឈឺនោមផង"

អាលិហ្សា បើកភ្នែក សម្លក់សម្លឹងដោយភាពឆ្មាសឆ្មើម ធ្វើឱ្យគែមមាត់

របស់គេកន្ត្រាក់ ព្រោះកំពុងអស់សំណើចฯ

លេងជេរឡើងអស់អារម្មណ៍ ចំមែន កញ្ញាបរទេស!

ពេលវេលាដើរយឺតណាស់ក្នុងអារម្មណ៍របស់ អាលិហ្សា ខ្យល់បក់ចោក

នឹងតួឡានៅតែដំណើរការមិនឈប់ឈរ គ្រវែងឡានឱ្យរអិលទៅជារឿយៗ

ស្ថានភាពអាកាសធាតុនៅខាងក្រៅងងឹងស្តុប ទើបមិនដឹងថាពេលនេះជាពេល

ថ្ងៃ ឬពេលយប់ฯ

សារីហ្វ មើលនាឡិកា ពេលនេះជិតអធ្រាត្រទៅហើយ តែព្យុះមិនទាន់

សូប់ទៀត ហើយងើយមើលនាង ឃើញកំពុងដេកវឹងខ្លួនស្តូក ដៃទាំងពីរបិទ

មាត់ ដើម្បីទប់សំឡេងអណ្តឹតអណ្តក ព្រោះខ្លាចខ្លាំង ទើបគេប្រាប់ខ្លួនឯងថា ព្រោះអាណិត ទើបបារម្ភពីនាង។

"មើលទៅព្យុះមានពេញមួយយប់"

"ហឹក... ហឹ..."

"មិនបាច់ខ្លាច នាងនឹងសុវត្ថិភាព"

គេទាញនាងឱ្យផ្ងោះកៅអីមករក ឱ្យដេកលើរាងកាយមាំមួន ដែលធ្វើឱ្យនាងរឹងខ្លួនស្តុកភ្លាមនឹងការប៉ះពាល់រឹងកំព្រឹស និងក្តៅគគុករបស់សាច់ដុំរឹងមាំ ចុងម្រាមដៃក៏បានដឹងពីចង្វាក់នៃការដកដង្ហើមចេញចូលរបស់គេ ច្រមុះក៏បានក្លិនក្រអូបរបស់អ្វីម៉្យាង វាមិនមែនជាក្លិនទឹកអប់ម៉ាកថ្លៃ តែជាក្លិនខ្លួនរបស់គេនោះឯង ចំណាយក្តៅឧណ្ហៗក៏ចម្លែក គ្រប់យ៉ាងលួងលោមឱ្យនាងស្ងប់។

សាច់កមានពណ៌មាសក្រហម ភាពធំទូលាយរបស់ស្មា និងដើមទ្រូងមាំមួន ធ្វើឱ្យនាងមានអារម្មណ៍ថាខ្លួនឯងជាមនុស្សក្រិន មុខដែលសង្ហាមាំជា



ដើមទុន ពេលបន្ថែមពុកមាត់ពុកចង្កាទៀត ធ្វើឱ្យនាងនឹកដល់ពាក្យថា *បុរស ដើមទ្រូងហត្ថ*។

ហើយយ៉ាប់ឃឺនបន្តិច ដែលក្នុងស្ថានការណ៍តានតឹងយ៉ាងនេះ ស្អីៗវា រឹងកំព្រឹស ត្រូវល្វែងក្រោមរបស់នាងបៀត វាធ្វើឱ្យគេបាត់បង់ភាពម្ចាស់ការ ហើយនាងមិនដឹងខ្លួនថាឆ្លោយបង្អួតគល់ទ្រូងសខ្ចីមកធ្វើតេស្តការអត់ធ្មត់របស់បុរសដើមទ្រូងប្រាំហត្ថយ៉ាងយូរ ហើយកំលោះក្រមុំក៏នៅស្ងៀមរាងខ្លួនជាច្រើនដងធ្លើម ព្រោះមិនច្បាស់ថាគួរធ្វើយ៉ាងណាបន្ត។

ពេលឃើញ អាលិហ្សា ព្រមដេកស្ងៀម ទើបគេរៀបចំនាងឱ្យដេកស្រួលតែភាពស្និទ្ធស្នាលរវាងកាយបុរសនារី ធ្វើឱ្យសាច់ឈាមរបស់គេមានប្រតិកម្មតែគេមិនសូវចង់ឱ្យនាងដឹងប៉ុន្មាន។ ដើមទ្រូងទន់ល្មើយរបស់នាងនៃបនិត្យ នឹងសាច់ដុំពោះកង់ៗល្មម ថ្ពាល់ពិតនឹងស្មាធំទូលាយ កែវភ្នែកមូលក្តុំបិទព្រឹមៗ ឱ្យរោមភ្នែកក្រាស់ ងរដូចផ្លិតក្រាបលើថ្ពាល់ ដែលភាពទន់ភ្លន់នេះក្លាយជា

គ្រាប់បែកពេលរាប់ថយក្រោយ។ សារីហ្វ ជេរខ្លួនឯងដែលជួញទុក្ខដាក់ខ្លួន

តែមិនអាចធ្វើចិត្តរុញរាងកាយដែលកំពុងញ័រឱ្យទៅដេកលើកៅអីរបស់នាងវិញ

ដោយគ្រប់ចង្វាក់ដកដង្ហើមរបស់ពួកគេឮដង្គក់ៗ។

បុរសដ៏ខ្ពង់ខ្ពស់ ទាញនាងឡើងមកប្រសព្វភ្នែកជាមួយឱ្យបានច្បាស់

ធ្វើឱ្យនាងភ្ញាក់ ក្រាញថយក្រោយដោយការមិនទុកចិត្ត គេក៏ភាំងបន្តិចដែរ

ដោយមិនច្បាស់ប៉ុន្មាន ប៉ុន្តែហើយក៏សម្លឹងមុខគ្នា ចង់ប៉ះបន្តិចអត់បន្តិច ហាក់

ដូចកំពុងលេងហ្គេមវាស់សមាធិយ៉ាងអីចឹង បន្ទាប់មកប្រើម្រាមដៃក្តៅអូសកាត់

បបូរមាត់ទន់ល្មើយពណ៌ផ្កាឈូករបស់នាងថ្មមៗ ដោយមិនសុំការអនុញ្ញាត

ហើយភ្លើយចង្ការរបស់នាង ខ្សឹបប្រាប់។

"កុំខាំ"

អាលិហ្សា មិនយល់ពីអ្វីដែលគេនិយាយ ក៏ត្រូវបបូរមាត់ទន់ ក្តៅ ឱនមក

សង្កត់ ខណៈនោះក៏ឱបរឹត ដៃម្ខាងចាប់កញ្ចឹងករបស់នាងជាប់ ជ្រែកអណ្តាត



ចូលមកដោយការស្រែកឃ្លាន ដួសដងយករសជាតិរបស់នាងទាំងអស់។

សារីហ្វ ក្រសោបមុខរបស់នាងដោយភាពទន់ភ្លន់ ដុតឱ្យសសៃប្រសាទទាំងអស់នៅក្នុងខ្លួនធ្វើការមួយរំពេច ឱ្យស្មារតីរត់ខ្ចាត់ខ្ចាយ គិតអ្វីមិនចេញ កម្រើកក៏មិនបាន ក្រៅពីបង្ហើបមាត់ និងរឹតរួតអណ្តាតរបស់គេតាមការបញ្ជា។ ពេលនៅក្នុងរង្វង់ដៃរឹងមាំ នាងមានអារម្មណ៍ថាខ្លួនឯងតូចតែមួយ ផុយស្រួយ និងញ័ររញ្ជួយ ពេលមានអារម្មណ៍ដល់រាងកាយ សុទ្ធតែសាច់ដុំហាប់ណែនក្តៅគគុក។

នាងកំពុងថើបគេ ថើបដោយភាពជ្រាលជ្រៅ និងធ្វើឱ្យខ្យល់ដង្ហើមក្តៅភាយៗ។ បបូរមាត់ក្តៅគគុកសង្កត់លើបបូរមាត់ទន់ល្មើយ ថ្នមៗ យឺតៗ ហាក់ដូចត្រូវការបឺតយករសជាតិរបស់នាងបន្តិចម្តងៗ អ្វីម៉្យាងនៅក្នុងខ្លួនរបស់នាងត្រូវដុតឱ្យឆេះ ដូចមានគេជាអ្នកបើកទ្វារ ហើយនាងក៏ព្រមទទួល។ សារីហ្វ ខាំកញ្ចឹងកររបស់នាងតិចៗ ជ្រាប់មុខ ឱនមកអក គ្រវាសអណ្តាត ថើបម្តងទៀត មក

ដល់ពេលនេះ ពួកគេទាំងពីរ ក៏ដកដង្ហើមដង្ហក់ ដោយចង្វាក់ស្របគ្នា វាត្តៅឧណ្ហៗ ដែលធ្វើឱ្យនាងមិនអាចបដិសេធបាន។

អាលិហ្សា លិចលង់នៅក្នុងភាពត្តៅគគុករបស់គេ មិនអាចដកខ្លួនចេញមកវិញបាន មិនធ្លាប់គិតទេថា រាងកាយរបស់បុរសធ្វើឱ្យកើតអារម្មណ៍អស្ចារ្យបែបនេះ គេទាំងរឹងមាំ ទន់ភ្លន់ និងត្តៅគគុកក្នុងពេលតែមួយ ឱ្យនាងថ្ងូចថ្ងូរ ធូរធន់ភ្នែកដោយតម្រូវការដែលគេជាអ្នកដុត។

នាងដកដង្ហើមដង្ហក់ ពេលត្រូវឱបរឹតកាន់តែណែន ពេលនេះបេះដូងរីកមាឌយ៉ាងចម្លែក ពេលគេសង្កត់ក្បាលឱ្យជ្រប់នឹងដើមទ្រូងថ្នមៗ។ នាងអណ្តឹតអណ្តកតិចៗ និងបិទភ្នែក លើកដៃម្ខាងទៀតឱបរឹត។ គេជាបុរសដំបូង និងជាបុរសតែម្នាក់គត់ដែលឱបនាង ចុងអណ្តាតប៉ះគ្នា ថើបជញ្ជក់គ្នាម្តងទៀត ដោយមិនហាមាត់សុំ មិនដឹងទេថា វាគួរឱ្យភ្ញាក់ផ្អើលជាងនេះ រវាងការដែលបុរសមាឌធំពោរពេញដោយថាមពលអាចទន់ភ្លន់បានដល់ថ្នាក់នេះ ឬជានាង



ដែលឈប់ភ័យខ្លាចទៅហើយ។

វាប្រហែលស្រដៀងនឹងពាក្យថាឆ្កួត នាងអធិប្បាយមិនបានទេថា ហេតុអ្វីបានជាមានអារម្មណ៍មានសុវត្ថិភាព ពេលនៅក្នុងរង្វង់ដៃរបស់បុរសមិនធ្លាប់ស្គាល់ម្នាក់នេះ។

នាងព្រមចុះចាញ់...ត្រឹមពេលនេះប៉ុណ្ណោះ ពេលព្យុះខ្សាច់ស្ងប់ គ្រប់យ៉ាងនឹងស្ងប់តាម ដោយគ្មានអ្វីឱ្យនឹកនា។

គ្មានពាក្យពេចន៍អីកើតឡើងរវាងពួកគេ មានតែសំឡេងខ្យល់ សំឡេងគ្រាប់ខ្សាច់ចោកបក់ឮខ្លាំងៗ សំឡេងបេះដូង និងសំឡេងខ្យល់ដង្ហើមរបស់នាង និងគេ...មានតែប៉ុណ្ណឹង។

...

ពេលវេលាកន្លងផុតទៅយូរប៉ុនណាមិនច្បាស់ ប៉ុន្តែព្រះអាទិត្យដែលរះ

កណ្តាលលំហ។ អាលិហ្សា បើកភ្នែកម្តងទៀត ព្រោះសំឡេងខ្យល់ និងសំឡេង

និយាយជាភាសាព័រសៀ ដែលបន្លឺចេញពីវិទ្យុទាក់ទង។ ពេលនេះព្យុះសមុទ្រ ខ្សាច់ចប់ហើយ ពន្លឺថ្ងៃក៏ចែងចាំងម្តងទៀត នាងមើលទៅជុំវិញខ្លួន ឃើញកញ្ចក់ប្រេះ និងស្រអាប់ មើលអ្វីមិនឃើញ ទ្វារឡានខាងចង្កូត ក៏បើកចំហ កៅអីឡានទទេស្អាត។

ចោរម្នាក់នោះទៅបាត់ហើយ ?

អាលិហ្សា ស្ទុះងើបអង្គុយទាំងមិងមាំងផង តិតភ័យផង តែបន្ទាប់មកក៏ធូរទ្រូង ដែលចិញ្ចៀនសំខាន់នៅមានសុវត្ថិភាព។

នាងបើកទ្វារចុះពីឡាន ខ្សាច់ដែលសង្កត់លើដំបូលក៏រអិលធ្លាក់ ហើយនាងក៏ប្រឹងរុញទ្វារជាច្រើនដង ទើបបើកបានសម្រេច ព្រោះឡានកប់នឹងខ្សាច់ជិតពាក់កណ្តាលឯណោះ ហើយពេលចុះមកបាន ក៏មើលទៅជុំវិញខ្លួនទាំងមិងមាំង ព្រោះមើលទៅដូចរូបរាងរបស់សមុទ្រខ្សាច់ប្រែប្រួល ដូចខ្យល់ព្យុះនាំឡានមកបោះចោលនៅកន្លែងផ្សេង ទាំងដែលឡាននៅកន្លែងដដែល ហើយ



មានពន្លឺចែងចាំងចាក់ភ្នែករបស់នាងចំៗតែម្តង ហើយដើមកំណើតរបស់ពន្លឺ
គឺបុរសពុកមាត់ស្រមូមម្នាក់នោះឯង។

"យ៉ាប់ឃឺនបន្តិចហើយ មើលទៅឡានទៅមុខមិនរួចទេ"

អ្នកដែលឈរទ្រានដែនឹងមុខឡាន ដែលបើកគម្របដើម្បីឆែកមើលស្ថានភាពរបស់វា ព្រលែងល្វែងលើ កំពុងតែជូតប្រេងម៉ាស៊ីនចេញពីដៃ ដោយសាច់អាវ សាច់ដុំពណ៌មាសក្រហមស្អាតរបស់គេ ធ្វើឱ្យនាងខះក និងធ្វើភ្នែកម៉ក់ៗមើលមិនព្រិចៗ រាងកាយរបស់គេរឹងមាំជាងការគិត ធ្វើឱ្យនាងអត់គិតមិនបានថា សមុទ្រខ្សាច់ក្តៅគគុកមួយនេះប្រហែលជាជំរករបស់បុរសក្តៅគគុកម្នាក់នេះ ហើយពេលនឹកដល់ការថើបដ៏ក្តៅគគុកដែលកើតឡើងនៅលើឡានរាងកាយរបស់នាង ក៏ក្តៅស្រៀវស្រាញ ហាក់ដូចគ្រុនក្តៅ។

អ៊ូយ! ម៉ាក់អើយ ប៉ាអើយ ខ្ញុំថើបគ្នាជាមួយប្រុសម្នាក់នេះទៅហើយ ថើបទាល់តែដេកលក់ស្រួលដោយមិនដឹងខ្លួន!

"ម៉ែចក៏មុខក្រហម កើតអី ?"

ម្ចាស់រាងកាយសង្ហាហាក់ដូចអ្នកបង្ហាញម៉ូត ដើរមករក ពន្លឺភ្នែករបស់គេ ក្តៅគគុក ធ្វើឱ្យនាងទន់ជង្គង់ ហើយក៏ទ្រាំមិនបាន ត្រូវរត់ទៅនៅក្រោយទួលខ្សាច់ដែលនៅជិតនោះ ហើយស្រែកប្រាប់។

"ហាមម៉ោខាងណេះដាច់ខាត!"

"ខ្មោចចូលទៀតហើយឬអីកញ្ញា"

សារីហ្វ បិទគម្របឡានលាន់គ្រាំង ហើយចូលទៅអូសនាង។

"ហ៎! ខ្ញុំកំពុងឈឺនោម ចង់ម៉ោមើលក៏ម៉ោៗ ម៉ោ!"

"បាទៗ កញ្ញា អញ្ជើញតាមសម្រួល"

បុរសដ៏ខ្ពង់ខ្ពស់គ្រវីក្បាល ហួសចិត្ត ចង់តែឆ្កួតដោយសារស្រីម្នាក់នេះ ស្រីស្អី ពាលខុសពីមុខមាត់ ហើយអត់ធ្មត់រង់ចាំឱ្យនាងធ្វើធុរៈផ្ទាល់ខ្លួនរួចរាល់ទើបនិយាយ។



"ចង់ទៅម្នាក់ឯង ឬចង់នៅជាមួយខ្ញុំ ជ្រើសរើស"

"ទៅម្នាក់ឯង"

"ច្បាស់ហើយ ?"

"បើខ្ញុំទៅម្នាក់ឯង បញ្ជាក់ថាលោកព្រមចាញ់ មិនយកចិញ្ចៀនទេមែនទេ

ខ្ញុំទៅម្នាក់ឯងបាន"

នាងពេញចិត្តជាខ្លាំងដើម្បីការពារចិញ្ចៀននេះឱ្យបាន ប៉ុន្តែ សារីហ្វ

ញាក់ស្មា។

"ចង់ពាក់ក៏ពាក់ទៅ បើនាងដើរលុយសមុទ្រខ្សាច់ទៅម្នាក់ឯង ខ្ញុំគ្រាន់តែ

តាមទៅយកចិញ្ចៀនពីសាកសពរបស់នាងនៅពេលក្រោយប៉ុណ្ណោះ"

"អាឆ្កួត !"

"សម្រេចថាម៉េច"

គេងាកមកចាប់អារម្មណ៍សម្ភារៈនៅគូទទ្បាន ពេលរើបានអាវក្រាស់មួយ

ក៏បោះឱ្យ រើម្តងទៀត ក៏ឃើញស្បែកជើង ខមបេត ក៏បោះឱ្យទៀត ហើយត្រៀម

ខ្លួនមិនយូរប៉ុន្មាន ក៏អាចចេញដំណើរបាន ដោយគេពាក់អាវរងា ព្រោះពេលយប់

នៅសមុទ្រខ្សាច់ សីតុណ្ហភាពដកសូន្យ។

"ស្អីគេ ?"

"វាហៅថាអាបាយ៉ា"

គេចង់និយាយពីអាវឃ្លុំពណ៌ខ្មៅដែរែង សម្រុងវែងដល់ចុងជើង។

"ពេលដែលព្រះអាទិត្យរះ វាក្តៅខ្លាំងណាស់ នាងត្រូវប្រើវា"

ពួកគេប្រសព្វភ្នែកគ្នា ដោយព្យាយាមមិននិយាយពីរឿងថើបគ្នាកាលពី

យប់មិញ ព្រោះប្រាប់ខ្លួនឯងរួចហើយថាវាកើតឡើងដោយសារអារម្មណ៍ដឹកនាំ

អារម្មណ៍ដែលកើតឡើងមួយឆាវ មិនអាចយកជាការបាន។

"លោកយកអាវមនុស្សស្រីមកពីណា ?"

"ពាក់ទៅ យើងមិនគួរត្រែតត្រែតនៅទីនេះ"

នាងធ្វើមុខស្ងួញ មើលទៅជុំវិញខ្លួនសុទ្ធតែខ្សាច់ ប៉ុន្មានម៉ោងទៀត

ព្រះអាទិត្យនឹងលិចហើយ ទើបមើលខោអាវដែលគេបោះឱ្យដោយការពិចារណា

ប៉ុន្តែភាពសោះកក្រោះ និងតានតឹងរបស់គេ ធ្វើឱ្យនាងមិនស្រួលចិត្ត ទើបងាក

មើលឆ្វេងមើលស្តាំដោយការភ័យខ្លាច។

"ហេតុអីយើងមិនប្រើឡាន ?"

"ឡានខូចទៅមុខមិនបាន"

"ហើយម៉ែច ?"

"យើងត្រូវដើរចូលក្រុង"

"តែពេលនេះមេឃជិតងងឹតហើយ ក្រែងពីដំបូងមានឡានមកជាមួយ

លោកច្រើនគ្រឿងមិនអីចឹង ទាក់ទងតាមវិទ្យុទាក់ទងគួរតែបានដែរ"

"វាខូចហើយគ្មានទឹកគ្មានអាហារហើយខ្ញុំក៏មិនចំណាយពេលនៅទីនេះ

ដែរ បើចង់ធ្វើដំណើរនៅសមុទ្រខ្សាច់ ដើរពេលយប់គឺជាពេលដែលល្អបំផុត"

គេនិយាយដោយទឹកមុខធម្មតា និងចេញដំណើរដោយមិនខ្វល់ពីនាង
ទៀត ហើយពេលដើរបានបន្តិច គែមមាត់ក៏មានស្នាមញញឹម។

ការពិតឡានវាមិនបានខូចវិទ្យុទាក់ទងក៏ប្រើការបានល្អផ្លូវថ្នល់នៅឆ្ងាយ
មិនប៉ុន្មានរយម៉ែត្រ ប៉ុន្តែគេត្រូវការប្រដៅស្រីខ្លួរក្បាលដងៀបក្តាមនេះឱ្យរំភើប
ដល់ពាក្យថា **អាចោរពាល** ដើម្បីឱ្យដឹងថា ភាពពាលពិតប្រាកដវាយ៉ាងណា។

អាលិហ្សាចងចិញ្ចើមមិនដឹងជាប៉ុន្មានដង ដាក់បណ្តាសាគេឱ្យស្លាប់នៅ
ក្នុងសមុទ្រខ្សាច់ សុំឱ្យត្រូវពស់ចឹកតំបន់សំខាន់ សុំឱ្យត្រូវខ្សាច់បឺតស្រូប ប៉ុន្តែ
ពេលឃើញរាងកាយរបស់គេកាន់តែតូចទៅៗ ទើបប្រញាប់រត់តាមភ្លាម ព្រម
ទាំងស្រែកអស់ទំហឹង។

"ចាំខ្ញុំផង ខ្ញុំទៅដែរ កុំទុកខ្ញុំចោលម្នាក់ឯងអាប្រុសឆ្កួត"



៩

នាងជាអាមិ៉ារបស់យើង

អាលិហ្សា សម្រេចចិត្តដើរតាមគេពីចម្ងាយ ហើយកាន់តែឆ្ងាយទៅៗ ព្រោះស្បែកជើងទាំងធ្ងន់ ទាំងធំ ពាក់មិនស្រួលជើង ឈានម្តងៗកប់ខ្សាច់ ហើយត្រឹមដើរបានមិនប៉ុន្មានរយម៉ែត្រ ក៏ហត់នឿយធ្លាក់អណ្តាតដូចឆ្កែកើតជំងឺហឺត ឈុតអាបាយ៉ា ស្ទេមស្ទាម រុំដៃរុំជើង ដួលញឹកញាប់ ទើប សារីហ្វ លួចដៀងមើល និងបន្តុយលេឿន ខណៈនោះនៅក្រោយខ្នងគេគឺព្រះអាទិត្យដ៏ធំដែលកំពុងតែបន្ទាបខ្លួនយឺតៗ។

"នែ៎! សួរបន្តិចម៉ោ"

"ស្អីគេ"

"លោកជាទាហានរបស់សម្តេចព្រះមាតាឬ ខ្ញុំសង្ស័យតាំងពីពេលនៅមុខវាំងម្ល៉េះ"

"ចង់ថាអីចឹងក៏បាន យើងគ្រប់គ្រងទាហានជើងគោក ទាហាននៅបន្ទាយ ទាំងនោះជាកូនចៅរបស់យើង"

គេជាមេបញ្ជាការយោធា គួបតំណែងប្រធានកងអង្គរក្សការពាររាជវាំងហើយបើនិយាយថាគេជាទាហានរបស់សម្តេចព្រះមាតាក៏មិនខុស។

"ជាទាហាន ហើយម៉េចក៏មិនធាប់ប្រាប់ ធ្វើឱ្យខ្ញុំភ័យ ផ្អើលចូលវាលខ្សាច់" នាងចងចិញ្ចើម សម្លក់សម្លឹងគេ។

"នែ៎ កញ្ញា នាងធ្លាប់ស្តាប់អីដែលខ្ញុំចង់ប្រាប់ពេញមួយផ្លូវដែរឬយ៉ាងម៉េច"

"មែនហ្នឹង មិនបានស្តាប់" នាងនិយាយដោយទឹកមុខធម្មតា "ខ្ញុំម៉េចនឹងដឹងទៅថានរណាម៉ោល្អ នរណាម៉ោអាក្រក់ សុខៗក៏មិនអធិប្បាយអូសខ្ញុំចេញពី



ឡាន មានបាញ់គ្នាប៉ូងប៉ង មានគំរាម មានអូស មានទាញ ខ្ញុំត្រូវតែស៊ូហើយ ជួបនឹងរឿងបែបនេះហើយ ខ្ញុំស្មានថាជាចោរប្លន់ទាំងអស់ហ្នឹង ចំណុចនេះ លោកត្រូវយល់ពីខ្ញុំ"

"អូខេ យើងយល់ ចំណុចនេះនិយាយគ្នារួចហើយ ចូលចំណុចមួយទៀត ...នាងបានចិញ្ចៀននេះដោយរបៀបណា ?"

"សម្តេចព្រះមាតាត្រូវការតួចិញ្ចៀនថ្មី យកម៉ូតថ្មីឱ្យស្អាត"

"ធ្វើបែបហ្នឹងគឺអាចលួចប្តូរពេជ្របាន"

"ខ្ញុំមានក្របសីលធម៌របស់ខ្ញុំ"

នាងនិយាយដោយមិនខ្វល់ទេថា គេបានឮឬអត់។

"បើគិតបែបនេះ ខ្ញុំមិនចង់រកស៊ីជាមួយទេ មុខរបររបស់ខ្ញុំត្រូវការរកស៊ី ដល់ថ្ងៃងាប់ ខ្ញុំយកគ្រប់យ៉ាងម៉ៅប្រថុយនឹងពេជ្ររបស់ភ្ញៀវធ្វើអី ពេលឆ្កឹះពេជ្រ ចេញពីតួចិញ្ចៀនចាស់ ពេជ្រក៏មានឱកាសខូចខាត ទោះរកពេជ្រដែលមាន

គុណភាពល្អដូចគ្នាមកប៉ះប៉ូវបាន ប៉ុន្តែពេជ្ររបស់សម្តេចព្រះមាតាជារបស់

សំខាន់ រឿងនេះកាន់តែប្រថុយ ហើយឃើញស្នាមបែកត្រង់នេះទេ ជាងមានថ្វី

ដៃភាគច្រើនមិនទទួលធ្វើទេ តែខ្ញុំសុខចិត្តប្រថុយព្រោះស្អីដឹងទេ"

"ព្រោះគម្រិះ"

"អៅ! ឆ្លាតដែរតើ ខ្ញុំចង់ជួញដូរជាមួយរាជវង្ស ឮទេ ហើយមើលចុះ ថ្មើរ

ណេះកេរ្តិ៍ឈ្មោះរបស់ខ្ញុំខ្ចេចខ្ចីអស់ទៅហើយ"

"ហើយបើខ្ញុំចង់ជួលនាងដែរ ចាត់ទុកថាប៉ះប៉ូវឱ្យទៅចុះ ខ្ញុំមានចិញ្ចៀន

ត្បូងទទឹមច្រើនវង់ ដែលពាក់មិនល្មម"

"មិនទទួលទេ បើខ្ញុំទទួលការងារហើយ ហើយមានអ្នកខ្លះគិតថាខ្ញុំ

ដោះដូរត្បូងនោះ ខ្ញុំឈឺក្បាលងាប់ហើយ"

សារីហ្វ អស់សំណើច ចំជាសម្តីហំមែន ហ៊ាននិយាយដោយមិន

ញញើត។



"ដឹងទេថាហេតុអី បានជាខ្ញុំតាមទាមទារយកចិញ្ចៀនដោយមិនគិត
ស្លាប់រស់បែបនេះ"

"មែនហ្នឹង ហេតុអី?"

"មនុស្សស្រីដែលមានសិទ្ធិពាក់ចិញ្ចៀនមួយវង់នេះ មានតែប្រពន្ធរបស់
យើងប៉ុណ្ណោះដែលខ្ញុំមិនទាន់ប្រគល់ឱ្យអ្នកណារហូតដល់ត្រូវនាងឆាបឆក់យក
វាទៅពាក់ ពេលនេះ មានតែយើងពីរនាក់ មិនទាន់មានសាក្សីដឹងឮ នាងគួរដោះ
វាឱ្យខ្ញុំវិញ"

"ឡប់ហើយ អ្នកណាទៅជឿ"

នាងនិយាយទាំងអស់សំណើច ពោះឡើងផត។

"អ្នកដែលអាចសម្រេចបានថាមែនឬមិនមែន គឺសម្តេចព្រះមាតា ឪណា
នាងហ៊ានទៅជាមួយខ្ញុំទេ បើអ្នកណារត់ អ្នកនោះជាកូនឆ្កែ"

"ហ៊ានតាំងពីកើតម៉ោម្ល៉េះ៎ ហើយខ្ញុំនឹងប្តឹងឱ្យអស់ថាលោកធ្វើអីខ្ញុំខ្លះ

ដល់ពេលនោះ កុំស្រែកបក់បក់ឱ្យសោះ ហ៊ឺស! ប្រពន្ធម្នាក់ណាបានធ្វើជាម្ចាស់

ចិញ្ចៀនទៅ លោកប្រហែលមានប្រពន្ធបួនគ្រប់តាមសាសនាអ៊ីស្លាមហ្នឹង"

"ខ្ញុំមិនទាន់រៀបការ ហើយមានមនុស្សប្រុសមិនច្រើនទេដែលមាន

ប្រពន្ធបួន មានតែអ្នកមានប៉ុណ្ណោះដែលមានសមត្ថភាពចិញ្ចឹមប្រពន្ធបួននាក់"

"ហើយបើលោកមិនមាន លោកចង់មានប្រពន្ធបួននាក់ឬអត់ ?"

នាងសួរ ដោយមិនចាប់អារម្មណ៍ចម្លើយ ដោយគ្រាន់តែមិនចង់ឱ្យមាន

ភាពស្ងប់ស្ងាត់កើតឡើងរវាងនាងនិងគេប៉ុណ្ណោះ ព្រោះវាធ្វើឱ្យល្ងឹងល្ងើយពេក

វាគួរឱ្យខ្លាច។

អ្នកដែលត្រូវសួរ ងាកមកប្រសព្វភ្នែកនាងមួយភ្លែត តែវាភ្នែកមានថាម-

ពលនោះ មើលភ្នែករបស់នាងចង់ធ្លុះ ដែលធ្វើឱ្យកើតកម្លាំងរញ្ជួយយ៉ាងខ្លាំង

ដែលធ្វើឱ្យនាងមានអារម្មណ៍ប្លែកៗ។

"សារីហ្វ"



"ស្ដី?"

"ឈ្មោះរបស់ខ្ញុំ សារីហ្វ អាល់មីឌីស ចុះនាង?"

អាលិហ្សា ធ្វើភ្នែកឡេមឡាម រឿងអីប្រាប់ឈ្មោះពិត រហស្សនាមរបស់នាងគឺ អាលីស អឺរោន ដឺវែល។

"ពេលខ្ញុំទៅរៀនអាហាររូបករណ៍នៅអាមេរិក ខ្ញុំចូលចិត្តឱ្យគេហៅ អានែ លោកជាទាហានរបស់សម្តេចព្រះមាតា ឌីណា អ៊ីចឹងច្បាស់ជាធ្លាប់ជួប ម្ចាស់វាំងហើយ ទ្រង់ចេញបញ្ជាថា ឱ្យត្រៀមគ្រឿងពេជ្រទុកសម្រាប់ពិធីមង្គលការរបស់ ហ្សឺក សារីហ្វ ហ្សឺក មិនទាន់រៀបការទេឬ?"

"មិនទាន់ទេ ប៉ុន្តែប្រហែលឆាប់ៗនេះហើយ ហ្សឺកសង្ហា និងមានខ្លាំងណាស់ នាងមិនចាប់អារម្មណ៍ទេឬ?"

"អ៉ូយ! ជាចៅហ្វាយនិងកូនចៅ ដឹងតែកាន់ជើងគ្នាហើយ ខ្ញុំជាអ្នកលក់ដូរជារាស្ត្រសាមញ្ញចំណែកហ្សឺកជាពូជពង្សក្សត្រ ខ្ញុំថាហ្សឺកអាយុប៉ុណ្ណឹងហើយ

មិនទាន់រៀបការ ប្រហែលជាចាស់កោងខ្នង ទើបស្រីៗរត់អត់ ឬមិនអីចឹងធំតែ អាយុ តែគំនិតមិនធំ យំងរង៉ក់ មិនព្រមរៀបការ អាណិតសម្តេចព្រះមាតា មើលទៅខ្វល់ព្រះទ័យ ម្យ៉ាងទៀតខ្ញុំមិនមែនជាស្រីក្នុងឧត្តមគតិរបស់ហ្សឺកទេ ទ្រង់មិនយកខ្ញុំទេ"

"ចុះបើឧបមាថាហ្សឺកយក ?"

"បើសង្ហា អ្នកមាន តែត្រូវបញ្ចុកនំបញ្ចុកទឹកដោះគោមុនចូលដេក មិនអូខេទេ ហើយដែលថាសង្ហានេះ គឺសង្ហាបែបណា បើសង្ហាពាលពុកមាត់ស្រមូមដូចលោក ខ្ញុំមិនយកទេ អញ្ជើញទៅរើសអ្នកផ្សេងទៅ"

នាងធ្វើឱ្យមោទនភាពចំពោះរូបរាងមុខមាត់របស់ សារីហ្វ ខ្ចេចខ្ចីក្នុងមួយប៉ព្រិចភ្នែក។ ខ្លួនគេត្រូវវិភាគឡើងគ្មានសល់កន្លែងល្អ ប៉ុន្តែមិនអាចធ្វើអ្វីបានក្រៅពីអេះបាតដៃតិចៗ ចង់ចាប់ស្រីសម្តីហំនេះ ទះកំប៉ះគូទឱ្យខ្លាំងៗម្តងទៀតហើយគេនឹងឱ្យនាងបញ្ចុកទឹកដោះគោមុនចូលដេករាល់យប់។



"ម៉ោថាខ្ញុំមុខពាលពុកមាត់ស្រមូម តែថើបខ្ញុំទាល់តែដេកលក់លើទ្រូង
នេះ អានែ"

"អ៎! កាលណោះ មិនរាប់ទេ បំភ្លេចចោលទៅ ហើយបើហ៊ាននិយាយ
ទៀត ខ្ញុំនឹងជេរឱ្យហូរអាចម៍ត្រចៀក"

"ថើបក៏ថើបជាមួយគ្នា ហេតុអីធ្វើដូចខ្ញុំខុសម្នាក់ឯង មិនយុត្តិធម៌ទេ"

"គឺខ្ញុំអៀនវើយ ច្បាស់ទេ បើមានអ្នកដឹងថាខ្ញុំថើបគ្នាជាមួយ អ៊ូយ! បាន
ហើយៗ មិនរាប់ទេៗ"

សារីហ្វ ទាំងអស់សំណើច ទាំងខឹងស្រីមាឌល្អិត ដែលធ្វើឫកពាកន្ធក់
កន្ធេញ បន្លប់អារម្មណ៍អឺមអៀនរបស់ខ្លួន។ មិនរាប់ក៏មិនរាប់ ប៉ុន្តែរង់ចាំសិនទៅ
គេនឹងថើបឱ្យរញ្ជួយ លេងឱ្យរាប់មិនទាន់។

អាលិហ្សា ដើរដំណើរដូចទា ព្រោះស្បែកជើង ហើយមិនដល់មួយម៉ោង
ក៏ឆ្អួញឆ្អែរ។

"យើងកំពុងដើរទៅណា ប្រាប់ឱ្យខ្ញុំសប្បាយចិត្តបន្តិចទៅ អ្នកកំលោះរូប
សង្ហា"

"នៅមិនឆ្ងាយពីទីនេះ មានក្រុមប៊ែឌូអ៊ីន គេអាចជូនយើងទៅបាន"

នាងព្យាយាមមិនរអ៊ូ ឃើញគេដើរកាន់តែលឿន ហាក់ដូចថ្មហោះលើ
ខ្សាច់បានយ៉ាងស្រួល នាងក៏ប្រឹងតស៊ូ ធ្វើឱ្យ សារីហ្វ គ្រវីក្បាលដោយនឹកហួស
ចិត្ត។ ដំបូងគិតថាស្រីមាឌល្អិតនេះ ប្រហែលទ្រហោយំ ឬមិនអីចឹងសុំឱ្យគេជួយ
ប៉ុន្តែនាងបែរជាធ្វើចិត្តរឹង មិនធ្វើទាំងពីរប្រភេទហ្នឹង ហើយក៏បានការភ្លាម ទោះ
ចិត្តនាងខ្លាំងយ៉ាងណា តែរាងកាយមិនខ្លាំង ជើងទាំងពីរខ្សោះកម្លាំង ដួលខ្ពើក
តែម្តង ទើបគេត្រូវដើរបកក្រោយ។

"ងើបឡើង អានែ"

អាលិហ្សា ហត់នឿយស្ទើរស្លាប់ ត្រូវមនុស្សពុកមាត់ស្រមូមហៅ **អានែ**
ទៀត នាងក៏ប្រឹងទប់សំណើចឡើងក្រហមមុខ។ កាលមុនពេលទៅរៀនអាហារ



រូបករណ៍នៅអាមេរិកត្រូវមិត្តភក្តិប្រុសៗ ចម្រុះជាតិសាសន៍ ទាំងចិន ឥណ្ឌា ជប៉ុន អង់គ្លេស កាណាដា ឥណ្ឌូនេស៊ី បុរសណាសង្កា នាងក៏ចោកឱ្យហៅនាងថា *អាវែន* ទើបក្លាយជាប្រពន្ធរួម ប្រពន្ធគ្រប់ជាតិសាសន៍ ធ្វើឱ្យពួកដែលចង់ចូលមកញ៉ែ នាំគ្នាដកថយអស់ ដែលកាលណោះ នាងគ្រាន់តែលេងសើចទេ ប៉ុន្តែពេលបុរសម្នាក់នេះហៅនាងថា អានែ ដោយសំឡេងគ្រលរ ស្រទន់ អង្រួនបេះដូង ថ្កាល់ទាំងពីរក៏ឡើងក្រហម គួរឱ្យស្អប់។

"ខ្ញុំទៅលែងរួចហើយ លោកទៅចុះ មិនបាច់ខ្វល់ពីខ្ញុំទេ"

"កុំធ្វើង៉ក់មើល៍ ស្លេចហើយឬថានាងជាស្រីក្របី គ្មានភាពទន់ភ្លន់ ធ្វើឱ្យខ្ញុំដេញតាមម៉ោដល់ទីនេះ ពេលដេញតាមខ្ញុំវិញម្តង នាងព្រមចាញ់ហើយឬ"

"ចង់ជេរ ឬលួងលោម រើសមួយម៉ោអ្នកកំលោះរូបសង្ហា"

អាលិហ្សា បញ្ឈឺឌីដង ហើយប្រមូលកម្លាំងកំហែង ងើបដើរបន្ត។ នាងចង់ត្រឡប់ទៅផ្លូវថ្នល់ ប៉ុន្តែគ្មានថ្នល់ មានតែសមុទ្រខ្សាច់ធំល្វឹងល្វើយ មើលមិន

ឃើញទិសតំបន់ មានតែចោរមុខកាច មាឌធំ កំដរ ហើយពេលនេះក៏ខះកដែរ

ថ្ងៃក៏ក្តៅខ្លាំង ធ្វើឱ្យស្រវាំងភ្នែក តែប្រឹងសម្លឹងមើលទៅជុំវិញខ្លួន ពេលឃើញពន្លឺ

ផ្លេកៗនៅក្រោមពន្លឺថ្ងៃ ក៏រំភើបចិត្ត ព្រោះវាជា...

"មើលចុះ ស្រះទឹក អូអេស៊ីស!"

"ឈប់សិន មិនមែនទេ"

សារីហ្វ តវ៉ា តែនាងរត់ប្លែចទៅហើយ ទើបគេឱបដៃ រង់ចាំនៅកន្លែង

ដដែល ទុកឱ្យនាងបានស្វែងយល់ដោយខ្លួនឯងថា នោះជាស្រមោលឆ្ពិនភ្នែក

ប៉ុណ្ណោះ ហើយមួយសន្ទុះ នាងក៏ដើរអូសជើងមកវិញ ធ្លាក់ស្មាសំយ៉ាក ដូចឆ្កែ

បាក់ត្រចៀក ឱ្យគេលួចសើច ហើយពេលនាងដើរមកដល់ ក៏ធ្វើមុខមាំដាក់។

"យើងនឹងស្រែកទឹកងាប់នៅទីនេះ ទីនេះគួរឱ្យខ្លាច សាហាវឃោរឃៅ

បំផុត"

នាងយំអណ្តឺតអណ្តក ហើយក៏ចាញ់កម្តៅថ្ងៃ ប្រុងខ្សល់គរនៅត្រង់នោះ



សំណាងល្អ ដែល សារីហ្វ ក្រសោបជាប់ ហើយលើកបី ដែលពេលនោះឯងនាង

ទ្រហោយ។

"ដៃជើងខ្ញុំធ្ងន់ណាស់ ខ្ញុំជិតស្លាប់ហើយ ខ្ញុំមិនទាន់ចង់ស្លាប់ទេ ខ្ញុំចង់ចាស់ស្លាប់តាមធម្មជាតិ"

"នាងមិនស្លាប់ទេ បើនាងស្តាប់បង្គាប់ខ្ញុំ"

"មានន័យថាម៉េច ?"

"ពេលនេះយើងនៅជិតហ្វេសសានហើយ ទីនេះប្រកាន់ភ្ជាប់សាសនាជាងរាជធានី ពួកបេឌូអ៊ីនមិនសូវស្វាគមន៍ជនជាតិបរទេសប៉ុន្មានទេ បើមនុស្សប្រុសស្រីដែលមិនមែនជាសាច់ញាតិ ឬជាស្វាមីភរិយាធ្វើដំណើរមកជាមួយគ្នាបែបនេះនឹងចាត់ទុកថាគឺជារឿងគួរឱ្យអាម៉ាសអីចឹងហើយពេលពួកយើងជួបគេ នាងត្រូវស្តាប់បង្គាប់ និងហៅខ្ញុំថា សៅជុន"

"ប្រែថាម៉េច ?"

"ស្វាមី"

អាលិហ្សា ខាំបបូរមាត់ នេះត្រូវគេសងសឹករឿងឈ្មោះ អានែ ឬអត់។

"បើហៅហើយបានផឹកទឹកទេ ?"

"អ៊ីនសាអាឡុស បើព្រះអាឡាមេត្តា...អូខេ ហៅទៅ អានែ ហើយនាង

នឹងបានផឹកទឹកច្រើនតាមដែលនាងត្រូវការ"

នាងដកដង្ហើមខ្លាំងៗចូលសួតរាងកាយក្តៅភាយៗពេលប្រសព្វនឹងកែវ

ភ្នែកមុតស្រួចមួយគូនោះ។

"សៅ...ជុន..."

"សៅជុន"

គេបញ្ជាក់ដើម្បីឱ្យនាងនិយាយភាសាពីសៀបានត្រឹមត្រូវ។

"សារីហ្វ ជាសៅជុនរបស់ខ្ញុំ"

"សារីហ្វ...សៅជុន...សារីហ្វ ជា សៅជុនរបស់ខ្ញុំ"



ថ្ពាល់របស់នាងក្តៅចង់ឆេះ ខណៈដែលសារីហ្វស្តាប់ហើយញញឹមពេញ

ចិត្តជាខ្លាំង ពេលស្រីឆ្មាសម្នាក់នេះអៀន មើលទៅគួរឱ្យស្រឡាញ់មែនទែន។

"សំឡេងនៅរឹងបន្តិច តែអាចប្រើការបាន អូខេ យើងមកដល់ហើយ

អានែ" គេងារដៃទៅខាងក្រោយ "ឃើញខាងមុខនោះទេ មានបឹង"

"មែនឬ"

ទឹកភ្នែករបស់នាងស្ងួតមួយរំពេច ពេលឃើញដើមល្វាតូចល្មមនៅ

កណ្តាលសមុទ្រខ្សាច់ មានបឹងដែលខះទឹកជិតអស់ទៅហើយ ទើបដើរទ្រេត

ទ្រោតវាសនេះវាសនោះនៅតាមផ្លូវដែលមានដុំថ្មតូចៗរាយប៉ាយចុះទៅអង្គុយ

នៅក្រោមដើមឈើ។

"ម៉េចក៏លោកដឹងថាទីនេះមានទឹក?"

"សមុទ្រខ្សាច់នេះ ប្រៀបដូចជាទីធ្លាក្រោយផ្ទះរបស់ខ្ញុំ"

"ប្រុសអារ៉ាប់នេះបិនប្រូមែន"

នាងលូកដៃទៅប៉ះទឹកត្រជាក់ ក្បង់វា ផឹកមួយក្អឹកហើយមួយក្អឹកទៀត បន្ទាប់មកក៏ទាញឈុតអាបាយ៉ាចេញ លើកសក់ក្របួច បង្គួតកញ្ជើងក និងស្មា ធ្វើឱ្យឈាមរបស់បុរសពេញវ័យ ក្តៅមួយរំពេច ហើយនាងប្រុងដោះបន្ត ប៉ុន្តែត្រូវគេឃាត់។

"ខ្ញុំដឹងថានាងរំតើបដែលបានធ្វើជាប្រពន្ធរបស់ខ្ញុំ តែចាំដោះវាពេលឡើងគ្រែក៏បានដែរ អានែ"

"ងាកចេញទៅលោកសុភាពបុរស!" នាងស្តីឱ្យ "ពេលម៉ាក់ខ្ញុំដាស់តឿនថា ប្រុសអារ៉ាប់កាមក្រាស់ ដឹងអីចឹងគួរតែស្តាប់ម៉ាក់ខ្លះ បើឃើញប៉ុណ្ណឹងហើយត្រែកកាមទប់មិនបាន អញ្ជើញទៅក្នុងណាទៅ បើគ្រប់គ្រងខ្លួនឯងមិនបាន កុំចេញមកដើរពាសវាលពាសកាល ធ្វើខ្លួនជាគ្រោះភ័យដល់សង្គម ហើយពេលចប់ រឿងក៏មិនបាច់មកកុហកគេថាខ្ញុំជាប្រពន្ធលោកដែរ សម្តីសំដៅបៀតបៀន



ផ្លូវភេទ គួរឱ្យចាប់កាច់កកប់ចោលក្នុងសមុទ្រខ្សាច់ ជេរហើយនៅញញឹម

ទៀត!"

ប្រសព្វជេរមែន!

គេនិយាយតែបន្តិចសោះ តែនាងជេរគេប្រាវៗ មិនដកមាត់តែម្តង។

"បឹងតូចមួយហ្នឹងឱ្យងាកទៅខាងណា"

"ខាងណោះក៏បាន"

"តែខ្ញុំចង់មើលខាងណោះ"

អាលិហ្សា សម្លក់សម្លឹង ព្រមទាំងគ្រហឹមដាក់ថាបើគេមានគំនិតអីមិន

ល្អ នាងនឹងកាត់អាញ្ជ៉ក់របស់គេកប់ក្នុងខ្សាច់ ដែលធ្វើឱ្យគេសើចក្អាកក្អាយ

ដោយការពេញចិត្ត ដែលបានញ៉ោះខ្លាញីឱ្យខឹងលេង បន្ទាប់មកនាងក៏លែង

ខ្វល់ពីគេទៀត ព្រោះចង់លុបលាងមុខមាត់ពេញទំហឹងហើយ។ នាងជ្រមុជ

ក្បាល ទៅក្នុងទឹកត្រជាក់នោះ ហើយគ្រវីក្បាល ប៉ាតយកតំណក់ទឹកចេញពីមុខ

បន្ទាប់មកក៏ដកដង្ហើមធំមានសេចក្តីសុខ ខណៈនោះ ចិញ្ចៀនពេជ្រដែលពាក់ជាប់នឹងម្រាមដៃ ក៏បញ្ចេញពន្លឺផ្លេកៗ។

នាងមិនបានធ្វើអីលើសពីនោះ តែ សារីហ្វ បែរជាមិនអាចដកខ្សែភ្នែកចេញពីនាងបាន អាវនៅត្រង់ដើមទ្រូងរបស់នាង ទទឹករឹបនឹងសាច់ កសខ្លីមានតំណក់ទឹក សក់ពណ៌ខ្មៅទទឹកជោក បបូរមាត់តូចច្រមិចបង្ហើប ដើម្បីស្រូបយកខ្យល់អាកាស អណ្តាតក៏លិទ្ធយកទឹកពីគែមមាត់ វាមើលទៅដូចរូបគំនូរដ៏ស្អាតដែលធ្វើឱ្យគេដកដង្ហើមមិនពេញពោះនិងខះកមួយរំពេចចង់យកទឹកដែលជាប់នឹងខ្លួនប្រាណរបស់នា មកផ្សើមបំពង់កមែនទែន។

"អាណែ..." គេហៅដោយសំឡេងស្អកៗ។

"ហ៊ឺយ! ខ្ញុំស្លាប់មិនខានបើមិនបានរលាស់ខ្សាច់ចេញពីខ្លួន វារមាស់ពេញខ្លួនអស់ហើយនេ៎ះ"



នាងស្ទើរតែមិនខ្វល់ពីគេ គិតតែដោះខោអាវរលាស់ បង្អួតសាច់ខ្នងសខ្លី

ដល់អ្នកមើល ខ្សែអារក្ខង មើលទៅប្រឹងធ្វើការពេក ព្រោះត្រូវក្រសោបដើមទ្រូង ទ្រលុកទ្រលន់យកងាប់យករស់តែម្តង ទើប សារីហ្វ សុខចិត្តធ្វើជាទស្សនិកជន ដ៏ល្អ មើលស្រីស្លាហានពាក់អារវិញ។

ម្តងនេះគឺល្វែងក្រោម...អ្នកកំលោះគិត ព្រមទាំងលេបទឹកមាត់ក្អឹកៗ ត្រគាកមូលក្តុំ សណ្តំខ្សែភ្នែក គេមិនខ្វល់ទេថា ខ្លួនឯងក៏ស្រែកទឹក ដោយគិតតែ សម្លឹងមើល និងបន់ស្រន់ឱ្យនាងដោះមួយជាន់ទៀត ដោះឱ្យអស់ក៏បានដែរ អានែ។

"មើលស្អី តិចចាក់ផ្តុះគ្រាប់ភ្នែក"

"តិចតួចទេ មានរបស់ស្អាតឱ្យមើលគឺត្រូវតែមើល កាចមែន អានែ"

គេទ្រចង្កា មើលស្រីស្អាត តែមមាត់មានស្នាមញញឹម គិតតែសម្លឹងមើល បបូរមាត់ក្រហមព្រឿងៗ ហើយឱនមើលដើមទ្រូងទ្រលុកទ្រលន់។

"មើល៍ សាករំឭកពាក្យដែលខ្ញុំបង្រៀនមើល៍"

"ខ្ញុំចាំបានហើយ រំឭកធ្វើអីញឹកញាប់"

"និយាយម៉ោ"

"សារីហ្វ ជា...សៅជុន...របស់ខ្ញុំ"

"ល្អ សំនៀងចាប់ផ្តើមល្អហើយ ពេលនេះងើយមុខមកប្រសព្វភ្នែក ជាមួយខ្ញុំ ហើយនិយាយ"

"សារីហ្វ..."

ម្តងនេះនាងនិយាយមិនទាន់ចប់ផង ក៏ត្រូវគេទាញទៅឱប ឱ្យរាងកាយនៃបនិត្យជិតគ្នា ជាពិសេសល្វែងក្រោម ដែលគ្រលែងយឺតៗ។ ដំបូងនាងងឿងឆ្ងល់ មិនយល់ តែបន្ទាប់មកថ្កាល់ក៏ក្តៅ និងហាមាត់ដើម្បីស្រែកឡូឡា ប៉ុន្តែត្រូវគេឱនមកខ្សឹបដាក់ត្រចៀក។

"នាងគឺ អាមិ៉ារបស់ខ្ញុំ របស់ សារីហ្វ អាល់ មីឌីស"



អាលិហ្សា ភ្ញាក់ព្រើត ចង់សួរថា អាមិ៉ាប្រែថាអ្វី ប៉ុន្តែត្រូវគេឱនថើប

ជញ្ជក់បបូរមាត់ បានត្រឹមតែស្រែកឮក្ងរៗនៅដើមកប៉ុណ្ណោះ។

ទាំងដែលចិត្តតតាំង តែរាងកាយបែរជាមិនព្រមធ្វើតាម ដូចត្រូវអណ្តាត

ភ្លើងក្តៅគគុកបស់សមុទ្រខ្សាច់ ដុត បបូរមាត់របស់គេបឺតជញ្ជក់ អណ្តាតរបស់

គេជ្រៀតជ្រែកចូលមក ពុកមាត់ពុកចង្កា ត្រដុសតាមថ្ពាល់ ដុតឱ្យពួកគេទាំងពីរ

ឆាបឆេះដោយភ្លើងប្រាថ្នា។

ត្រឹមការថើប ក៏ធ្វើឱ្យគេ ជ្រួលច្របល់ ខ្លាំងទៅហើយ ឈាមគ្រប់តំណក់

នៅក្នុងរាងកាយ ក៏ទៅផ្ទុំនៅចំណុចយុទ្ធសាស្ត្រ សំឡេងថ្ងូរតិចៗរបស់នាងមិន

ខុសពីខ្សែតី វ៉ែទ្ធលើខ្លួន ឱ្យ សារីហ្វ កញ្ជ្រោល ប៉ុន្តែនៅតែប្រឹងបឺតជញ្ជក់បន្ត

ហាក់ដូចរកឃើញរបស់ដែលតាមរកយូរមកហើយ...គេរកឃើញហើយថា គឺជា

នាងនេះឯង។

"ឈប់ ឈប់ភ្លាម គិតថាធ្វើភ្នែកស្រទន់ហើយ អាចល្បួងស៊ីបានស្រួលៗ

ឬ ឈប់ទៅអាញ៉ក់"

"តែខ្ញុំគិតថានាងទៅវិញទេដែលធ្វើភ្នែកស្រទន់ដាក់ខ្ញុំ"

"ផ្តេសផ្តាសហើយ ខ្ញុំគ្មានផ្លូវធ្វើភ្នែកស្រទន់ដាក់ទេ កុំម៉ោប្លូ ហ៊ឺយ! ពុកមាត់ចាក់ថ្ពាល់ អ៊ឹៗ ហើយថយចេញបានហើយ ខ្ញុំជាកូនមានម៉ែមានឪ គិតថាធ្វើអី ឱ្យចេះផ្តល់កិត្តិយសគ្នាផង ខ្ញុំមិនមែនរបស់លេងសើចរបស់លោកទេវើយ!"

នាងត្រដុសមាត់ត្រដុសថ្ពាល់ ធ្វើឫកពាខ្ពើមរអើមពេញបន្ទុក ប៉ុន្តែគេបែរជាអស់សំណើច ព្រោះថ្ពាល់ក្រហមរបស់នាងគួរឱ្យគ្រញិចណាស់។

"បើនាងមិនចូលចិត្តពុកមាត់របស់ខ្ញុំ ខ្ញុំកោរឱ្យក៏បាន"

"ចំណុចសំខាន់វាមិនបាននៅត្រង់នោះទេ"

"អីចឹង បើខ្ញុំចង់ធ្វើជាសៅជុនពិតប្រាកដរបស់នាង អានែ?"

គេនិយាយដោយទឹកមុខស្មើ មនុស្សស្អីមុខក្រាស់មុខស៊ីម៉ង់ត៍ ចំណែកនាងវិញទៅជាស្រឡាំងកាំង ស្ទើរដកដង្ហើមមិនចេញ។



"ស្អី... ស្អី?"

"ខ្ញុំចង់ធ្វើជាសៅជុនរបស់នាង តាំងពីវិនាទីដំបូងដែលឃើញនាងនៅ

ក្នុងវាំង ខ្ញុំក៏មានអារម្មណ៍បែបនោះរហូត"

"មិនលេងចូលទេ ឆ្កួតទេអ្ហ្ម លោកមិនមែនបុរសក្នុងឧត្តមគតិខ្ញុំទេ"

"បុរសក្នុងឧត្តមគតិរបស់នាង តើបែបណា និយាយម៉ោមើល៍"

"គឺ... មិនបាច់សង្ហាខ្លាំងក៏បាន សុំត្រឹមពឹងពាក់បាន មើលថែខ្ញុំបាន

ចេះធ្វើការរកស៊ី មិនខូចខិលស្រីញី មិនផឹកស្រា មិនលេងល្បែង និងស្រឡាញ់

ខ្ញុំតែម្នាក់ អ៎ុំ! ត្រូវស្រឡាញ់កូនដែរ"

"ខ្ញុំថាខ្ញុំត្រូវតាមឧត្តមគតិរបស់នាងហើយ ថែមទាំងសង្ហាខ្លាំងទៀត"

"មនុស្សលង់ខ្លួនឯង"

បេះដូងរបស់នាងលោតញាប់ខុសពីធម្មតា ពិបាកនឹងគ្រប់គ្រង ទោះ

ព្យាយាមហើយក៏ដោយ ប៉ុន្តែនៅតែត្រូវខ្សែភ្នែកមុតស្រួចមួយគូនោះទាក់ទាញ

គេសង្កត់កដៃរបស់នាង ហើយឱនមកថើបបបូរមាត់ម្តងទៀត ដែលម្តងនេះក្តៅជាងមុន ដើម្បីជាការដាក់ទោសពីបទក្បាលរឹងគួរឱ្យគ្រញ៉ិច ឱ្យនាងស្រែកឮក្ងរៗ ប្រឹងប្រឆាំងគ្រប់វិធី ទាំងជាក់ ទាំងទាត់ តែគេមិនរង្គើ ថែមទាំងពេលដោះលែងនាងឱ្យមានសេរីតែដងខ្លួន ចំណែកបបូរមាត់នៅតែបឺតជញ្ជប់។

គេកំពុងប្រាប់ដោយប្រយោលថា បើ អាលិហ្សា មិនត្រូវការ នាងអាចដកបបូរមាត់ចេញបានគ្រប់ពេល តែនាងបែរជាតាមថើបបបូរមាត់គេទៅវិញ។

សារីហ្វ ជ្រួលច្រាល់ដោយអារម្មណ៍រញ្ជួយ លើកដៃអង្អែលខ្នងរលោងថ្នមៗ បន្ទាប់មកក៏គ្រវាសអណ្តាតលើបបូរមាត់ក្រហម គ្រវាសតិចៗ ជាការបង្គាប់ឱ្យនាងបង្ហើបមាត់។

គ្រប់ការប៉ះពាល់ រាល់ពេលខ្សែភ្នែកប៉ះគ្នា គ្រប់ពេល មិនថាពេលណាក៏ដោយ នាងមានអារម្មណ៍ដល់អ្វីដែលកំពុងបង្ករូបរាង វាមិនអាចអធិប្បាយថា



ជាអ្វី ដឹងត្រឹមថា វាឆេះសន្ធោសន្ធៅ ពិបាកពន្លត់ និងមានអារម្មណ៍ល្អណាស់
ពេលគេឱ្យបហៅនាងថា អានែ ដោយសំឡេងពីរោះ។

"ណូ!"

នាងច្រានគេចេញ រាងកាយទាំងមូលញ័រទទ្រើត ហើយមើលមុខគេ
ដែលកំពុងតែមើលមក។

រាងកាយរបស់គេក្តៅគគុក នាងក៏មិនខុសគ្នា និងព្យាយាមគេចភ្នែក
មិនមើលបបូរមាត់ក្តៅគគុក មិនមើលសាច់ដុំកង់ៗ មិនមើលអ្វីទាំងអស់ ហើយ
វិនាទីនោះឯង ដែលឃើញជនពនេចរបេឌូអ៊ីនបីនាក់អង្គុយយ៉ាងសង្ហាលើខ្នង
អូដ្ឋ បំបោលមកខាងណេះ ទើប សារីហ្វ ស្រវាយកអាបាយ៉ាមកពាក់ឱ្យនាង
ព្រោះមិនត្រូវការឱ្យបុរសណាយល់សម្រស់ដ៏ស្រស់ស្អាត។

"អាឡោះ អាក់បា ព្រះអាទិត្យដ៏មានឫទ្ធានុភាព អាឡោះ អាក់បា"
សារីហ្វ ដោះអាវគ្រវី ស្រែកឮខ្ទរប្រឹថពី។

មុខមាត់របស់ពួកនោះមានស្នាក់ស្នាម សម្បុរមាសក្រហម ព្រោះពន្លឺថ្ងៃ រាងកាយឡើងសរសៃធំៗ តែរឹងមាំ។ ពួកគេស្លាយកាបិតក្រឹស ដាវបុរាណ ពាក់ឈុតយេទ្ធាបា និងមានស្នាំងប្រមាញ់សត្វទំលើស្រោមដៃ ដែលធ្វើឱ្យនាងមានអារម្មណ៍ដូចត្រឡប់ទៅកាន់សម័យកាលពីរាប់រយឆ្នាំមុន។

ពួកគេជាជនពនេចរក្នុងសមុទ្រខ្សាច់ទាំងពីបុរាណ ទោះមើលទៅគួរឱ្យខ្លាច តែតាមពិតទៅមានទឹកចិត្ត គ្មានណាប្រៀបបាន ព្រោះពួកគេចាត់ទុកថាជាតួនាទីការពារឃុំគ្រងដល់មនុស្សគ្រប់រូបដែលមកសុំពឹងពាក់ ទោះអ្នកនោះជាសត្រូវក៏ដោយ ទោះត្រូវសម្លាប់អូដ្ឋមួយចុងក្រោយ ដើម្បីធ្វើជាអាហារទទួលភ្ញៀវ ក៏ពួកគេចាត់ទុកថាជាទង្វើដែលគួរគប្បីធ្វើ។

ជនជាតិបេឌូអ៊ីនទាំងបីចុះពីខ្នងអូដ្ឋ ដើរមកថើបខ្នងដៃរបស់ សារីហ្វ ដោយការគោរពលើកតម្កើង និងនិយាយគ្នាយ៉ាងរីករាយ បន្ទាប់មកបុរសជរាម្នាក់ក៏បង្វែរមុខកាចមកមើលនាង។



"សារីហ្វ ជាសៅជុនរបស់ខ្ញុំ"

អាលិហ្សា ប្រញាប់និយាយញាប់មាត់ស្អេកតែម្តង ព្រមទាំងប្រឹងញញឹម តែបីនាក់នោះមិនមាត់មិនក មានតែស្វាមីរបស់នាងដែលសើចឡើងញ័រស្មា ហើយបន្ទាប់មកគេក៏ក្អកគ្រហែម ណែនាំនាងជាផ្លូវការ។

"នាងគឺ អានែ អាមិ៉ារបស់ហ្សឺក សារីហ្វ អាល់ មីឌីស ***អាសាដុលឡោះ*** វ៉ាលីនៃហ្វេសសាន"

"អ៊ូ! អាមិ៉ា។។"

ពួកគេដាក់បាតដៃលើដើមទ្រូង ហើយឱនក្បាលបន្តិច ដើម្បីសម្តែងការគោរព នាងក៏ធ្វើភ្នែកឡេមឡាម ហើយពេល សារីហ្វ ងារដៃ ប្រាប់ឱ្យធ្វើតាម នាងក៏ប្រញាប់ប្រតិបត្តិភ្លាម។

អាមិ៉ាក៏អាមិ៉ាទៅ តែពួកគេនិយាយស្អីគ្នា មិនយើញស្តាប់យល់!

"ហេតុអីពួកគេដឹងថាយើងនៅត្រង់នេះ?"

គេឆ្លើយដោយទឹកមុខធម្មតា ព្រមទាំងយកម៉ាស៊ីនបញ្ជូនសញ្ញាចេញពីកាបូប ហើយឃើញឡានតូយ៉ូតារត់មកចត ក្នុងនោះមានឧបករណ៍ទាក់ទងតាមប្រព័ន្ធផ្កាយរណបទាន់សម័យ ត្រឹមប៉ុណ្ណឹងក៏ធ្វើឱ្យនាងបើកភ្នែកធំៗ។

"ហេតុអីបេឌូអ៊ីន មានតូយ៉ូតា បេឌូអ៊ីនកាលីបហួស"

"កញ្ញា សព្វថ្ងៃនេះមនុស្សដាក់ផែនការឡើងទៅនៅភពអង្គារ៍ហើយ នេះចង់ឱ្យបេឌូអ៊ីនជិះអូដ្ឋមួយជីវិតឬយ៉ាងម៉េច"

អាលិហ្សា ធ្វើភ្នែកព្រិចៗ ព្រោះបានស្រមើស្រមៃពាក់ព័ន្ធនឹងបេឌូអ៊ីនច្រើនណាស់ តែដល់បានជួបផ្ទាល់បែបនេះ ឃើញថាបេឌូអ៊ីភាគច្រើននៅជាយក្រុង មានឡានជូនកូនទៅរៀន ទៅផ្សារទំនើប បើចង់ជួបបេឌូអ៊ីនពិតប្រាកដគឺត្រូវចូលសមុទ្រខ្សាច់ជ្រៅជាងនេះ។

ពេលឡើងឡានជាមួយគេ នាងក៏នឹកឃើញរឿងមួយ។



"នេះមានន័យថាលោកបោកឱ្យខ្ញុំដើរកាត់សមុទ្រខ្សាច់ឬ?"

សារីហ្វ មិនឆ្លើយ ព្រោះគិតតែអស់សំណើច ទោះត្រូវនាងសម្លក់សម្លឹង

ចង់ស៊ីសាច់ហុតឈាមក៏ដោយ។

"សូមស្វាគមន៍មកកាន់ហ្វេសសាន អានែ"

១0

ហ្វេសសានដែនដីក្តៅគគុក

បេឌូអ៊ីនមានវិថីជីវិតសាមញ្ញ មិនស្មុគស្មាញ មិនសាំញ៉ាំ ទាំងការតែងខ្លួន ការហូបចុក និងការរស់នៅ។ ទោះមានកុលសម្ព័ន្ធផ្សេងចូលមករស់នៅក្នុងដែនដីសមុទ្រខ្សាច់ តែមិនអាចយកឈ្នះសមុទ្រខ្សាច់បានដូចបេឌូអ៊ីន។ ពួកគេអាងសិទ្ធិក្នុងអាណាចក្រដែលមានវាលស្មៅ និងប្រភពទឹក។ ក្រុមគ្រួសារដែលបន្តជំនាន់មកពីត្រកូលនីមួយៗជាម្ចាស់ប្រភពទឹក ឬ អូអេស៊ីស ដាំលម៉ើ និងបន្លែបង្ការ រួមទាំងចិញ្ចឹមសត្វ ដូច្នេះហើយចំនួនហ្វូងសត្វជួយបញ្ជាក់ហានៈរបស់ម្ចាស់។



អាលិហ្សា សម្លក់គេថ្មែ ចង់ច្របាច់កបុរសម្នាក់នេះឱ្យស្លាប់។ ហេតុអីគេ

ហ៊ានបោកឱ្យនាងទៅលំបាកលំបិននៅក្នុងសមុទ្រខ្សាច់មួយយប់មួយថ្ងៃ ថើប

នាង បោកឱ្យនាងហៅគេថាស្វាមី អ៊ុំ! រឿងនេះដកចេញ ព្រោះនាងក៏បញ្ឆោត

ឱ្យគេហៅ អានែ ដូចគ្នា។

អានែ ជាភាសាកូរ៉េប្រែថា *ប្រពន្ធ*

"ប៊ុនបោកណាស់!"

"ស្រីឆ្នាសដូចនាងគ្មានសិទ្ធិខឹងខ្ញុំទេ"

"ក៏បាន ចាត់ទុកថារួចគ្នា ចូលរាជធានីវិញពេលណា ខ្ញុំនឹងថ្វាយចិញ្ចៀន

ដល់សម្តេចព្រះមាតា ឪណា វិញ ហើយមិនមកទីនេះទៀតទេ"

"ពេលនេះ យើងមិនទៅរាជធានី តែទៅហ្វូសសាន យើងនឹងនៅទីនោះ

មួយរយៈ ហើយបើខ្ញុំមិនអនុញ្ញាត នាងក៏ទៅណាមិនបានដែរ"

"ស្អីគេ! ក្រែងប្រាប់ថាចប់រឿង ដើរផ្លូវរៀងខ្លួន បែបនេះខុសសម្តីហើយ

មានចេតនាធ្វើបាបគ្នាច្បាស់ណាស់ នេះខ្ញុំមិនមែនជាទាសកររបស់លោកទេ

ខ្ញុំនឹងប្តឹងប៉ា ចាំមើលទៅ គិតឬថាខ្ញុំស្តាប់បញ្ជាលោក ខ្ញុំជាពលរដ្ឋ មិនមែនជា
កូនចៅរបស់លោកទេវើយ! មានសិទ្ធិអីមកហាមខ្ញុំទៅណាមកណា ចង់ទុកខ្ញុំ
ធ្វើជាទាសកររបម្រើកាមអីចឹងឬ បានត្រូវមិនខាន ចាំមើលទៅ ម៉ែនឹងលេងឱ្យ
ផ្ដើលគេផ្ដើលឯង"

ពូកែឡូឡាមែននាង!

"ខ្ញុំថើបនាងរួចហើយ"

"មែនហ្នឹងហើយ"

នាងញ្ជេញចង្អូមដាក់ ឆ្លើតទាំងគំរោះគំរើយ ទាំងខឹង ទាំងខ្មាស ដែល
បណ្តោយខ្លួនបែបនោះ។

"មិនបាច់បារម្ភទេ ខ្ញុំជាមនុស្សមានទំនួលខុសត្រូវ ថើបហើយគឺព្រម
ទទួលថាថើប ខ្ញុំមិនយកមកធ្វើជាលេស ទាមទារស្អីពីលោកទេ ហើយមិនបាច់
ម៉ោទទួលខុសត្រូវអីទេ ខ្ញុំមិនត្រូវការ"



"នាងមិនត្រូវការទាមទារ តែខ្ញុំត្រូវការ ខ្ញុំប្រទះឃើញថាខ្លួនឯងមានចិត្ត ចំពោះនាងយ៉ាងជ្រាលជ្រៅ ចុះនាង អានែ នាងថើបខ្ញុំហើយ គ្មានអារម្មណ៍អី មែនឬ?"

"មានចិត្ត ប្រែថាស្អីក៏មិនដឹង"

"ខ្ញុំស្រឡាញ់នាង និងកំពុងសុំនាងជាប្រពន្ធ"

សម្តីត្រង់ទៅត្រង់មកររបស់គេ ធ្វើឱ្យ អាលិហ្សា ឈ្លក់ទឹកមាត់ តែរឿងស្អី មកស្តាប់ពាក្យសារភាពស្រឡាញ់នៅក្រោយគូទឡានតូយ៉ូតាកំពុងយោកនេះ មហារ៉ូមែនទិកហួស។

នាងប្រុងច្រែតៗដាក់ តែពេលប្រសព្វនឹងកែវភ្នែកម៉ឺងម៉ាត់មួយគូនោះ ហើយ ថ្ពាល់រលោងក៏ទៅជាក្តៅចង់ឆេះ ខណៈនោះ សារីហ្វ ក៏លូកដៃមកប៉ះ ថ្ពាល់ និងបបូរមាត់ផ្អែមល្ហែមដោយការដង្ហោយរក។

"ម៉េចដែរ អានែ នាងមានអារម្មណ៍អីចំពោះខ្ញុំទេ?"

"ខ្ញុំ... មិនដឹងទេ"

នាងធ្វើឆើឆាយដាក់ ទាំងបេះដូងកំពុងលោតខ្ទុកខ្ទាក់។

ពេលឡានរត់មកដល់កន្លែងស្នាក់អាស្រ័យរបស់បេឌូអ៊ីន ស្រីៗ ដែល ឃើញថាមានបុរសប្លែកមុខមកជាមួយ ក៏ប្រញាប់គ្រវាត់សែ្បឃ្លុំមុខ និងចូល ទៅក្នុងតង់បាត់ ព្រមទាំងស្រវាយកកូនចៅទៅជាមួយ។ នាងសង្កេតឃើញ ហ្វូងអូដ្ឋឈរក្បែរឡានដឹកទឹក នៅបន្ទាប់ពីនោះគឺក្រោលចៀម មានរបស់របរ ប្រើប្រាស់ទាន់សម័យច្រើនប្រភេទ ជាពិសេសគ្រឿងអគ្គិសនី។ ទោះការរស់នៅ ការធ្វើដំណើរបស់បេឌូអ៊ីនមានភាពងាយស្រួលជាងមុន ក៏ពួកគេនៅតែជឿជាក់ ថាអូដ្ឋជារបស់ចាំបាច់ ព្រោះអូដ្ឋផ្តល់ឱ្យទាំងសាច់ ទាំងទឹកដោះ រោមគ្រឿមៗ របស់វាសម្រាប់ត្បាញធ្វើក្រណាត់ ចំណែកខ្នងធ្វើជាខ្សែក្រវាត់ និងអាន (កែប) រួមទាំងធ្វើធុងទឹកសម្រាប់ដាក់តាមខ្លួនពេលធ្វើដំណើរ។



ពួកគេអញ្ជើញភ្ញៀវដ៏ខ្ពង់ខ្ពស់ចូលទៅសម្រាកក្នុងតង់ដោយការគោរព។

តង់ធំដែលមានផ្ទៃក្រឡាធំទូលាយ មានភ្នក់ភ្លើងនៅចំកណ្តាល មានដែកជើង
បីសម្រាប់ដាក់កំសៀវឆុងកាហ្វេដាល់ឡាឱ្យក្តៅគ្រប់ពេល។

បុរសជរាអែនខ្នងលើព្រំពណ៌ស្រស់ដែលមានស្ថានភាពចាស់ និងងារ
ដៃអញ្ជើញភ្ញៀវឱ្យអង្គុយលើព្រំថ្មីសន្លាង និងលើកកាហ្វេរូបមន្តសមុទ្រខ្សាច់
ឱ្យ មានផ្លែលម៉ើចំនួនបីដងតាមប្រពៃណី ប៉ុន្តែនាងផឹកមួយពែងប៉ុណ្ណោះក៏
ឈ្លក់ ព្រោះមិនសុំនឹងក្លិនក្រវាញ ដែលពួកគេដាក់ក្នុងកាហ្វេ។

"គ្រឡុកពែងតិចៗទៅ អានែ ពួកគេនឹងដឹងថានាងមិនយកកាហ្វេថែម
ទៀតទេ"

យល់ដល់គេដែលហៅ អានែ ទើបនាងព្រមធ្វើតាម និងវិះភ្នាក់ក្រញាង
ពេលមានមនុស្សលើកចៀមអប់ទាំងមូលចូលមក និងយកបាយមកចាក់ពីលើ
តាមបែបបុរាណ ដោយគ្រាប់ភ្នែកចៀមសម្លឹងមើលមកនាងមិនព្រិច។ គ្រប់គ្នា

ប្រើដៃស្តាំទាញសាច់ម្នាក់មួយដុំពីរ ហើយប្រើម្រាមដៃពូតបាតជាពំនូត ដែល
តាមទំនៀមទម្លាប់ អាហារដែលល្អបំផុតជារបស់ភ្ញៀវ ទើប សារីហ្វ លូកយក
សាច់ត្រង់ពោះ និងពូតបាយឱ្យនាងមើលជាគំរូ។

"លៀនអណ្តាត"

"ម៉េចចាំបាច់លៀនអណ្តាត?"

"ពេលញ៉ាំអាហារចានរួមជាមួយអ្នកដទៃ ត្រូវដាក់អាហារចូលមាត់
ដោយម្រាមដៃមិនប៉ះមាត់ និងអណ្តាត ពេលនេះខ្ញុំបញ្ចុកនាងសិន ចាំរៀន
ពេលក្រោយ យល់ព្រមទេ អានែ"

មិនគួរទេ មិនគួរឱ្យគេហៅ អានែ!

អាលិហ្សា ឈឺក្បាលខ្លោកៗ ខណៈនោះក៏លៀនអណ្តាតទទួលយក
អាហារ ទាំងដែលក្នុងចិត្តចង់ស្រែកឱ្យបែកមេឃ ព្រោះរឿងស្អីដែលត្រូវមក
ហាមាត់ លៀនអណ្តាតនៅចំពោះមុខបុរសម្នាក់នេះ តែដោយសារជាមាន់ឬ



ទើបជួយមិនបានទេដែលអណ្តាតរបស់នាងប៉ះម្រាមដៃរបស់គេ។

សារីហ្វ គ្រហឹមតិចៗ ជូតម្រាមដៃនឹងក្រណាត់ស្អាត ហើយបញ្ចុកសាច្ចី ត្រឹមប៉ុណ្ណឹង មុខនាងក៏ក្រហមទៅហើយ ប្រឹងទំពាផ្ទាញៗ កណ្តាលចំណោមសំឡេងនិយាយគ្នាយ៉ាងរីករាយ ស្តាប់មិនយល់សេចក្តី ទើបត្រូវឈ្លោកមុខទទួលទានបន្ត។

ហើយមិនយូរប៉ុន្មាន កូនប្រុសរបស់បុរសជរាក៏យករបស់មកឱ្យ សារីហ្វ មើល វាជាចិញ្ចៀនត្បូងទទឹមបុរាណរចនាបថអារ៉ាប់។ ពួកគេនិយាយគ្នាថាអ្វីខ្លះ នាងមិនបានចាប់អារម្មណ៍ ព្រោះស្តាប់មិនយល់ បន្ទាប់មក សារីហ្វ ក៏ងាកមករកនាង។

"នាងឱ្យតម្លៃចិញ្ចៀនត្បូងទទឹមមួយវង់នេះបានទេ អានែ"

"បានតើ ថីឬ?"

"កូនប្រុសពៅរបស់គេត្រូវរកបណ្ណាការទៅរៀបការ ទើបគេត្រូវការលក់

ចិញ្ចៀនឱ្យខ្ញុំ តម្លៃ ស្រេចតែខ្ញុំឱ្យ"

បណ្ណាការដែលថានេះគឺចៀម យ៉ាងហោចណាស់មួយរយក្បាល ទើប កូនកំលោះស្តីដណ្តឹងកូនក្រមុំបាន។ ចិញ្ចៀនមួយវង់នេះជាមរតកដែលបានពី លោកតា (ខាងឪពុក) សារីហ្វ ឱ្យតម្លៃថ្លៃគួរសម តែនាងគ្រវីក្បាល ព្រោះមើល តែមួយភ្លែតក៏ថាជាត្បូងទទឹមក្លែងក្លាយ។

"តម្លៃចិញ្ចៀនមួយវង់នេះបានត្រឹមថ្លៃបាយថ្លៃទឹកថ្ងៃនេះប៉ុណ្ណោះ"

"មានន័យថាម៉េច ?"

"ត្បូងទទឹមនេះជារបស់ក្លែងក្លាយ គុណភាពអន់"

"តែគេកាត់កញ្ចក់ឱ្យមើលថាជារបស់សុទ្ធ"

"អ៊ុំ! ព្រះអាទិត្យ! ដុំថ្មក៏កាត់កញ្ចក់ឱ្យមានស្នាមបានដែរ បើពិសោធបាន ស្រួលៗបែបនេះ ហើយមានស្តាប់ត្បូងមណីទៅធ្វើអី សង្កេតសាច់ត្បូងទៅ មានរ៉ែលោហៈលាយឡំ ដែលវាខុសពីធម្មជាតិវា ទោះជារបស់ក្លែងក្លាយ តែបើ



មានតម្លៃផ្នែកផ្លូវចិត្ត គឺវាមានតម្លៃហើយ បើលោកទិញយកដោយទឹកចិត្ត ឬ
ចូលចិត្តចិញ្ចៀនមួយវង់នេះ ក៏មិនអីទេ តែកុំទិញ ព្រោះគិតថាវាជារបស់សុទ្ធ
មើលទៅពួកគេមិនដឹងទេ លោកថ្មមទឹកចិត្តពួកគេបន្តិចទៅ"

សារីហ្វ ថើបថ្ពាល់នាង ហើយងាកទៅចរចាម្តងទៀត បេឌូអ៊ីនទាំងឡាយ
ក៏យកចិត្តទុកដាក់ស្តាប់ ហើយញញឹមពព្រាយដោយការសប្បាយចិត្ត នាំគ្នា
ងើបមកប៉ះបាតដៃរបស់គេដោយចិត្តរំភើបចិត្តទើបអាលិហ្សាដែលកំពុងសម្លក់
សម្លឹងគេក៏អត់សួរមិនបានដោយការចង់ដឹង។

"លោកប្រាប់ពួកគេថាម៉េច ទើបពួកគេសប្បាយចិត្តយ៉ាងនេះ ?"

"ខ្ញុំសុំធ្វើជាម្ចាស់ដើមការឱ្យកូនប្រុសរបស់គេ និងឱ្យចិញ្ចៀននេះជាកាដូ
ដល់ទាយាទរបស់ពួកគេ ចិញ្ចៀនមួយវង់នេះជាមរតកបីជំនាន់ហើយ គួរតែបន្ត
ទៅជំនាន់ទីបួន ទីបន្តបន្ទាប់របស់ពួកគេ"

"អ៉ូហ៎! ល្អណាស់ តែលោកមានលុយឬ ?"

"មិនច្រើនទេ អាចចិញ្ចឹមប្រពន្ធម្នាក់បាន"

គេឈ្ងោកមើលចិញ្ចៀនជាប់នឹងម្រាមដៃរបស់នាង ដោយស្នាមញញឹម

លាក់កំណួច។ យូរហើយដែលគ្មានអ្នកណាសួរគេថាមានលុយឬអត់ ហើយ

ការដែលអាមិ៉ាសួរបែបនេះ វាគឺជាតួនាទីរបស់គេដែលត្រូវពិសោធ។

"អ័រដក់ហា... គឺស្អី?"

នាងស្តាប់ និងព្យាយាមបញ្ចេញសំឡេង ទើបគេអែនខ្លួនមកឱ្យឺបជាក់

ត្រចៀក។

"វាជាការរាំគុនដាវបែបបុរាណ មុនពេលអ្នកចម្បាំងចេញទៅធ្វើសង្គ្រាម

ចង់មើលទេ អានែ?"

"និយាយស្រួលបួលក៏បាន ម៉េចចាំបាច់ឱ្យឺបដោយសំឡេងស្អកៗ ស្តាប់

ហើយព្រឺសម្បុរ"

នាងសម្លក់សម្លឹង បន្ទាប់មកក៏ត្រូវតរិយាបេឌូអ៊ីនចូលមកអញ្ជើញឱ្យ



ចេញទៅក្រៅជាមួយ ទើបនាងងាកទៅមើល សារីហ្វ ជាការសួរនាំ និងសុំ
យោបល់ ទើបគេងារដៃជាការអនុញ្ញាត។

"អ៊ីនឆា អាឡោះ ទទួលយកទឹកចិត្តរបស់ពួកគេទៅ"

ស្រីៗ នាំនាងទៅងូតទឹកជម្រះខ្លួនប្រាណដែលស្រមេកស្រមកដោយ
ខ្សាច់ ដោយប្រេងក្រអូប និងយកឈុតខាហ្វតានពណ៌បៃតងស្រស់មកពាក់ឱ្យ
បន្ទាប់មកអញ្ជើញនាងឱ្យអង្គុយលើកម្រាលពូកបែបអារ៉ាប់ គូសក្បាច់*ហេនណា*
(ស្លឹករបស់ឈើមួយប្រភេទ) ខណៈនោះពួកនាងក៏ទះដៃ ច្រៀងចម្រៀងយ៉ាង
រីករាយ ឱ្យនាងយោកខ្លួនតាម និងសើចកក្អិច។

នេះជាបទពិសោធដែលរកបានមិនពិបាក នេះហើយជាការទេសចរណ៍
អារ៉ាប់ដ៏ពិតប្រាកដ។

ព្រះអាទិត្យលិចយូរហើយ មានតែព្រះចន្ទមួយចំណិតនៅក្នុងលម្ហដ៏ធំ

ល្ងឹងល្ងើយ ដួងតារាបញ្ចេញពន្លឺព្រិចៗ ឱ្យអារម្មណ៍រីករាយ ពេលងើយមើល

ហើយ ចង់ច្រៀងសរសើរ ប៉ុន្តែពេលនេះហត់នឿយណាស់ រាងកាយកំពុងតែ

ទ្រាំទ្រលែងបាន ខ្សែភ្នែកស្រវាំង ស្មារតីចង់រលត់ តែដែលទ្រាំទ្របានមកដល់

ពេលនេះ ព្រោះចង់មើលការរាំគុនដាវបែបអារ៉ាប់បុរាណ។

មិនដឹងថាមានជនជាតិបេឌូអ៊ីនមកពីណាទៀតច្រើនម្ល៉េះ គ្រប់គ្នារូតរះ

មកជួប សារីហ្វ ដោយក្តីរីករាយ និយាយផង ស្តាប់គេនិយាយផង ដោយការ

យកចិត្តទុកដាក់ ធ្វើឱ្យនាងងឿងឆ្ងល់ថា ការពិតទៅគេមានហាន:ជាអ្វី ព្រោះ

មើលទៅបេឌូអ៊ីនទាំងនោះគោរពកោតខ្លាចគេខ្លាំងណាស់។

សារីហ្វ អង្គុយទល់មុខនាង មានភ្នក់ភ្លើងនៅចំកណ្តាល បេះដូងរបស់

នាងស្ទើរតែឈប់លោត ពេលឃើញថាគេកោរពុកមាត់ពុកចង្កា ឱ្យនៅសល់តែ

រោមរ៉ៃៗ ប៉ុណ្ណោះ។ ដើមឡើយមន្តស្នេហ៍បុរសពិតរបស់គេក៏ខ្លាំងក្លាណាស់

ទៅហើយ ពេលរៀបចំខ្លួនឯងតាមចិត្តនាងបែបនេះ គេកាន់តែអង្អែនព្រលឹង



ឱ្យរញ្ជួយខ្លាំង។

ស្រីៗ ដែលអង្គុយដំកង់ជុំវិញនាងតែងខ្លួនដោយអាបាយ៉ាដូចគ្នា តែ សារីហ្វ សម្លឹងមើលតែនាងម្នាក់គត់ ដែលនាងព្យាយាមមិនចាប់អារម្មណ៍ តែ ពេលងាកទៅពេលណា ប្រសព្វភ្នែកជាមួយគេរហូត។

គេសម្លឹងមើលនាងមិនដាក់ភ្នែក មើលបបូរមាត់តូចច្រមិចដែលខើចលើ ពេលនាងធ្វើមាត់ស្រួច វាទាក់ទាញឱ្យថើបណាស់។ នាងកំពុងប្រាប់ដោយការ ប្រើភាសាកាយឱ្យគេចូលទៅរកឬអត់ ហើយពេលដល់ត្រគាកមូលក្តុំដែលសម នឹងចង្កេះ ក៏ធ្វើឱ្យគេអង្គុយមិនសុខ ព្រោះដឹងថាមានមនុស្សប្រុសច្រើនទៀត កំពុងមើលនាងដូចគ្នា និងត្រឹមនាងញញឹម ក៏អាចធ្វើឱ្យបុរសដែលមានសាច់ មានឈាមគ្រប់គ្នាក្តៅគគុកតែម្តង។

គ្រប់គ្នាទះដៃតាមចង្វាក់ស្គរ បុរសៗក៏រាំគុនដាវ ដោយមានគេចូលរួមដែរ រាំដោយកាយវិការសង្ហា ថ្លៃថ្នូរ មួយក្បាច់ៗ ពោរពេញដោយថាមពល និងមាន

ស្រីៗនាំគ្នាមើល សារីហ្វ ដោយការសរសើរ រាងកាយរបស់គេមាំមួន គួរឱ្យខ្លាចក្រែង មានសាច់ដុំកង់ៗសព្វសាច់ ជាពិសេសពេលគេបញ្ចេញកម្លាំង និងបញ្ចេញសម្រែកដូចតោ។

អាលិហ្សា តាមមើលគេជាច្រើនដង គេមានរាងរៅដូចអ្នកបង្ហាញម៉ូត គួរឱ្យស្អាបអង្អែល មុខមាត់ចាត់ទុកថាប្រើការបាន **បញ្ហក់** *ត្រឹមប្រើការបាន ប៉ុណ្ណោះ*។

បទចម្រៀងដែលបុរសជរាស្រែកច្រៀងខ្លាំងៗនោះ សម្តែងពីអំណាច និងកិត្តិយស រៀបរាប់ពីការដណ្តើមដែនដី ការប្រយុទ្ធតស៊ូ ដើម្បីប្រភពទឹក និងទឹកដី និងពណ៌នាពីភាពក្លាហានរបស់អ្នកចម្បាំង។

អាលិហ្សា ស្តាប់មិនយល់ន័យ ប៉ុន្តែមើលដឹងតាមរយៈកាយវិការ និងចង្វាក់កញ្ជ្រោលអារម្មណ៍ ហើយស្វែងយល់បានតិចៗ ថាជនជាតិអារ៉ាប់តែង



ចម្រៀងប្រលងគ្នាយកងាប់យករស់ កាច់កុងគ្នារវាងកុលសម្ព័ន្ធនីមួយៗ។

នាងក្រមុំអង្គុយមើលការរាំគុនដាវសុខៗ ក៏មានអារម្មណ៍ថាត្រូវលើកបី
មានសំឡេងនិយាយគ្នាចេចចាច និងពន្លឺភ្លើងឆេចឆ្ងាច។ នាងមិនដឹងខ្លួនទេថា
ហត់នឿយខ្លាំងដល់ថ្នាក់ដេកលក់តាំងពីពេលណា ទើបត្រូវ សារីហ្វ នាំចូល
មកក្នុងតង់ថ្មីសន្លាង មានកម្រាលពូក និងព្រំក្រាស់ ហើយពេលខ្នងប៉ះពូក
នាងក៏ដឹងខ្លួន និងឃើញថាគេកំពុងជួយដោះកងដៃធូន់ៗ និងអាបាយ៉ាឱ្យ។

"លក់ហើយឬ"

"នៅទេ"

នាងញេញចង្អុមដាក់ និងមើលគេជាសំណួរថា ហេតុអីគេមិនទៅដេក
នៅកន្លែងផ្សេង។

"យើងប្រាប់ពួកគេថាជាស្វាមីភរិយានឹងគ្នា ទើបគេរៀបចំតង់ឱ្យមួយ
បែបនេះ"

"ចាំខ្ញុំទៅដេកត្រង់នោះ លោកដេកត្រង់នេះចុះ"

អាលិហ្សា ងើបអង្គុយ សម្លឹងទៅព្រំទំហំតូចល្មមនៅកៀនជញ្ជាំង និង ត្រឹមមានភួយក្រាស់មួយ នាងក៏ដេកលក់ទៅហើយ តែត្រូវគេចាប់ដៃជាប់។

"បើខ្ញុំចង់ដេកឱបនាង?"

"លោកតែងតែសុំស្អីពីមនុស្សស្រីងាយៗបែបនេះឬ?"

"អត់ទេ... នាងជាមនុស្សដំបូង"

ហើយពួកគេក៏នៅស្ងៀម បានឮតែសំឡេងខ្យល់ផាត់មកប៉ះតង់ស្បែក អណ្តាតភ្លើងក្នុងផើងខាងក្រៅលោតផ្លោតៗ ខណៈនោះ អាលិហ្សា ដកដង្ហើមចូល ដើម្បីរម្ងាប់អារម្មណ៍ញាប់ញ័រ។

នាងមានអារម្មណ៍ដូចកូនក្តាន់ដែលកំពុងប្រឈមមុខនឹងតោ ពេលគេលើកដៃមែកប៉ះកញ្ចឹងក ដែលពេលនេះរាងកាយមាំមួនរបស់គេនៅតែបញ្ចេញចំហាយក្តៅភាយៗ ដោយសារការបញ្ចេញកម្លាំងរាំគុនដាវអម្បាញ់មិញ។



"បើនាងមិនត្រូវការ ខ្ញុំនឹងចេញ"

អាលិហ្សា ប្រាប់គេតាមរយៈខ្សែភ្នែកដែលកំពុងប្រសព្វគ្នាថាឱ្យគេចេញ ព្រោះហាមាត់និយាយមិនចេញ ហើយនៅក្រោមពន្លឺព្រាលៗនេះ នាងបានឮសំឡេងជាយអាវបើងតាមខ្យល់ និងឃើញស្រមោលស្មុងៗ របស់គេកំពុងដោះខោអាវម្តងមួយៗ ម្តងមួយៗ រហូតដល់រាងកាយសុទ្ធតែសាច់ដុំហាប់ណែននលគកស្ថិតនៅចំពោះមុខ ទើបនាងងាកមុខចេញ ទាំងដែលមិនឃើញអ្វី ប៉ុន្តែបានសំឡេងខ្យល់ដង្ហើមរបស់ខ្លួនដែលញាប់រន្ទើន ហើយពេលគេខិតមកឈរចំកន្លែងដែលមានពន្លឺព្រាលៗ ក៏ធ្វើឱ្យនាងដកដង្ហើមកាន់តែញាប់។

សារីហ្វ លុតជង្គង់នៅចំពោះមុខនាង ឱនមកថើបថ្នមៗ បន្ទាប់មកក៏បន្ថែមកម្រិត ឱ្យកាន់តែក្តៅគគុក។

"កុំ!"

នាងរុញគេចេញ។

"ខ្ញុំមិនបានត្រៀមចិត្តធ្វើជាប្រពន្ធម្នាក់ក្នុងចំណោមបួនរបស់លោកទេ"

"មានតែម្នាក់ មានតែនាង"

កែវភ្នែករបស់គេមិនធ្លាប់កុហក នាងដឹង ហើយខណៈដែលប្រសព្វភ្នែក ជាមួយគេ ក៏ព្យាយាមចងចាំគ្រប់យ៉ាង។

ពេលគេលើកដៃអង្អែលថ្ពាល់ក្រហមប្រឿងៗ ចិញ្ចៀនពេជ្រម៉ូតកុលាប ក៏បញ្ចេញពន្លឺ ដែលវាឱ្យអារម្មណ៍ញាប់ញ័រ បន្ទាប់មកក៏អូសកាត់ក ជីពចរ ស្មា និងដៃ ហើយក្រសោបឱ្យនាងងើបឈរ ឱ្យឈុតខាហ្វតានពណ៌បៃតងស្រស់ របូតធ្លាក់ពីស្មា សល់តែស្បៃបិទបាំងដើមទ្រូង និងត្រគាក ដែលវាទាំងរឹប ទាំងស្តើង។

អាលិហ្សា ដឹងថាបើត្រូវការបញ្ឈប់ គឺគួរឈប់ឥឡូវនេះ ដឹងថាបើមានអី កើតឡើង វានឹងក្លាយជាការចងចាំមុនពេលនាង និងគេបំបែកផ្លូវគ្នាបន្ទាប់ពី នេះ ដឹងថាវាគ្រាន់តែទំនាក់ទំនងមួយរាត្រី តែនាងចង់ស្រវាចាប់វាឱ្យបាន។



"ពេលលោកសួរថា ខ្ញុំមានអារម្មណ៍អីខ្លះទេ ពេលយើងថើបគ្នា ខ្ញុំឆ្លើយ
ថាខ្ញុំមិនដឹង"

"មែន"

"ខ្ញុំកុហកទេ"

គេដាក់បាតដៃក្តៅលើដើមទ្រូងទ្រលក់ទ្រលន់ ហើយច្របាច់វា ហើយ
ពេលនាងហាមាត់ ព្រោះអារម្មណ៍ស្រៀវស្រើប គេក៏ជ្រែកអណ្តាតចូលភ្លាម
ដោយការជឿជាក់ ដែលនាងក៏ទទួលយកអណ្តាតរបស់គេដោយការពេញចិត្ត
កៀវរឹតរួតចុងអណ្តាតគ្នាដោយភាពក្តៅគគុក។

ទាំងដឹងហើយថាកំពុងលេងជាមួយភ្លើង វាគ្រោះថ្នាក់ ត្រូវវាដុតកម្ទេច
ប៉ុន្តែនៅតែនាំខ្លួនឯងលេងជាមួយវាទៀត។

បាតដៃក្តៅម្ខាងទាញក្រណាត់ស្តើង ដែលរុំដើមទ្រូងចេញបន្តិចម្តងៗ
ចំណែកម្ខាងទៀតអង្អែលភ្លៅអូសមកដល់ចង្កេះ ឱ្យនាងប្រឹងត្បៀតជើង ហើយ

ទាល់តែរលាយសាច់មួយ។ គេឱនមកបឺតជញ្ជក់ចុងទ្រូង ដោយទប់ចិត្តមិន
បាន ស្របពេលដែលម្រាមដៃពិនិត្យកាន់តែជ្រៅ អង្អែលលើក្រោម បន្ទាប់មក
ក៏ជ្រែកម្រាមដៃ កម្រើកយឺតៗ ដែលវាមិនខុសពីត្រូវខ្សែតឹនៃអារម្មណ៍រញ្ជួយវាត់
ចំរាងកាយ ឱ្យនាងកន្ត្រាក់ និងប្រឹងទប់សំឡេងដ៏គួរឱ្យអាម៉ាស់ ទើបវាក្លាយជា
សំឡេងអណ្តឹតអណ្តកតិចៗ។

"សូមមេត្តា... ខ្ញុំមិនធ្លាប់..."

"អ៊ូ... អានែ"

គេឱនទៅថើបជញ្ជក់ ប្រើអណ្តាតបឺតជញ្ជក់យកសំឡេងថ្ងូរចង្អុរឱ្យវា
ក្លាយជារបស់គេតែម្នាក់គត់។ នាងព្រមទទួលថា ចូលចិត្តក្លិនខ្លួនក្រអូបប្រហើរ
របស់គេ ចូលចិត្តការប៉ះពាល់ពេលដែលពុកមាត់ពុកចង្កាវ៉ះត្រដុសលើស្បែក
ទោះមិនសុំនឹងការបបោលអង្អែលនេះ តែក៏ព្រមទទួល និងរីករាយស្វែងយល់



នោះហើយដែលធ្វើឱ្យ សារីហ្វ ញ័រខ្លួនទទ្រើតដោយចិត្តរីករាយ។

បាតដៃរបស់គេស្អាបអង្អែលសព្វសាច់ទន់ល្បឿយ ភ្លៅសរលោងដែលបៀតណែនចាប់ផ្តើមរសាយ រាងកាយទាំងពីររញ្ជួយដោយសាររសប្រាស្នា ហើយពេលគេបន្ថែមកម្រិតចង្វាក់ រាងកាយរបស់នាងក៏កន្ត្រាក់ ទោរទន់ទៅតាមមាត់ និងម្រាមដៃរឹងមាំ រម្លាយអារម្មណ៍ឱ្យត្រូវនឹងចង្វាក់អណ្តាតភ្លើងក្តៅតែរាងកាយបែរជាផ្អែមល្ហែម។

គេចាប់ដៃរបស់នាងមកដាក់ចំណុចសំខាន់របស់គេ ឱ្យនាងផ្ចើល ធ្វើអីមិនត្រូវ ព្រោះវាទាំងរឹងកំព្រឹស ទាំងក្តៅគគុក និងកន្ត្រាក់រហូត ហាក់ដូចរបស់មានជីវិត។

"ខ្ញុំនៅក្នុងកណ្តាប់ដៃនាងហើយ គ្រប់យ៉ាងតាមតែនាងបញ្ជា"

សារីហ្វ ប្រាប់ឱ្យនាងសិក្សាស្វែងយល់រាងកាយរបស់បុរស ស្វែងយល់រាងកាយដែលកំពុងតែក្លាយជារបស់នាង ដែលដំបូងនាងញញើតញញើម តែ

បន្ទាប់មកក៏ហ៊ានប៉ះពាល់ថ្នមៗ។ ពេលបានប៉ះពាល់ភាពក្តៅគគុករបស់បុរស ជាលើកដំបូងនៅក្នុងជីវិត វាឱ្យអារម្មណ៍ទាំងរំភើប ញាប់ញ័រ ត្រេកត្រអាល និង គ្មានទំនុកចិត្ត ព្រោះត្រឹមប៉ះពាល់គ្នាគឺហាក់ដូចមានចរន្តភ្លើងរត់កាត់។

បាតដៃទន់ល្មើយ ធ្វើឱ្យវាក្តៅទៅៗ រឹងទៅៗ ធ្វើឱ្យម្ចាស់គ្រហឹម បន្ទាប់ មកក៏ស្រវាទាញនាងមកឱប និងសម្លឹងមុខ ហើយគេក៏ប្រគល់ឱ្យនាង។

រាងកាយរបស់គេធំពេកហើយ បើប្រៀបធៀបនឹងនាង ធ្វើឱ្យនាងបើក ភ្នែកធំៗ ញ័រខ្លួនទទ្រើត និងយំ ព្រោះមិនស៊ាំនឹងភាពប្លែកថ្មីដែលជ្រៀតជ្រែក ចូលមក ខណៈដែលមុខមាំសង្ហារបស់ សារីហ្វ ទៅជាជ្រីវជ្រួញ ញើសជោកខ្លួន និងប្រឹងខាំធ្មេញជាការអត់ធ្មត់ ព្រោះត្រូវការឱ្យនាងស៊ាំ និងព្រមទទួលយកគេ សិន ទើបសម្ងំនៅស្ងៀម និងលួងលោម។

"បន្ទូរអារម្មណ៍... អានែ ទុកចិត្តខ្ញុំ ជឿជាក់ខ្ញុំ"

គេនាំខ្លួនឯងចូលទាំងអស់ ហើយមកវិញពាក់កណ្តាល។



អាលិហ្សា ទើបតែដឹងខ្លួនថាកំពុងអត់ដង្ហើម និងគ្រប់គ្រងចង្វាក់នៃការ
ដកដង្ហើមលែងបានហើយ ទើបប្រញាប់ស្វែងរកអុកស៊ីសែន និងថយក្រោយ
ដើម្បីគេច តែត្រូវគេសង្កត់ជាប់ និងកម្រើកតិចៗ ដើម្បីឱ្យជ្រៀតជ្រែកចូលមក
ទៀត ឱ្យស៊ីជម្រៅតែម្តង បន្ទាប់មកក៏ធ្វើបែបនោះដដែលៗ។

គេថើបអង្អែល ល្បួងឱ្យនាងទទួលយកការថើបនេះ រឹតរួតអណ្តាត និង
បីតជញ្ជក់យកសំឡេងដង្ហក់ខ្សល់ ពេលដែលការឈឺចាប់ត្រូវជំនួស ដោយ
អារម្មណ៍ភ្លើតភ្លើន រាងកាយទាំងពីរញ័រទទ្រើត ពេលឡើងទៅដល់ទីខ្ពស់
នៃបនិត្យទាំងកាយ ចិត្ត និងវិញ្ញាណ ហើយការអត់ធ្មត់របស់គេក៏ត្រូវបញ្ចប់
ទើបបន្ថែមចង្វាក់តាមអារម្មណ៍ប្រាថ្នាដ៏ព្រៃផ្សៃ។

១១

សុំកូន

អាកាសធាតុពេលព្រលឹមអុលនៅដែនដីសមុទ្រខ្សាច់រងាត្រជាក់ ធ្វើឱ្យ អាលិហ្សា ដេកលក់ស្រួលនៅក្នុងរង្វង់ដៃដ៏សែនកក់ក្តៅ ដោយអារម្មណ៍មាន សុវត្ថិភាព។

សារីហ្វ បើកភ្នែកយឺតៗ ព្រោះនេះជិតដល់វេលាថ្វាយបង្គំព្រះហើយ។ គេឈ្ងោកមើលអ្នកនៅក្នុងរង្វង់ដៃ ដែលពេលដេកលក់ នាងទន់ភ្លន់ ផ្អែមផ្អែម តែកុំឱ្យភ្ញាក់ឱ្យសោះ ព្រោះជាងខ្លាញីទៅទៀត ទាំងឆ្មាស ទាំងបុិនតមាត់ បុិនដេរ តែពេលត្រូវគេចាត់ការកាលពីយប់មិញ ក៏អស់ឫទ្ធិ ដេកលក់ស្រួល។

គេលើកដៃវាសសក់ចេញពីថ្ងាស ថើបថ្នមៗ ព្រមទាំងដណ្តប់ភួយឱ្យ



ជិត។ នេះជាលើកដំបូងដែលគេមើលឃើញអនាគត មានគេ មាននាង និង
មានក្មេងៗ រត់លេងក្នុងសួន នេះហើយជាការប្រាថ្នាដ៏ធំរបស់គេ។

"បង្កើតកូនឱ្យបងប្អូនប្រាំនាក់ម៉ោ បងនឹងចាត់ការរាល់យប់ ត្រៀមខ្លួន
ឱ្យបានល្អទៅ"

អាលិហ្សា ដេកលក់មិនដឹងរឿងអី ដឹងត្រឹមថាដេកលក់ស្រួលណាស់
ទាំងមានសេចក្តីសុខ ទាំងមានសុវត្ថិភាព តួយរោមអូដ្ឋលាយរោមចៀម ទាំង
ទន់ ទាំងម៉ដ្ឋ ហាក់ដូចត្បាញពីរោមបក្សី។

ខណៈដែល សារីហ្វ ងើបចេញពីពូក នាងយល់សប្តថាកំពុងដើរលេង
នៅក្នុងវាលផ្កា សុខៗ មានក្មេងស្រីរត់មករក តោងសំពត់របស់នាង ព្រមទាំង
លើកដៃម៉ាប់ៗ មករក។

'ម៉ាក់ បីៗ'

នាងងឿងឆ្ងល់ ពេលមើលឆ្វេងមើលស្តាំ មិនឃើញមានអ្នកណា ទើប

អង្គុយចុះទល់មុខនាងតូច និងពេលឃើញកែវភ្នែកដែលមើលមកម៉ក់ៗ ថ្ពាល់ ប៉ោងគ្រហាញៗ ក៏ស្តិញ។

'រង្វេងផ្លូវឬ នាងតូចទៅណាដែរ?'

'ម៉ាក់របស់ខ្ញុំគឺម៉ាក់ហ្នឹងអ្នែ ខ្ញុំជាកូនរបស់ម៉ាក់ បីខ្ញុំបន្តិច ហើយទៅរកប្អូនជាមួយគ្នា'

និយាយហើយនាងតូចក៏លើកដៃម៉ាប់មករក ធ្វើឱ្យនាងអស់សំណើច។ ម៉ាក់កូនក៏ម៉ាក់កូនដែរ ទើបនាងលើកនាងតូចបី។

អាលិហ្សា បើកភ្នែកដោយមិនសូវពេញចិត្តប៉ុន្មាន ព្រោះចង់និយាយជាមួយនាងតូចបន្ត។ នាងព្រិចភ្នែកពីរបីដង ដោយសារនៅងងុយ បន្ទាប់មកក៏បើកភ្នែកស្រឡះ ព្រោះមានមនុស្សស្រីមកពីណាក៏មិនដឹងជាងដប់នាក់អង្គុយចាំនាងភ្ញាក់ពីដេក ដោយពួកនាងបិទមុខបិទមាត់តាមប្រពៃណីអារ៉ាប់។



នាងក្រមុំស្ទុះងើបអង្គុយ ទាំងមិងមាំង ទាំងភ្ញាក់ មុខក្រហមងាំង ព្រោះ

ខ្លួនប្រាណនលគក និងមានស្នាមថើបក្រហមរាយប៉ាយពេញខ្លួន ខណៈនោះ

ស្រីៗ ក៏សើចខឺកៗ និងនាំគ្នាគោរព ទើបនាងប្រឹងគិតថាពួកនាងជានរណា និងមកទីនេះដោយរបៀបណា បន្ទាប់មកនាងក៏រាក់ទាក់ ព្រមទាំងងក់ក្បាលជាក់តាមទំនៀមទម្លាប់។

"សា-ឡាម អាមិ៉ា ហ្ស៊ឺកបញ្ជូឱ្យពួកខ្ញុំម្ចាស់មកចាំបម្រើអាមិ៉ាព្រះម៉ែម្ចាស់"

"សុំទោសផង ខ្ញុំស្តាប់អ្នកទាំងអស់គ្នាមិនយល់ទេ"

អាលិហ្សា សួរថាមានអ្នកណានិយាយភាសាអង់គ្លេសបានខ្លះ តែស្រីៗ បេឌូអ៊ីនមើលមុខគ្នាឡិងឡង់ ហើយនិយាយជាភាសាព័រសៀដដែល។

ពួកនាងចូលមកតែងខ្លួន ផាត់មុខ បាញ់ទឹកអប់ផ្កាកុលាប ដែលធ្វើពីផ្កាកុលាប ដោយប្រើតែបន្តិចបន្តួចប៉ុណ្ណោះ ក្លិនរបស់វាក៏ក្រអូបសាយ ពេលអង្គុយនៅត្រង់ណា ត្រង់នោះនឹងក្រអូប និងទោះជាងើបចេញក៏ដោយក៏នៅតែ

ក្រអូប។

នាងពាក់ឈុតខាហ្វាន ដែលត្រូវកាត់ដេរយ៉ាងប្រណិតពណ៌សភ្លុកដំរី សក់ពណ៌ខ្មៅរលើបរលោងទម្លាក់រាយពេញខ្នង ពាក់ស្បែកជើងដែលមានម៉ូតងចុងមុខ លម្អដោយគ្រាប់អង្កាំមានពន្លឺផ្លេកៗ គ្រឿងអលង្កាមានតែមួយគត់គឺចិញ្ចៀនពេជ្ររបស់សម្តេចព្រះមាតា ឌីណា ប៉ុន្តែទោះតែងខ្លួនយ៉ាងណាក៏ត្រូវពាក់អាបាយ៉ាដដែល ចង់បីខាដែលជាស្បែឃ្លុំមុខ បើកតែប្រឡង់ភ្នែក ព្រោះហ្វេសសានតែប្រកាន់ភ្ជាប់តាមច្បាប់អ៊ីស្លាមយ៉ាងតឹងរឹង ហាមមនុស្សស្រីបង្ហាញផ្ទៃមុខនៅទីសាធារណៈ។ ចុងក្រោយគេ គឺពាក់ស្បែឃ្លុំក្បាល បើមិនចង់មានបញ្ហានឹង មុតតាវ៉ា ឬមន្ត្រីសាសនា នាងគួរតែធ្វើតាម តែដល់មែនទែនទៅនាងចង់តែស្រែក ព្រោះទើសទែងនឹងស្បែឃ្លុំមុខ ឃ្លុំខ្លួន ទោះអាកាសធាតុនៅខាងក្រៅត្រជាក់ ក៏នាងចប់ដង្ហើម ចង់សន្លប់ទៅហើយ ជាពិសេសបីខាដែលធ្វើឱ្យក្តៅ ស្ទើរដកដង្ហើមមិនចេញ និងរមាស់ទៀត។



"សារីហ្វ នៅឯណា ខ្ញុំត្រូវការនិយាយជាមួយគេសិន"

នាងទាញស្បៃឃ្មុំមុខចេញ តែត្រូវហាម ហើយនាងបានជួបគេម្តងទៀត បន្ទាប់ពីញ៉ាំអាហារពេលព្រឹករួចរាល់ ដែលសឹងតែចាំគេមិនបានតែម្តង ព្រោះគេមិនបានតែងខ្លួនដោយឈុតទាហានពាក់កណ្តាលខ្លួនដូចមុននេះ តែពាក់អាវវែងសាច់ស្តើងពណ៌ខ្មៅ ប៉ាក់ជាយពណ៌មាស ជាក្រណាត់ធ្វើពីរោមសត្វតម្លៃថ្លៃដូចដែលជនជាតិអារ៉ាប់មានឋានៈជាព្រះញាតិវង្ស ឬតំណែងជាន់ខ្ពស់និយមពាក់ក្នុងកម្មវិធីសំខាន់ៗ។ គេពាក់គុត្រាក្រឡាការ៉ូពណ៌ក្រហមស ជាយវែងដល់ស្មា មើលទៅសង្ហា ថ្លៃថ្នូរ ហាក់ដូចរាជសីហ៍។

"ម៉ោះ! ទៅជាមួយបង"

គេដើរយឺតៗ មកឈរទល់មុខនាង និងហុចដៃមកឱ្យ។

អាលិហ្សា មានសំណួរជាច្រើន តែវារលាយអស់ ពេលប្រឈមនឹងបុរសចែងចាំងដូចព្រះអាទិត្យ។ នាងដាក់ដៃនៅលើបាតដៃរបស់គេ ឱ្យគេទាញទៅ

ឱប ខណៈនោះស្រីៗ ដែលមកជួយតែងខ្លួនក៏ចូលមកថើបខ្នងដៃរបស់នាងដូច
ដែលនាងធ្លាប់ឃើញបរិវារថើបខ្នងដៃរបស់សម្តេចព្រះមាតា ឌីណា និយាយ
ជូនពរដោយការគោរព ហើយឈានជើងថយក្រោយ ដើរចេញទៅ។

"សារីហ្វ លោកគ្រាន់តែជាទាហានមែនឬ ហេតុអី..."

"យប់មិញ... ចូលចិត្តទេ ?"

"ចូលចិត្តស្អី អឺ... អឺ... គឺតិចតួច តែតិចតួចប៉ុណ្ណោះ"

"តែបងចូលចិត្តខ្លាំង"

គេខាំច្បិចបបូរមាត់ពេលប្រសព្វភ្នែកជាមួយ កែវភ្នែកមុតស្រួចបង្ហាញ
ឱ្យឃើញច្បាស់ថាគេប្រាថ្នាថើបនាង ប៉ុន្តែគេអាចធ្វើបែបនោះបាន ទាល់តែនៅ
ពីរនាក់។

អាលិហ្សា មិនចង់ឱ្យខ្លួនឯងធ្វើអ្វីលើសលស់ដូចកាលពីយប់មិញទៀត
ទើបដើរចេញទៅ ដូច្នេះហើយទើបបុរសខ្ពង់ខ្ពស់ស្រវាចាប់ដៃ ទាញទៅថើប



នឹងបបូរមាត់ ហើយអង្អែល.កដៃដែលជាចំណុចទន់ជ្រាយដោយម្រាមដៃ ឱ្យ

នាងភ្ញាក់ក្រញាង ហើយងាកទៅសម្លក់សម្លឹង ទាំងដែលក្នុងចិត្តកំពុងតែមាន

អារម្មណ៍ប្លែកៗ។

"កុំម៉ោបៀតបៀន"

"គ្រាន់តែចាប់ដៃហ្នឹង... អានែ"

"មិនបាន មិនឱ្យចាប់ អ៎ា!"

នាងស្រែកភ្លាត់មាត់ ព្រោះត្រូវគេលើកបី និងឱនមកថើបថ្ពាល់ និងអូស

មករកបបូរមាត់ តែនាងប្រញាប់លើកដៃបាំង និងសម្លក់សម្លឹង ទាស់ត្រង់ថា

បុរសមាឌធំមិនញញើត។

"បែបនេះទេដែលហៅថាបៀតបៀន"

"ដឹងហើយៗ ដាក់ខ្ញុំចុះទៅ"

"មិនបានទេ បានបីហើយ រឿងអីដាក់ចុះវិញ"

ពេលចេញមកខាងក្រៅតង់ អាលិហ្សា ក៏បើកភ្នែកធំៗ ពេលឃើញក្បួន
ទ្បានប្រេនត៍លីយ៍ជាងដប់គ្រឿងចតចាំ និងដោតទង់អាសាដុលឡោះនៅជ្រុង
គម្របទ្បានខាងមុខទាំងសងខាង ហើយពេលឃើញមន្ត្រីវាំងក៏នាំគ្នាគោរព
ពេល សារីហ្វ បង្ហាញខ្លួន និងហៅនាងថា អាមិ៉ា។

"សារីហ្វ លោកច្បាស់ជាមិនមែនទាហានធម្មតាទេ"

"បងគ្រាន់តែមនុស្សធម្មតាម្នាក់ ដែលប្រាថ្នាបង្កើតគ្រួសារជាមួយអូន
អានែ"

"សារីហ្វ ឈប់សិន ខ្ញុំមិន..."

"ថ្ងៃនេះបងនាំអូនទៅហ្វេសសាន"

"សារីហ្វ ខ្ញុំមិនយល់ មានអីកើតឡើង ខ្ញុំមិនចង់ទៅហ្វេសសាន ខ្ញុំចង់
ចូលគាល់សម្តេចព្រះមាតា ឪណា ថ្វាយចិញ្ចៀនវិញ ខ្ញុំចង់ត្រឡប់ទៅផ្ទះហើយ
ថ្មើរណោះប៉ាខ្ញុំជេរស្លាប់ហើយ សារីហ្វ"



ត្រូវបិទ កញ្ចក់ខ្មៅដែលខណ្ឌបន្ទប់ដោយសារ និងបន្ទប់បើកបរក៏ត្រូវចុចទម្លាក់ ហើយគេក៏ទាញបីខារបស់នាងចេញ។ នាងលួចអរគុណគេ ព្រោះវាអាចឱ្យនាងដកដង្ហើមបានស្រួល តែមិនទាន់បានដកដង្ហើមពេញពោះផង ក៏ត្រូវលើកទៅអង្គុយលើភ្លៅ និងតាមដោយការថើបជញ្ជក់ខ្លាំងៗ ចង់ដាច់ខ្យល់។

បបូរមាត់ទាំងពីរនៃបនិត្យគ្នា គ្មានប្រឡោះឱ្យខ្យល់ចេញចូល ហើយវាក្តៅដល់ថ្នាក់នាងនិងគេសឹងតែឆេះ។ រសក្រអូបផ្អែមដែលគេរកឃើញជារបស់អស្ចារ្យដែលគេប្រាថ្នា ទើបសច្ចាថា មិនព្រមឱ្យនាងទៅណាដាច់ខាត។

"លោកកំពុងធ្វើឱ្យខ្ញុំខ្លាច សារីហ្វ"

នាងនិយាយស្លាម ពេលប្រឹងរុញច្រានគេចេញបានសម្រេច ដែលត្រូវចំណាយកម្លាំងច្រើនគួរសម។

"អានែ បបូរមាត់អូនផ្អែមដូចស្ករ សំឡេងថ្លរហៅឈ្មោះបងក៏ពីរោះ ហៅ

បងទៀតម៉ោ បងចូលចិត្តពេលអូនហៅបងថា សៅជុន"

សារីហ្វ ខ្សឹបប្រាប់ ព្រមទាំងថើប ហើយញញឹមមានសេចក្តីសុខ ពេល ដើមទ្រូងទន់ល្មើយបៀតនឹងដើមទ្រូង។ ស្រីម្នាក់នេះសក្តិសមមែនទែន ដូច ព្រះអាទិត្យបង្កើតនាងមក ដើម្បីគេតែម្នាក់ប៉ុណ្ណោះ។

គេមិនធ្លាប់មានជំនឿចំពោះស្នេហា ប៉ុន្តែពេលនេះគេកំពុងងប់ងល់នឹង វា។ នាងជាកាដូដែលមិនអាចកាត់ថ្លៃបាន គេសុឋថានឹងឱ្យនាងបានតែងខ្លួន ដោយសម្លៀកបំពាក់ត្បាញពីមាស ឱ្យនាងបានផឹកទឹកដែលផ្អែមត្រជាក់ និង ថ្លាយង់ ឱ្យនាងបានធ្វើជាម្ចាស់បសុសត្វ និងដែនដីដ៏សម្បូរបែប ផ្លូវថ្មល់ដែល នាងដើរត្រូវតែប្រាសចាកធូលីដី និងបន្លា គេសុឋថានឹងមិនព្រមឱ្យស្មៅ បន្លា ដុះដាលក្នុងដែនដីរបស់នាង។

អាលិហ្សា ទន់ខ្លួនល្អកដោយសាររសជើបរបស់គេ ដែលមានតែធ្វើឱ្យ លិចលង់ផុងជ្រៅ មានតែឈឺចាប់។



"អរគុណ ដែលលោកមានអារម្មណ៍ល្អចំពោះខ្ញុំ ប៉ុន្តែខ្ញុំមិនត្រូវការទេ សារីហ្វ ខ្ញុំធ្វើមិនបានទេ ខ្ញុំទ្រាំតែងខ្លួនបែបនេះមិនបានទេ ខ្ញុំមិនត្រូវការធ្វើជាចាបក្នុងទ្រុងរបស់លោក"

"អូនធ្វើចិត្តចាកចេញពីបងបានមែនឬ?"

សារីហ្វ ប្រសព្វភ្នែកជាមួយនាង សម្លឹងចំៗ ខណៈនោះ អាលិហ្សា ដកដង្ហើមមិនចង់ពេញពោះ។

"សារីហ្វ ខ្ញុំនឹងនឹកលោក យប់មិញខ្ញុំមានក្តីសុខ លោកវិសេសណាស់ យើងសុខព្រមរៀងខ្លួន មែនហើយ គឺស្មើភាពគ្នា និងចប់ត្រឹមហ្នឹង រឿងរបស់យើងមិនអាចទៅរួចទេ ខ្ញុំនៅទីនេះមិនបានទេ"

នាងនិយាយដល់រឿងយប់មិញ ថាវាគ្រាន់តែជាការដោះដូរសេចក្តីសុខដោយទឹកមុខស្មើ ខណៈដែល សារី រញ្ជួយពេញទ្រូង ពោះវៀនពោះតាំងរមួលព្រោះក្រៅពីនាងមិនព្រមទទួលក្តីស្រឡាញ់គេហើយ នៅចង់ចាកចេញទៀត។

ត្រឹមគិតថាពេលនាងចាកចេញទៅហើយ អាចមានបុរសផ្សេងឱបនាងជំនួស

គេ ក៏ធ្វើឱ្យគេខឹងសម្បាស្លាម។

"ឈាមត្រជាក់ពេកហើយ យើងទាំងពីរធ្វើរឿងជ្រាលជ្រៅជាមួយគ្នា

ហើយ តែអូនឱ្យតម្លៃវាត្រឹមជាទំនាក់ទំនងមួយរាត្រី ប៉ុណ្ណឹងទេឬ?"

បាតដៃក្តៅគគុកប៉ះពាល់នាងយ៉ាងអង់អាច ប៉ះពាល់ដើមទ្រូងទាំងពីរ

ផ្សោចតែបន្តិចក៏អាចជ្រែកចូលទៅក្តោបត្រគាកមូលក្តុំ និងផ្សោចតែបន្តិចដូចគ្នា

ក៏ធ្វើឱ្យជើងស្រឡូនញែកចេញពីគ្នា ហើយប៉ះពាល់នាង។

"សារីហ្វ កុំ! បើមិនឈប់ ខ្ញុំនឹងខ្វាចអាញ៉ក់លោកឱ្យចេញឈាម"

នាងតតាំង តែគេស្គាល់ចរិតរបស់នាងច្បាស់ ទើបចុចប៊ូតុង និងចេញ

បញ្ជា ៖

"ចតទ្បាន"

ទ្បានឈប់តាមបញ្ជាស្លាម និងឈប់មួយក្បួនតែម្តង។

នាងនឹង...

"លើកនេះបងមិនបណ្តោយឱ្យអូនរត់ពេញសមុទ្រខ្សាច់ទៀតទេ អានែ"

គេដឹងគំនិតរបស់នាង តែ អាលិហ្សា ល្បិចខ្លាំងជាង ដោយការស្រែក និងចង្អុលទៅក្រោយខ្នងរបស់គេ ហើយពេលគេងាកទៅមើល នាងក៏បើកទ្វារចុះពីឡាន ព្រមទាំងក្តាប់ដីខ្សាច់ គប់ភ្លាម។

"ចាំមើលទៅ!"

"ស្មានថាខ្ញុំខ្លាចឬយ៉ាងម៉េច គ្រាន់តែបានគ្រប់គ្រងព្រហ្មចារីខ្ញុំ ហើយគិតថាត្រូវទទួលខុសត្រូវខ្ញុំឬ ខ្ញុំមិនមែនជាស្រីបុរាណទេ អាដៃណូស័រ"

"មែន បងបានគ្រប់គ្រងព្រហ្មចារីរបស់អូន ហើយអូនចង់ទៅបាបូជាមួយអ្នកផ្សេងនេ៎ះ"

"បាបូប្រៃថាស្អី?"

"ប្រែថាដាក់របស់បងចូលទៅក្នុងរបស់អូន យោកចង្កេះតិចៗ ហើយ
មានអារម្មណ៍នៅចុងបញ្ចប់នោះអ្អែ"

"អាឆ្កួត ទៅបាបូនៅកន្លែងផ្សេងទៅ"

មិនខ្វល់ទេថា ស្រីជើងល្អនឹងឡូឡាកម្រឹងយ៉ាងណា គេចាប់ឱបចង្កេះ
របស់នាង ហើយលើកដាក់លើស្មា ដើរសំដៅចិញ្ចឹមផ្លូវ ដោយទឹកមុខមួម៉ៅ
ចំណែកអ្នកហែហមត្រូវបញ្ជាឱ្យរង់ចាំនៅឡាន ហាមអ្នកណាទៅតាម។

"នែ៎! ចង់នាំខ្ញុំទៅណា ដាក់ខ្ញុំចុះវើយ! សារីហ្វ! ចង់ត្រូវធម៌ក្តៅមែនទេ
ចាំព្រះម៉ែចាត់ការឱ្យ អ៊ុយ! ប្រុសឆ្កួត និយាយស្រួលបួល មិនចេះស្តាប់គ្នា
មែនទេ!"

"ហ្សឹកនាំអាមិ៉ាទៅណាហ្នឹង?"

អ្នកបើកបរឡានអើត.កតាមមើលដោយការព្រួយបារម្ភ តែ អាលី ដែល
ជាមនុស្សជំនិតរបស់ហ្សឹកគិតតែពីហាមាត់ស្លាបហ៊ាម។ កាលពីព្រលឹមអុល គេ



ត្រូវបញ្ជាឱ្យហៅមនុស្សមកទទួលអាមិរ៉ា ចំណែកខាងដំណាក់នៅហ្វេសសាន ក៏ត្រូវបញ្ជាឱ្យបើកក្រឡាបន្ទុំសម្រាប់អាមិរ៉ា រួមទាំងក្រឡាបន្ទុំ និងរបស់របរសម្រាប់ក្មេង ធ្វើឱ្យរវល់ពេញមួយដំណាក់។

អាលី ទ្រានដែបង្ហួចឡាន មិនស្មានទេថាហ្សីកអន្ទះសាចង់បានកូនអីយ៉ាងនេះ មនុស្សណ៎ា មិនមែនមើមឆែឆាវទេ។

"ទ្រង់ចាប់អាមិរ៉ាទៅបាបូទាល់តែពេញព្រះទ័យពេលណា នឹងយាងមកវិញហើយ មិនបាច់បារម្ភទេ"

"ហើយពេលណា ទើបទ្រង់ពេញព្រះទ័យ?"

មែនហើយ តើពេលណា ទើបទ្រង់ពេញព្រះទ័យ?

អាលី ធ្វើភ្នែកឡេមឡាម ពេលគិត ហើយកំណត់ពេលវេលា។

"យ៉ាងលឿន មួយម៉ោង យ៉ាងយូរ កន្លះថ្ងៃ រឿងបែបនេះត្រូវនិយាយគ្នាសន្សឹមៗ"

...

ផ្ទៃមេឃនៅដែនដីសមុទ្រខ្សាច់មានពណ៌ផ្ទៃមេឃស្រឡះ គ្មានពពក និងនៅឆ្ងាយ មើលឃើញជ្រលងពើងថ្មខ្ពស់ ជាជ្រលងធម្មជាតិ ដែលកើតព្រោះការសឹករេចរឹលដោយសារទឹក កាលពីរាប់ម៉ឺនឆ្នាំមុន។ កាលពីបុរាណតំបន់នេះធ្លាប់ជាតំបន់គ្រោះថ្នាក់ មានចោរខ្លួយ តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់វ៉ាលីបច្ចុប្បន្ន ទីនេះកំពុងតែអភិវឌ្ឍជាតំបន់កសិកម្មកណ្តាលសមុទ្រខ្សាច់និងខួងយកប្រេង។

"សារីហ្វ! ប្រាប់ថាឱ្យដាក់ខ្ញុំចុះ លោកឆ្កួតហើយក៏អី អាមនុស្សពាល ខ្ញុំប្រាប់ថាឱ្យដាក់ចុះ"

អាលិហ្សា ស្រែកឡូឡាពេញផ្លូវ មិនដឹងថាគេកំពុងតែនាំទៅណា ដឹងត្រឹមថាឈាមកំពុងតែហូរមកផ្ដុំនឹងក្បាល ពោះដែលទង្គិចនឹងស្មាមាំមួនក៏ចុក។ សារីហ្វ ដែលកំពុងដើរទៅតាមគុម្ពោធឈើអាខេសៀស្ងិតៗ គ្រវីក្បាល



ហួសចិត្តនឹងស្រីជើងល្អ ដែលនៅតែសម្បុរកម្លាំង។

"បើស្តាប់បងគ្គាប់បងនឹងដាក់ឱ្យចុះដើរខ្លួនឯង អូខេទេ ?"

អាលិហ្សា ធ្វើមុខខ្ឹរ ថែមទាំងធ្វើឆើយដាក់មិនព្រមឆ្លើយតបទៀត ទើប គេដាក់នាងចុះឱ្យឈរខ្លួនឯង។ នាងគិតនៅក្នុងចិត្តរួចហើយថា ពេលចូលដល់ក្នុងក្រុងនឹងរកឡានទៅរាជធានីដោយខ្លួនឯងប៉ុន្តែប្រុសម្នាក់នេះហាក់ដូចមានព្រាយចាំខ្សឹប ទើបឱនមកខ្សឹបដាក់ត្រចៀក។

"អូនគេចពីបងមិនរួចទេ អានែ"

គេចាប់ដៃរបស់ អាលិហ្សា នាំដើរបន្ត នាងគិតតែធ្វើមុខក្រមូវ តែក៏ព្រមដើរតាម ហើយពេលមើលទៅឆ្ងាយ ឃើញគ្រឿងចក្រកំពុងធ្វើការនៅលើសមុទ្រខ្សាច់។

"ឆ្នាំក្រោយ...ទីនេះនឹងក្លាយជាកសិដ្ឋានសាបព្រួស បងចង់ដាំដើមស្រល់ អាប្រីខន ស្រូវសាលី បន្លែនិង អូលីវ បងចង់ឱ្យអូនបានឃើញ"

"ធ្វើយ៉ាងម៉េច បើទីនេះហួតហែងអីចឹង"

"បងនឹងធ្វើឱ្យអូនមើល អូននៅមើលជាមួយបងទេ ?"

ស្មាមញ្ញឹមរបស់គេ ទង្គិចបេះដូងរបស់នាងមួយទំហឹង។ គេញញឹមហាក់ដូចកំលោះតូចដែលកំពុងអួតរឿងល្អៗដែលគេលាក់ទុកឱ្យនាងមើលតែម្នាក់ឯង ទើបនាងងាកមុខចេញ ខណៈនោះក៏ដើរបន្ត។

"ចង់នាំខ្ញុំទៅណា ?"

"ដល់ហើយ"

នៅចំពោះមុខនាង គឺវាលផ្កាសមុទ្រខ្សាច់ ដែលរីកស្គុះស្គាយ ផ្កាមានច្រើនណាស់ ដល់ទៅប៉ែតសិបប្រភេទ ស្អាតៗ ហាក់ដូចរូបគំនូរ ធ្វើឱ្យនាងបើកភ្នែកធំៗ ដើរទៅរកវាហាក់ដូចកំពុងមមើ។

"ទីនេះស្អាតដល់ហើយ សារីហ្វ ស្អាតដល់ថ្នាក់ដូចនៅឋានសួគ៌"

"ពេលដែលអូនញញឹមដាក់បង បងក៏មានអារម្មណ៍ដូចបានឡើង

ហានសួគ៌ដែរ"

គិតថាសម្តីផ្អែមហើយខ្ញុំទន់ខ្លួនល្អកឬយ៉ាងម៉េច!

នាងធ្វើធឹសដាក់ ចំណែកគេកើយស្មានឹងក្បាលរបស់នាង ថែមទាំងមាន ចេតនាទម្លាក់ទម្ងន់មកលើទៀតផង ទើបនាងប្រញាប់ដើរចេញ ប៉ុន្តែមិនស្រួល ប៉ុន្មាន ព្រោះឈុតវាស្តេស្ដ ទើបជាន់ជាយសំពត់ រិះតែជ្រមិលផ្តាប់មុខ សំណាង ល្អដែលមានគេឱបចង្កេះពីក្រោយទាន់។

"កើតអីឬអត់ អានែ"

ខ្ញុំមិនគួរណាបង្រៀនឱ្យគេហៅបែបនេះទេ!

នាងគិតដោយការធុញទ្រាន់ ខណៈនោះ សារីហ្វ ក៏ជួយបោសវាស ខ្លួនប្រាណឱ្យ ហើយឈ្ងោកមើលស្បែកជើង។

"ម៉េចក៏ញ៉ែខ្លួន មិនស្រួលខ្លួនឬអត់"

"អត់ទេ កុំ..."

ចុងម្រាមដៃ...ម្រាមដៃ...បាតដៃក្តៅ ប៉ះដោយភាពទន់ភ្លន់ ថ្នមៗ និង

គ្មានអ្វីលើសលួស តែនាងវិញធ្ងន់កណ្តុកហាក់ដូចក្លាយជាថ្មទៅហើយ ហើយ

ដែលយ៉ាប់ឃឺនជាងនោះ ពេលដែលប៉ះពាល់គ្នាភ្លាម គ្រប់យ៉ាងក៏ផ្ទុះ ភាព

រឹងកំព្រឹសដែលបៀតនឹងត្រគាករបស់នាង ធ្វើឱ្យនាងដឹងដល់អារម្មណ៍ស្រេក

ឃ្លានរបស់គេ។

"នែ៎! ឈប់សិន នេះកណ្តាលថ្ងៃចែស ចង់ធ្វើអី"

"សុំបាបូបន្តិច"

"សុំគ្នាងាយៗបែបនេះឬ តិចជេររយះរយាយ"

ម្តងនេះគេប្រើសំឡេងអង្រួនចិត្តដាក់។

"សុំបាបូបន្តិច អានែ"

"គឺ...គឺប្រាប់ថាមិនបានគឺមិនបានហើយ ពេលនេះមេឃមិនទាន់ងងឹត"

"ហើយម៉េចក៏ធ្វើពេលថ្ងៃមិនបាន ?"



"ខ្មោចសមុទ្រខ្សាច់...គឺវាមិនល្អ មិនល្អ"

"មានអីមិនល្អ វាល្អខ្លាំងទៅវិញទេ"

អាលិហ្សា និយាយមិនចេញ ប្រឹងដោលចេញឱ្យឆ្ងាយ ប៉ុន្តែត្រូវគេចាប់កញ្ចឹងកជាប់ព្រមទាំងឱនមកថើបជញ្ជក់បបូរមាត់ជ្រែកអណ្តាតចូលមករឹតរួត។ នាងមិនបានគិតថារើបម្រះ ឬតវ៉ា មានតែតបស្នងតាមដែលគេជុត។ ពេលនេះ នាងគិតអីមិនចេញទាំងអស់ ខួរក្បាលវាទទេស្អាត អស់ទៅហើយ។

បបូរមាត់ដែលប្រដេញតិចៗតាមប្រឡោះក ធ្វើឱ្យនាងទោរទន់ទៅរកពិតនឹងដើមទ្រូងធំទូលាយដោយគ្មានកម្លាំងកំហែង រាងកាយមានប្រតិកម្មតបស្នងប្លែកៗ វាកាន់តែក្តៅ ស្រៀវស្រើបដល់ថ្នាក់ទប់ខ្លួនមិននឹង ទើបដកដង្ហើមធំហើយសម្ងំស្តាប់សំឡេងបេះដូងរបស់គេដែលវាឱ្យអារម្មណ៍វិសេសខ្លាំងណាស់។

"ទៅវិញទៅ គ្រប់គ្នាកំពុងរង់ចាំយើង"

សារីហ្វ គ្រហឹមតិចៗ ខណៈនោះក៏ដោះគុតត្រាមកក្រាលលើខ្សាច់ទន់ល្មើយ ហើយរុញនាងឱ្យដួលដេកទៅលើនោះកណ្តាលវាលផ្កា។

គេដោះអាវផាយពណ៌ខ្មៅរបស់ខ្លួនឯងចេញ ទាញសម្លៀកបំពាក់ផ្សេងទៀតដោយចិត្តអន្ទះសា ធ្វើឱ្យបេះដូងរបស់ អាលិហ្សា លោតញាប់ ពន្លឺពណ៌ក្រហមចាំងលើស្បែករបស់ពួកគេទាំងពីរ សាច់ដុំដែលត្រូវនឹងពន្លឺថ្ងៃ មើលទៅរឹងមាំហាក់ដូចសាច់ទង់ដែង ចែងចាំងនិងស្អាតគ្មានអ្វីឱ្យទាស់ ចំណែកខ្លួនប្រាណរបស់នាងក៏មានពន្លឺផ្លេកៗដើមទ្រូងនិងត្រគាកមូលក្តុំធ្វើឱ្យបេះដូងរបស់គេលោតញាប់ខ្លាំង សឹងតែឈឺអស់ទៅហើយ។

មុនពេលបានតវ៉ាត្រឹមមួយប៉ព្រិចភ្នែកប៉ុណ្ណោះ សម្លៀកបំពាក់របស់នាងក៏ត្រូវទាញឱ្យមកនៅលើគល់ទ្រូង ដែលធ្វើឱ្យនាងកាន់តែជ្រួលច្រាល់ ពេលគេប្រើអណ្តាតក្តៅប៉ះពាល់ចុងទ្រូងថ្នមៗ បន្ទាប់មកក៏បីតជញ្ជក់ដោយប្រអប់មាត់



អូសអណ្តាតកាត់គល់ទ្រូងសខ្ចីក និងមករកអណ្តាតរបស់នាងដៃក៏នៅមិនសុខ
ធ្វើឱ្យនាងហត់នឿយខ្ជិលវាសចេញ។

"ដឹងបែបនេះ ខ្ញុំគួរតែស្តាប់សម្តីម៉ាក់ ខ្ញុំនេះឆ្កួតមែន"

នាងថ្ងូចថ្ងូរគួរឱ្យអាណិត ខណៈដែល សារីហ្វ លួចអស់សំណើច។

"ម៉ាក់អូនប្រាប់ថាម៉េច ?"

"ម៉ាក់ប្រាប់ថាប្រុសអារ៉ាប់កាមក្រាស់"

"ម៉ាក់អូននិយាយត្រូវ ត្រៀមទទួលវគ្គពេលព្រឹក ពេលល្ងាច ពេលយប់
បាន"

"ប្រុសឆ្កួត សុំឱ្យអាញ៉ក់ស្វិតងាប់"

នាងពត់ពែនខ្លួនប្រាណនៅក្រោមការប៉ះពាល់របស់គេ ខ្យល់ដង្ហើម
ចាប់ផ្តើមដង្ហក់ ប្រឹងស្រូបយកខ្យល់អាកាសចូលឱ្យពេញសួត ដើម្បីកាត់បន្ថយ
អារម្មណ៍ស្រៀវស្រើបដែលគេផ្តល់ឱ្យ រាងកាយរបស់គេ ក៏ក្តៅហាក់ដូចភ្លើង

ត្រូវការរកកន្លែងកម្ចាយជាបន្ទាន់។

"យប់មិញអូនធ្វើឱ្យបងស្ទើរឆ្កួត...ហើយបងកាន់តែឆ្កួតទៅៗ"

"កុំម៉ោឲ្យឺបដោយសំឡេងត្រែកកាមបែបនេះដាក់ត្រចៀកខ្ញុំ"

"ហើយបើសំឡេងថ្ងូររបស់បង ?"

"ហ្នឹងហើយត្រែកកាម អាប្រុសត្រែកកាម អ៉ា !"

អាលិហ្សា ភ្ញាក់ក្រញ្ជាង រាងកាយទាំងមូលក៏កន្ត្រាក់ និងអែនទៅរកតាម សញ្ញាតិ ភ្លើងប្រាថ្នាឆាបឆេះបន្ទាប់ពីបាត់បង់ការគ្រប់គ្រង សំឡេងថ្ងូចថ្ងូរឮកាន់តែខ្លាំង សារីហ្វ ងើបខ្លួនបន្តិចដកដង្ហើមក្តៅភាយៗ សាច់ដុំមានញើសតោងទាម ពេលត្រូវនឹងពន្លឺថ្ងៃ វាឱ្យពន្លឺផ្លេកៗ។

នាងដកដង្ហើមដង្ហក់ រាងកាយទាំងមូលឡើងរឹងកំព្រឹស មានអារម្មណ៍ ដល់កម្លាំងមហាសាល ដែលកំពុងធ្វើសកម្មភាព គេប្រើភាពមហិមារបស់គេ ប៉ះពាល់នាងត្រង់នោះ ទោះមិនទាន់មានអ្វីជ្រៀតជ្រែកចូលទៅ ប៉ុន្តែនាងថ្ងូចថ្ងូរ



សឹងតែអស់កម្លាំងទៅហើយ ភាពរំភើបញាប់ញ័រកាន់តែកើនឡើង ពេលដែល

ពួកគេប្រាថ្នាគ្នានិងគ្នាយ៉ាងខ្លាំងក្លា។ នាងអូសម្រាមដៃ តាមស្មាធំទូលាយ និង

រឹងមាំ ផ្តិតយកកម្តៅភាយៗរបស់បុរស ពេលរាងកាយនៃបនិត្យជិតគ្នា។

ពួកគេថើបគ្នាម្តងទៀត និងត្រឹមមើលភ្នែកគ្នា មិនចាំបាច់និយាយអីទាំង

អស់ ហើយទីបំផុត...

ភាពខ្លាំងក្លារបស់បុរស ប៉ះផ្នែកទន់ជ្រាយបំផុតរបស់ស្ត្រី ពួកគេប្រសព្វ

ភ្នែកគ្នា បន្ទាប់មកគេក៏លើកអ្នកនៅក្នុងរង្វង់ដៃ ឱ្យខ្ពស់បន្តិច ហើយជ្រៀតជ្រែក

ចូលទៅនៅពេលនោះ។

១២

ដឹងការពិត

កាលពីអតីតហ្វេសសាន ជាក្រុងអូអេស៊ីស កាលពីរាប់ពាន់ឆ្នាំកន្លងផុត
ទៅ មនុស្សម្នាទិញលក់ ដោះដូរពីអូអេស៊ីសមួយទៅអូអេស៊ីសមួយទៀតដោយ
មិនប្រញាប់ប្រញាល់ ទំនិញត្រូវលក់ពីម្ចាស់មួយទៅម្ចាស់មួយ ទើបការរក្សា
ទំនាក់ទំនងនៃការជួញដូរ គឺជារឿងសំខាន់។ ពេលអូអេស៊ីសហួតហែង ក្រុងក៏
ត្រូវបោះបង់ដែរ ប៉ុន្តែការរកឃើញមាសពណ៌ខ្មៅនៅក្រុងហ្វេសសាន បានកែប្រែ
ស្ថានភាពមេឌីសពីដែនដីសមុទ្រខ្សាច់ដ៏ធំល្វឹងល្វើយ ស្ងាត់ជ្រងំ ឱ្យក្លាយជា
ប្រទេសអ្នកមាននៅក្នុងពេលមិនប៉ុន្មានឆ្នាំប៉ុណ្ណោះ។

"មិនប៉ុន្មានឆ្នាំទីនេះ នឹងត្រូវអភិវឌ្ឍឱ្យក្លាយជាក្រុងដ៏សំខាន់របស់



មឈ្សៀមបូពា"

សារីហ្វ ប្រាប់ដោយទឹកមុខមានមោទនភាពដែលបានអួតនាង ដែល អាលិហ្សា ក៏យល់ស្របនឹងសម្តីរបស់គេដែរ ទោះពេលនេះ មីឌីសទើបតែបើក ប្រទេស ប៉ុន្តែទីក្រុងដែលធ្លាប់មានតែដីហួតហែង និងសមុទ្រខ្សាច់កំពុងតែរីក ចម្រើន មានគម្រោងសាងសង់ធំៗកើតឡើងជាច្រើន ទាក់ទាញវិនិយោគិនទាំង ឡាយឱ្យចូលមកវិនិយោគនៅក្នុងប្រទេសប្រជាជនមានជីវភាពធូរធារទើបនាង ជឿជាក់ថា នៅក្នុងពេលពីរបីឆ្នាំនេះ ហ្វេសសាន នឹងក្លាយជារាជសីហ៍នៃផ្នែក សេដ្ឋកិច្ចដែលរឹងមាំ។

"អូនគ្មានសម្លៀកបំពាក់ជាប់ខ្លួនទេ យើងទៅទិញសិនទៅល្អជាង"

"ទីនេះមានហាងខោអាវដែរឬ ?"

"សុំត្រឹមអូនត្រូវការ ទីនេះមានគ្រប់យ៉ាង"

អាលិហ្សា លាក់ការសង្ស័យកាន់តែច្រើនទៅៗ អាវផាយពណ៌ខ្មៅ ជាយ

មាសដែលគេពាក់ ជាសម្លៀកបំពាក់ដែលត្រូវកំណត់ឱ្យប្រើប្រាស់សម្រាប់វណ្ណៈ
ជាន់ខ្ពស់ប៉ុណ្ណោះ ដូច្នេះហើយគេមិនមែនធម្មតា។

"សារីហ្វ..."

"សារីហ្វ ខ្ញុំគ្រាន់តែជាស្រីធម្មតាម្នាក់ ជាពលរដ្ឋទូទៅ និងធ្វើដំណើរមកពី
ទីឆ្ងាយ មកដល់ទីនេះដើម្បីទាក់ទងរឿងជួញដូរត្បូងមណី លោកយល់ពីខ្ញុំមែន
ទេ ?"

"បងយល់...បងនឹងបង្រៀនអូនសន្សឹមៗ ឱ្យយល់ពីជីវិតរបស់បង
ហើយបងនឹងរៀនពីជីវិតរបស់អូនវិញ មើលនោះ គឺជាទីក្រុងរបស់បង"

ហ្វេសសាន នៅឆ្ងាយពីរាជធានីដោយចំណាយពេលត្រឹមពីរម៉ោងកន្លះ
ប៉ុណ្ណោះ ស្ថិតនៅជាប់នឹងឆ្នេរសមុទ្រខ្សាច់ ទើបក្តៅនិងហួតហែងជាងរាជធានី។
ទោះជាប្រភពខ្លងប្រែង ប៉ុន្តែបាសារ៍នៅក្នុងក្រុងក៏មានទំនិញច្រើនប្រភេទដែល
នាងចូលចិត្ត។ សារីហ្វ កុម្ម៉ង់ទិញក្រណាត់សូត្ររលោងឱ្យនាង ក្បាច់ប៉ាក់ស្អាត



ហាក់ដូចមានព្រលឹងព្រលះ ជាងកាត់ដេរក៏មកចោមរោមវាស់ទំហំខ្លួន ដើម្បី កាត់ឈុតខាសានលម្អផ្កាស្អាតៗឱ្យនាងជាច្រើនឈុត ប៉ុន្តែនាងបែរជាចាប់អារម្មណអ្នកលក់គុជខ្យងពណ៌ស ហាក់ដូចទឹកដោះគោនិងផ្កាថ្មពណ៌ក្រហម ដូចព្រះអាទិត្យលិច ទើប សារីហ្វ បញ្ជាឱ្យទិញគ្រប់យ៉ាងឱ្យ ទោះនាងគ្រាន់តែត្រូវការសួរតម្លៃក៏ដោយ។

"មួយនេះថ្លៃប៉ុន្មាន ?"

នាងសួរអ្នកលក់នៅហាងបន្ទាប់ព្រោះចង់ប្រៀបធៀបតម្លៃត្បូងមណីនៅក្នុងទីផ្សារ ហើយពេលសួររួច ក៏ដើរទៅហាងបន្ទាប់ ខណៈដែល សារីហ្វ ចង្អុលប្រាប់ឱ្យយកខ្សែកត្បូងគុជដែលនាងសួរអម្បាញ់មិញ ដោយមិនខ្វល់ពីតម្លៃរបស់វា។ នេះជាលើកដំបូងដែលគេដើរតាម និងកាន់អីវ៉ាន់ឱ្យមនុស្សស្រី និងស្ទើរតែបិទបាសាវ៍ដើម្បីម៉ៅយកអីវ៉ាន់ទាំងអស់ ទៅបើកបាសាវ៍ផ្ទាល់ខ្លួននៅក្នុងដំណាក់ទៅហើយ។

"អ៉ូហូ! អ្នកធំតើ បណ្តើរស្រីកំណាន់មកស៊ីបតឹងផង ពួកបរទេសនេះគឺ គ្មានកេរ្តិ៍ខ្មាសបែបនេះឯង ដង្ហែរគ្នាមកជីកយកមាសត្រៀបត្រា"

ស្រីម្នាក់ដែលពាក់អាបាយ៉ា និងបឺខាបិទមុខបិទមាត់ ខ្សឹបខ្សៀវគ្នាជាមួយម្នាក់ទៀតដោយមិនខ្វល់ទេថា អាលិហ្សា ស្តាប់យល់ឬអត់។ ពេលនិយាយគ្នាហើយ ពួកនាងក៏ដើរចេញទៅបាត់ ខណៈដែល អាលិហ្សា ស្តឹកមុខតែម្តង ទោះព្យាយាមធ្វើជាមិនចាប់អារម្មណ៍ហើយក៏ដោយ។

"កើតអី ?"

"គ្មានអីទេ"

អាលិហ្សា ដើរមកដល់ហាងលក់សម្លៀកបំពាក់នៅបាសារ៍ ម៉ូតម៉ាកហ្វេសហ្សិនស្អាតៗ និងតម្លៃមិនថ្លៃ ទើបនាងចូលទៅទិញម៉ូតសាមញ្ញ ទោះដឹងថាជ្រើសរើសបែបណា ក៏ត្រូវតែពាក់អាបាយ៉ាពណ៌ខ្មៅបិទបាំងដដែល និងដោយសារថប់ដង្ហើម ទើបនាងដោះបឺខាចេញ ដើម្បីដកដង្ហើមចូលឱ្យពេញសួត



ប៉ុន្តែបែរជាបានឮសំឡេងកាមេរ៉ា ទើបងាកទៅមើល និងឃើញថាបុរសម្នាក់ពួន
នៅក្រោយបង្គោល កំពុងចុចកាមេរ៉ាថតរូបរបស់នាង ហើយពេលឃើញថានាង
ដឹងខ្លួន ក៏ប្រញាប់ដើរចេញទៅ។ នាងកាន់តែមិនយល់ និងមានការភ័យខ្លាច
ទើបពាក់បឺខាបិទបាំងមុខដូចដើម ហើយដើរមួយជុំស្ទួលខោអាវ ប្រញាប់
ប្រញាល់យកវា ប៉ុន្តែ សារីហ្វ ក៏ដើរចូលមកទាញយកខោអាវទាំងនោះពីដៃ
របស់នាង។

"ហាងនេះឈុតស្អាតជាង"

គេស្រវាចាប់កដៃរបស់នាង ព្រមទាំងចង្អុលហាងទំនើបមកពីបារាំង។

"មិនយកទេវាថ្លៃ ខ្ញុំគ្មានលុយទេ"

"តែបងមាន មោះ របស់កាន់តែថ្លៃ បញ្ជាក់ថាជារបស់ល្អ"

"វាមិនមែនបែបហ្នឹងគ្រប់តែរបស់ទេ"

មិនថាគេនិងនាងដើរទៅខាងណា ក៏មនុស្សរបស់គេធ្វើតួនាទីបើកផ្លូវឱ្យ

ហើយបុគ្គលិកហាងទាំងអស់សុទ្ធតែចេញមកតម្រៀបគ្នាដើម្បីស្វាគមន៍។ គ្រប់

យ៉ាងបញ្ជាក់ថា សារីហ្វ មិនមែនជាមនុស្សធម្មតាទូទៅ ដែលនាងព្យាយាមសួរ

ដែរ ប៉ុន្តែបានចម្លើយត្រឹមថា...

'បងជាអ្នកណាមិនសំខាន់ បងគឺបង'

គេនាំនាងចូលហាងខោអាវទំនើប ដែលខាងក្នុងតុបតែងស្អាត មាន

សម្លៀកបំពាក់ស្អាតៗជាច្រើន និងត្រជាក់ស្រែងដោយម៉ាស៊ីនត្រជាក់ ទើបនាង

ឈរនៅក្នុងនេះយូរបន្តិច ព្រោះពាក់អាបាយ៉ានិងបឺខាយូរហើយ វាថប់ដង្ហើម

និងគិតថាចូលមកមើលលេងប៉ុណ្ណោះ មិនទិញអីទេ ប៉ុន្តែពេលងាកទៅមើលម្តង

ទៀត សារីហ្វ កំពុងតែម៉ៅយករបស់ពីហាងដោយទឹកមុខធម្មតា។

"យកឈុតនេះ ឈុតនេះ ហើយអានេះដែរ"

គេដើរមួយជុំហាង ហើយចង្អុលប្រាប់អ្នកចាត់ការ។

"ឈុតនេះដែរ ពាក់លើស្នួលនោះដែរ រួមទាំងគ្រឿងលម្អទាំងនោះនៅ



ក្នុងទូនោះ"

"ដោយក្តរកវាយ"

អ្នកចាត់ការហាងត្រដុសដៃ ដោយទឹកមុខញញឹម ព្រោះមិនប៉ុន្មាននាទី ក៏អាចរកប្រាក់បានរាប់សែនដុល្លា ទើប អាលិហ្សា ស្ទុះទៅហាមប្រាម និង ប្រញាប់អូសគេចេញពីហាង។

"ខ្ញុំមិនចង់មើលខោអាវទេ ខ្ញុំល្ងីយ ចង់ទៅសម្រាក យើងមានរឿងត្រូវ និយាយគ្នាមិនទាន់ចប់ទៀត"

"អូខេ អាមិ៉ា..."

សារីហ្វ ញញឹមដាក់ ហើយងាកទៅបញ្ជាអ្នកចាត់ការហាង។

"ផ្ញើទៅឱ្យទាំងអស់នៅខាសាន"

"ក្រាបទូល"

ក្បួនរថយន្តរត់នៅតាមផ្លូវថ្នល់ទំហំដប់លែន សំដៅទៅកន្លែងស្នាក់

អាស្រ័យ។ បរិយាកាសនៅក្នុងក្រុង ស្រស់ស្រាយ នៅតាមដងផ្លូវ មានផ្ទះស្អាតៗ ធំៗ និងមានទ្រង់ទ្រាយពិសេសនៅហ្វេសសានប៉ុណ្ណោះ។ ផ្ទះធំៗទាំងនេះ ជារបស់ឈ្មួញ អ្នកជំនួញ ដែលមានបានដោយសារមាសពណ៌ខ្មៅ ប៉ុន្តែស្ថាបត្យកម្មដែលធំល្វឹងល្វើយ និងស្អាតបំផុតនៅទីក្រុងនេះ គឺដំណាក់ខាសាន។

"នេះជាកន្លែងណា ?"

"ផ្ទះរបស់បង"

"ផ្ទះរបស់លោកធំដូចវាំង"

ពេលឡានរត់ចូលមកចតហើយ សារីហ្វ ក៏នាំនាងដើរកាត់ទ្វារធំចូលទៅខាងក្នុង អ្វីដំបូងដែលមើលឃើញ គឺទីធ្លានៅមុខផ្ទះ ម៉ូតព័រសៀ ជាម៉ូតដែលពេញនិយមនៅសតវត្សទី១៦-១៧ តួអគារត្រូវសាងសង់ឡោមព័ទ្ធទីធ្លានេះ ប៉ុន្តែដំណាក់ខាសាននេះ មានទីធ្លាច្រើនកន្លែង សសរមូលៗ ដំបូលកោង មាន



ទ្វារ បង្អួច ដែលលម្អដោយក្បូរក្បាច់យ៉ាងប្រណិត មានសាលតូចធំរាប់មិនអស់

មិនបូកទាំងបន្ទប់អង្គុយលេង បន្ទប់ដេក បន្ទប់ផឹកទឹកតែ និងប្រាកដណាស់ថា

មាន ប៉មដែលសាងលយទៅខាងលើបន្ទាប់ពីដំបូលច្រើនម៉ែត្រ មានតួនាទីមូប

យកខ្យល់ធម្មជាតិដើម្បីចែកចាយមកក្នុងអគារទាំងមូល ព្រមទាំងបណ្តេញ

អាកាសធាតុក្តៅហប់ទៅផ្នែកម្ខាងទៀត ដូច្នេះហើយទើបនៅក្នុងដំណាក់នេះ

ត្រជាក់ល្ហឹមគ្រប់ពេលវេលា។

"យើងនឹងប្រើបន្ទប់តាមរដូវកាល អគារខាងណេះនៅភាគខាងត្បូង តែ

បែរមុខទៅទិសខាងជើង ដើម្បីទទួលពន្លឺព្រះអាទិត្យឱ្យគ្រប់គ្រាន់ ដូច្នេះហើយ

ប្រើអគារផ្នែកខាងណេះ នៅរដូវរងា ពេលចូលដល់រដូវក្តៅ នឹងទៅនៅផ្នែកទល់

មុខដើម្បីគេចពីកម្តៅនៅរដូវក្តៅ តែជួនកាលបើក្តៅខ្លាំង ប៉មបញ្ចូនខ្យល់មកមិន

គ្រប់គ្រាន់ បងនឹងប្រើបន្ទប់ក្រោមដីមួយទៀត"

អាលិហ្សា មើលតាមចង្កុលដៃរបស់គេ និងគិតតែម្នាក់ឯង។

"លោកប្រាប់ខ្ញុំបានហើយឬនៅ ថាលោកជាអ្នកណា លោកពាក់ព័ន្ធអី
នឹងសម្តេចព្រះមាតា ឌីណា មែនទេ ?"

"មែន"

គេដឹកដៃនាងដើរតាមផ្លូវថ្មភក់ ដែលក្រាលដោយព្រំព័រសៀក្រាស់ទន់
ល្មើយ មានក្បូរក្បាច់វិចិត្រ នៅសងខាងតុបតែងដោយរបស់របរប្រើប្រាស់មាន
តម្លៃ ដែលនាងប្រុងឈ្លេចសួរបន្ត ប៉ុន្តែទៅជំពប់ភ្នែកនឹងរូបថតដែលធំមួយជំហ
ខ្លួន ព្យួរនៅកណ្តាលសាល ដោយគេតុបតែងខ្លួនស្អាតរកកន្លែងឱ្យរិះគន់គ្មាន។

"នេះជារូបលោកតើ"

"មែន នេះជាបង បងធ្លាប់សួរអូនថា អូនស្គាល់ហ្ស៊ីកទេ ហើយអូនឆ្លើយ
ថាមិនស្គាល់ ចាំបានទេ"

"ចាំបាន"

"នោះរូបគេ"



"វាជារូបរបស់លោក"

"មែន រូបរបស់បង"

"និយាយស្អីពិបាកយល់ម្ល៉េះ"

នាងចងចិញ្ចើម ព្រោះមិនយល់ ហើយដើរចូលទៅអានអក្សរនៅក្រោមរូបភាព បន្ទាប់មកក៏ងាកមកសម្លឹងមុខគេដោយការភ្ញាក់ផ្អើលបំផុត ខណៈដែលសារីហ្វ អស់សំណើច ប៉ុន្តែនាងមិនសើចជាមួយ ថែមទាំងស្ទុះទៅឈរនៅមាត់ទ្វារដំណាក់ ទះភ្ជាំងៗ ឱ្យបើកទ្វារ ប៉ុន្តែទាហានការពារឈរនឹងថ្កល់ មិនកម្រើក ព្រោះម្ចាស់ដំណាក់ឈរឱបដៃបញ្ជាដោយខ្សែភ្នែកថា បើមានអ្នកណាហ៊ានបើកទ្វារ ជានាថាច្បាស់ជាមានរឿង។

"អានែ បងគឺបង ចូលទៅសម្រាកនៅខាងក្នុងជាមួយបងទៅ"

"មិនទៅ! ខ្ញុំដឹង បើចូលទៅហើយ គ្មានថ្ងៃចេញមកវិញបានទៀត មិនបាច់ម៉ោហៅ ខ្ញុំមិនចង់នៅក្នុងហារេម ខ្ញុំមិនចង់ធ្វើជាប្រពន្ធលំដាប់ទីមួយ ទីពីរ

ទីបី ទីបួនរបស់អ្នកណា ខ្ញុំមិនត្រូវការធ្វើជាស្រីកំណាន់!"

នាងងាកមកសម្លក់សម្លឹងគេម្តងទៀត ខណៈដែល សារីហ្វ គ្រវីក្បាលគិតថានាងអានប្រលោមលោកច្រើនពេកឬអត់។

"លែងទៅ អាមនុស្សឆ្កួត ញញឹមស្អី កំប្លែងណាស់មែនទេដែលបោកខ្ញុំបាន គិតថាខ្ញុំខ្លាចឬ អាហ្ស៊ីកទេវតា"

"ខួរក្បាលក្រឡុកហើយ និយាយមិនចេះស្តាប់គ្នាទៀតហើយ"

"ប្រាប់ថាឱ្យលែង លែងៗៗ"

នាងទាំងរើបម្រះ ទាំងជាក់ ទាំងគ្រវែង មិនព្រមស្តាប់អីទាំងអស់ ទើបគេលើកដាក់លើស្មាម្តងទៀត ដែលនាងទទួលបានមេរៀនហើយថាការត្រូវគេធ្វើបែបនេះ នាងនឹងបង់ខ្លួនប្រាណ ដូច្នេះហើយទើបកាន់តែតស៊ូ ទើប សារីហ្វ ដាក់នាងចុះនិងដឹកដៃឱ្យដើរទៅជាមួយគ្នាពេលនាងក្រាញនៀលក៏ប្រឹងអូសផង ទាញផង។



"បើនៅតែរឹងទទឹងទៀត បងនឹងចាត់ការម្តងទៀត"

"សាកមើលទៅ មិនបាច់ម៉ោធ្វើភ្នែកផ្លេកៗដាក់ទេ ខ្ញុំមិន..."

នាងប្រុងជេរ តែសុខៗក៏ងងឹតមុខ ប្រហែលមកពីឈុតអាបាយ៉ា និង

ស្បែឃ្មុំមុខបីខាដែលវាពិបាកដកដង្ហើម ទាស់ត្រង់ថានាងមិនព្រមបង្ហាញភាព

ទន់ជ្រាយឱ្យឃើញ ទើបធ្វើចិត្តរឹងមាំ តស៊ូ ខណៈនោះក៏ឱ្យ សារីហ្វ ឱបស្មា នាំ

ដើរកាត់បន្ទប់ស្អាតៗ ខណៈនោះអ្នកបម្រើក៏នាំគ្នាមើល។

"បងមានប្រពន្ធតែម្នាក់គត់ គឺអូន គ្មានប្រពន្ធពីរបីបួន គ្មានស្រីកំណាន់"

អាលិហ្សា មិនមាត់ តែទៅជាអណ្តឹតអណ្តក។

"មានអ្នកណានិយាយអីឱ្យអូនមិនសប្បាយចិត្ត ប្រាប់បងម៉ោ"

"គឺពេលដើរនៅបាសារ៍..."

នាងជូតទឹកភ្នែកចេញភ្លាម មិនចង់យំឱ្យគេឃើញ។

"មានមនុស្សខ្សឹបខ្សៀវថាខ្ញុំជាស្រីកំណាន់ គ្មានកេរ្តិ៍ខ្មាស ខ្ញុំចង់តែចូល

ទៅទៈកំផ្លៀងតែខ្ញុំធ្វើមិនបាន ព្រោះវាជារឿងពិត ខ្ញុំមិនអាចប្រាប់មនុស្សទាំង

នោះ បានថាខ្ញុំត្រូវជាអ្វីនឹងលោក ខ្ញុំគ្រាន់តែជាស្រីចិត្តងាយដែល...ណ្ហើយចុះ

ខ្ញុំជាជនជាតិបរទេស ជាអ្នកក្រៅ ខ្ញុំក៏មានកិត្តិយសរបស់ខ្ញុំដែរ សារីហ្វ"

"និយាយប្រយោគដែលបងបង្រៀនអូនឱ្យស្តាប់បន្តិចម៉ោ"

"សារីហ្វ...ជាសៅជុនរបស់ខ្ញុំ"

ម្ចាស់ឈ្មោះ ស្តាប់ហើយងក់ក្បាល។

"លើកក្រោយឱ្យចូលទៅទៈមាត់ពួកអស់នោះ ហើយនិយាយប្រយោគ

នេះ"

"ខ្ញុំប្រាប់លោកហើយតើថាខ្ញុំនៅទីនេះមិនបាន លោកមិនដែលស្តាល់ខ្ញុំ

ផង ខ្ញុំទៅផ្ទះវិញ"

"ស្រែកចង់ទៅផ្ទះដូចកូនក្មេងអាយុបីឆ្នាំ ក្រែងថាបើអ្នកណារត់ អ្នកនោះ

ជាកូនឆ្កែនោះអី"



គេស្រវាចាប់ដើមដៃរបស់នាងទាញតិចៗ ឱ្យមកបុកនឹងដើមទ្រូងធំ ទូលាយ ហើយស្រវាឱបចង្កេះ រឹតកាន់តែណែន ព្រមទាំងឱនមកខ្សឹបដាក់ត្រចៀក ដោយលួចស្រង់យកក្លិនក្រអូប។

"គិតថា *ស៊ី* ហ្សីកនៃមីឌីសហើយ ក៏រត់ទៅបាត់ដោយមិនទទួលខុសត្រូវបានអីចឹងឬ"

គេដឹងថានាងត្រូវតែរឹងទទឹងដាក់ ប៉ុន្តែ អាលិហ្សា បែរជាឈរស្ងៀមព្រោះវិលមុខ បន្ទាប់មកក៏ផ្ងារក្រោយ ប៉ុន្តែសំណាងល្អ ដែលគេឱបជាប់ ហើយស្រែកហៅអ្នកបម្រើ។

អាលិហ្សាភ្ញាក់ដឹងខ្លួននៅក្នុងបន្ទប់ដេកដ៏ប្រណិតរៀបចំទៅដោយមាសនៅក្នុងដំណាក់ផ្កែកស្ត្រី ទើបនាងបានដឹងថាខ្លួនឯងដេកលក់ ព្រោះជាតិថ្នាំនិងព្រោះល្វីយ ដែលសន្សំអស់រយៈពេលមួយយប់មួយថ្ងៃ ក្រុមស្រីបម្រើក៏នាំគ្នាចូលមកគោរព និងតម្រង់ជួរគ្នាចូលមកថើបថ្ពាល់តាមប្រពៃណីរាក់ទាក់របស់

រាជវង្ស នោះមានន័យថា នាងត្រូវប្រកាសជា *អាមិ៉ា ហឺ រ៉ូយ៉ាល់ ហៃនេស ព្រះជាយារបស់បុត្រា សារីហ្វ អាល់ មីឌីស ព្រះអនុជនៃ ហ្ស៊ីក ហ្វារីស អាល់ មីឌីស* ប្រមុខប្រទេសមិឌីសរួចរាល់ទៅហើយ។

បន្ទប់ធ្វើការរបស់ សារីហ្វ អាល់ មីឌីស វ៉ាលិសនៃហ្វេសសានស្ថិតនៅ លើអគារកម្ពស់មេឃ ដែលអាចមើលឃើញការដ្ឋានខួងប្រេង និងឈូងសមុទ្រ មាននាវាដឹកប្រេងចេញចូល។ នៅក្នុងបន្ទប់ធំ ដែលបំពាក់ទៅដោយបច្ចេកវិទ្យាទាន់សម័យ តុបតែងដោយសិល្បៈរួមព័រសៀ មើលទៅស្អាត ម្ចាស់បន្ទប់កំពុងឈរមើលទស្សនីយភាពនៅខាងក្រោមដៃម្ខាងក្រព័ទ្ធទៅក្រោយដាក់ត្រឹមចង្កេះ ពាក់អាវគ្រែរហ្សពណ៌ប្រផេះ ខណៈនោះសញ្ញាណនៅលើបូតុងពណ៌ក្រហមលើតុធ្វើការឈើម៉ាហកកានី ក៏ផុះពន្លឺ បញ្ជាក់ថាមានមនុស្សត្រូវការនិយាយជាមួយគេ។



(គិតថាឯងប្រហែលឃើញកាសែតនោះហើយ យើងមានរឿងត្រូវ
និយាយគ្នា)

សារីហ្វ ទទួលបានការទាក់ទងតាមអនឡាញន៍ពីហ្សឹក ហ្វារីស ដែលជា
បងប្រុស ឧបករណ៍ភ្ជាប់នឹងសញ្ញាណបញ្ចាំងរូបភាពលើអេក្រង់ ឆាប់រហ័ស
បង្ហាញទិដ្ឋភាពបន្ទប់ធ្វើការដ៏ទំនើបពីផ្នែកម្ខាងទៀត។

គេមិនធ្លាប់មានអារម្មណ៍ថាខ្លួនឯងជាក្មេងពាលបែបនេះទេ តាំងពីកើត
មក ខណៈនោះក៏ដាក់បង្គុយចុះ ចំណែកបងប្រុសឈរផ្អែកនឹងតែមតុ ព្រមទាំង
ជក់ហ្សឹកាដោយទឹកមុខមិនសូវល្អ។

(ប្រាប់យើងបន្តិចបានទេថាមានអីកើតឡើង ហេតុអីយើងដឹងរឿង
មង្គលការរបស់ឯងក្រោយកាសែតខ្សឹបខ្សៀវអស់នេះ សម្តេចម៉ែមិនពេញ
ព្រះទ័យជាខ្លាំង)

នៅលើតុរបស់ហ្សឹក សារីហ្វ មានកាសែតថេបឡយល្បីឈ្មោះ នៅក្នុង

នោះមានរូបរបស់ សារីហ្វ អាល់ មីឌីស បុត្រាដែលមើលការខុសត្រូវការនាំ
ចេញ ប្រេងដ៏ធំរបស់ពិភពលោកកំពុងតែដឹកដៃស្រីស្បែកសផូរផង់ ចំណែករូប
មួយទៀត គឺ អាលិហ្សា ខណៈដែលនាងកំពុងតែដោះបឺខាចេញ ហើយកាសែត
ក៏ដាក់ចំណងជើងច្បាស់ៗថា *ស្នេហារបស់ព្រះបុត្រានៃមីឌីស និងស្រីអាស៊ី
ស្រឡាញ់ ឬលង់*។

កាសែតមួយច្បាប់នេះ លក់តែរឿងរ៉ាវស្នេហា ចំណង់តណ្ហារបស់រាជវង្ស
តារា សេដ្ឋី អ្នកមាន អ្នកនយោបាយទូទាំងពិភពលោក។ មីឌីស ទើបតែបើក
ប្រទេស ទើបខ្សែភ្នែករបស់ពិភពលោកចាប់អារម្មណ៍ពីរនាក់បងប្អូន រាជាមាស
ខ្មៅនៃមជ្ឈឹមបូព៌ា ពិភពលោកចាប់អារម្មណ៍គ្រប់យ៉ាងដែលពួកគេពីរនាក់
បងប្អូនធ្វើ រួមទាំងកំពុងតែរង់ចាំមើលថា ស្ត្រីម្នាក់ណាបានឡើងជាព្រះជាយា
ដោយខ្លឹមសារនៅក្នុងនោះ សរសេរថាស្រីស្អាតម្នាក់នេះ ជាស្រីបម្រើនៅក្នុងវាំង
និងបម្រើនៅលើគ្រែទើបទទួលបានការតែងតាំងខ្លឹមសារដែលពួកនោះសរសេរ



កំពុងតែធ្វើឱ្យ អាលិហ្សា ខូចខាត។

"ទូលបង្គំមិនឱ្យតម្លៃទៅលើព័ត៌មានទាំងនោះទេក្រាបទូល"

(យើងមិនព្រមឱ្យមានរឿងខូចខាតអីទាំងអស់កើតឡើង ពួកប្រមាញ់រូបថត គិតតែរកព័ត៌មានអាស្រូវទៅលក់ សម្តេចព្រះមាតាឃើញព័ត៌មានហើយទ្រង់ចង់ជួប មីស ឈិន ម្តងទៀត)

បងប្រុសលើកចង្កុលដៃអាករ ប្រាប់ដោយប្រយោលថា រឿងនេះដឹងតែលំបាក។

អាលិហ្សា គ្រាន់តែជាស្រីមាឌល្អិតដែលគ្មានផ្លូវតស៊ូ នាងមិនខ្លាំងដូចកូនស្រីសេដ្ឋីៗ ឬតារាៗដែលមានព័ត៌មានហើយ នៅតែសើចចូលចិត្តដែលខ្លួនឯងមានរឿងអាស្រូវ។

(អ្នកកាសែតច្បាស់ជាតាមប្រមាញ់នាង)

"ទូលបង្គំដឹង"

គេស៊ាំនឹងការដែលមានអ្នកដទៃចាប់អារម្មណ៍ ប៉ុន្តែម្តងនេះវាធ្វើឱ្យខឹង
មែនទែន។ បងប្រុសរបស់គេ មានភាពជាអ្នកដឹកនាំ និងសម្រេចចិត្តដាច់ខាត
តាមសញ្ជាតិញ្ញាណអ្នកដឹកនាំដែលវាគួរឱ្យខឹងដែលបងប្រុស យករឿងនេះមក
ដាក់សម្ពាធ។ ត្រឹមគិតថា នាងត្រូវក្លាយជាជនរងគ្រោះ សាច់ដុំទាំងអស់នៅលើ
ដងខ្លួនក៏ឡើងរឹងកំព្រឹស កែវភ្នែកក៏ដូចគ្នា តែបើមានអ្នកណាហ៊ានប៉ះពាល់ ឬ
ធ្វើអី អាលិហ្សា គេនឹងសម្លាប់វា។

(ឯងទទួលយកស្រីម្នាក់នោះ ទាំងដែលដឹងថានឹងមានបញ្ហា)

"នាងមិនមែនបញ្ហា នាងជាភរិយារបស់ទូលបង្គំ ហើយទូលបង្គំមាន
សេរីភាពក្នុងការជ្រើសរើស"

សារីហ្វ បញ្ជាក់ដោយទឹកមុខមាំ ធ្វើឱ្យ ហ្វារីស ស្មានមិនដល់ទេថា
ប្អូនប្រុសចិត្តដាច់យ៉ាងនេះ។

"អ្វីដែលទូលបង្គំសម្រេចចិត្តរួចទៅហើយ គ្រប់យ៉ាងនឹងដំណើរការតាម



នោះ"

(តាមចិត្តឯងចុះ តែចាំទុក បើឯងចាត់ការរឿងនេះមិនបាន យើងនឹង

លូកដៃទៅចាត់ការ)

ហើយសញ្ញាណក៏ត្រូវកាត់ផ្តាច់។

កម្រាលពូកស្បែកពពែ ទន់ល្មើយ ធ្វើឱ្យនាងសឹងតែលិចបាត់ទៅក្នុង

នោះ...

អាមិរ៉ានៃហ្វេសសាន ក្លាយជាប្រធានបទព័ត៌មានដ៏ល្បីកក្រើកនៅក្នុង

សង្គមជាន់ខ្ពស់។ ប្រាកដហើយ ស្រីបរទេស សាសនាផ្សេងគ្នា ឯកសារជាប់ខ្លួន

ក៏គ្មាន លុយក៏គ្មាន រឿងតែមួយគត់ដែលធ្វើបាន គឺអង្គុយស្ងៀម ត្រឹមកម្រើកក៏

មានស្រីបម្រើងើបតាម ដែលវាជាសញ្ញាថានាងត្រូវឃុំឃាំងដោយស្ងប់ប្រវត្ត។

បើគេគិតថារឿងប៉ុណ្ណឹងអាចឃុំឃាំងនាងបាន ប្រាប់ឱ្យដឹងទៅចុះថា

នាងមិនព្រមអង្គុយយំខ្សឹកខ្សួល ធ្វើជាតួឯកស្រីក្នុងរឿងប្រលោមលោក ដូច្នេះ ហើយ រឿងដំបូងដែលត្រូវធ្វើ គឺរកមើលផ្លូវរត់។

អគារធំៗ ត្រូវសាងសង់ និងតុបតែងដោយសិល្បៈព័រសៀដែលនាងជាម្ចាស់មានភ្នែកមានត្រចៀកចាំឃ្លាំមើលគ្រប់ពេលវេលាជញ្ជាំងដំណាក់ខ្ពស់កប់ពពក អ៊ូ នៅមានអាងហែលទឹកស្អាតក្នុងសួនដែរ បន្ទប់អង្គុយលេងធំដែលនាងប្រើពេលសម្រាក មានទូរទស្សន៍ទំហំធំ ទាន់សម័យ ប៉ុន្តែកម្មវិធីទូរទស្សន៍ជាភាសាអារ៉ាប់ នាងមិនចង់មើល ប៉ុន្តែពួកស្រីបម្រើ សុំព្រោះចូលចិត្តមើលទូរទស្សន៍ណាស់ ដែលយ៉ាងហោចណាស់ ពួកស្រីបម្រើក៏អាចនិយាយភាសាអង់គ្លេសបានល្អ អាចជួយឱ្យនាងមានអារម្មណ៍មិនកណ្តោចកណ្តែងពេក និងជួយបកប្រែឱ្យស្តាប់ ឬមិនអីចឹងក៏បបួលនិយាយ ទើបនាងឆ្លៀតឱកាសនោះរៀនភាសាដែរ។

"ពេលចង់ទៅទិញរបស់ ទៅកន្លែងណា ទៅយ៉ាងម៉េច ?"



"មានស៊ុបពើម៉ាយីត និងហាងទំនិញដែលទើបតែបើកថ្មីព្រះម៉ែម្ចាស់

និងទៅបាសារ៍ មានអ្នកបើកបរជូនទៅ ពេលនេះទ្រង់ជាចៅហ្វាយផ្ទៃកស្ត្រី

ហើយ បើទ្រង់ត្រូវការស៊ិបតីងគឺអាចទៅបាន ប៉ុន្តែព្រះបុត្រាបញ្ជាថាត្រូវជូន

ដំណឹង ដើម្បីសុំឱ្យទ្រង់អនុញ្ញាតជាមុនគ្រប់ពេល ព្រះម៉ែម្ចាស់"

យឺស! ចេញបញ្ជាផង!

"ហើយបើរបស់ដែលចង់បានគ្មានលក់នៅទីនេះ?"

"ទ្រង់កុម្ម៉ង់បាន នឹងមានអ្នកចាត់ការឱ្យយ៉ាងឆាប់រហ័ស ព្រះម៉ែម្ចាស់"

"មិនបានទេ បើខ្ញុំធុញ គឺត្រូវរកកន្លែងស៊ិបតីងថ្មីៗខ្លះ ឧបមារថាបើខ្ញុំទៅ

ស៊ិបតីងនៅក្នុងរាជធានី បើ សារីហ្វ អនុញ្ញាត ខ្ញុំទៅបាន ត្រូវទេ?"

"ព្រះម៉ែម្ចាស់ បើទ្រង់ត្រូវការហោះហើរទៅស៊ិបតីងនៅកន្លែងណា សូម

ជូនដំណឹង ព្រះបុត្រាទ្រង់នឹងប្រទានយន្តហោះផ្ទាល់ខ្លួនឱ្យទ្រង់ប្រើប្រាស់

ព្រះម៉ែម្ចាស់"

អាលិហ្សា ស្តាប់ហើយ ក៏បើកភ្នែកធំៗភ្លាម។

"ភាគច្រើនគេហោះហើរទៅណា ?"

"សូដង់ ឌូបៃ អ៊ីតាលី ឡុនដុន ប៉ារីស ឬទីណាក៏បាននៅក្នុងលោកនេះ ព្រះម៉ែម្ចាស់ ព្រះបុត្រាបញ្ជាថា អាមិរ៉ា ចង់ទៅណាក៏បាន តែត្រូវប្រាប់ឱ្យដឹងជាមុនព្រះម៉ែម្ចាស់"

អ្នកបម្រើម្នាក់និយាយឱ្យស្តាប់ថា ព្រះបុត្រាខ្វល់ខ្វាយខ្លាំងណាស់ វិជ្ជបណ្ឌិតផ្ទាល់របស់ព្រះអង្គត្រូវតាមមកជាបន្ទាន់ និងត្រូវបញ្ជាក់ដល់ទៅបីដង ទើបទ្រង់ទុកចិត្តព្រមត្រឡប់ទៅវិញធ្វើឱ្យពួកនាងសើចខឹកៗពេលអធិប្បាយឱ្យអាលិហ្សា ស្តាប់ថា មានកម្មករនៅក្នុងដំណាក់ជាជនជាតិកូរ៉េ និងប្រាប់ឱ្យព្រះអង្គបានដឹងពីអត្ថន័យនៃពាក្យថា អានែ ទ្រង់ញញឹមពព្រាយ ថែមទាំងប្រទានរង្វាន់ឱ្យច្រើនទៀតផង។

អ៊ុំយ! គួរឱ្យខ្មាសគេណាស់!



អាលិហ្សា ស្រែកនៅក្នុងចិត្តលេងខ្លាំងៗ និងធ្វើឫកធម្មតា ទាំងដែលមុខ
កំពុងក្តៅភាយៗ។ ឈុតដែល សារីហ្វ ត្រៀមឱ្យនាងពាក់ វាស្អាតហាក់ដូចនៅ
ក្នុងក្តីស្រមៃ សាច់ក្រណាត់ពណ៌សស្តើង ប៉ាក់ឱនពណ៌ប្រាក់ បញ្ចេញពន្លឺផ្លេកៗ
ពាក់គ្រឿងលម្អគុជខ្សងសមុទ្រខាងត្បូង ជាខ្សែកត្បូតគ្នាប្រាំមួយជាន់ ស្បែក
ជើងកែងខ្ពស់មានខ្សែចងកជើង ធ្វើឱ្យនាងស្អាត ហាក់ដូចផ្លាយចេញពីរូបគំនូរ
នៅក្នុងសម័យវីតូរៀ ទោះនាងអង្គុយស្ងៀម ក៏អាចទាក់ទាញខ្សែភ្នែកគ្រប់គ្នាឱ្យ
សម្លឹងមើលមកបានដែរ។

នាងមិនចូលចិត្តនៅស្ងៀម ទើបទៅជាធុញទ្រាន់ ធ្វើបានត្រឹមតែមើល
សួន ដែលមានផ្លូវដើរទៅក្នុងវាលកុលាប ម្លិះ និងមានទឹកជាញ់ ដែលមានរូប
បដិមាដ៏វិចិត្រលម្អ។

ខណៈដែលស្រីបម្រើកំពុងតែជួយផាត់មុខធ្វើសក់ឱ្យ សារីហ្វ ក៏ដើរចូល
មក មើលតាមរយៈគ្រែហ្សសកលដែលគេពាក់ហើយ នាងសន្និដ្ឋានបានថាគេ

ទើបតែត្រឡប់មកពីធ្វើការ។

ហ៊ឹស! គិតថាជាព្រះបុត្រា ជាទេវបុត្ររូបសង្ហា ជាអ្នកមានហើយ នាង

ព្រមទន់ចិត្តឬ ដេកចាំទៅ!

"អ្នកណាធ្វើឱ្យខឹងទៀតហើយ ប្រាប់បងម៉ោ"

"គ្មានទេ"

"និយាយមិនពីរោះ តិចត្រូវទះកំប៉ះគូទ"

"សាកមើល៍ ខ្ញុំម្ចាស់នឹងកាត់អាញ៉ក់ទៅដំឱ្យសំប៉ែត"

"ចេញទៅ យើងត្រូវការនៅជាមួយអាមិ៉ា"

"ព្រះពរ"

ស្រីបម្រើទាំងឡាយមិនទាន់បានងើបចេញទៅណាផង គេក៏ដើរមក

អង្គុយបៀត ពេលនាងខិតចេញ គេក៏ខិតទៅតាម ថែមទាំងក្រសោបឱបជាប់

ហើយពេលឃើញនាងធ្វើមុខខ្ឹរ តែថ្ពាល់ក្រហមងាំង ក៏ឱនមកថើបថ្ពាល់។



"ត្រជាក់ចិត្តដល់ហើយ"

"អ៎! អ្នកណាប្រាប់ឱ្យថើបថ្ពាល់"

"អីចឹងឱ្យធ្វើអីទៅ យកបែបដែលអារម្មណ៍ល្អបំផុត ល្អណាណី ល្អទេ ញ៉ក់ៗចង់រកកន្លែងកក់ក្តៅជ្រកហើយ"

"កុំម៉ោធ្វើខ្លួនត្រេកកាមនៅម្តុំនេះ កុំម៉ោចាប់"

អាលិហ្សា ខឹងដល់ថ្នាក់ចង់បែកទ្រូងស្លាប់ ចង់ជេរជាសាធារណៈក៏ជេរមិនបាន ព្រោះហានៈរបស់គេគឺជាក្រោះការពារដ៏ល្អ ទើបបានត្រឹមតែសម្លក់សម្លឹង ហើយងាកឆ្វេងងាកស្តាំ ឃើញផ្លែប៉មស្រស់នៅក្នុងកញ្រ្ជែងផ្លែឈើ ក៏ស្រវាយកវា ហើយយកកាំបិត មកឆ្លាក់លើផ្លែប៉ម ចេញជារូបមនុស្ស ហើយយកមកដាក់ពីមុខ សារីហ្វ បន្ទាប់មកក៏និយាយជាមួយផ្លែប៉ោម ហៅវាថាអាចោរប្លន់ព្រហ្មចារីយ គ្មានចិត្តស្មោះ អាព្រះបុត្រាផ្លែប៉ោមរលោងពណ៌ផ្កាឈូក គិតឬថាពេលប្រាប់ការពិតថាខ្លួនជាអ្នកណាហើយ មនុស្សស្រីនឹងស្រែកគ្រឺត អ៊ូយ! ចិត្ត

ស្មោះមានដែរទេ គ្មានទេ មានតែភាពត្រេកកាម គ្មានក្រមសីលធម៌ បោកប្រាស់
មនុស្សស្រីឱ្យមកធ្វើជាទាសករបម្រើតណ្ហា ហាឡ្ង នេះជាសម័យកាលអីហើយ
លោកផ្លែប៉ោម។

នាងជេរប្រទេច វែងដូចកន្ទុយថ្លែន បែបអ្នកថ្លៃថ្នូរជេរ ប៉ុន្តែបែរជាធ្វើឱ្យ
សារីហ្វ អស់សំណើច ទាញផ្លែប៉ោមនោះមកច្របាច់ឱ្យខ្ទេចក្នុងដៃ។

"ពូកែជេរបែបនេះ ត្រូវតែអប់រំ"

"ខ្ញុំម្ចាស់និយាយជាមួយផ្លែប៉ោម ពាក់ព័ន្ធអីដែរ"

ប្រពន្ធធ្វើសំឡេងក្អរៗដាក់ ទើបគេបញ្ចេញកម្លាំងតែបន្តិចប៉ុណ្ណោះ ឱ្យ
នាងមកអង្គុយលើភ្លៅ ទោះនាងប្រឹងរើបម្រះយ៉ាងណា ក៏មិនរបូត មានតែត្រូវគេ
ឱបរឹតថែម ហើយភ្ញើយចង្កាឱ្យងើយមុខមករក។

"បងប្រកាសរួចហើយថាបងរៀបការជាមួយអូន ហ្សឺក ហ្វារីស បងប្រុស
របស់បងមិនពេញចិត្តជាខ្លាំង ដែលបងប្រាប់ឈ្មោះកូនក្រមុំមិនបាន"



"ខ្ញុំម្ចាស់...ស្ដី...ស្ដី"

នាងច្របូកច្របល់ រៀបរៀងគំនិតមិនត្រូវ។

"យើងរៀបការពីអង្កាល់"

"យប់...នៅជំរុំបេឌូអ៊ីន"

"តែនោះ..."

"អ្នកនៅទីនោះជាសាក្សីឱ្យបងបាន ហើយបងចាត់ទុកថារាត្រីនោះជា កិច្ចសន្យាជានិរន្ដ៍ មង្គលការរបស់យើងនឹងពេញលក្ខណៈតាមច្បាប់ពេលប្រាប់ ឈ្មោះរបស់អូនឱ្យផ្នែកសាសនាដឹង ឯកសារផ្ទាល់ខ្លួនរបស់អូនបាត់ពេលជួប ព្យុះសមុទ្រខ្សាច់ បងទាក់ទងទៅស្ថានទូតតែវ៉ាន់ហើយ ប៉ុន្តែអ្នកដែលទទួល ខុសត្រូវរឿងនេះត្រឡប់ទៅតែវ៉ាន់បាត់ទៅហើយ អូននេះ អាថ៌កំបាំងពេកហើយ អានែ"

គេហៅនាង មានចេតនាបង្អួសសំឡេងយ៉ាងពិរោះ ដែលធ្វើឱ្យនាងព្រឺ

"កុំម៉ោភគេ បើភាគីម្ខាងទៀតមិនដឹងអី មិនយល់ព្រម គ្រប់យ៉ាងត្រូវ ចាត់ទុកជាមោយៈ សុខៗមកចាត់ការគេបែបនេះ វាមិនយុត្តិធម៌ ខ្ញុំម្ចាស់មិនត្រូវ ការធ្វើជារបស់ព្រះអង្គ យល់ទេ ខ្ញុំម្ចាស់ធ្វើជាខ្លួនរបស់ខ្ញុំម្ចាស់"

"ពេលអូនថ្ងូរលើទ្រូងបង បងគិតថាអូនព្រមមួយរយភាគរយហើយ អានែ"

គេផ្ទឹបថ្ពាល់របស់ខ្លួន នឹងថ្ពាល់រលោង ត្រជុសតិចៗ ឱ្យនាងរសើប និង ថ្នមចថ្ងូរតិចៗ ហើយចំហាយក្តៅដែលជ្រាបតាមសាច់ក្រណាត់ ក៏ធ្វើឱ្យចង្វាក់ បេះដូងរបស់នាងលោតញាប់ ប៉ុន្តែព្យាយាមតតាំង ធ្វើជាមិនចាប់អារម្មណ៍ ទាស់ត្រង់ថាពេលគេប្រដេញដៃតាមសាច់ក ក៏ធ្វើឱ្យនាងភ្ញាក់ក្រញាង ហាក់ ដូចមានអណ្តាតភ្លើងរត់កាត់ មុខឡើងក្រហមងាំង។

"ថ្ងៃនេះអូនស្អាតដល់ហើយ"



អាលិហ្សា សម្លក់សម្លឹង ស្អាតស្អី មិនបាច់ម៉ោនិយាយពីរោះទេ ប៉ុន្តែគេ
ប្រឹងធ្វើមុខស្មើ ខណៈនោះកំពុងតែប្រឹងទប់សំណើចស្ទើរស្លាប់ ព្រោះមនុស្សស្រី
ស្អីក៏មិនដឹង ធ្វើភ្នែកក្តាម លៀនចេញមកក្រៅបានគួរឱ្យស្អប់មែនទែន។

"ប្រាប់ឈ្មោះរបស់អូនឱ្យបងស្គាល់ផងបានទេ អានែ"

"ចាប់អារម្មណ៍ធ្វើអី ថាខ្ញុំម្ចាស់អ្នកណា នែ៎! ប្រាប់ថាកុំម៉ោចាប់ កុំគិតថា
ណែនាំខ្លួនឯងថាជាព្រះបុត្រាហើយខ្ញុំម្ចាស់នឹងមិនហ៊ានផេរ"

"រឹងក្បាលណាស់"

គេញញឹមចុងមាត់ ឆ្នាសបែបនេះហើយទើបល្អ តាមធម្មតាបើមាន
នរណា មកធ្វើហំដាក់គេបែបនេះ គេនឹងចាត់ការវិញមិនខាន ប៉ុន្តែបើជា អានែ
ទោះផេរយ៉ាងណាក៏គេមានអារម្មណ៍ថា ស្តាប់ទៅឱ្យអារម្មណ៍ភ្លើតភ្លើន។

"មិនត្រឹមតែស្អាតទេ សំឡេងផេរក៏ពីរោះ ផេរទៀតទៅ អានែ បង
ចូលចិត្ត"

គេអូសបាតដៃតាមដៃរបស់នាង មកដល់ម្រាមដៃដែលពាក់ចិញ្ចៀន ពេជ្រ ហើយលើកថើប និងញញឹម ខណៈនោះក៏អង្អែលថ្ពាល់ក្រហម បបូរមាត់ ពណ៌ផ្កាឈូក ច្រមុះស្អួច និងភ្នែកគួរឱ្យស្រឡាញ់។

"អូនជារបស់បងតាំងពីពាក់ចិញ្ចៀនមួយវង់នេះម្ល៉េះ ព្រោះនេះជាចិញ្ចៀនមង្គលការដែលសម្តេចព្រះមាតា រក្សាទុកដើម្បីប្រគល់ឱ្យកូនក្រមុំរបស់បង បងអស់សំណើចស្ទើរស្លាប់ ពេលអូនញេញចង្អុមគំរាមបង"

"ដោះឱ្យវិញក៏បាន ខ្ញុំម្ចាស់មិនយកទេ បើភាគីទាំងសងខាងព្រមព្រៀងរស់នៅជាមួយគ្នា ទើបគេហៅថារៀបការ តែបើបង្ខំ គេហៅថា..."

នាងខំរកនឹកដែរ តែរកនឹកមិនចេញ។

"ហៅថាអី?"

"គឺហៅថាអីចឹងឯង"



"ពូកែឆ្លើយយករួចខ្លួនមែន មើលចុះ ធ្វើមុខគគ្រិចទៀតហើយ"

"អ៉ែ!"

"សរសើរថាស្អាតមិនចូលចិត្ត អីចឹងសរសើរថាគគ្រិចទៅចុះ អាមិ៉ា បង ប្រគល់បេះដូងឱ្យអ្នកណាហើយគឺប្រគល់ឱ្យ បើមិនបានគិតអីមកលើបងមែន ហេតុអីពេលនោះប្រាប់ឱ្យបងហៅអូនថា អានែ"

"គឺឈ្មោះ អានែ ទើបឱ្យហៅ អានែ ប្លែកមែន ឈប់ម៉ោប្លូទៅ នែ៎...កុំ"

នាងធ្វើមាត់ស្រួចដាក់ ប៉ុន្តែពេលត្រូវថើបថ្ពាល់មួយខ្សឺតទៀត ក៏ធ្វើធឺះដាក់ ខណៈដែល សារីហ្វ ឱបក្រសោបនាងដោយការថ្នាក់ថ្នម និងឱនទៅថើបបបូរមាត់ ជ្រែកអណ្តាតចូលទៅដួសដងយករសជាតិ។

ភាពទន់ភ្លន់របស់គេ ធ្វើឱ្យនាងមិនអាចបដិសេធបាន ទើបបិទភ្នែកបង្ហើបបបូរមាត់ឱ្យ។ បុរសម្នាក់នេះគឺជាតំណាងសមុទ្រខ្សាច់ដ៏ក្តៅគគុកពោរពេញដោយថាមពល និងទាក់ទាញបំផុត។

គេថើបសព្វមុខស្រស់ស្អាត ថើបហើយថើបទៀត ឱ្យនាងញ័រខ្លួន គ្រប់

គ្រងខ្លួនឯងមិនបាន តែការប្រាថ្នាកំពុងតែត្រូវរត់ ភាពស្រៀវស្រើបហូរសឹប

ពេញរាងកាយ ធ្វើឱ្យបេះដូងលោតញាប់។

"សម្រាកឱ្យស្បើយចិត្តនៅទីនេះមួយរយៈ ចាំបងនាំអូនត្រឡប់ទៅ

រាជធានី ទៅជួបហ្ស៊ីក ហ្វារីស និងសម្តេចព្រះមាតាជាមួយគ្នា"

"សម្តេចព្រះមាតា ឪណា..."

"មែន បងចង់ឱ្យសម្តេចព្រះមាតាឃើញថាបងជ្រើសរើសនារីម្នាក់នេះ

ជាភរិយា ទ្រង់តឿនឱ្យបងរៀបការឆាប់មានចៅឱ្យព បងរៀបការហើយ តែចៅ

វិញ...ត្រូវឱ្យអូនជួយ"

"នេះចង់បានកូនទាំងដែលមិនស្គាល់ឈ្មោះខ្ញុំម្ចាស់នេ៎ះ ព្រះពរ?"

"បងកំពុងរង់ចាំឱ្យអូនមេត្តាបងនេះអី ប៉ុន្តែបងពេញចិត្តហៅអូនថា

អានែ"



គេប្រដេញម្រាមដៃលើថ្ពាល់ក្រហម ស្ទាបអង្អែលស្មាតូចស្តើងទាំងសង

ខាង ត្រឹមប៉ុណ្ណឹង នាងក៏ទន់ជើង ឱ្យគេឱបក្រសោប និងថើបបន្ត។

នាងថ្ងូរតិចៗ ញាប់ញ័រខ្លួន ពេលគេដកបបូរមាត់ចេញ ប៉ុន្តែវិនាទីបន្ទាប់

មក ក៏ត្រូវថើបម្តងទៀត ដែលនាងខំដកដង្ហើមឱ្យត្រូវចង្វាក់ និងលើកដៃឱបក

របស់គេ ព្រោះគ្មានកម្លាំងកំហែង ហើយថ្ពាល់ឡើងក្តៅពេលសម្លឹងឃើញ

ចិញ្ចៀនពេជ្រចាំងពន្លឺ លើម្រាមដៃរបស់ខ្លួន។ គេប្រកាសថានាងជាព្រះជាយា

ហើយក៏ពិតមែន ប៉ុន្តែតែងតែមានការដាក់សម្ពាធពីរាជដំណាក់។

"កុំខ្លាច" គេនិយាយហាក់ដូចដឹង ទើបនាងងើយមុខមកប្រសព្វភ្នែក

ជាមួយ។

"មិនបានខ្លាចទេ"

"អូនខ្លាច បងដឹង ស្មារបស់អូនញ័រដូចពេលដែលជាប់នៅក្នុងព្រុះខ្សាច់"

"ខ្ញុំម្ចាស់ចង់បានសេរីភាព...សារីហ្វ សុំមេត្តា ទ្រង់ឃុំឃាំងខ្ញុំម្ចាស់រហូត

មិនបានទេព្រះពរ"

"អានែ...បងមិនធ្លាប់ឃុំឃាំងអូន សុំត្រឹមឱ្យអូននៅក្បែរបង...រហូត"

គេឱបក្រសោបនាងជាប់ដើមទ្រូង ភាពកក់ក្តៅរបស់គេ ដែលប្រគល់ឱ្យ ធ្វើឱ្យនាងមិនអាចបដិសេធបាន។

"ខ្ញុំម្ចាស់មិនទាន់បានយល់ព្រមធ្វើជារបស់ព្រះអង្គម្ចាស់ទេ"

នាងបញ្ជាក់ តវ៉ាឱ្យគេថយចេញ។

"មិនទាន់ឆ្លើយនៅពេលនេះក៏បាន ត្រឹមថ្ងូរឱ្យស្តាប់សិនទៅបានហើយ"

រាងកាយរបស់គេរឹងមាំ មានថាមពល ក្តៅគគុកហាក់ដូចអណ្តាតភ្លើង គ្រប់ផ្នែកតែម្តង ដុតរាងកាយរបស់នាងឱ្យឆេះខ្លាំងចង់ផ្ទុះទៅហើយ។ គេតប ស្នងដោយការរុញនាងឱ្យដេក ចំណែកគេ ស្រាយក្រវាត់ក ប្រទេះទ្បេវអាវជា បន្ទាន់ ដើម្បីឆាប់បានចូលទៅនៃបនិត្យ ឱ្យរាងកាយគ្រប់ផ្នែកនៃបនិត្យជិតគ្នា ខណៈនោះក៏លូកដៃក្តៅគគុកចូលទៅក្នុងអាវ ស្ទាបអង្អែលដើមទ្រូងទ្រលុក



ទ្រលន់ៗ

គេប្រើមេដៃជន្លួជន្លេញចុងរបស់វាឱ្យឡើងរឹង ម្ចាស់របស់វាក៏ដកដង្ហើមដង្ហក់ និងអែនខ្លួនមករក ប៉ុន្តែគេបង្វែរការចាប់អារម្មណ៍ទៅលើចុងទ្រូងម្ខាងទៀត ធ្វើឱ្យរាងកាយរបស់នាងកន្ត្រាក់ និងថ្ងូចថ្ងូរតិចៗ ខណៈដែលគេគ្រហឹមខ្លាំងៗ ដោយការពេញចិត្ត ព្រោះស្បែករបស់នាងរលោងពេកហើយ។

"បង្កើតកូនឱ្យបងម្នាក់ម៉ោ..." គេខ្សឹបប្រាប់ ខណៈដែលទាញអាវឱ្យរបូតពីស្មា។ ស្មាមញ្ញឹមរបស់គេ ចែងចាំងដូចពន្លឺព្រះអាទិត្យ ធ្វើឱ្យនាងព្រិលភ្នែក និងមិនអាចចេញពីបន្ទប់នេះរហូតដល់ព្រឹកថ្ងៃថ្មី។

១៣

ភ្ញាក់ពីយល់សប្ដ

ពេលវេលានៅហ្វេសសានដើរលឿនណាស់ ត្រឹមមួយពព្រិចភ្នែកសោះ នាងរស់នៅជាមួយគេបានមួយសប្ដាហ៍ហើយក្នុងដំណាក់ខាសាន និងធ្វើរឿងក្ដៅគគុកជាមួយគ្នាគ្រប់ពេលវេលា មិនថានៅទីណាក៏ដោយ ប៉ុន្តែបែរជាធ្វើឱ្យស្រែកឃ្លានកាន់តែខ្លាំង។ អាលិហ្សា បានស្វែងយល់ពីប្រពៃណីទំនៀមទម្លាប់នៅក្នុងវាំងកាន់តែច្រើន ដែលនៅហ្វេសសាន នាងមានសេរីភាព គ្មានអារម្មណ៍តានតឹង ព្រោះគ្មានអ្នកណាឃ្លាំមើល ទីនេះសុទ្ធតែជាមនុស្សរបស់គេ ប៉ុន្តែបើចូលរាជធានីពេលណា នាងមិនអាចធ្វើអ្វីតាមអំពើចិត្តបានទេ ព្រោះទីនោះមានមនុស្សតាមឃ្លាំមើលគ្រប់ពេលគ្រប់វេលា និងគ្រប់ទីកន្លែង មិនខុសអីពីត្រីក្រឹម



ថ្ងៃខ្លះ សារីហ្វ នាំនាងទៅលេងកសិដ្ឋានដែលកំពុងចេញជារូបរាង តាម
កំណាត់ផ្លូវនៅដែលអមដោយដើមស្រល់និងដើមប៉ោមកំពុងផ្កាផ្លែនៅកណ្តាល
សមុទ្រខ្សាច់ ទីកន្លែងដែលស្អាតហាក់ដូចព្រះប្រទាន។ គេចាប់ដៃនាងជាប់
នៅជាមួយនាងទាល់តែព្រះអាទិត្យលិចពីទួលខ្សាច់មានព្រះចន្ទចូលមកជំនួស
និងបាត់ទៅម្តងទៀតពេលពន្លឺព្រះអាទិត្យនាពេលព្រឹកត្រឡប់មកចែងចាំងលើ
សមុទ្រខ្សាច់វិញ។

នាងលួចសារភាពជាក់ខ្លួនឯងថានាងលង់ស្នេហ៍ទីនេះ ប៉ុន្តែមិនអាច
សម្របខ្លួនរស់នៅដោយការអង្គុយដេក ដេកអង្គុយ ដកដង្ហើមចោល រង់ចាំគេ
ត្រឡប់មកវិញ និងដឹងថាថ្ងៃមួយនាងត្រូវត្រឡប់ទៅកាន់ពិភពរបស់ខ្លួន ត្រឡប់
ទៅធ្វើជាឈ្មួញត្បូងមណីដែលនាងស្រឡាញ់។

"ថ្ងៃនេះទៀតហើយឬ?"

អាលិហ្សា ខ្សឹបសួរនាពេលព្រឹកព្រលឹម មានអារម្មណ៍ដល់បាតដៃក្តៅ
គគុកដែលកំពុងស្អាបអង្អែលអាវដេកសាច់ស្តើង ហើយប្រឹងបើកភ្នែក ពត់ពេន
ខ្លួនដោយភាពខ្ជិលច្រអូស ខណៈនោះគេក៏ខ្សឹបប្រាប់ឱ្យនាងដេកបន្ត ព្រោះដឹង
ច្បាស់ថាធ្វើឱ្យនាងសឹងតែមិនបានដេកមិនបានពួនពេញមួយរាត្រី បន្ទាប់មក
គេក៏ចុះពីគ្រែដ៏កក់ក្តៅទាំងរាងកាយនននលគក ដើម្បីទៅថ្វាយបង្គំព្រះ ហើយ
ត្រឡប់មកវិញនាពេលថ្ងៃត្លឺច្បាស់។

"ដល់ពេលដែលយើងត្រូវចូលរាជធានីហើយ"

សារីហ្វ ខ្សឹបប្រាប់ ព្រមទាំងអង្អែលនាងថ្នមៗ ហើយក្រសោបមុខឱ្យ
ងើបពីខ្នើយ ព្រមទាំងថើបថ្ងាស ខ្សឹបដាស់ម្តងទៀត ប៉ុន្តែនាងមិនទាន់ចង់ក្រោក
ទើបប្រែខ្លួន ព្រមទាំងដកដង្ហើមធំ ទោះត្រូវគេថើបជញ្ជក់បបូរមាត់ ថើបរាងកាយ
និងទាញខោអាវដំណេកចេញយ៉ាងណាក៏ដោយ។

អ្នកកំលោះមិនដាស់នាងម្តងទៀត ប៉ុន្តែធ្វើឱ្យនាងភ្ញាក់ ព្រមទាំងថ្ងូរចង្ហ



ហើយក្រសោបត្រគាកមូលក្តុំគ្រប់គ្រងដោយការប្រាថ្នារាល់ព្រឹក រាល់ពេល

រាលរាត្រី។

"ខ្ញុំម្ចាស់ដោះបីខាបានទេព្រះពរ?"

នាងសួរពេលរថយន្តទំនើប ត្រូវបញ្ឈប់ឱ្យរត់នៅលើផ្លូវចេញពីដំណាក់

ខាសាន ដើម្បីធ្វើដំណើរចូលរាជធានី។

"ប្រាកដណាស់"

សារីហ្វ ងើយមុខពីឯកសារ និងជួយដោះបីខាដែលធ្វើឱ្យថប់ដង្ហើម

ចេញ ដោយទឹកមុខញញឹម។ បីខាធ្វើឱ្យនាងមិនទម្លាប់ ប៉ុន្តែវាមានប្រយោជន៍

ពេលត្រូវរស់នៅក្រុងហ្វេសសាន។ ថ្ងៃដែលមានខ្យល់ខ្លាំងនាំធូលីដីមកពី

សមុទ្រខ្សាច់មកជះលើមុខធ្វើឱ្យផ្សា និងចូលភ្នែក គឺមានបីខានេះឯងដែលជួយ

បាន។

"យូរទៀតទេទម្រាំដល់រាជធានី ព្រះពរ ?"

"កន្លះម៉ោងទៀត"

"ហេតុអីលឿនម្ល៉ះ ?"

នាងទៅជាតានតឹង ទោះធ្លាប់ចូលវាំងថ្មភក់ម្តងក៏ដោយ ប៉ុន្តែលើកនេះ កំពុងតែទៅទីនោះក្នុងឋានៈថ្មី ទើបធ្វើខ្លួនមិនត្រូវនិងខ្វល់ខ្វាយជាខ្លាំង ខ្វល់ថា សម្លៀកបំពាក់ដែលជ្រើសរើស វាមានរបៀបរៀបរយទេ សម្តីសំដៅត្រូវប្រើបែបណា។ នាងច្របូកច្របល់ គ្មានទំនុកចិត្តចំពោះខ្លួនឯងថាអាចចុះសម្រុងនឹងរាជវង្សអារ៉ាប់ប៉ុន្តែមានបាតដៃដ៏កក់ក្តៅលូកក្រសោបថ្ពាល់ហើយម្ខាស់បាតដៃក៏ឱនមកថើបបបូរមាត់ថ្នមៗ ជាការលើកទឹកចិត្ត និងស្តាប់នាងរអ៊ូរទាំដោយមិនមាត់មិនក។

មិនយូរប៉ុន្មានក្បួនរថយន្តទំនើប ក៏រត់ចូលមកក្នុងបរិវេណរាជវាំងថ្មភក់ដែលស្ថិតនៅចំកណ្តាលរាជធានី ដែលបរិយាកាសមើលទៅសោះកក្រោះ រឿង



ផ្លូវការជាងការគិត។ នាងមិនដឹងទេថាហេតុអ្វីបានជាមានអារម្មណ៍ប្រែប្រួល

ឡើងចុះបែបនេះ ប៉ុន្តែ សារីហ្វ មិនធ្លាប់និយាយ ឬធ្វើមុខធុញទ្រាន់ពេលនាង

ប៉ប៉ាច់ប៉ប៉ោចឥតប្រយោជន៍ ហើយកាន់តែនិយាយទឹកភ្នែកកាន់តែហូរដូចទឹក

បាក់ទំនប់ ទើបគិតថាខ្លួនឯងជិតឆ្កួតមែនទែនហើយ។

"យ៉ាងហោចណាស់ខ្ញុំម្ចាស់ចង់ត្រឡប់ទៅផ្ទះឱ្យបានម្តងសិន បានទេ

ព្រះពរ?"

"បងខ្លាចអូនមិនព្រមត្រឡប់មកវិញ"

សារីហ្វ អង្អែលថ្ពាល់របស់នាងដល់ការប្រុងប្រយ័ត្ន។ ភាពស្និទ្ធស្នាល

ដ៏ក្តៅគគុករវាងគេនិងនាង ប្រាប់ឱ្យដឹងថាចិត្តនាងនៅតែរឹងទទឹង។

"ចាំបងជូនអូនទៅ"

"មែនឬ?"

កែវភ្នែករបស់នាងបញ្ចេញពន្លឺដូចពេជ្រទឹកល្អ ទើបគេអត់មិនបាននឹង

ស្រវាឱប។

"មែន ប៉ុន្តែបើគ្មានឯកសារបញ្ជាក់ពីសមាសភាព អូននឹងគ្មានលិខិត បញ្ជាក់ជំនួសលិខិតឆ្លងដែន ខាងតែវ៉ាន់ឱ្យដំណឹងមកវិញថាអូនមិនមិនបាន កាន់សញ្ជាតិតែវ៉ាន់ តែដាក់សំណើមកមើលការខុសត្រូវផ្នែកត្បូងមណីកម្មវិធី តាំងពីពណ៌ទំនិញ មានតែមីស្ទ័រ វ៉ាង ម្នាក់គត់ដែលមានឯកសាររបស់អូន"

"ហើយគេនៅឯណា?"

"សំណាងអាក្រក់ដែលគេគ្រោះថ្នាក់ចូលមន្ទីរពេទ្យ និងបាត់បង់ជីវិត កាលពីថ្ងៃមុន ទើបបងដាក់លិខិតសុំបញ្ជីឈ្មោះអ្នកដំណើរចូលប្រទេសពី ប៉ូលីសអន្តោប្រវេសន៍... ដែលប្រព័ន្ធទុកដាក់ឯកសាររបស់យើងអន់ខ្លាំង ណាស់ ប្រហែលពីរបីថ្ងៃទៀតទើបបានសាច់ការ"

សារីហ្វ ឱនទៅថើបថ្ពាល់រលោង និងកាន់ដៃរបស់នាងជាប់។

"អូនជានរណា បងចង់ដឹងណាស់ អូនមកលេចក្នុងចិត្តបង និងអាច



រលាយបាត់ពីបងបានគ្រប់ពេល ប្រាប់តាមត្រង់ថាបងហួងហែងអូនណាស់"

"ខ្ញុំម្ចាស់..."

មានខ្លឹបបបូរមាត់ណែន បើគេដឹងឈ្មោះនិងសញ្ជាតិរបស់នាងពេលណា នាងនឹងមិនអាចរត់គេចពីគេផុតជារៀងរហូត។

"ខ្ញុំម្ចាស់ឈ្មោះ អាលិហ្សា"

"អេលីហ្សា!"

សារីហ្វ ទើបតែស្គាល់ឈ្មោះពិតរបស់នាងជាលើកដំបូង ទើបសម្លឹងមើលនាងមិនដាក់ភ្នែក និងហៅដដែលៗ ដោយសំនៀងអារ៉ាប់។ អេលីហ្សា ឈ្មោះរបស់នាងពីរោះណាស់ ពន្លឺភ្នែករបស់គេចែងចាំង ដូចមនុស្សធ្លាក់ក្នុងអន្លង់ស្នេហ៍ម្តងទៀត ទើបនាងប្រញាប់ងាកមុខចេញ។

Alisha/ **អាលិហ្សា** ប្រែថា *ត្រូវការពារដោយព្រះជាម្ចាស់*។

Elisha/ **អេលីហ្សា** ឈ្មោះរបស់បុគ្គលផ្សព្វផ្សាយព្រះធម៌ និងទទួល

និងអ៊ីស្លាមក្នុងព្រះគម្ពីរថ្មី និងអាល់កុរអាន។

"សម្តេចព្រះមាតារាងកាច តែទ្រង់ចិត្តល្អ កុំខ្លាចអី ពេលអូនចូលគាល់ទ្រង់លើកដំបូង ទ្រង់ក៏ស្រឡាញ់ចូលចិត្តអូនណាស់ដែរ មានបងនៅជាមួយទុកចិត្តចុះ"

គេញញឹមនិងអង្អែលថ្ពាល់នាងថ្នមៗ ខណៈនោះឡានក៏ចូលមកចតនៅបរិវេណអគារធំ ហើយ អាលី ក៏ម្ដីម្នាមកបើកទ្វារឡានឱ្យចៅហ្វាយ ទើបសារីហ្វ ចុះពីឡាន ហើយហុចដៃឱ្យនាង។

អាលិហ្សា មើលដៃកក់ក្តៅដែលហុចមកឱ្យដោយការពិចារណា បន្ទាប់មកក៏ចុះពីឡានដោយខ្លួនឯង ប៉ុន្តែគេមិនព្រមឱ្យនាងដើរម្នាក់ឯង ដោយការស្រវាចាប់ដៃជាប់ និងបញ្ជាដោយប្រយោល ហើយរាក់ទាក់អ្នកនៅក្នុងវាំងដូចសព្វមួយដង។



រាជវាំងនេះនៅតែស្អាតគួរឱ្យជាប់ចិត្តដដែល តែឱ្យអារម្មណ៍មានសម្ពាធ
ជាខ្លាំង ធ្វើឱ្យនាងមានអារម្មណ៍ថាខ្លួនឯងមកខុសកន្លែង ខ្សែភ្នែកបង្ហាញពីការ
សង្ស័យរបស់មនុស្សទាំងឡាយដែលមើលមក ធ្វើឱ្យនាងញ័រជើង តែព្យាយាម
អត់ធ្មត់ ដើរតាម សារីហ្វ ចូលដំណាក់ផ្នែកស្ត្រី។

"បងកំពុងរកមើលកន្លែងល្អៗក្នុងវាំង ទុកឱ្យអូន ពីរបីថ្ងៃទៀតនាំទៅ
មើល"

"កន្លែងល្អៗ យកទៅធ្វើអីព្រះពរ?" នាងសួរពីការងឿងឆ្ងល់។

"ក្រែងលអូនចង់បើកហាងគ្រឿងអលង្ការស្អាតៗ ល្អទេ"

"ខ្ញុំម្ចាស់ធ្វើបានមែនឬព្រះពរ វាមិនបង្កបញ្ហាអីទេ មែនទេ?"

កែវភ្នែករបស់នាងមានពន្លឺដូចពេជ្រម្តងទៀត ទៅជារលីងរលោង
ទឹកភ្នែកមួយរំពេច បេះដូងក៏រីកមាឌពេញទ្រូង។

"ខ្ញុំម្ចាស់បើកហាងលក់ពេជ្រលក់ត្បូងបានមែនឬព្រះពរ?"

"មែន បងជាស្វាមីដែលមានខ្លាំងសង្ហាខ្លាំងរបស់អូន បងដឹងថាអូនជា

រឹកយីងហ៊ុំមែន បើត្រូវដេកអង្គុយដកដង្ហើមចោលនៅផ្ទះមានតែធ្វើឱ្យមួម៉ៅ អូន

ចង់ធ្វើអី បងគាំទ្រជានិច្ច"

គេអស់សំណើច ព្រមទាំងជូតទឹកភ្នែកឱ្យនាងថ្នមៗ។

"ត្រូវវាយ ត្រូវចាប់ចង ត្រូវដើរឆ្លងសមុទ្រខ្សាច់ អូនមិនដែលស្រក់ទឹក

ភ្នែកមួយតំណក់ ពេលបងថាបើកហាងគ្រឿងអលង្ការឱ្យ បែរជាទ្រហោយំ ដឹង

បែបនេះប្រមូលពេជ្រមកចាប់ស្រីឆ្នាសល្អជាង"

"គឺខ្ញុំម្ចាស់សប្បាយចិត្ត... សប្បាយចិត្តដែល សារីហ្វ យល់ពីខ្ញុំម្ចាស់"

"អានែកុំយំអី តិចមិនស្អាត"

អាលិហ្សា ប្រឹងទប់សំឡេងយំ។

"ខ្ញុំម្ចាស់សប្បាយចិត្តដែលបាននៅជាមួយមនុស្សជាទីស្រឡាញ់ដោយ

មិនចាំបាច់បោះបង់រឿងដែលខ្លួនឯងចូលចិត្ត ខ្ញុំម្ចាស់ប្រហែលមិនលោភលន់



ពេកទេ មែនទេ និយាយតាមត្រង់ចុះ ខ្ញុំម្ចាស់គ្រាន់តែជាស្រីឡប់ៗ ម្នាក់ប៉ុណ្ណោះ

តែខ្ញុំម្ចាស់នឹងព្យាយាមធ្វើខ្លួនឱ្យសក្តិសមនឹង សារីហ្វ មិនឱ្យអ្នកណាប្រមាថ

មើលងាយបានថា សារីហ្វ គិតខុសដែលជ្រើសរើសខ្ញុំម្ចាស់"

"បងសប្បាយចិត្តដែលអូនព្រមទទួលយកក្តីស្រលាញ់របស់បង"

"អ្នកណាស្រឡាញ់អ្នកណា កុំទាន់អាលប្លែ" នាងអស់សំណើច "គ្រាន់

តែបើកហាងពេជ្រឱ្យប៉ុណ្ណឹង ចង់ក្រសោបយកទាំងអស់ផងឬ"

"ចំមែន អានែ"

គេស្រាក់ម្រាមដៃជាមួយនាង ហើយថើបថ្នមៗ ព្រមទាំងខ្សឹបប្រាប់។

"ត្រឹមមានអូន ដែលបងចង់ដើរដឹកដៃបែបនេះ រហូតដល់ចាស់កោងខ្នង

... បើអូនខ្វល់ខ្វាយ កុំដើរឈ្លោកមុខបែបនេះ... ញញឹមឱ្យស្រស់ និងកៀកដៃ

បងបែបនេះ"

សារីហ្វ ចាប់ដៃរបស់នាងឱ្យកៀកដៃរបស់ខ្លួន ព្រមទាំងឱ្យពើងទ្រូង

ហើយងារដៃ ឱនគំនាប់ ខណៈដែល អាលិហ្សា បន្ទន់ជង្គង់ ព្រមទាំងចាប់ជាយ
សំពត់លើកឡើងលើបន្តិច។

គេជាព្រះបុត្រា ចំណែកនាងជាព្រះនាងហើយភាគបញ្ចប់ គឺពួកគេមាន
សេចក្តីសុខសុភមង្គលជាមួយគ្នាជារៀងរហូត ប៉ុន្តែនៅក្នុងពិភពពិតវាមិនងាយ
ដូចប្រលោមលោក។

ទ្វារបន្ទប់សម្រាប់គយគន់បុប្ផារបស់សម្តេចព្រះមាតា ឌីណា ត្រូវបើក
ហើយពេលនេះស្ត្រីដ៏ខ្ពង់ខ្ពស់កំពុងនិយាយលេងជាមួយស្ត្រីជាច្រើននាក់ទៀត
យ៉ាងរីករាយ ហើយពេលពួកនាងមកដល់ សំឡេងនិយាយគ្នាក៏ស្ងប់ស្ងាត់
គ្រប់គ្នាក៏ងាកមកមើលដែលធ្វើឱ្យបេះដូងរបស់នាងចង់កក បើគ្មានគេក្តោបដៃ
ជាប់ នាងប្រហែលទន់ជង្គង់ដួលខ្ពើកទៅហើយ។

"ពេលអូនរំភើប ច្រមុះរីកដល់ហើយ"

"ចំមែន នេះជាពេលបង្អាប់គ្នាទេ!"



តែដួល។

សម្តេចព្រះមាតាអង្គុយផ្អែកខ្នងនឹងសាឡុងធំ ទឹកមុខស្លេកស្លក់ ប៉ុន្តែពេលឃើញមុខកូនប្រុស ទ្រង់ក៏សប្បាយចិត្តជាខ្លាំង ឱ្យ សារីហ្វ ចូលទៅឱបនិងងថើបថ្ពាល់ដោយក្តីស្រលាញ់ ព្រមទាំងរាក់ទាក់ព្រះញាតិវង្ស ដែលមានទាំងម្តាយមីងធំម្តាយមីងតូច និងមានស្រីស្អាតម្នាក់ដែលមើលមក អាលិហ្សា ដោយទឹកមុខមិនរួសរាយ ប៉ុន្តែនាងញញឹមដាក់។

"សួស្តី"

"ថ្វាយបង្គំអាមិរ៉ា"

ស្រីស្អាតម្នាក់នោះតបតជាភាសាអង់គ្លេស ដោយសំនៀងត្រឹមត្រូវល្អ និងណែនាំខ្លួនថាឈ្មោះ សាហ៊ីរ៉ា។

"ខ្ញុំម្ចាស់ធ្លាប់ជាគូដណ្តឹងរបស់ព្រះបុត្រា តែត្រូវផ្តាច់ពាក្យ"

"ចុះ..."

"តែចាស់ទុំកំពុងតែដាក់សម្ពាធឱ្យព្រះបុត្រាទទួលខុំម្ចាស់ជាព្រះជាយាម្នាក់ទៀត សូមអាមិ៉ាជួយខុំម្ចាស់ផង"

សាហ៊ិ៉ា ញញឹម។ នាងជាសាច់ញាតិដែលមានអាយុតិចជាង សារីហ្វ និងជាព្រះញាតិវង្សសម័យថ្មី រៀនចប់នៅបរទេស និងធ្វើការនៅក្នុងអង្គការធំលំដាប់ពិភពលោក ត្រូវចាស់ទុំរៀបចំជាគូរៀបការរបស់ សារីហ្វ។ សាហ៊ិ៉ារស់នៅក្នុងសង្គមបើកទូលាយយូរមកហើយ ទើបមិនចង់ត្រឡប់មករស់នៅក្នុងហាន:ខ្ពង់ខ្ពស់ តែគ្មានសេរីភាពនេះវិញ ដូច្នេះហើយទើបតែងតែធ្វើព្រងើយកណ្តើយ ប៉ុន្តែពេល អាលិហ្សា លេចមុខមកដណ្តើមតំណែងព្រះជាយាលំដាប់ទីមួយ ទើបត្រូវចាស់ទុំហៅត្រឡប់មកវិញ។

"មិស ឈិន..."

ពេលត្រូវសម្តេចព្រះមាតាហៅ នាងក៏ទប់អារម្មណ៍ភិតភ័យ ចូលទៅថើប



ថ្ពាល់តាមទំនៀមទម្លាប់ ខណៈនោះក៏ដឹងថាដៃរបស់ទ្រង់ត្រជាក់ស្រែង។

"សូមទ្រង់មេត្តាហៅខ្ញុំម្ចាស់ថា អាលិហ្សា ព្រះម៉ែម្ចាស់"

ព្រះញាតិវង្សទាំងឡាយមើលមកនាង ដោយមិនបង្ហាញអាកប្បកិរិយា ឬទឹកមុខអ្វី ប៉ុន្តែនាងមើលដឹងថាពួកគេគ្មានសេចក្តីសុខ និងពេលបានឮសំឡេងដកដង្ហើមធំ នាងក៏យល់ភ្លាមថាខ្លួនមិនត្រូវបានស្វាគមន៍ ទើបញញឹមមិនសូវសម។

"ព្រះសុណិសារបស់ទ្រង់ជាមនុស្សក្រៅសាសនាបែបនេះ មិនខុសប្លែកទេឬ ព្រះម៉ែម្ចាស់"

"មែនហ្នឹង ព្រះម៉ែម្ចាស់ ប្រញាប់ប្រញាល់ប្រកាសតែងតាំងបែបនេះ បើប្រវត្តិមនុស្សស្រីម្នាក់នេះមិនល្អ មិនធ្វើឱ្យខូចព្រះកិត្តិយសទេឬ ព្រះម៉ែម្ចាស់ស្រីបរទេសខុសសាសនា បើត្រូវចូលរួមពិធីសំខាន់ៗ តើថ្លៃថ្នូរឬ សារីហ្វ"

"ទូលបង្គំស្រឡាញ់នាង"

"ពួកយើងមានបំណងល្អចំពោះព្រះបុត្រា នាងម្នាក់នេះមិនសក្តិសមទេ"

"នាងកំពុងតែសម្របខ្លួន"

"តែ..."

ព្រះញាតិវង្សប្រុងប្រឆាំង មិនព្រមស្ងប់ ទាមទារឱ្យព្រះយាជារបស់ព្រះបុត្រាត្រូវតែមានគុណសម្បត្តិច្រើន ប៉ុន្តែត្រូវ សារីហ្វ បង្អាក់ដោយការងាកទៅរកសម្តេចព្រះមាតា។

"សម្តេចព្រះមាតាទ្រង់ទទួលយក អាលិហ្សា ជាព្រះសុណិសា ឬអត់ក្រាបទូល"

"មាតាព្រមដោយក្តីរីករាយ"

សារីហ្វ សម្លឹងមើលមុខគ្រប់គ្នាដែលស្ងាត់មាត់ម្នាក់ម្តងៗ ហើយនិយាយច្បាស់លាស់។

"សង្ឃឹមថាម្ចាស់អ៊ំម្ចាស់មីងស្វាគមន៍ អាលិហ្សា ក្នុងហាន:ជា



ព្រះញាតិវង្ស សូមជូនពរយើងទាំងពីរផង ក្រាបទូល"

សារីហ្វ បង្ហាញអារម្មណ៍ត្រង់ទៅត្រង់មក ការហាមប្រាមសាច់ញាតិ ប្រយោល ហើយបើមាននរណាហ៊ានធ្វើបាបនាង គេច្បាស់ជាមិនទុកទេ។

អាលិហ្សា អង្គុយស្ងៀម ទោះស្តាប់មិនយល់ពួកគេនិយាយគ្នាពីអ្វី ប៉ុន្តែ ពេលឃើញបរិយាកាសហើយគិតថាប្រហែលគិតថាមិនសូវល្អប៉ុន្មាន និងពេលឃើញសារីហ្វចេញមុខការពារបែបនេះគេនឹងកាន់តែរងសម្ពាធទើបនាងកេះគេប្រាប់ថានាងមិនអីទេ ហើយពេលនោះឯងដែលគេដឹងថានាងដោះចិញ្ចៀនពេជ្រដាក់ក្នុងប្រអប់កាំម្ទីពណ៌ក្រហមតាំងពីពេលណាក៏មិនដឹង។

"ខ្ញុំម្ចាស់សន្យាថានឹងមកទីនេះជាមួយចិញ្ចៀនដែលប្តូរតួថ្មីរួចរាល់ ប៉ុន្តែ ខ្ញុំម្ចាស់មិនអាចធ្វើតាមការសន្យាបានទេ ព្រះម៉ែម្ចាស់"

"សារីហ្វ និយាយឱ្យយើងស្តាប់ហើយថាគេធ្វើឱ្យនាងខកខានប្តូរតួចិញ្ចៀនថ្មីឱ្យយើង"

សម្តេចព្រះមាតាញញឹមស្រទន់ដាក់នាង។

"មិនមែនទេព្រះម៉ែម្ចាស់"

"ហើយទៅស្រឡាញ់គ្នាដោយរបៀបណា និយាយឱ្យយើងស្តាប់បន្តិចមក"

"គឺ... គឺ..."

សម្តេចព្រះមាតានៅតែមានក្តីមេត្តា ប៉ុន្តែនាងទេដែលភ័យឡើងក្រហមមុខនិយាយស្តីរដាក់រដុបទាំងធ្វើឱ្យកំពប់ទឹកធ្វើឱ្យកាបូបជ្រុះធ្លាក់នេះធ្លាក់នោះរាយប៉ាយ ទើបព្រះបុត្រាចេញមុខនិយាយជំនួស។

"យើងទាំងពីរលង់ស្នេហ៍គ្នាតាំងពីជួបដំបូងម្ល៉េះព្រះមាតា"

អាលិហ្សា ងាកទៅមើលមុខអ្នកនិយាយដែលពូកែយកចំណុចល្អដាក់ខ្លួនឯង។

ស្រឡាញ់គ្នាតាំងពីជួបដំបូងស្អីទៅ ស្អប់គ្នាតាំងពីជួបដំបូងមិនថា!



"មែនឬ មានគេរាយការណ៍ថាបុត្រគ្មានមារយាទចំពោះ អាលិហ្សា ឱប
គ្មាទាល់តែត្រូវមុតតារ៉ាវ៉ែ"

"មានរឿងយល់ច្រឡំគ្នាតិចតួច តែសរុបទៅនាងគួរឱ្យស្រលាញ់ដល់
ថ្នាក់បុត្រត្រូវរត់តាមចែចង់ពេញសមុទ្រខ្សាច់ ក្រាបទូល នាងទាំងរឹងទទឹង ទាំង
ពូកែតវ៉ា ធានាថាពូកែនិយាយ និយាយបានពេញមួយថ្ងៃ"

"តាមចែចង់ ឬតាមដេញវ៉ែ និយាយឱ្យស្រួលបួល ទ្រង់ពូកែនិយាយ
និយាយបានពេញមួយថ្ងៃស្អី ត្រង់អាញ៉ក់របស់ សារីហ្វ ផ្ទៀងឆ្វេង ខ្ញុំម្ចាស់
មិនទាំងនិយាយផង"

អាលិហ្សា ខ្សឹបខ្សៀវដាក់ ទើបគេខ្សឹបដាក់វិញឱ្យបានឮតែពីរនាក់។
គ្មានអ្នកណាដឹងថាព្រះបុត្រាខ្សឹបអី ទើបមុខរបស់ព្រះជាយាក្រហមបែបនេះ។

ពេលប្រសព្វភ្នែកជាមួយសម្តេចព្រះមាតា អាលិហ្សា ក៏ភិតភ័យ សឹងតែ
បោលចេញទៅតាមបង្អួចដោយការខ្មាសអៀន ទាំងដែលទ្រង់មិនស្តីបន្ទោស

គិតតែញញឹមស្រទន់ដាក់ ហើយពេលនោះឯងដែលនាងមើលឃើញថា
មុខមាត់ដ៏ស្រស់ស្អាតរបស់ សារីហ្វ បានមកពីម្តាយនោះឯង ហើយគេមិនត្រឹម
តែជាស្វាមីរបស់នាងប៉ុណ្ណោះទេ ឋាន:ដ៏ខ្ពង់ខ្ពស់របស់គេផ្តល់សេរីភាពឱ្យមិន
បានច្រើន ដូច្នេះហើយបានរស់នៅទីនេះបន្ត នាងត្រូវព្រមទទួលយករឿងនេះឱ្យ
បាន។

"ខ្ញុំម្ចាស់សូមព្រះរាជទានទោស រឿងចិញ្ចៀនមួយវង់នេះរបស់ទ្រង់ផង
ព្រះម៉ែម្ចាស់ ដែលយកមកពាក់ដោយគ្មានការអនុញ្ញាត"

អាលិហ្សា យកចិញ្ចៀនចេញពីថង់កាំម្ញី ប៉ុន្តែសម្តេចព្រះមាតាគ្រីក្បាល
ហើយយកចិញ្ចៀននោះមកថើប បន្ទាប់មកក៏បំពាក់ឱ្យនាង។

"ស្នេហានឹងធ្វើឱ្យចិញ្ចៀនបញ្ចេញពន្លឺ ចិញ្ចៀនមួយវង់នេះមិនអាចកាត់
ថ្លៃបានទាល់តែនៅលើម្រាមដៃរបស់មនុស្សស្រីដែលសក្តិសម ហើយម្នាក់នោះ
គឺនាង នាងជាមនុស្សស្រីដែលព្រះបុត្រារបស់យើងស្រលាញ់ សូមពាក់វាឱ្យ



ជាប់នឹងដៃ"

"ព្រះម៉ែម្ចាស់"

នាងឱនមុខជ្រប់ ព្រមទាំងតបដោយសំឡេងខ្សាវៗ។

"យើងសប្បាយចិត្តដែល សារីហ្វ ជួបមនុស្សដែលគេស្រលាញ់ បើខឹង

គឺខឹងរឿងដែលគេមិនខ្វល់ពីពិធីមង្គលការ ហានៈរបស់គេមិនមែនកំលោះ

សមុទ្រខ្សាច់ដែលត្រឹមឱ្យព្រឹទ្ធាកុលសម្ព័ន្ធបេឌូអ៊ីនធ្វើពិធីឱ្យ ហើយក៏ចប់

ចាត់ទុកមាតា និងចាស់ទុំជាអ្វី អត់ធ្មត់រង់ចាំបន្តិចទៀតមិនបានផងឬ"

សម្តេចព្រះមាតាស្តីបន្ទោសឱ្យកូនប្រុសដោយមិនទុកមុខ ខណៈដែល

អាលិហ្សា អស់សំណើចពេលបានឃើញអ្នកខ្លះបែកញើស ព្រោះត្រូវម្តាយ

បន្ទោស។

"សូមព្រះមាតាព្រះរាជទានទោស រឿងនេះបុត្រសុំទទួលកំហុសតែម្នាក់

ឯង"

"ឆេវឆាវដូចព្រះបិតាបេះបិទ"

សម្តេចព្រះមាតាប្រគល់គ្រឿងអលង្ការមួយឈុតធំទៀត ជាអំណោយ ជាត្បូងទទឹមពណ៌ក្រហមស្រស់ សាច់ថ្លាយង់គ្មានមន្ទិល ចាំងពន្លឺផ្លេកៗ ពេលត្រូវនឹងពន្លឺភ្លើង ដែលរកស៊ីមុខរបរជួញដូរត្បូងពេជ្រយូរមកហើយ នាងមិនធ្លាប់ឃើញត្បូងទទឹមណាស្អាតបែបនេះទេ។

"អបអរផង"

សាហ៊ុរ៉ា ងើបមកឱប អាលិហ្សា ព្រមទាំងខ្សឹបដាក់ត្រចៀក។

"គួរឱ្យច្រណែនមែនទែន បើគ្មានព្រះនាង ខ្ញុំម្ចាស់នឹងបានឈរនៅត្រង់នេះ"

សាហ៊ុរ៉ា ដកដៃចេញ ហើយងាកទៅញញឹមស្រស់ដាក់ សារីហ្វ និយាយគ្នាយ៉ាងរីករាយ ព្រោះធំធាត់ជាមួយគ្នា ទើប អាលិហ្សា សុំទៅដើរលេងក្នុងសួន។



"បងទៅជាមួយអូនដែរ"

"ឱ្យខ្ញុំម្ចាស់សុំពេលគិតមួយសន្ទុះផងទៅព្រះពរ"

នាងដើររលេះរលាំងសំដៅជណ្តើរចុះទៅរកសួនផ្កា ព្រោះខ្លាចបេះដូងប្រេះស្រាំនៅចំពោះមុខគេ។ នាងគ្មានអារម្មណ៍គយគន់ផ្កាដែលកំពុងរីករហង់ទាំងនេះទេ ប៉ុន្តែចេះតែដើរទៅដើរមកនៅតាមផ្លូវដើរបត់បែន មិនខុសពីគំនិត។

នាងស្រឡាញ់គេ ប៉ុន្តែទ្រាំមិនបានទេពេលដឹងថាគេត្រូវមានមនុស្សស្រីជាច្រើននាក់ទៀតនៅក្នុងរង្វង់ដៃ។

"អាមិ៉ា"

មន្ត្រីរាជវាំងម្នាក់ដើរចូលមកគោរពនិងប្រាប់ពីគោលបំណងរបស់ខ្លួន។

"ហ្សឺក ហ្វារីស អាល់ មីឌីស មានរាជបញ្ជាឱ្យនាំទ្រង់ចូលគាល់"

"ចំ"

នាងតបដោយសំឡេងខ្សាវៗ មានអារម្មណ៍ដូចមនុស្សកំពុងលង់ទឹក

ទើបងាកទៅរក សារីហ្វ ប៉ុន្តែឃើញគេកំពុងនិយាយជាមួយ សាហ៊ីរ៉ា ទើប
ងាកមុខចេញ ហើយដើរតាមមន្ត្រីម្នាក់នោះ។

អាលិហ្សា អត់ដង្ហើមពេលដើរចេញពីជណ្តើរយន្តដែលបើកទ្វារនៅជាន់

លើបង្អស់របស់អគារដែលខ្ពស់ជាងគេ និងទាន់សម័យជាងគេរបស់មីឌីស
ហើយមានប្រធានផ្នែកលេខាធិការរបស់ហ្ស៊ីក ហ្វារីស រង់ចាំបើកទ្វារឱ្យដោយ
ទឹកមុខស្មើ បន្ទាប់មកក៏ត្រូវគេនាំដើរលើព្រំក្រាស់ទន់ល្មើយលាតសន្ធឹងវែង
ទៅដល់ចុងផ្លូវដែលជាបន្ទប់ធំមួយទៀត។

ជញ្ជាំងបន្ទប់ដែលលម្អដោយសៀវភៅជាច្រើន តុបតែងដោយរូបថត
ទំហំមួយជំហរខ្លួន និងមានរូបថតដូចគ្នាបេះបិទនៅដំណាក់ខាសាន ហើយ
ក្រៅពីរូបថតរបស់ទ្រង់ មានរូបគំនូរជាច្រើនទៀត ដូចជារូបស្នាំងកំពុងឆាបចាប់
ទន្សាយ រូបឆ្កែចចកសមុទ្រខ្សាច់កំពុងរត់ បន្ទាប់មកជារូបវាលផ្កាចំរុះពណ៌



រូបបឹងទន្លេសាប មានគ្រឿងសង្ហារឹមឈើ តុបតែងដោយរចនាបថអភិរក្សនិយម
មើលទៅមានអំណាច។

ហើយពេលនេះនាងកំពុងឈរស្ងៀមនៅចំពោះមុខហ្ស៊ីក ហ្វារីស បុរស
ដែលមានអំណាចលើសមនុស្សទាំងពួងក្នុងប្រទេសនេះ។

គេជាបុរសដែលមានរូបរាងសង្ហាកម្រកនរណាផ្ទឹមបាន ស្មាមញ្ញឹម
និងបបូរមាត់មានមន្តស្នេហ៍ មើលទៅកាច តែកក់ក្តៅ ជាបុគ្គលិកលក្ខណៈរបស់
អ្នកដឹកនាំដែលទាក់ទាញមនុស្សម្នាក់ឱ្យចូលមករក។ ហ្ស៊ីក សារីហ្វ អាល់
មីឌីស ប្រៀបដូចតោឈ្មោលកំណាច ចំណែក ហ្ស៊ីក ហ្វារីស គឺស្អាងដ៏គួរឱ្យ
កោតក្រែង។ នាងមើលឃើញថាទម្រង់មុខរបស់ហ្ស៊ីកទាំងពីរស្រដៀងគ្នា ប៉ុន្តែ
ហ្ស៊ីក ហ្វារីស ដាច់ខាតជាងក្នុងឋានៈជាប្រមុខប្រទេស ហើយនាងដឹងច្បាស់
ថាគេមិនមែនជាមនុស្សចិត្តល្អ។

"សារីហ្វ ប្រកាសថានាងជារបស់គេ ដែលធ្វើឱ្យយើងមានការភ្ញាក់

ផ្អើលខ្លាំងតែម្តង"

គេជាអ្នកចាប់ផ្តើមការសន្ទនាដោយឫកពាររំភើយៗ។

"ពេលនៅក្បែរ សារីហ្វ នាងមើលឃើញអនាគតខ្លួនឯងយ៉ាងម៉េច ខ្លះ?"

"ខ្ញុំម្ចាស់គិតថាបើកហាងគ្រឿងអលង្ការនៅទីនេះ ព្រះពរ ហើយខ្ញុំម្ចាស់ កំពុងតែដាក់ផែនការជួលក្រុមហ៊ុនត្រួតពិនិត្យរ៉ែត្បូង ដើម្បីត្រួតពិនិត្យរ៉ែត្បូងនៅ មជ្ឈិមបូព៌ា បើសំណាងល្អរកឃើញអណ្តូងពេជ្រ ឬអណ្តូងត្បូងថ្មី ព្រះពរ"

នាងរៀបរាប់ដោយការប្រុងប្រយ័ត្ន។

"ស្រីរបស់រាជវង្សមិនធ្វើការ យើងនៅតែប្រកាន់គំនិតថាមនុស្សស្រីត្រូវ រក្សាខ្លួននៅក្នុងផ្ទះ យើងច្បាស់ហើយថា សារីហ្វ មិនអនុញ្ញាតពីរឿងនេះ"

"តែ សារីហ្វ ប្រាប់ថា..."

"មើលទៅនាងមិនទាន់ឃើញព័ត៌មានរបស់ខ្លួនឯងទេ"



ទ្រង់យកហូកា (Hookah) លម្អដោយត្បូងមណីមកជក់ ហើយព្រួស

ផ្សែងចេញតាមច្រមុះ ហ្គេមមាត់មានស្នាមញញឹមភាពធូរស្រាល និងរាក់ទាក់

ប៉ុន្តែវាមិនរាលទៅដល់ពន្លឺភ្នែក។

"ព័ត៌មាន... អីឬ ព្រះពរ"

អាលិហ្សា ខាំធ្មេញ ឈរស្ទៀម ប្រឹងដកដង្ហើមចូល បញ្ចូមិនឱ្យខ្លួនឯង

សន្លប់ តែពេលប្រធានផ្នែកលេខាធិការហុចកាសែតមកឱ្យ ដៃរបស់នាងក៏

ត្រជាក់ស្រែង មើលមិនយល់ខ្លឹមសារនៅក្នុងអត្ថបទ។

"សារីហ្វ ដល់ថ្នាក់បញ្ជូនមនុស្សទៅគំរាមទីភ្នាក់ងារកាសែត គេមិនធ្លាប់

ធ្វើបែបនេះទេ ប្រាកដណាស់ថាព្រោះតែនាង"

នាងនិយាយអីមិនចេញ។

"សារព័ត៌មាននៅទីនេះមិនចុះផ្សាយរឿង ឬរូបថតរបស់ព្រះញាតិវង្ស

ស្រីជាដាច់ខាត វប្បធម៌របស់យើងតឹងរឹងណាស់ចំពោះភាពផ្ទាល់ខ្លួនរបស់

ចៅហ្វាយផ្នែកស្ត្រី ហេតុផលគឺដើម្បីមិនឱ្យរូបថតធ្លាក់ទៅក្នុងដៃរបស់មនុស្ស
ប្រុសដូច្នេះហើយរឿងរបស់ផ្នែកខាងក្នុងគ្មានថ្ងៃលេចឮជាព័ត៌មាននៅតាមទំព័រ
កាសែត ការដែលនាងមានព័ត៌មានពេញប្រទេសបែបនេះវាធ្វើឱ្យមានការមិន
ពេញចិត្តសម្រាប់ផ្នែកជាច្រើន"

"ហេតុអីរឿងនេះក្លាយជាកំហុសរបស់ខ្ញុំម្ចាស់ ?"

ហ្វារីស លើកចិញ្ចើមបន្តិចពេលត្រូវតវ៉ាបែបនេះ ខណៈដែល អាលិហ្សា
ប្រឹងដកដង្ហើមចូលឱ្យពេញសួត និងពង្រឹងស្មារតីមិនឱ្យភ័យខ្លាច ព្រោះបុរស
អារ៉ាប់សុំនឹងមនុស្សស្រីដែលមិនចេះប្រើពាក្យប្រើសម្តី។

សម្តីមួយម៉ាត់ៗរបស់ហ្សឺក ហ្វារីស ធ្វើឱ្យចិត្តរបស់នាងស្រែកចេញមក
ដោយការឈឺចាប់។ មិនយល់ទេថាហេតុអ្វីបានជាទស្សនៈរឿងស្នេហារបស់
អ្នកនៅទីនេះគឺការឃុំឃាំង។

"សង្គមរបស់យើងមិនទាន់បើកទទួលជនជាតិបរទេសទេ នាងមិនដឹង

ទេថា ពេលនេះគេកំពុងតែត្រូវដាក់សម្ពាធខ្លាំងប៉ុនណាដែលទទួលនាងជា

ជាយា បើនាងយល់ដល់គេមែន គួរតែចាកចេញពីគេ វត្តមានរបស់នាងនឹង

ធ្វើឱ្យគេអំពល់ទុក្ខ យើងត្រូវការឱ្យប្អូនប្រុសម្នាក់នេះជួយការងារច្រើនទៀត"

ហ្វារីស សរសេរសែកមួយសន្លឹកហុចហើយ ដោយមិនដាក់តួលេខ

តែនាងមិនទទួលយក ព្រមទាំងសម្លឹងមុខគេចំៗ ជាការប្រឆាំង។

"យើងមិនបានស្អប់កំណើតកើតជារបស់នាង បើគេកំណត់ឱ្យនាងត្រឹម

ជាស្រីកំណាន់ យើងក៏មិនរវល់ដែរ តែកន្លងមកមិនធ្លាប់មានស្រីបរទេសណា

ទទួលបានតំណែងអាមិរ៉ា រឿងនេះថ្មីណាស់សម្រាប់រាជវង្សរបស់យើង តាម

យោបល់របស់យើង អារម្មណ៍ដែល សារីហ្វ មានចំពោះនាងគឺ *លង់* ដូច្នេះ

ហើយទទួលយកលុយនេះទៅ និងចាកចេញពីគេស្ងាត់ៗ"

"ខ្ញុំម្ចាស់សូមបដិសេធ"

នាងក្តាប់ដៃណែន ខាំបបូរមាត់ទាល់តែបានក្លិនឈាម ទោះកំពុងតែត្រូវ

គំរាមកំហែងដោយទឹកមុខសោះកក្រោះក៏ដោយ។ នាងប្រឆាំងនឹងបញ្ហានេះ ដោយការយកសែកមួយសន្លឹកនោះមកហែកជាពីរ ហើយដាក់នៅចំពោះមុខ ដែលធ្វើឱ្យប្រមុខប្រទេសមីឌីសបិទភ្នែក ញ្ជោចចុងមាត់ម្ខាង ព្រមទាំងស្រាក់ដៃដាក់លើតុ។

"គិតអីចេះខុសថាត្រូវតែបដិសេធតែជឿចុះថាយើងគ្មានបំណងអាក្រក់អ្វី ដែលធ្វើទាំងនេះគឺដើម្បីនាង"

អាលិហ្សា ប្រឹងទប់ទឹកភ្នែក មិនព្រមបង្ហាញភាពទន់ជ្រាយឱ្យនរណាឃើញជាដាច់ខាត។ នាងតែងតែទាមទារសេរីភាពពី សារីហ្វ ប៉ុន្តែវិនាទីនេះបែរជាឈឺចាប់ ព្រោះរារែក គ្មានទំនុកចិត្ត និងភ័យខ្លាច។

ហ្សឺក ហ្វារីស មើលឃើញការឈឺចាប់ដែលបង្ហាញឱ្យឃើញច្បាស់តាមរយៈពន្លឺភ្នែករបស់នាង ទើបបិទភ្នែក ដកដង្ហើមធំ។

"យកសម្តីរបស់យើងទៅពិចារណាមើលទៅ មានមនុស្សច្រើនណាស់



ដែលស្រឡាញ់គ្នា តែមិនចាំបាច់រស់នៅជាមួយគ្នា បើនាងយល់ព្រមចាកចេញ

យើងនឹងចាត់ចែងឱ្យ ជានាថាគេតាមរកនាងមិនឃើញ"

ប្រមុខនៃមីឌីសដាក់ឯកសារជំនួសលិខិតឆ្លងដែន ដែលចេញដោយ

រដ្ឋបាលស្របច្បាប់នៅលើតុ នោះមានន័យថានាងអាចចាកចេញពីទីនេះបាន

គ្រប់ពេល បន្ទាប់មកក៏បក់ដៃហៅលេខាធិការឱ្យចូលមករក ជាការប្រាប់ថាការ

ចរចាត្រូវបញ្ចប់ហើយ ខណៈនោះ សារីហ្វ ក៏លេចមុខចូលមកដោយទឹកមុខ

មិនស្រស់ស្រាយជាខ្លាំង ទើប អាលិហ្សា ប្រញាប់យកឯកសារនោះលាក់។

"មានរឿងអី ?"

សារីហ្វ ចាប់ភាពមិនប្រក្រតីបានលឿនជានិច្ច។

"គ្មានអីទេព្រះពរ ទ្រង់គ្រាន់តែត្រូវការចម្លើយច្បាស់លាស់ថាខ្ញុំម្ចាស់

ព្រមធ្វើជាសមាជិកថ្មីរបស់រាជវង្សមែនទែនហើយ ខ្ញុំម្ចាស់ភ័យសឹងស្លាប់"

"អូនឆ្លើយថាម៉េច ?"

នាងក្រមុំអស់សំណើច ថ្ពាល់ឡើងក្រហម។

"ខ្ញុំម្ចាស់ឆ្លើយថាបើ សារីហ្វ ធ្វើខ្លួនមិនល្អខ្ញុំម្ចាស់នឹងប្តូរស្វាមី"

"ព្រះអាទ្បា! អូនគិតថាបងព្រម"

សារីហ្វ សប្បាយចិត្តជាខ្លាំងដែលគ្រប់យ៉ាងដំណើរការរលូន ទោះដឹង ហើយថាឧបសគ្គធំមិនមែនព្រះញាតិវង្ស តែជាបងប្រុសបង្កើត ព្រោះបើបញ្ចុះបញ្ចូលបងប្រុសមិនបាន សំឡេងគាំទ្ររបស់ព្រះញាតិវង្សក៏គ្មានន័យ។

"អរព្រះគុណ ព្រះអង្គ"

"ចាប់ពីពេលនេះទៅ ព្រះអង្គម្ចាស់នៃហ្វេសសានជាអ្នកបញ្ជាក់ចម្លើយ របស់នាងនៅថ្ងៃនេះ ជូនពរសំណាងល្អ"

អាលិហ្សា ងឿងឆ្ងល់ចំពោះអារម្មណ៍ខ្លួនក្នុងពោះដែលកើតឡើង។ គ្រប់យ៉ាងកើតឡើងលឿនណាស់ត្រៀមខ្លួនទទួលមិនទាន់ រាងកាយទៅជាល្ហិតល្ហៃ បេះដូងទទេស្អាត ទោះដកដង្ហើមក៏លំបាក។



ព្រលប់ថ្ងៃនោះ មានកម្មវិធីជប់លៀងមិនផ្លូវការជាមួយព្រះញាតិវង្ស។ អាលិហ្សា ថ្លៃថ្នូរណាស់ដោយឈុតសាច់ក្រណាត់ខេស្មៀរពណ៌សបរិសុទ្ធម៉ូតព្រះនាង និងធ្វើឱ្យនាងស្អាត មានពន្លឺចែងចាំងកាន់តែខ្លាំង។ សក់ពណ៌ខ្មៅត្រូវលើកចងកន្ទុយសេះ លាក់ក្នុងស្បៃឃ្មុំ និងពាក់ខ្សែក្រវាត់ពេជ្រគ្រាប់ធំ ពាក់គ្រឿងអលង្ការត្បូងទទឹមដែលសមនឹងឈុត មានទាំងក្រវិល ខ្សែកនិងកងដៃ។ នាងបណ្តើរហ្ស៊ឺក សារីហ្វ ដែលយេទ្បាបាពណ៌ប្រផេះស្រាល កាត់ដេរដោយក្រណាត់សម្រាប់វណ្ណៈជាន់ខ្ពស់ចូលមកក្នុងកម្មវិធី។ មុខមាន់សង្ហាតាមបែបម្ចាស់សមុទ្រខ្សាច់ដ៏ក្តៅគគុក ឈរមជ្ឈដ្ឋានជាទាហាននៅក្នុងខ្លួនធ្វើឱ្យគេមើលទៅ

កាន់តែមានអំណាច និងសណ្តាំគ្រប់យ៉ាង។

ពិធីជប់លៀងមានតែសំឡេងនិយាយគ្នាយ៉ាងរីករាយ អាហារចំណីបែប អារ៉ាប់សុទ្ធសាធ និងមានក្លិនក្រវាញក្រអូបប្រហើរនៅក្នុងបរិយាកាស តុមាន កម្ពស់ត្រឹមជង្គង់ក្រាលដោយកម្រាលដែលតុបតែងដោយផ្កាស្អាតនិងបែងចែក ច្បាស់លាស់រវាងតុរបស់មនុស្សស្រីនិងមនុស្សប្រុស។ ពួកគេនិយាយគ្នាជា ភាសាព័រសៀ ប៉ុន្តែសម្តេចព្រះមាតា ឌីណា ទ្រង់មេត្តា បបួលនាងនិយាយនិង ប្រែអត្ថន័យជាភាសាអង់គ្លេសឱ្យស្តាប់ ព្រមទាំងណែនាំព្រះញាតិវង្សស្រីៗឱ្យ ស្គាល់ជាច្រើននាក់ទៀត។ ម្នាក់ៗញញឹមដាក់នាងតាមមារយាទ និងខ្សឹបខ្សៀវ គ្នានៅចំពោះមុខតាមប្រពៃណី។ អ្នកខ្លះនិយាយភាសាអង់គ្លេសបាន តែមិន ព្រមបន្ទាបខ្លួនមកនិយាយជាមួយនាង ចំណែក សាហ៊ីរ៉ា អង្គុយបន្ទាប់ តាម តំណែង នាងគិតតែមើលទៅខាងបុរសដែលមានហ្សឺក ហ្វារីស និងហ្សឺក សារីហ្វ អង្គុយជាប្រធាន។



ទោះជាស្រីបរទេស តែនាងមិនឯកាពេលនៅកណ្ដាលចំណោមស្ត្រីមូស្លីម ព្រោះអ្នកទាំងនោះពូកែនិយាយពូកែចរចា ហើយស្រីក្មេងៗនិយាយគ្នាថាហ្សឹកសារីហ្វ កាចណាស់។ ពេលគ្រប់គ្នាដឹងថាទ្រង់ប្រកាសតែងតាំងអាមិរ៉ា ក៏នាំគ្នាសង្ស័យថាទ្រង់ពេញចិត្តមនុស្សស្រីបែបណា ហើយពេលបានជួបអាលិហ្សា ដោយផ្ទាល់ គឺខ្សឹបខ្សៀវគ្នាកាន់តែខ្លាំង ថាស្រីមាឌល្អិត មិនចេះមាត់មិនចេះកម្ដាក់នេះឬដែលបង្ក្រាប *សីហៈនៃព្រះអាឡា* បាន។

តុអាហារខាងបុរសនិយាយគ្នាឮខ្លាំងៗ មានមនុស្សចាស់ពីរបីនាក់ងើបចេញទៅដោយទឹកមុខក្រមូរ ដែលសូម្បីក្មេងក៏ដឹងថាប្រកែកគ្នារឿងអី។

សម្ដេចព្រះមាតា ឌីណា ដកដង្ហើមធំ ហើយស្រវាចាប់ដៃរបស់នាងទៅអង្អែលថ្នមៗ ប្រាប់ថាមិនបាច់ខ្វល់ខ្វាយទេ ខណៈនោះព្រះញាតិវង្សផ្នែកស្ត្រីមួយចំនួនក៏បញ្ចេញយោបល់។

"មើលចុះ សាហ៊ីរ៉ា ដ៏គួរឱ្យអាណិត ខ្ញុំម្ចាស់ទូលហើយថាកុំឱ្យនាងមក

ថ្លៃនេះ"

"មែនហ្នឹង អាណិត សាហ៊ីរ៉ា សុខៗក៏ត្រូវដណ្តើមតំណែងប្រពន្ធទីមួយទាំងមុខក្រាស់ នាងមិនមែនមូស្លីមផង"

សម្តេចព្រះមាតាស្តាប់ហើយក៏ចង់ចិញ្ចើម ហើយតបទៅវិញជាភាសាព័រសៀ ទើបធ្វើឱ្យស្រីៗបិទមាត់មិនហ៊ាននិយាយអីទៀត។

"បើនាងមានអារម្មណ៍មិនសូវល្អ ចូលទៅសម្រាកនៅខាងក្នុងសិនល្អទេ ?"

"មិនអីទេ ព្រះម៉ែម្ចាស់ ខ្ញុំម្ចាស់..."

"អូនមិនស្រួលខ្លួនឬអត់ មើលទៅល្ហើយៗ"

សារីហ្វ ដើរមកដាក់បាតដៃលើស្មាតូចស្តើង ហើយឱនមកខ្សឹបសួរដោយសម្តីស្រទន់ ធ្វើឱ្យ អាលិហ្សា ភ្ញាក់បន្តិច ព្រោះត្រូវពុកមាត់ពុកចង្កាចាក់ថ្ពាល់ ដែលរូបភាពនោះធ្វើឱ្យព្រះញាតិវង្សស្រីៗ មើលមកដោយចិត្តច្រណែន។



"ខុំម្ចាស់គ្រាន់តែរំភើបតិចតួច គ្មានអីទេ ខុំម្ចាស់សុំទៅសម្រាកមុនបាន ទេ ព្រះពរ?"

នាងបដិសេធ ទាំងដៃដែលកាន់ពែងតែកំពុងញ័រ។

"ពេលនេះយប់ជ្រៅហើយ ទៅសម្រាកមុនចុះ បងនឹងឆាប់ទៅតាម"

"ព្រះពរ"

ហើយពេល អាលិហ្សា ងើបចេញពីកម្មវិធី សាហ៊ីរ៉ា ក៏ដើរមករក សារីហ្វ ហាក់ដូចបក្សីប្រមាញ់ចំណីដែលរង់ចាំឱកាសនេះយូរហើយ ថែមទាំងញញឹមដាក់នាងទៀត។

សារីហ្វ ឱ្យមន្ត្រីរាជវាំងយ៉ាងហោចណាស់ពីរនាក់ តាមបម្រើនាងជានិច្ច ទើបនាងគ្មានឱកាសនៅម្នាក់ឯង ទាល់តែដល់បន្ទប់ដេក។ នាងមើលគ្រប់យ៉ាងនៅក្នុងវាំងដោយចិត្តត្រជាក់ រាប់ចំនួនទាហានយាមកាម ពេលវេលាប្តូរវេនគ្នា

និងជារៀងរាល់បីថ្ងៃម្តង អ្នកនៅផ្ទះបាយនិងក្មងវាំងចេញទៅកទិញអីវ៉ាន់។

អាលិហ្សា ងូតទឹក ផ្លាស់ខោអាវដេក ហើយអង្គុយមើលចិញ្ចៀនពេជ្រ ជាប់នឹងម្រាមដៃនាងខាងឆ្វេងរបស់ខ្លួន ដោយមិនមាត់មិន.ក ហើយពេលបាន ឮសំឡេង សារីហ្វ កំពុងដើរចូលមក ទើប់ចុចបិទអំពូលភ្លើងនៅក្បាលគ្រែ និង ចូលដេកភ្លាម។

គេបើកទ្វារបន្ទប់ដេកចូលមក និងបិទវិញថ្នមដៃបំផុត ទាញយេបាឡា ចេញពីក្បាល ងូតទឹកជម្រះភាពហត់នឿយ និងត្រូវការឱ្យរាងកាយមានក្លិន ក្រអូប ព្រោះដឹងថានាងចូលចិត្តដេកក្នុងលង្វែកទ្រូងរបស់គេ ហើយឡើងមក លើគ្រែ ត្រសុលចូលភួយជាមួយថ្នមៗ ដេកមើលនាងយ៉ាងមានសេចក្តីសុខ។

ពេលនៅក្នុងកម្មវិធីជប់លៀង នាងមិនព្រមប្រសព្វភ្នែកជាមួយគេ មិនដឹងថា ងរឿងអី។

ពេលនាងដេកបិទភ្នែកព្រឹមៗ មើលទៅគួរឱ្យស្រឡាញ់គួរឱ្យលង់។ គេ



វាសជើងសក់ចេញពីថ្ពាល់ ឱនថើបថ្នមៗ ហើយត្រសុលទៅបៀត។

"ដេកលក់ហើយឬ?" គេសួរដោយសំឡេងស្អកៗ ប៉ុន្តែគ្មានសំឡេង ឆ្លើយតប "បងស្រឡាញ់អូន"

គេខ្សឹបប្រាប់ ព្រមទាំងថើបបបូរមាត់ផ្អែម ជ្រែកអណ្តាតចូលទៅរឹតរួត អណ្តាតរបស់នាង និងធ្វើឱ្យនាងថើបតបវិញ ហើយឱនទៅបឺតជញ្ជក់ចុងទ្រូង ត្រឹមប៉ុណ្ណឹង នាងក៏ថ្ងូរតិចៗទៅហើយ... បញ្ជាក់ថានាងមិនទាន់ដេកលក់ទេ។

"សារីហ្វ..."

"ដេកទៅ ចាំបងចាត់ការ"

គេលើកសំពត់មកដាក់នៅនឹងចង្កេះ ហើយដួសដងយករសផ្អែមល្អែម នៅចំពោះមុខ ខណៈនោះដៃម្ខាងក៏ស្ទាបអង្អែលត្រគាកមូលក្តុំ និងចង្កេះតូច បន្ទាប់មកក៏សើយឈុតដេករបស់នាងទៅដល់លើគល់ទ្រូង ឱ្យខ្លួនប្រាណក្រមុំ ក្តៅស្ទើរផ្ទុះក្នុងរាងកាយបុរស អារម្មណ៍របស់នាងឆាប់មានប្រតិកម្មណាស់។

នាងឆ្លើយប្រាប់គេនៅក្នុងចិត្ត ព្រមទាំងបិទភ្នែក ព្យាយាមទប់អារម្មណ៍ចង់ឱបក្រសោបរាងកាយមាំមួនកក់ក្តៅនេះឱ្យពេញរង្វង់ដៃ។

អាលិហ្សា ជ្រើសរើសទប់ចិត្ត ជ្រើសរើសសូប់ស្ងាត់ និងញញឹមដាក់គេជ្រើសរើសយំក្នុងចិត្តម្នាក់ឯង។

ថ្ងៃបន្ទាប់...

ឈ្មួញត្បូងមណីជនជាតិឥណ្ឌាត្រូវហៅមកជួប ដើម្បីឱ្យ អាលិហ្សា ទិញត្បូង និងមានព្រះញាតិវង្សជាស្ត្រីជាច្រើននាក់មកទិញដែរ អ្នកខ្លះពេញចិត្តជាខ្លាំងដែលនាងជួយរើសត្បូងល្អឱ្យ។

"ឈ្មួញប្រាប់ថាពេជ្រ ប៉ែលហ្សិកខាត់ ឥណ្ឌាខាត់ មានន័យថាបែលហ្សិកនិងឥណ្ឌាមានអណ្តូងពេជ្រឬ?"

"មិនមែនអីចឹងទេ ព្រះម៉ែម្ចាស់ *ខាត់* ជាឈ្មោះហៅជ្រុងរបស់ពេជ្រដែល

ថ្មៃនៅប្រទេសណា នឹងហៅពេជ្រនោះថា ខាត់ តាមឈ្មោះប្រទេសនោះ ដូចជា ពេជ្ររុស្សីខាត់ ពេជ្រប៊ែលហ្សិកខាត់ ពេជ្រអ៊ីនដៀខាត់ ពេជ្រដែលថ្មៃស្អាតជាងគេក្នុងលោកគឺនៅរុស្សី បន្ទាប់មកគឺប៊ែលហ្សិក ការថ្មៃដោយថ្វីដៃយ៉ាងប្រណិតនឹងមានឥទ្ធិពលចំពោះពន្លឺរបស់ពេជ្រ និងអាចជួយលាក់មន្ទិលរបស់វាបានដែរ ដូច្នេះហើយពេជ្រប៊ែលហ្សិកខាត់ គឺពេជ្រសុទ្ធតែត្រូវហៅតាមជ្រុងដែលថ្មៃពេជ្រនោះឯង ព្រះម៉ែម្ចាស់"

សម្តេចព្រះមាតា ឌីណា ស្តាប់ហើយមានការពេញព្រះទ័យជាខ្លាំង។

"មានរបាយការណ៍ថា យើងអាចរកឃើញអណ្តូងពេជ្រនៅទិសខាងកើតលទ្ធផលរុករកច្បាស់នឹងចេញរបាយការណ៍ម្តងទៀតឆាប់ៗនេះ"

"អស្ចារ្យមែនទែន ព្រះម៉ែម្ចាស់"

"បើយើងឱ្យនាងជួយមើលការខុសត្រូវរឿងនេះ តើនាងថាម៉េចដែរ? បើចាប់អារម្មណ៍ ចាំយើងប្រាប់ ហ្វារីស ឱ្យចុះឈ្មោះនាងក្នុងបញ្ជីអ្នកត្រួតពិនិត្យ"



"ខ្ញុំម្ចាស់ចង់ធ្វើ ព្រះម៉ែម្ចាស់"

នាងសប្បាយចិត្ត ព្រោះបើរកការងារធ្វើបាន នាងនឹងមានហេតុផលរស់នៅទីនេះបន្តបាន ម្យ៉ាងទៀតនាងចូលចិត្តធ្វើការ។

"មិនបានទេ នេះជារឿងរបស់មនុស្សប្រុស មនុស្សស្រីគ្មានសិទ្ធិចូលទៅជ្រៀតជ្រែក ឮថា សារីហ្វ នឹងបើកហាងពេជ្យឱ្យនាងហើយតើ តែសំណាងដែលហ្សឺក ហ្វារីស មិនទាន់អនុម័ត មិនអីចឹងអាម៉ាស់មុខហើយ ព្រះសុណិសាទៅឈរលក់អីវ៉ាន់ក្នុងហាង"

ព្រះញាតិវង្សខ្សែក្នុងម្នាក់បូញមាត់បូញកនិយាយបង្អាក់ ខណៈនោះអ្នកឯទៀតក៏យល់ស្រប។

"មែនហ្នឹង ស្រីបរទេសមើលការខុសត្រូវអណ្តូងពេជ្ររបស់មីឌីសម៉ែចបាន មិនគិតថាចម្លែកទេឬ ខ្ញុំមិនបានចោទប្រកាន់ទេ បើឧបមថាអណ្តូងពេជ្របើកបានមែន យើងទុកចិត្តថាស្រីបរទេសបានឬនឹងរក្សាផលប្រយោជន៍របស់

មីឌី បើលួចកើបយកពេជ្រទៅលក់យកលុយដាក់ហោប៉ៅខ្លួនឯង បែបហ្នឹងមិន
ខូចខាតអស់ទៅហើយ"

"មែនៗ ត្រឹមជាឈ្មួញត្បូង ឈ្មួញពេជ្រ ដែលសំណាងល្អបានក្លាយជា
ព្រះសុណិសា មានចំណេះដឹងប៉ុន្មានទៅ"

អាលិហ្សា ស្តាប់ការប្រមាថកាតទានដោយមិនមាត់មិន.ក ស៊ប់ជាខ្លី
ពួកគេនិយាយទាល់តែពេញចិត្ត ទើបតបតដោយសម្តីត្រជាក់។

"ខ្ញុំម្ចាស់សុំនិយាយក្នុងហាន:ជាអ្នកជំនាញ មិនមែនក្នុងហាន:ជាឈ្មួញ
ឬក្នុងហាន:ជាអាមិ៉ាបានទេ ព្រះម៉ែម្ចាស់"

"និយាយម៉ោ" សម្តេចព្រះមាតា ឌីណា អនុញ្ញាត។

"មរកតមួយគ្រាប់នោះ..."

នាងចង្អុលទៅខ្សែកមរកតឡោមពេជ្រប្រដេញពន្លឺផ្លេកៗ លើ.ករបស់
ព្រះញាតិវង្សបានសម្តី។



"មើលចម្ងាយរាប់គីឡូម៉ែត្រក៏ថាក្លែងក្លាយ"

"ស្អី... ស្អីគេ!"

"ហើយខ្សែដៃពេជ្រនោះ..."

នាងចង្អុលព្រះញាតិវង្សម្នាក់ទៀត។

"ឈប់អួតថាពេជ្រសុទ្ធទៅ ល្អជាង នោះគេហៅថាពេជ្ររុស្សី ជាត្បូង សំយោគ ដែលមានឈ្មោះថា *ឃ្យូប៊ីក សឺខូនៀ* ចាត់ទុកថាត្បូងក្លែងក្លាយដែល សំយោគ ដើម្បីឱ្យដូចពេជ្រសុទ្ធ ដែលនិយាយឱ្យស្រួលស្តាប់គឺពេជ្រក្លែងក្លាយ នោះឯង បើយកទៅនិយាយទៅអួតថាជារបស់សុទ្ធ ហើយបើគេមើលដឹង ដឹង តែខ្មាសគេ"

"ព្រហើន! ស្រីម្នាក់នេះម៉េចហ៊ាននិយាយបែបនេះ ផ្តេសផ្តាសមែន នេះ ជារបស់សុទ្ធ រុស្សីខាត់"

អាលិហ្សា ញញឹមស្រស់ រឿងអារ.កមនុស្សឱ្យប្រកាប់ នាងមិនចាញ់

"បើនិយាយឱ្យត្រូវ ក្នុងវិស័យត្បូងហៅថា *រុស្សីខាត់* មានន័យដល់ពេជ្រសុទ្ធដែលថ្នែនៅរុស្សី ចាត់ទុកថាជាពេជ្រដែលមានជ្រុងថ្នែស្អាតជាងគេ តែមានការធ្វើពេជ្រ ឃ្យូប៊ីក សឺខូនៀ គឺធ្វើឱ្យឈ្មោះហៅ ពេជ្ររុស្សី ក្លាយជាឈ្មោះហៅរបស់ពេជ្រសំយោគដែលមិនមែនពេជ្រសុទ្ធដោយស្វ័យប្រវត្តិ សូមយល់ផង ព្រះម៉ែម្ចាស់"

"កុហក ខ្ញុំមិនជឿ គឺអ្នកលក់ប្រាប់ថារបស់សុទ្ធ"

"ទិញថ្លៃប៉ុន្មាន ?"

"បីលាន"

"អ៊ូ! ព្រះអាទិត្យ! តាមធម្មតាពេជ្រលំដាប់នេះ ខ្ញុំម្ចាស់លក់តែពីរសែនប៉ុណ្ណោះ ព្រះម៉ែម្ចាស់ លើកក្រោយចង់ទិញដូរ ត្រូវសុំលិខិតបញ្ជាក់ពី GIA ឧបមាថា ខ្ញុំម្ចាស់មាត់មិនល្អ និយាយអីផ្តេសផ្តាស ទ្រង់នឹងបានទាញលិខិត



នោះមកទះកំផ្លៀងខ្ញុំម្ចាស់"

"សម្តីហំណាស់"

"ហើយរឿងអណ្តូងពេជ្រដែលមិនទាន់ដឹងថាមានឬអត់នោះ ឧបមាថា មានមែន វាមិនមែនជីកបានស្រួលៗ ដូចក្នុងកុនដែរ តម្រូវការពេជ្រតែងតែដើរ បញ្ច្រាសទិសនឹងបរិមាណពេជ្រដែលដាក់លក់ក្នុងទីផ្សារ ហើយកន្លងមកមិនមានការជីកយើញអណ្តូងពេជ្រថ្មីៗ ដែលមានកម្លាំងផលិតខ្ពស់ ទោះរកយើញអណ្តូងថ្មីនៅថ្ងៃនេះមែន តែត្រូវរង់ចាំយ៉ាងហោចណាស់ជាងដប់ឆ្នាំទៀតឯនោះទើបអាចយកពេជ្រមកលក់លើទីផ្សារបាន ទំនេរៗ ទៅបើកភ្នែកបើកត្រចៀកមើលប្រព័ន្ធការធ្វើអណ្តូងនៅអាហ្វ្រិចខ្លះទៅ ថាគេធ្វើយ៉ាងម៉េច ហើយការជួញពេជ្រលំដាប់ពិភពលោក Bourses ស្ថិតនៅក្រោមការមើលខុសត្រូវរបស់ បើមិនដឹង ហើយនិយាយផ្តេសផ្តាស ដោយគ្មានអ្វីសម្អាង អ្នកស្តាប់អាចចំអកបាន ព្រះម៉ែម្ចាស់"

"គ្មានមារយាទ គ្មានមារយាទមែន ខ្ញុំជាអ្នកណា នាងជាអ្នកណា ម៉ែចក៏ហ៊ាននិយាយបែបនេះ"

នាងក្រមុំពើងទ្រូងដាក់ដោយមិនខ្វល់ ហើយជ្រើសរើសេជ្របន្ត ដោយត្រូវព្រះញាតិវង្សពីរនាក់សម្លក់ថ្មែ និងពេលមិនឃើញថាអ្នកណានិយាយអី ទើបសុំលាដោយការមិនពេញចិត្ត ខណៈដែលអ្នកដទៃសរសើរ អាលិហ្សា មិនដាច់ពីមាត់។

"ត្រូវខ្លះ ល្អហើយ សមមុខ ពូកែណាស់ថាបន្ទាបបន្ថោកអ្នកដទៃ"

"ជាព្រះញាតិវង្សដ៏ខ្ពង់ខ្ពស់ បែរជាប្រើក្លែងក្លាយ ដឹងដល់ណា ខ្មាសគេដល់នោះ ហ៊ឹៗ ព្រះសុណិសារបស់សម្តេចព្រះមាតាពូកែមែនទែន"

អាលិហ្សា ស្តាប់ តែមិននិយាយអី ក្រៅពីសើចញឹមៗ។

"មើលទៅនាងល្ងីយៗ អេលីហ្សា ម៉ែចក៏មុខស្លេកយ៉ាងនេះ"

សម្តេចព្រះមាតា ឌីណា សួរនាំដោយការព្រួយបារម្ភ ពេលដេញដួល



ដឹងថានាងមិនសូវបាយទឹក ទើបបញ្ជាឱ្យតាំងតុអាហារភ្លាម។

"ខ្ញុំម្ចាស់មិនឃ្លានទេ ព្រះម៉ែម្ចាស់"

នាងឈ្លោកមុខឈ្លោកមាត់ ដើម្បីលាក់អារម្មណ៍មួហ្មងរបស់ខ្លួន។

"នាងត្រូវតែញ៉ាំ នាងស្គមពេកហើយ អេលីហ្សា"

ខ្ញុំបម្រើលើកស៊ុបដំឡូវបារាំងខាប់ៗ មកឱ្យ ដែលក្លិនរបស់វា ធ្វើឱ្យចង់អាហារភ្លាម ពេលភ្លក្សមួយម៉ាត់ រសជាតិ និងកម្តៅរបស់វាភាយពេញរាងកាយតែញ៉ាំបានបន្តិច ក៏ទ្រាំលែងបាន ទើបសម្តេចបញ្ជាឱ្យធ្វើខេកផ្លែឈើដែលនាងចូលចិត្តមកឱ្យមួយចំណិតធំ ទើបប្រឹងញ៉ាំ បានច្រើនគ្រាន់បើ ដែលរសជាតិផ្អែមរបស់វា ធ្វើឱ្យមានកម្លាំង ប៉ុន្តែឱ្យអារម្មណ៍អន្ទឹមអន្ទមដដែល។

"ថ្ងៃស្អែកនេះ ខ្ញុំម្ចាស់សុំរាជានុញ្ញាតទៅទិញរបស់នៅក្នុងក្រុងបានទេ ព្រះម៉ែម្ចាស់ ខ្ញុំម្ចាស់ចង់ទៅមើលគ្រឿងសម្អាងពីរបីមុខ"

"ទៅដើរលេងលម្ហែខ្លះក៏ល្អ ទៅចុះ យើងអនុញ្ញាត"

អាលិហ្សា មានលុយសុទ្ធ និងក្រែឌីតកាតមិនកំណត់ចំនួនទឹកប្រាក់បីបួនសន្លឹកដែល សារីហ្វ ឱ្យ ហើយស្អែកនាងចាកចេញពីទីនេះ ទើបថ្ងៃនេះចំណាយពេលនៅជាមួយសម្តេចព្រះមាតាពេញមួយថ្ងៃ។

ខណៈនោះ សារីហ្វ ពាក់យេទ្បាបាពណ៌សស្អាតវែងដល់កជើង ឈរយ៉ាងសង្ហានៅមាត់ទ្វារ គេសង្ហាជាងដែលនាងធ្លាប់ចាំបានទៅទៀត បន្ទាប់មកគេក៏ដើរចូលមកថើបរាល់ទាក់សម្តេចព្រះមាតា និងព្រះញាតិវង្ស ហើយចូលមកអង្គុយក្បែរនាង។

"កំពុងមើលអី?"

"ច្រើនមុខណាស់ ព្រះពរ ខ្ញុំម្ចាស់កំពុងរើសមរកតឱ្យ ទុកធ្វើគ្លីបកៀបក្រវាត់កឱ្យ សារីហ្វ ហ្នឹង ព្រះពរ"

"នេះជាមរកតឬ បងស្មានថាថ្លើមថ្ម"



"មួយនេះជាមរកតមិនទាន់ថ្មៃ បើចង់នៅក្នុងវិស័យនេះត្រូវចេះមើល

ពេជ្រល្អ គជ់ខ្យង ថ្លើមថ្ម ត្បូងបែបណាហៅថាស្អាត បែបណាហៅថាមិនស្អាត

មួយណាសុទ្ធ មួយណាក្លែងក្លាយ បើចេះមើលគឺអូខេ"

"វាមើលទៅដូចៗគ្នាទាំងអស់ហ្នឹង បងព្រិលភ្នែកហើយនេ៎ះ"

"ជំនួញត្បូងពេជ្រជាជំនួញគ្រោះថ្នាក់ ជារឿងរបស់អ្នកដឹងតិចនិងអ្នក

ដឹងច្រើនមកជួបគ្នា ដូច្នេះហើយទើបមានឱកាសត្រូវកេងចំណេញ បើមិនទាន់

ល្បិច ដឹងតែចប់ហើយ ក្សីយធនច្រើននាក់ហើយ មើលថ្លើមថ្មមួយនេះចុះ

ជាថ្លើមថ្មសាច់ទន់ តម្លៃថោកជាង ចំណែកនេះថ្លើមថ្មសាច់រឹង តម្លៃខុសគ្នា

ឆ្ងាយណាស់ បើបែងចែកមិនដាច់ ដឹងតែចប់ហ្មង"

អាលិហ្សា ជួយបង្រៀនពីវិធីមើលត្បូងដល់គេ។

"ចង់បានមួយណាទេ បងទិញឱ្យ"

"មិនយកទេ ខ្ញុំម្ចាស់គ្រាន់តែមកជួយរើសប៉ុណ្ណោះ ព្រះពរ"

"ម៉ៅយកទាំងអស់ ប៉ុន្មាន ?"

ពេលគេងាកទៅសួរឈ្មួញ ទើបនាងសម្រេចចិត្តចង្អុលត្បូងកណ្តៀង ដើម្បីបង្វែរចំណាប់អារម្មណ៍ ប៉ុន្តែត្រូវកែវភ្នែកមុតស្រួចសម្លឹងមិនព្រិច ឱ្យនាងញ័រខ្លួន ព្រោះដឹងច្បាស់ថាខ្សែភ្នែករបស់គេកំពុងតែប្រាប់ថាត្រូវការអ្វី។

"អូនសមនឹងត្បូងកណ្តៀង តែស្បែកអូនរលោង ពាក់ត្បូងអីក៏ស្អាតដែរ"

គេយកត្បូងកណ្តៀងមួយគ្រាប់ធំមកដាក់លើ.កសខ្ចី ហើយវាល់ចំអាម ពីចុងចង្កាដល់ជីពចរ ដែលធ្វើឱ្យនាងញ័រ ពេលដៀងមើលអ្នកជិតខាង ទើប ឃើញថាពេលនេះនាងនិងគេនៅតែពីរនាក់តាំងពីពេលណាក៏មិនដឹង។

"ចាំបងរកត្បូងកណ្តៀងមកឱ្យអូនច្រើនជាងនេះ ហើយក៏ពេជ្រ...ពេជ្រ តំណាងឱ្យភាពរឹងមាំ និងសម្រស់របស់មនុស្សស្រី បងនឹងរកពេជ្រដែលស្អាត បំផុត ល្អបំផុតមកឱ្យអូន"

"សារីហ្វ ខ្ញុំម្ចាស់មិនត្រូវការ ខ្ញុំម្ចាស់មិនចង់បានអីពីទ្រង់ទេ"



"ហើយអូនចង់បានអី ន្ទាលបងរកមកគរនឹងជើងអូន អាមិ៉ា"

អាលិហ្សា ឱនមុខជ្រប់ មើលព្រំក្រាស់ ទ្រាំស្តាប់សំឡេងខ្សឹបខ្សៀវប្រាប់

ថាស្រឡាញ់របស់គេមិនបាន ព្រោះនាងចង្អុំយំហើយពេលនេះ។

"សារីហ្វ..."

"ហឹម!"

"កន្លងមកយើងទាំងពីរចាប់ផ្តើមជាមួយគ្នាមិនល្អប៉ុន្មាន ខ្ញុំម្ចាស់ធ្វើខ្លួន

មិនល្អ ចូលចិត្តប្រកែក និយាយច្រើន ថែមទាំងទម្លាក់កំហុសឱ្យទ្រង់ជានិច្ច តែ

មានតែពីរយ៉ាងដែលខ្ញុំម្ចាស់ចង់ឱ្យ សារីហ្វ ចងចាំទុក"

"ប្រាប់ម៉ោ"

"ខ្ញុំម្ចាស់ស្រឡាញ់ សារីហ្វ អាចោរពាល អាឆ្កួតកាមរបស់ខ្ញុំម្ចាស់"

"បងដឹង"

គេញញឹមពព្រាយ ហើយទប់ចិត្តមិនបាននឹងដាក់បាតដៃលើដើមទ្រូង

ស្អាបអង្អែលថ្នមៗ ទាំងឆ្វេងទាំងស្តាំ ដែលកម្តៅចេញពីបាតដៃ ធ្វើឱ្យនាងភ្ញាក់

និងកាន់តែញ័រ ពេលចុងម្រាមដៃគ្រវាចុងទ្រូង។ ទោះគេមិនបានប៉ះពាល់លើស

ពីនោះ តែនាងបានដឹងពីភាពក្តៅគគុកដែលកំពុងដុតរាងកាយ។

សារីហ្វ ដាក់បាតដៃក្តៅៗ លើភ្លៅសខ្ចី អូសឡើងលើជារឿយៗ ដែល

ត្រឹមប៉ុណ្ណឹង ក៏មានពន្លឺផ្កាភ្លើងបែកព្រាកៗ ឱ្យនាងដកដង្ហើមដង្ហក់ទៅហើយ

ទើបដៀងមើលទៅផ្សេង និងក្តិចដៃគេជាការដាស់តឿនដោយប្រយោល ប៉ុន្តែ

កែវភ្នែកមុតស្រួចមួយគូនោះនៅតែសម្លឹងនាងមិនព្រិច ថែមទាំងលើកដៃមក

ចាប់មុខ ចាប់ចង្ការរបស់នាងជាប់ ព្រោះនាងចង់គេច ហើយប្រដេញមេដៃលើ

បបូរមាត់ស្តើង បន្ទាប់មកធ្វើឱ្យនាងដឹង ថាគេមានអារម្មណ៍យ៉ាងណា ដោយ

ការថើប។

"ហើយម្យ៉ាងទៀត អូនចង់ប្រាប់អីបង"

"ទាយសាកមើលទៅ ព្រះពរ"



ចំកែវភ្នែកពណ៌ខ្មៅ ស្វែងរកថាមានអ្វីលាក់នៅក្នុងនោះ ហើយជឿជាក់ថាមើលឃើញពន្លឺភ្លើងក្នុងកែវភ្នែកថ្លាយង់នោះ។

"ពូកែធ្វាញ់ធ្វាលមែន ចាំមើលទៅ នឹងសួរចម្លើយពេញមួយថ្ងៃ"

គេអស់សំណើច ទាញរ៉ូបមកដាក់នឹងត្រគាកមូលក្តុំ ចំណែកអាវក្នុងក៏ត្រូវលើកដាក់លើគល់ទ្រូង ហើយក្រសោបសាច់ទន់ល្មើយ និងដួសដងយករសផ្អែមល្ហែមបន្តិចម្តងៗ ទាល់តែនាងរមួលខ្លួនដោយអារម្មណ៍វេទនា ហើយមិនអាចទប់បានទៀត ទើបគេអូសបាតទៅ និងមាត់ទៅតាមអារម្មណ៍ប្រាថ្នាដ៏ព្រៃផ្សៃ។

សារីហ្វ ថើបនាងថ្នមៗ ផ្គឹបថ្ងាសគ្នា ដោយមិនមាត់មិន.ក ហើយនេះជាភាពកក់ក្តៅដ៏ផ្អែមល្ហែម ទើបលែងចាប់អារម្មណ៍ត្បូងកណ្តៀងមួយគ្រាប់នោះទៀត។

គេលើកខ្លួននាងបន្តិច ហើយជ្រៀតជ្រែកទៅរក ឱ្យនាងខ្ចាំម្រាមជើង ខ្លាំងៗ ដៃទាំងពីរក៏ខ្ចាំដើមទ្រូងហាប់ណែន។ ភាពស្រៀវស្រើបដ៏ខ្លាំងក្លាហូរ ដូចទឹកបាក់ទំនប់ ប៉ុន្តែពេលនោះសំឡេងទូរសព្ទក៏រោទ៍ ដែលមិនបាច់មើលក៏ដឹងត្រូវតេរមកតាមទៅធ្វើការ ទើបនាងបញ្ឈប់ ទាស់ត្រង់ថាគេមិនព្រមឈប់។

"សារីហ្វ ត្រូវទៅធ្វើការ"

"មិនបាច់បារម្ភទេ បងនៅមានពេលមួយម៉ោង ដើម្បីឈ្លូចសួរប្រពន្ធក្បាលរឹង"

គេលើកពនាងឱ្យកម្ពស់ត្រូវគ្នា ឱ្យជើងស្រឡូនកៀរចង្កេះបាវសាក់ និងធ្វើសកម្មភាពម្តងហើយម្តងទៀត ទម្រាំតែការស្រែកឃ្លាននេះដល់ទីបញ្ចប់។

អាលិហ្សា រើបម្រះ ពេលត្រូវគេជ្រៀតជ្រែកចូលមកម្តងហើយម្តងទៀត តែត្រូវគេសង្កត់ជាប់ដោយសាច់ដុំ ចាប់ដៃទាំងពីរឱ្យតោងគែមតុ ដោយដៃម្ខាងរបស់គេចាប់ចង្កេះតូចស្តើង ម្ខាងទៀតចាប់ត្រគាកមូលក្តុំ និងគ្រប់គ្រងដោយ



មិនប្រណី ឱ្យនាងប្រឹងទប់សំឡេងថ្ងូរថ្ងូរ រាងកាយកន្ត្រាក់ ពេលដើមទ្រូងទាំង
ពីរត្រូវច្របាច់។

"បើមិនប្រាប់ បងមិនព្រមដោះលែងទេ អានែ"

និយាយចប់ គេក៏ជ្រៀតជ្រែកម្តងទៀត ទាល់តែនាងស្រែកថ្ងូរ ហើយ
ក្រសោបត្រគាកកាន់តែណែន និងចាប់ជើងស្រឡូនដាក់លើដៃមាំមួន បន្ទាប់
មកបន្តការឈ្លានពាន ឱ្យខ្យល់ដង្ហើមរបស់ អាលិហ្សា ដង្ហក់។ គេឱនទៅថើប
គល់ទ្រូងសខ្ចី និងខ្នងម៉ដ្ឋខៃ ទាល់តែកើតស្នាមក្រហម។

សារីហ្វ សម្តែងភាពជាស្វាមីពេញទី ខណៈនោះនាងក៏បានគ្រប់គ្រងគេ
តែម្នាក់ឯង អារម្មណ៍ជាម្ចាស់ក៏ហូរចូលមកជន់ជោរ។

"គិតតែថ្ងូរបែបនេះ និយាយគ្មាយល់ទេហ្នឹង"

"មិនស្រែកក៏បាន មនុស្សឆ្កួត ត្រែកកាមពេកហើយ"

នាងតតាំងដោយសារទប់សំឡេងដង្ហក់ តែការធ្វើសកម្មភាពរបស់គេ

ញាប់រន្ដាន់ ស្ដប់ស្ដល់គ្រប់ពេល និងគ្រប់វិនាទីដែលគេមានឱកាស បង្កើត
ភាពស្រៀវស្រើបដែលមិនអាចប្រឆាំងបាន ព្រោះគ្រប់ពេលកាន់តែខ្លាំងឡើងៗ
ជ្រាលជ្រៅ ឱ្យនាងធ្វើសកម្មភាពតាមគេដែលជាជនឈ្លានពាន ឱ្យសំឡេង
បេះដូងពីរដួងឮបន្ទរគ្នា។

"កុំចាកចេញពីបង មិនអីចឹង កុំថាបងមិនអត័យឱ្យអូន"

អាលិហ្សា ភ្ញាក់ពីដំណេកនៅពេលព្រលឹម ដោយនៅក្បែរខ្លួនទទេស្អាត
និងត្រជាក់ស្រែង គិតថាគេចេញទៅថ្វាយបង្គំព្រះ ហើយប្រញាប់ទៅធ្វើការ។
នាងលើកជង្គង់បញ្ឈរ ជ្រប់មុខនឹងក្បាលជង្គង់ បណ្ដោយឱ្យទឹកភ្នែកហូរ ព្រោះ
នៅលើតុក្បែរក្បាលគ្រែមានកុលាបសមុទ្រខ្សាច់មួយបាច់ និងណូតមួយសន្លឹក
សរសេរថា *ជូនម្ចាស់បេះដូងបង*។

នាងយកណូតនោះទុកក្នុងសៀវភៅក្រាស់ ក្ដិចយកកុលាបមួយទងមក



សង្កត់ពីលើ។ រយៈពេលមួយខែមកនេះ មានរឿងជាច្រើនកើតឡើង ហាក់ដូច

យល់សប្តិ មានទាំងសុខ ទុក្ខ សោកសៅ និងសំឡេងសើច ហើយថ្ងៃនេះជា

ថ្ងៃដែលនាងត្រូវទៅ មានតែគេប៉ុណ្ណោះដែលនាងមិនត្រូវការលា។

"គ្រប់យ៉ាងរួចរាល់ហើយ ព្រះម៉ែម្ចាស់ ថ្ងៃនេះអាមិរ៉ាត្រូវការយាងទៅ

សបតីងនៅឯណាដែរ មានហាងទំនិញបើកថ្មីពីរបីកន្លែង ព្រះម៉ែម្ចាស់"

"ខ្ញុំមិនធ្លាប់ស្គាល់ ជួយណែនាំផង ខ្ញុំចង់ទិញកាបូបស្អាតបានមួយ ទៅ

ទាំងអស់គ្នាតែម្តងទៅ"

"ព្រះម៉ែម្ចាស់"

"ពេលហ្សឺកត្រឡប់មកវិញ ជួយថ្វាយរបស់នេះដល់ទ្រង់ផង និងផ្តាំ

ប្រាប់ថាខ្ញុំសុំទោស"

អាលិហ្សា ហុចប្រអប់លម្អត្បូងមណីតូចៗ ឱ្យខ្ញុំបម្រើ ដែលខាងក្នុងជា

ចិញ្ចៀនពេជ្រដែលនាងគួរដោះឱ្យគេវិញតាំងពីថ្ងៃដំបូង ហើយពេលគេយើញវា

គេនឹងយល់គ្រប់យ៉ាង។

"គ្រប់យ៉ាងរៀបរយល្អទេ ?"

សារីហ្វ កំពុងជាប់ប្រជុំ តែត្រូវបែងចែកពេលវេលាតេរទៅប្រជានផ្នែក អង្គរក្សយូរៗម្តង សួរនាំពីសកម្មភាពរបស់ អាលិហ្សា ដោយមិនដឹងថាហេតុអ្វី ចេះតែខ្វល់ខ្វាយ និងបារម្ភ។ កាលពីយប់មិញនាងញញឹម នាងសើចកក្អិចក្នុងលង្វែកទ្រូងរបស់គេ ប៉ុន្តែពន្លឺភ្នែកដែលមានការឈឺចាប់របស់នាង រំខានចិត្តគេមកដល់ពេលនេះ។

(ក្រាបទូល រៀបរយល្អ អាមិ៉ាកំពុងរើសអីវ៉ាន់ជាមួយខ្ញុំបម្រើ ទូលបង្គំនិងអង្គរក្សឯទៀត ការពារយ៉ាងតឹងរឹង សូមទ្រង់កុំព្រួយព្រះទ័យ ក្រាបទូល)

"យើងកំពុងត្រឡប់ទៅវាំង ប្រាប់អាមិ៉ាថាយើងរង់ចាំសោយអាហារថ្ងៃត្រង់"



(ក្រាលទូល)

ពេលដាក់ទូរសព្ទចុះហើយ សារីហ្វ ក៏គ្រវីក្បាលដាក់ខ្លួនឯងឱ្យឈប់គិត ច្រើន ប៉ុន្តែពេលត្រឡប់មកដល់វាំង និងទទួលបានរបស់ដែលនាងផ្ញើឱ្យក៏មានអារម្មណ៍ដូចត្រូវផ្តាច់ខ្យល់ដង្ហើមមួយរំពេច។

"នាំនាងម៉ោវិញភ្លាម"

គេបញ្ជូតាមទូរសព្ទជាបន្ទាន់។

(អាមិ៉ាកំពុងលព្រះពស្ត្រនៅក្នុងហាង ក្រាបទូល)

"ហៅនាងម៉ោវិញ!"

សំឡេងគ្រហឹមឮខ្លរ ហាក់ដូចរន្ទះបាញ់ ធ្វើឱ្យប្រធានក្រុមអង្គរក្សភាំង ដូចត្រូវទះក្បាលឱ្យបែកអំពិលអំពែក បន្ទាប់មកក៏រូតរះទៅធ្វើតាមបញ្ជា ប៉ុន្តែពេលគោះទ្វារលខោះអាវ បែរជាគ្មានសំឡេងឆ្លើយតប។

"អាមិ៉ានៅខាងក្នុងមែនឬអត់ ?"

"ខ្ញុំឃើញទ្រង់ចូលទៅផ្ទាល់ភ្នែក គ្រប់គ្នាក៏ឃើញ"

ពេលខ្ញុំបម្រើបញ្ជាក់បែបនេះ ទើបប្រធានក្រុមអង្គរក្សសម្រេចចិត្តទម្លាយទ្វារចូលទៅ ដែលខាងក្នុងទទេស្អាត គ្មានមនុស្ស ដែលធ្វើឱ្យគ្រប់គ្នាបើកភ្នែកធំៗ ហាក់ដូចត្រូវខ្មោចលង។

"មួយសន្ទុះធំមុន មានមនុស្សស្រីចេញមកពីបន្ទប់លក្បែរគ្នា តែខ្ញុំមិនបានចាប់អារម្មណ៍"

"ទ្រង់ផ្លោះទៅបន្ទប់ក្បែរ អាមិ៉ារត់បាត់ហើយ"

បញ្ជាតាមរកអាមិ៉ានៃហ្ស៊ីក សារីហ្វ ត្រូវបានផ្សព្វផ្សាយស្លាម ប៉ុន្តែព្រោះព្រះញាតិវង្សជាស្ត្រីត្រូវហាមថតរូប ដូច្នេះហើយការតាមរកស្រីអាស៊ីម្នាក់ដែលមិនចេះនិយាយភាសាព័រសៀគឺបញ្ហាធំ ទើបហាងទំនើបត្រូវបញ្ជាឱ្យបិទទ្វារគ្រប់ច្រក និងហាមមនុស្សស្រីចេញចូល។



"ទូលបង្គំបញ្ជាឱ្យបិទច្រកអស់ហើយ អាមិ៉ាគួរតែនៅខាងក្នុងនៅឡើយ

ក្រាបទូល"

(កុំប្រមាថអាមិ៉ារបស់យើង ថ្មើរណេះចេញទៅខាងក្រៅបានហើយទេ

ដឹង បញ្ជាប៉ូលិសឱ្យពិនិត្យយានយន្តគ្រប់ប្រភេទ ជាពិសេសផ្លូវទៅព្រលាន

យើងនឹងទៅដល់ទីនោះក្នុងពេលដប់នាទី)

"ក្រាបទូល"

មនុស្សស្រីទាំងអស់សុទ្ធតែពាក់អាបាយ៉ាពណ៌ខ្មៅ ពិបាកបែងចែកថា

នរណាជានរណា ខណៈនោះប៉ូលិស និងប្រធានក្រុមអង្គរក្សកំពុងតែវិលក្បុង។

មានស្ត្រីជរាម្នាក់កាន់ឈើច្រត់ដើរង៉ុកៗ ចូលមកតម្រង់ជួរ ដើម្បីចេញពី

ហាង ពេលប៉ូលិសសុំមើលអត្តសញ្ញាណប័ណ្ណ ប៉ុន្តែស្ត្រីជរាត្រចៀកថ្លង់ ស្តាប់

មិនឮ ទោះនិយាយប៉ុន្មានដងក៏ឥតប្រយោជន៍ ថែមទាំងមានក្រុមស្រីជាត់មក

ចោមរោមសុំការអធិប្បាយ ព្រមទាំងគំរាមប្តឹង ទើបប៉ូលិសធុញទ្រាន់ បក់ដៃឱ្យ

ចេញឱ្យអស់។

ខណៈដែលស្ត្រីជរាដើរងុំកៗ នៅតាមចិញ្ចើមផ្លូវហាង ក្បួនរថយន្តរបស់សារីហ្វ ក៏បត់ចូលមកល្មម ទើបលោកយាយឈ្លោកមុខ ដើរបន្ត ហើយទ្បើងទ្បានជំមួយដែលរត់មកចតក្បែរ ដោយអ្នកបើកបរមិននិយាយអីមួយម៉ាត់ ប៉ុន្តែច្បាស់ណាស់ថាមានអ្នកបញ្ជាឱ្យមកយក។

លោកយាយដកដង្ហើមធំ ងើយក្បាលទៅផ្អែកនឹងបង្អែកកៅអី ដោយចិត្តឈឺចាប់ មេកអាប់ប្រឡាក់ពេញមុខដោយសារទឹកភ្នែក។

"ទូលបង្គំទទួលលបញ្ជាឱ្យជូនអាមិ៉ាទៅព្រលានយន្តហោះ"

"ចំា ផ្តាំអរព្រះគុណហ្សឹក ហ្វារីស ផង"

ពេលនោះ វិទ្យុទាក់ទងនៅក្នុងទ្បានក៏បន្លឺទ្បើង ជាសំឡេរបស់ សារីហ្វ កំពុងបញ្ជាការដោយផ្ទាល់ថាឱ្យនាំកងកម្លាំងទៅស្ទាក់នៅអាកាសយានដ្ឋាន។

(អេលិហ្សា ឈិន... ស្រីអាស៊ី រាងខ្ពស់ រូបរាងសមសួន និយាយភាសា



ព័រសៀមិនច្បាស់)

អ្នកនៅក្នុងឡានទាំងប៉ុន្មានបានឮច្បាស់ អ្នកបើកបរលួចមើលនាងតាម កញ្ចក់ក្រោយ តែបែរជាឃើញនាងនឹងធឹងគួរឱ្យភ្ញាក់ផ្អើល ដោយមិនដឹងទេថា ពេលនេះ នាងចង់ដាច់ដង្ហើមទៅហើយ។

ពេលមកដល់អគារអ្នកចេញដំណើរ អាលិហ្សា ក៏ដើរសំដៅការិយាល័យ របស់ក្រុមហ៊ុនជើងហោះអារ៉ាប់អេមិរេតស៍ ប្រាប់គោលបំណងរបស់ខ្លួន និង ឱ្យលិខិតបញ្ជាក់លិខិតឆ្លងដែន អាលិហ្សា តាំង (*ភាសាចិនតៀជីវអាន **តាំង** ភាសាចិនផ្លូវការអាន **ឈិន***) ពេលបានសំបុត្រហើយ ក៏ខ្ចាំវាចោះក្នុងធុងសំរាម បន្ទាប់មកទិញសំបុត្រ ក្រុមហ៊ុនជើងហោះឆែណាអ៊ែរឡាញន៍ បន្តទៅក្រុមហ៊ុន ផ្សេងទៀតចំនួនបី និងខ្ចាំសំបុត្រចោលដូចគ្នា បន្ទាប់មកក៏ហៅតាក់ស៊ីនៅមុខ អគារ ហើយសំណាងដែលជួបអ៊ំបើកតាក់ស៊ីដដែល។

"អ៎ូ! អ៊ិតាអាឡោះ សួស្តី ខ្ញុំប្រាប់ហើយថាយើងត្រូវតែបានជួបគ្នាទៀត

តើចង់ឱ្យខ្ញុំជូនទៅទីណាដែរ ?"

"សួស្ដី"

នាងញញឹមទាំងបង្ខំ ពេលឡើងឡាន។

"ខ្ញុំដាក់ផែនការឡើងនាវាទៅឌូបៃ ជួយជូនខ្ញុំទៅកំពង់ផែផង"

"ល្អ ជានាថារហ័សទាន់ចិត្ត"

ពេលតាក់ស៊ីរបស់អ៊ំរួសរាយបើកចេញពីអាកាសយានដ្ឋាន ក្បួនឡាន បំពាក់សីរ៉ែនជាងដប់គ្រឿងរបស់ហ្សឹក សារីហ្វ ក៏បើកចូលមកយ៉ាងលឿនដូចព្យុះ មានប៉ូលិស និងទាហានរាយកម្លាំងពេញបរិវេណ។

"មានប៉ូលិសពេញព្រលានតាំងពីអម្បាញ់មិញម្ល៉េះ មិនដឹងមានរឿងអីសង្ស័យតាមចាប់ឧក្រិដ្ឋជន"

"បែបហើយ"

នាងធ្វើភ្នែកឡេមឡាម ដើម្បីហាមទឹកភ្នែក មិនចង់ឱ្យអ៊ំតាក់ស៊ីសង្កេត



ឃើញថាបេះដូងរបស់នាងខ្ចៃខ្ចាំបាត់ទៅហើយ។

អូនត្រូវតែទៅ អូនដឹងតែប៉ុណ្ណឹង!

គេគួរបានជួបមនុស្សស្រីដែលសក្តិសមនឹងគេជាងនាង មិនមែននាង

ដែលទាំងជាស្រីបរទេស ស្រីខុសសាសនា ហាន:តូចទាប ត្រឹមជាឈ្នួញត្បូង។

លាហើយ ម្ចាស់បេះដូងអូន!

១៥

តាមរក

ពីរថ្ងៃក្រោយមក អាលិហ្សា ក៏ឡើងយន្តហោះចាកចេញពីឌូបៃមកកាន់សេអ៊ូល ដោយបេះដូងទទេស្អាត។ សំឡេងតាមវិទ្យុទាក់ទងពីបន្ទប់បញ្ជាការហោះហើរ ប្រាប់ថាកន្លះម៉ោងទៀត យន្តហោះនឹងចុះចតនៅអាកាសយានដ្ឋានអន្តរជាតិអ៊ីនឆនហើយ។

ដល់ផ្ទះហើយ តែផ្ទះរបស់នាងគឺកន្លែងណាឱ្យប្រាកដទៅ?

អនុស្សាវរដ៏រីករាយផុសនៅក្នុងការចងចាំ ធ្វើឱ្យនាងញញឹមដោយមិនដឹងខ្លួន តែបន្តិចក្រោយមកទឹកភ្នែកក៏រលីងរលោង ពេលរូបភាពនោះរលាយ។



នាងអង្គុយស្ងៀមនៅលើយន្តហោះជាពេលជាច្រើនម៉ោង មិនញ៉ាំ មិនផឹក មិន

កម្រើកខ្លួន ព្រោះវាពិបាកណាស់ដែលប្រាប់ឈឺចាប់ខ្លាំងប៉ុនណា ទោះចង់ជួប
គេយ៉ាងណា តែវាចប់ទៅហើយ។

អ្នកដំណើរទាំងឡាយចុះពីយន្តហោះហើយ សល់តែ អាលិហ្សា ម្នាក់ ដែលអង្គុយបិទភ្នែក មិនព្រមងើប ទើបអ៊ែរ៍ហូធែសចូលមកដាស់ តែបែរជាជួប ភាពមិនប្រក្រតី គឺដាស់យ៉ាងណាក៏មិនភ្ញាក់។

"ហៅក្រុមសង្គ្រោះបន្ទាន់របស់ព្រលានយន្ត អ្នកដំណើរសន្លប់!"

'លាហើយ សារីហ្វ'

សារីហ្វ មើលនាងទាល់តែបាត់ពីភ្នែក ឃើញ អាលិហ្សា ឈរញញឹម ទើបស្ទុះចុះពីឡាន រត់ទៅរកនាងភ្លាម។ គេឃើញនាងយំ ព្រមទាំងឈ្លោកមុខ ដើរចូលទៅលាយឡំនឹងមនុស្សម្នាជាច្រើន នាងដើរចេញឆ្ងាយហើយ ដោយគេ គិតតែពីស្រែកហៅដូចមនុស្សឆ្កួត និងមិនយូរប៉ុន្មានក៏លែងមាននាងឱ្យឃើញ

នៅក្នុងចំណោមមនុស្សម្នាទាំងនោះ ដែលធ្វើឱ្យគេងងឹតជុំទិស។

គិតទៅ! ធ្វើយ៉ាងម៉េចទៅ! ធ្វើយ៉ាងណាឱ្យនាងត្រឡប់មកវិញ គិតទៅ

អាល្ងង់ ធ្វើយ៉ាងណាទើបប្រាប់ឱ្យនាងដឹងថាគេកំពុងអង្វរករនាងនៅត្រង់នេះ!

"ព្រះបុត្រា"

សារីហ្វ មិងមាំង ច្របូកច្របល់ និងអស់កម្លាំងកំហែង។

ហេតុអី...

"ព្រះបុត្រា"

អាលី ដាស់ចៅហ្វាយតិចៗ ទើប សារីហ្វ ភ្ញាក់ពីយល់សប្ដ ហើយពេល

សម្រាបខ្សែភ្នែកបាន និងឈ្លេកមើលនាឡិកា ទើបដឹងថាបានសម្រាកខ្សែភ្នែក

កន្លះម៉ោងប៉ុណ្ណោះ។

គេក្ដាប់ដៃមកសង្កត់គ្រាប់ភ្នែកដែលក្រហមងាំង ព្រោះមិនបានដេកពួន

ដើម្បីបណ្ដេញអារម្មណ៍ហេងហាងចេញពីក្នុងទ្រូង។



"មានអីរឹតចម្រើនខ្លះ?"

"ទូលបង្គំត្រួតពិនិត្យលម្អិតហើយ គ្មានមនុស្សស្រីឈ្មោះ អេលីហ្សា ចេញទៅក្រៅប្រទេសទេ ក្រាបទូល"

បានស្តាប់ហើយ គេក៏ខាំធ្មេញក្រតៗ ភ្នែកក្តៅតាយៗ។

"ចុះខាងព្រំដែនជើងគោក ជើងទឹក ជើងអាកាស គ្រប់ជើង ប្រពន្ធយើង បាត់ខ្លួន ដោយគ្មានតម្រុយបែបនេះម៉េចបាន ឈ្មោះនាង អេលីហ្សា រកមើលតួប្រកបឱ្យច្រើនប្រភេទហើយនៅ?"

"សូមទ្រង់អភ័យ ទូលបង្គំសាកល្បងគ្រប់វិធីហើយ អាចទៅរួចទេថាជាឈ្មោះក្លែងក្លាយ ក្រាបទូល"

"ចេញទៅ ចេញឱ្យផុត ចេញ!"

"ថ្វាយបង្គំលា"

អាលី ស្ទុះស្ទាថយក្រោយ ចេញទៅភ្លាម។

សារីហ្វ ជេរខ្លួនឯងមិនដឹងប៉ុន្មានដង ព្រោះមួយថ្ងៃហើយមួយថ្ងៃទៀត ដែលមិនបានដំណឹងពីនាង គ្មានទិន្នន័យ គ្មាន... គ្មានអីរឹកច្រើន គេចាប់ផ្តើមក្លាយជាអាល្ងីល្ងើបំផុតនៅក្នុងលោក ប្រពន្ធម្នាក់នៅធ្វើឱ្យបាត់ គេចង់កម្ទេចតែគ្រប់យ៉ាងដែលនៅពាំងមុខ។

កាមេរ៉ាសុវត្ថិភាពតាមចាប់រូបភាពនាងបានត្រឹមមុខទ្វារហាងទំនិញ និងបន្ទាប់ពីនោះនាងក៏បាត់ទៅជាមួយក្រុមស្ត្រីពាក់អាបាយ៉ាពណ៌ខ្មៅ នាងបាត់ទៅ ហាក់ដូចមិនធ្លាប់មានវត្តមាននៅក្នុងលោកនេះ។

ពេលវេលាដែលកន្លងផុតទៅ មានន័យថានាងកាន់តែទៅឆ្ងាយពីគេ។ គេមិនអាចបិទភ្នែកបានទៀតទេ ពេលផ្តួលខ្លួនទៅលើគ្រែ ពេលភ្លេចខ្លួនគឺតែងតែហៅឈ្មោះនាង ហើយឃើញតែភាពទទេស្អាតនៅក្បែរខ្លួន ពេលជួបនរណាមានមុខមាត់ស្រដៀងនាង ក៏រត់ទៅរកដោយមិនដឹងខ្លួន ដើម្បីទៅជួបនឹងភាពអស់សង្ឃឹម។



ពេលវេលាកន្លងផុតទៅច្រើនប៉ុនណា សេចក្តីស្រឡាញ់ក៏ក្លាយជាគំនុំ

ស្រឡាញ់ខ្លាំង គុំកួនក៏ខ្លាំង អារម្មណ៍របស់គេមួហ្មង ព្យាយាមទប់កំហឹង គ្មាន

អារម្មណ៍ចង់អាហារ គ្មានចិត្តឆ្លើយសំណួរអ្នកណា និងមិនត្រូវការឱ្យអ្នកណា

មកចេះដឹង។ គ្រប់ដង្ហើមចេញចូល គិតតែទប់ការឈឺចាប់ ដែលជោរជន់ ធ្វើឱ្យ

ដកដង្ហើមមិនចេញ ព្រោះគេបានបត់បង់មនុស្សស្រីដែលធ្លាប់ដកដង្ហើមរួមគ្នា

មានបេះដូងលោតក្នុងរង្វាក់តែមួយ ហើយគេក៏បាត់បង់ពិភពលោកទាំងមូល។

ពេលវេលាកន្លងផុតទៅយូរប៉ុនណាក៏មិនដឹង ដឹងត្រឹមថាបើកភ្នែកឡើង

ក៏ឃើញពិតានពណ៌ស ក្រែមន្ទីរពេទ្យ និងមានអារម្មណ៍ថាមិនស្រួលខ្លួនសោះ

ហើយ ដៃជើងទាំងពីរឈឺសង្កៀរ ព្រោះត្រូវម្ភុលចាក់មិនដឹងជាប៉ុន្មានម្ភុល។

នាងដកដង្ហើមកាន់តែញាប់ និងមានអារម្មណ៍ភ័យខ្លាចយ៉ាងម៉េចក៏មិនដឹង

ហើយមនុស្សដំបូងដែលស្ទុះចូលមករកគឺអ្នកម្តាយ។

"អាលីស... អាលីស ឈឺខ្លាំងទេកូន ?"

អាលិហ្សា ព្រិចភ្នែកញាប់ស្អែក ទើបអាចនិយាយបាន។

"ម៉ាក់..."

"លែងអីហើយកូន ម៉ាក់នៅទីនេះហើយ ម៉ាក់ប៉ាភ័យចង់ងាប់ពេលពេទ្យតេរទៅ"

អ្នកម្តាយយំហាក់ដូចចង់ដាច់ខ្យល់ ចំណែកឪពុកក៏អង្គុយធ្វើមុខក្រមូវនៅលើសាឡុង។

"សារីហ្វ ជាអ្នកណា ?"

"ប៉ាវ៉ា អាលីស ទើបតែដឹងខ្លួន កុំទាន់អាលសួរ"

"ត្រូវតែសួរ! កូនជើងល្អគិតតែយំហៅ សារីហ្វៗ វាជាអ្នកណា!"

ថៅកែ ឈិន ខឹងសម្បា ព្រោះកូនស្រីទោលលួចទៅមជ្ឈិមបូព៌ារាប់ខែ



មិនដែលទាក់ទងមកសូម្បីម្តង ហើយដែលខឹងចេញផ្សែងនោះគឺ...

"សុំអនុញ្ញាតពិនិត្យអ្នកជំងឺ"

លោកគ្រូពេទ្យចូលមកជាមួយគិលានុបដ្ឋាយិកាឈុតស រុញរទេះដាក់ឧបករណ៍នានាចូលមក។

នាងរៀបរៀងគំនិតមិនទាន់ត្រូវ មានអារម្មណ៍ប្លែកៗ ដែលមនុស្សស្រីមិនពាក់ស្បែឃ្មុំ ទាំងដែលត្រឡប់មកដល់ប្រទេសរបស់ខ្លួនហើយ ក៏នៅតែមានអារម្មណ៍មិនទម្លាប់។

"ខ្ញុំ... កើតអីលោកគ្រូពេទ្យ?"

"អ្នកនាង ឈិន កំពុងមានផ្ទៃពោះខ្ចីខែ ចាប់ពីពេលនេះទៅត្រូវយកចិត្តទុកដាក់ចំពោះការហូបចុកផង ទោះចាញ់ខ្លាំង ញាំអីមិនកើត តែត្រូវញាំខ្លះ"

លោកគ្រូពេទ្យនិយាយច្រើនណាស់ ប៉ុន្តែនាងមិនចាប់អារម្មណ៍ស្តាប់ព្រោះចិត្តរវល់ផ្ចង់ទៅលើពាក្យថា *មានផ្ទៃពោះ* ដែលពាក្យមួយម៉ាត់នេះ ធ្វើឱ្យនាងរឹងមាំម្តងទៀត។

អាលិហ្សា ឱបខ្លួនឯង យំដោយមិនខ្មាសអ្នកណា យំទាល់តែឪពុកម្តាយ

យំតាម។

"ម៉ាក់និយាយជាមួយពេទ្យរឿងរម្លូតហើយ"

"មិនបាន មិនបានដាច់ខាត ខ្ញុំមិនព្រមឱ្យអ្នកណាធ្វើបាបកូនរបស់ខ្ញុំទេ"

"ហើយវាមានអីកើតឡើង អាលីស ប្រាប់ម៉ាក់ម៉ោ សារីហ្វ ម្នាក់នោះជា

អ្នកណា វាធ្វើបាបកូនមែនទេ ?"

"ខ្ញុំសុំនៅម្នាក់ឯងមួយសន្ទុះ ខ្ញុំសុំទោសដែលធ្វើឱ្យប៉ាម៉ាក់ខូចចិត្ត ខ្ញុំ

សច្ចបានថា ខ្ញុំនិងគេស្រឡាញ់គ្នា យើងស្រឡាញ់គ្នា... ពេលនេះកុំទាន់អាល

សួរនាំអីខ្ញុំ"

ពីរបីថ្ងៃក្រោយមក អាលិហ្សា ក៏ចេញពីមន្ទីរពេទ្យ ហើយសម្រេចចិត្ត



រកមើលផ្ទះមួយខ្នងដែលមានទីផ្លាឱ្យកូនរត់លេង មានរបងជុំជិត មានសុវត្ថិភាព

និងសូប់ស្ងាត់ តែពេលឪពុកដឹងថានាងចង់រើចេញក៏ខឹងដាច់ក្បាល។

"ទៅណាមិនបានទេ ប៉ាមិនព្រមដាច់ខាត ទោះប៉ាស្អប់ អាសារីហ្វ ស្អីគេ នោះ តែឯងជាកូនស្រីរបស់ប៉ា កូនក្នុងពោះជាចៅរបស់ប៉ា ឯងចង់យកចៅរបស់ប៉ាទៅណា!"

ភ្នែករបស់ថៅកែ ឈិន ឡើងក្រហម ទាំងខឹង ទាំងសម្បា តែកូនគឺកូន ទោះយ៉ាងណាក៏ស្រឡាញ់ និងអភ័យឱ្យបានជានិច្ច។

អាលិហ្សា ទ្រហោយំ ឱនក្រាបឪពុកម្តាយ ព្រោះនាងមិនចាំបាច់រកមើលផ្ទះ ឬអាឡោះអាល័យផ្ទះណា ក្នុងពេលដែលផ្ទះមួយនេះនៅតែបើកទ្វារស្វាគមន៍នាងជានិច្ច... នាងត្រឡប់មកដល់ផ្ទះហើយ។

បន្ទាប់ពីពាក់ឈុតខាហ្វតាន និងអាបាយ៉ាជាងមួយខែ អាលិហ្សា មានអារម្មណ៍ប្លែកៗចំពោះខ្លួនឯងដូចគ្នា ដែលបានពាក្យរ៉ូបខ្លី សម្រុងត្រឹមស្មងជើង

ម្តងទៀត និងទើបតែសង្កេតឃើញថាក្នុងទូមានខោអាវរឹបរាងច្រើនយ៉ាងនេះ។

នាងសម្រាកតែពីរបីសប្តាហ៍ក៏មកធ្វើការនៅហាងវិញ និងជារៀងរាល់សប្តាហ៍ទៅជួបពេទ្យ ដើម្បីតាមដានការលូតលាស់របស់គភ៌។ នាងព្រមផឹកទឹកដោះគោដែលមហាស្អប់ ដោយការស្តាប់បង្គាប់ ទទួលទានវិតាមីន និងអាហារតាមពេទ្យណែនាំគ្រប់យ៉ាង ហើយទំនេរក៏អានសៀវភៅរាប់សិបក្បាលពាក់ព័ន្ធនឹងការចិញ្ចឹមកូន។

ឪពុកកុម្ម៉ង់ពង្រីកបន្ទប់ទាំងនៅផ្ទះ និងហាងឱ្យសក្តិសមសម្រាប់ក្មេងរួចរាល់ លទ្ធផលពិនិត្យប្រាប់ថា នាងពពោះកូនភ្លោះ។

"ត្រូវតបន្ទប់ទៀត"

ថៅកែ ឈិន អេះក្បាលបណ្តើរ កុម្ម៉ង់គេបណ្តើរ ខណៈនោះក៏ទិញរបស់លេងមកពេញបន្ទប់ សម្ភារៈរៀនសូត្រ សៀវភៅរឿងនិទាន តុកៅអីសៀវភៅខោអាវគ្រប់ម៉ូតគ្រប់ម៉ាក។



ពេលវេលាកន្លងផុតទៅមួយខែហើយមួយខែទៀត ពោះរបស់នាងធំ
បន្តិចម្តងៗ និងដឹងថាគភ៌រឹងមាំណាស់។ ដំបូងនាងគិតថារាងកាយប្រហែល
ស្គីកស្រពន់ អីកអ៊ាក ធ្វើអីមិនសូវស្រួល តែនាងបែរជាស្រឡាញ់ពេលដែល
មានកូនៗ លូតលាស់នៅក្នុងផ្ទៃ។ រាងកាយសម្របខ្លួនទៅតាមចង្វាក់របស់វា
ដោយមិនដឹងខ្លួន គ្រប់យ៉ាងសូប់ស្ងៀម ផ្ទេរក្តីស្រឡាញ់ និងភាពកក់ក្តៅឱ្យ
កូនៗគ្រប់ពេល។

"ជិតសម្រាលហើយឬនៅអ្នកនាង ?"

"ខែនេះហើយ"

មួយរយៈក្រោយនេះឈ្មួញកណ្តាលតែងតែងយកវត្ថុសក្តិសិទ្ធិមកផ្ញើ សុំ
ឱ្យស្រួលសម្រាលកូន។ នាងក៏ធ្លាប់បានឮពាក់ព័ន្ធជំនឿផ្សេងៗ ជាច្រើនដែរ
តែមិនធ្លាប់នឹកនា ព្រោះនាងមាន សារីហ្វ នៅក្នុងចិត្តជានិច្ច នាងនឹកគេ និង
រក្សាទុកក្តីស្រឡាញ់របស់គេនៅក្នុងចិត្តជារៀងរហូត។

ហើយថ្ងៃមួយ ខណៈដែលកំពុងធ្វើបញ្ជី អាការៈឈឺពោះក៏ចាប់ផ្តើម និង
ឈឺខ្លាំងទៅៗ ធ្វើឱ្យនាងដកដង្ហើមមិនទាន់ មានអារម្មណ៍ថាស្បូនកំពុងច្របាច់
ទើបប្រមូលកម្លាំងកំហែង ដើរទៅគោះទ្វារបន្ទប់ដេករបស់ឪពុកម្តាយ ហើយ
ពីរនាទីក្រោយមក នាងក៏ត្រូវនាំទៅឯឡាន ដើម្បីទៅមន្ទីរពេទ្យ។

"គ្រប់យ៉ាងនឹងអូខេ បន្ធូរអារម្មណ៍ សប្បាយៗ កុំខ្លាច ម៉ាក់នៅត្រង់នេះ
ហើយ អាលីស"

ថៅកែស្រីនិយាយពាក្យដដែលៗ ទើបនាងត្រូវលួងលោមគាត់វិញថា
នាងមិនអីទេ។ ការសម្រាលកូនត្រូវតែឈឺចាប់ហើយ នាងរីករាយទទួលយក
ព្រោះចង់ឃើញមុខកូនៗ ខ្លាំងណាស់ ចង់ប្រាប់ សារីហ្វ ថាកូនរបស់យើងជិត
កើតហើយ ចង់ទាញគេមកឱប ខ្សឹបប្រាប់ពាក្យពេជ្រជាច្រើនឱ្យគេដឹង។

អាលិហ្សា ឈឺពោះសម្រាលរយៈពេលប្រាំបីម៉ោង ពេទ្យឆ្មបតាមជាន
អាការៈជារៀងរាល់ម៉ោង ប្រាកដណាស់ថាបណ្តោយឱ្យដំណើរការតាមធម្មជាតិ



រហូតមកដល់ពេលវេលាមួយ នាងទ្រាំសឹងលែងបាន រាងកាយចង់ដាច់ជាពីរ ខំប្រឹងរាប់ចង្វាក់ដកដង្ហើមចេញចូល ដកដង្ហើមចូលជ្រៅៗ រាប់មួយ រាប់ពីរ សម្រួលអារម្មណ៍ភ័យខ្លាចឱ្យបាន មិនអីចឹងនឹងខ្យល់គរមិនខាន ហើយមិនយូរប៉ុន្មាន គ្រប់យ៉ាងក៏ធូរស្រាល។

សំឡេងស្រែកយំរបស់ទារកទើបកើតពុះងំ គិលានុបដ្ឋាយិកាកត់ត្រាពេលវេលា ហើយប្រាប់ថាកូនស្រីកើតមុនកូនប្រុសមួយនាទី ហើយកូនទាំងពីរមាំមួនល្អណាស់ ដែលធ្វើឱ្យពេទ្យសរសើរ។

"ចង់មើលកូនៗទេ?"

គិលានុបដ្ឋាយិការុំកូនភ្លោះនឹងក្រណាត់ស ហើយបីមកឱ្យ អាលិហ្សាក៏ងក់ក្បាល ញញឹមទាំងទឹកភ្នែក ហើយខ្សឹបប្រាប់ សារីហ្វ នៅក្នុងចិត្ត ពេលបានប៉ះថ្ពាល់ទន់ៗ របស់កូនទាំងពីរ។

កូនៗរបស់ទ្រង់ដូចទ្រង់បេះបិទ!

នាងស្រឡាញ់កូនៗ ហើយសង្ឃឹមថា សារីហ្វ នឹងស្រឡាញ់កូនភ្លោះដូចនាងដែរ។

រយៈពេលម្តែបួនម៉ោងក្នុងមួយថ្ងៃ តើមានប៉ុន្មានដងទៅដែលមនុស្ស

ពីរនាក់នឹកគ្នានៅក្នុងពេលតែមួយ។ សារីហ្វ ឧទ្ទិសពេលវេលាធ្វើការហាក់ដូចគ្រឿងចក្រ លាក់ទុកអារម្មណ៍ទាំងអស់ឱ្យក្លាយជាភាពសោះកក្រោះ គ្មានភាពកក់ក្តៅ គ្រប់គ្នាខ្លបខ្លាចគេ និងគ្មានអ្នកណាហ៊ាននិយាយដល់ឈ្មោះអាមិ៉ានៃហ្វេសសានទៀត ប៉ុន្តែសុខៗ ថ្ងៃនេះមានអារម្មណ៍មួយដាស់តឿនមិនឈប់ដែលធ្វើឱ្យគេមួម៉ៅ ដូចបានឮសំឡេងរបស់នាង ប៉ុន្តែគេមិនដឹងថាទៅស្វែងរកនាងនៅឯណា។

"សារីហ្វ អារម្មណ៍មិនល្អឬ?"

"ក្រាបទូល ទ្រង់ក្តៅក្រហាយគ្រប់ពេលវេលា ខឹងដាច់ក្បាលដាច់កន្ទុយ

គ្មានអ្នកណាហ៊ានមើលមុខ"

"ណ្តើយ! មួយរយៈទៀតគង់តែអស់អីហើយ?

ហ្វារីស មិនជ្រៀតជ្រែករឿងផ្ទាល់ខ្លួនរបស់ប្អូនប្រុស ប៉ុន្តែពេលវេលាកន្លងផុតទៅជិតមួយឆ្នាំហើយ សារីហ្វ នៅតែតាមរក អាលិហ្សា។ គេតែងតែស្តាប់ការរាយការណ៍រឿងនេះ ដឹងថាប្អូនប្រុសទៅគ្រប់ទីកន្លែង ជាពិសេសកោះតៃវ៉ាន់ សុំត្រឹមមានតម្រុយទោះបន្តិចបន្តួច ក៏ហោះហើរទៅភ្លាមហាក់ដូចព្យុះហើយសព្វថ្ងៃនេះមានតែកំហឹង រហូតដល់...

អានែអូនកុំចាកចេញពីបងទៀតអីយើងបានជួបគ្នានៅកណ្តាលសមុទ្រខ្សាច់ បងលង់ស្នេហ៍អូន ទោះវាមើលទៅឆាប់រហ័សពេកក៏ដោយ... អានែបងនឹកអូនស្ទើរឆ្កួតទៅហើយ មិនដឹងអីពាក់ព័ន្ធនឹងអូន សូម្បីតែឈ្មោះពិតប៉ុន្តែបងព្យាយាមតាមរកអូនឱ្យឃើញ សូមមេត្តាទាក់ទងមកបងវិញ។

បើនរណាដែលគិតថាអាចជួយតាមរកនាងបាន សូមទាក់ទងមកជា
បន្ទាន់។

ហ្ស៊ីក សារីហ្វ អាល់ មីឌីស

ការប្រកាសតាមទំព័រកាសែតអន្តរជាតិ និងតាមទំព័របណ្តាញសង្គម
របស់រាជវាំង ធ្វើឱ្យប្រមុខនៃមីឌីសទះថ្ងាសខ្លួនឯង ធ្វើមុខដូចមិនចង់ជឿថា
ប្អូនប្រុសមហាសោះកក្រោះប្រឹងប្រែងតាមរកស្រីម្នាក់ដល់ថ្នាក់នេះ។

ក្នុងសេចក្តីប្រកាសមិនបានប្រាប់ភិនភាគរបស់ស្រីម្នាក់នោះ ប៉ុន្តែបើ
នាងបានអានកាសែតមួយច្បាប់នេះ នាងនឹងដឹងភ្លាមថាប្អូនប្រុសរបស់គេមាន
ន័យដល់នាង។

ប៉ុន្តែមួយឆ្នាំហើយមួយឆ្នាំទៀត ក៏នាងមិនផ្លាប់ទាក់ទងមក។



១៦

វិលវិញ

ការចិញ្ចឹមបីបាច់ក្មេងទាំងសប្បាយ និងហត់នឿយជាងការអានតាមរយៈសៀវភៅ។ បូបូ និង យ៉ូយ៉ូ សរសេរអក្សររបស់ពួកគេដោយខ្លួនឯង ក្មេងៗញញឹមរីករាយនិងសើចស្រស់ស្រាយនៅលើគ្រែ និងអាចស្រែកដោយគ្មានហេតុផលដោយមិនកំណត់ពេលវេលា។

អាលិហ្សា ថតរូបនិងថតវីដេអូជារៀងរាល់ខែ មានមោទនភាពដែលទម្ងន់របស់ក្មេងៗកើនឡើងនិងមានសុខភាពល្អ។ ឪពុកម្តាយរបស់នាងលង់ចៅទាំងពីរស្ទើរតែមិនធ្វើការធ្វើងារអីផ្សេង ពេល យ៉ូយ៉ូ តើឮអីកៗ លោកតាក៏ស្រែកប្រាប់ថាចៅញញឹមដាក់ ហើយនាំចៅៗដាក់ក្នុងរទេះថ្មីសន្លាងទៅដើរ

ហត់មាត់ថា ចៅខ្ញុំៗ។

"លោកតាលង់ចៅហួសហេតុពេកហើយ"

ចៅកែស្រីរអ៊ូរទាំងអស់សំណើច ព្រោះរបស់លេងនៅក្នុងបន្ទប់ក្មេងៗ កើនឡើងជារឿយៗ លើកចុងក្រោយលោកតាលួចទៅទិញសេះបះបើកធំ សម្បើមចូលផ្ទះហើយត្រូវលោកយាយស្តីឱ្យថាទើសទែង នោះហើយទើប លោកតាផ្អាកទិញ។

អាលិហ្សា ញញឹមនិងមើលលោកតាបីចៅ ហើយអត់មិនបាននឹងគិតថា កូនគ្មានឪពុកបីដូចគេ។

ពេលក្មេងៗ អាចញ៉ាំអាហារផ្សេងក្រៅពីទឹកដោះម្តាយ នាងក៏ដាំបបរ ប៉ន់លាយល្ពៅ ការ៉ុត និងប័របញ្ចុកវាល់ថ្ងៃ ដោយមិនភ្លេចមើលថែខ្លួនឯងដែរ ដោយការមើលថែរូបរាងគ្រប់គ្រងអាហារការហូបចុក និងហាត់ប្រាណ ដើម្បី



ត្រៀមខ្លួនត្រឡប់ទៅកាន់ពិភពចាស់ នោះគឺពិភពគ្រឿងអលង្ការ។

ពេលវេលារបស់ទារកតូចដែលចូលចិត្តស្រែកយំអះង៉ាៗ បានកន្លងផុត ទៅ ត្រូវជំនួសដោយក្មេងកំពុងរៀនវារ រៀនងើបឈរ រៀនដើរ រៀននិយាយស្តី បុិកប៉ក់ បន្ទាប់មកក៏អាចរត់ត្រង់ផ្លូវ និងនិយាយស្តីចែសចស។

បូបូ បុិនម្ញឹកម្ញ៉ក់ និងតាំងខ្លួនជាបងស្រីដែលមានបទពិសោធជ្រៅជ្រះ ជាងប្អូនប្រុស ទាំងដែលកើតមុនមួយនាទីសោះ។

ពេលមានអាយុគ្រប់ពីរខួប បូបូ និង យ៉ូយ៉ូ ក៏ក្លាយជាបិសាចតូច ងរង៉ក់ មិនស្តាប់ហេតុផល ចូលចិត្ត ជួសជុល របស់របរ រឹងក្បាលតាមធម្មជាតិរបស់ ក្មេងអាយុពីរខួប។ ពីរនាក់បងប្អូនជួយគ្នាយកពណ៌មេជីកផាត់ពណ៌ទូតាំង ពេជ្រ យកអំបិលមកចាក់លើកម្រាល ហើយស្រោចទឹក មិនអីចឹងក៏វើទូរទស្សន៍ ហែកសៀវភៅរឿងនិទាន ហើយនិយាយប៉ប៉ាច់ប៉ប៉ោចមិនឈប់មាត់ និងចេះ ចាំពាក្យអសុរោះដែលបានឮក្នុងទូរទស្សន៍។ កាលនោះនាងសឹងតែចង់ឱ្យកូន

ទៅអ្នកដទៃ ប៉ុន្តែពេលគ្រប់អាយុបីខួប ពួកគេក៏ក្លាយជាទេវតាតូច សុភាពរាបសារ ទន់ភ្លន់ ដែលនេះជាការលូតលាស់មួយដំណាក់កាលទៀតរបស់ក្មេងៗ។ យ៉ូយ៉ូ ចូលចិត្តជិះកង់ និងគូររូបផាត់ពណ៌ក្នុងសៀវភៅ ចំណែក បូបូ ចូលចិត្តឆ្កែងឆ្កេងពេជ្រជាមួយម្តាយ។

"មាសមួយខ្សែនេះទម្ងន់... ខ្សែនេះទម្ងន់... មែនទេ ?"

បូបូ ជួយម្តាយលក់អីវ៉ាន់ដោយការធ្វើខ្លួនជាភ្ញៀវ។ នាងតូចដាក់កាក់តម្លៃ... ទៅលើតុ ហើយប្រាប់ដោយការជឿជាក់ថា ខ្ញុំទិញមួយខ្សែនេះ ធ្វើឱ្យលោកតាលោកយាយអស់សំណើចមិនឈប់។

"ម៉ាក់... ម៉ាក់ស្រឡាញ់ បូបូ ម៉ាក់... ម៉ាក់ស្រឡាញ់ បូបូ ទេ ?"

"ចំ៎ ស្រឡាញ់ស្រីស្អាត"

អាលិហ្សា ឱបនិងថើបប្អូនស្រី ចំណែកកូនប្រុសដែលកំពុងដាំដូងដុំវិញបន្ទប់ ក៏ប្រញាប់រត់មកឱ្យម្តាយដោយចោះរបស់លេងនៅក្នុងដៃចោល



ទើប បូបូ លើកដៃច្រត់ចង្កេះ ត្រាប់កាយវិការនិងសំឡេងរបស់ម្តាយដូចបេះបិទ។

"យ៉ូយ៉ូ លេងហើយត្រូវចេះរៀបទុកដាក់ឱ្យមានរបៀប"

"គេនឹងលេងត"

"ខ្លួនឯងកុំតមាត់នឹងបង បងប្រាប់ត្រូវតែស្តាប់បង្គាប់"

បូបូ និយាយដោយទឹកមុខមាំត្រាប់តាមម្តាយ ហើយដឹកដៃប្អូនប្រុសទៅ

ជួយរៀបចំរបស់ដាក់កន្ត្រក ធ្វើឱ្យអ្នកម្តាយដែលកំពុងថតវីដេអូអត់សើចមិន

បាន។ ការមានកូនគឺជារឿងដែលអស្ចារ្យបំផុតនៅក្នុងជីវិត។ បូបូ ចូលចិត្តឈរ

ឱបដៃមើលត្រង់ទៅមុខដូចម្តាយ ចំណែក យ៉ូយ៉ូ ចូលចិត្តញញឹមរបុលរប៉ូចដូច

ឪពុកបេះបិទ។

ក្មេងៗលូតលាស់លឿនជាងការគិត អ្នកខ្លះអាចគិតថាក្មេងអាយុបីឆ្នាំ

ទៅដឹងខ្យល់អី ប៉ុន្តែការពិតទៅកូនភ្លោះដឹង។ ពួកគេតែងតែមកឱបនិងសួរ

ញឹកញាប់ថាឪពុកជាអ្នកណា ឪពុកនៅឯណា នាងក៏ឱបពួកគេវិញនិងប្រាប់

តាមត្រង់ថាឪពុកម្តាយស្រឡាញ់គ្នា ប៉ុន្តែមានរឿងជាច្រើនដែលម្តាយគិតថាគួរ
តែបែកផ្លូវគ្នា។

"ព្រោះខ្ញុំរឹងឬ ទើបប៉ាបោះបង់យើង ?"

"មិនមែនទេ រឿងទាំងអស់កើតឡើងមុនពេលពួកកូនកើតទៀត"

"ម៉ាក់តាមប៉ាមកផ្ទះវិញមិនបានឬ ?"

"ប៉ាចិត្តអាក្រក់ ប៉ាបោះបង់ម៉ាក់ ហឺ..."

"មិនមែនទេ មិនមែន"

ក្មេងៗងរង៉ក់ មិនយល់និងចង្អុលសួរមិត្តភក្តិរបស់ម្តាយដែលជាមនុស្ស
ប្រុសថាម្នាក់ណាគឺឪពុក ទើប អាលិហ្សា ឱបក្រសោបអារម្មណ៍របស់កូនៗ និង
ចំណាយពេលនៅជាមួយពួកគេឱ្យបានច្រើន ហើយយូរៗទៅ យ៉ូយ៉ូ ឈប់សួររក
ឪពុក ប៉ុន្តែ បូបូ មិនព្រមឈប់។

"ប៉ាចិត្តអាក្រក់ មិនព្រមមករកពួកយើង អីចឹងចាំខ្ញុំទៅរកប៉ាឱ្យម៉ាក់



ប្រាប់ពីចំណង់ចំណូលចិត្តមក ចាំខ្ញុំរកឱ្យ"

អាលិហ្សា អស់សំណើច ញីសក់ក្បាលកូនស្រី ហើយឱបរឹតណែនដៃ។

"ម៉ាក់សច្ចាហើយថាមិនរៀបការទៀតទេកូនប៉ារបស់កូនមានតែម្នាក់គត់ ស្វាមីដែលម៉ាក់ស្រឡាញ់គឺមានតែម៉ាក់ម្នាក់ដូចគ្នា"

ពេលដែលកូនភ្លោះកំពុងរៀនត្រៀមថ្នាក់មត្តេយ្យ នាងនិងឪពុកក៏ដើរមើលសាលារៀនជាងដប់កន្លែង។ លោកតាចូលចិត្តសាលារៀនល្បីឈ្មោះ មានកូនចៅរបស់មិត្តភក្តិរៀននៅទីនោះច្រើន ការសិក្សាត្រូវតាមក្បួនខ្នាត និងមានគុណភាព មានគ្រូមកពីបរទេសបង្រៀនមុខវិជ្ជាជំនាញ ដែលធ្វើឱ្យភាគរយនៃការប្រឡងចូលមហាវិទ្យាល័យមានភាពងាយស្រួល។

"ទីនេះល្អណាស់ អាលីស ថ្ងៃបង់សាលាកុំបារម្ភ ប៉ាជួយចេញ"

"ខ្ញុំចង់ឱ្យពួកគេរៀននៅទីនោះជាង ចង់ឱ្យពួកគេរស់នៅឱ្យសមជាក្មេង"

អាលិហ្សា សម្រេចចិត្តជ្រើសរើសសាលារៀនដែលមានស្ថានភាពមធ្យម

ក្នុងមួយថ្នាក់យ៉ាងច្រើនមានសិស្ស ១០ នាក់ កិច្ចការក្នុងមួយថ្ងៃៗគឺលេង ជាង

នោះទៅទៀតសាលារៀនមួយនេះមានរបងជាប់នឹងស្ថានទូតមីឌីស ត្រឹមងើយ

មើលលើនឹងឃើញទង់ជាតិមីឌីសបក់រវិចៗលើដំបូលអគារ។ មានកូនចៅរបស់

អ្នកនៅក្នុងស្ថានទូតមករៀននៅទីនេះច្រើន ថ្ងៃខ្លះអ្នកម្តាយដែលជាជនជាតិ

មីឌីសធ្វើតែនខេកផ្អែម ដែលហៅថា *ចាក់ឡាវ៉ា* ញ៉ាំជាមួយ *ឡាបាន់* ឬយ៉ាអួ

ដាក់ផ្លែលម៉ើមកចែកក្មេងៗ។ នាងគិតថាយ៉ាងហោចណាស់កូនៗ នឹងមាន

ឱកាសបាននៅជិតវប្បធម៌របស់ឪពុកពួកគេ ទោះតិចតួចក៏ល្អ។

ថ្ងៃដំបូងដែលនាំកូនមកសាកល្បង នាងគិតថាពួកគេនឹងទ្រហោយំ

មិនព្រមបែកពីម្តាយ ប៉ុន្តែ បូបូ បែរជាដឹកដៃប្អូនប្រុសទៅចូលរួមច្រៀងចម្រៀង

ជួយមិត្តភក្តិវ័យស្រករគ្នា ហើយនាងទៅវិញទេដែលឈរតោងរបងចាំមើល

ទាំងទឹកភ្នែកហូររហាមទាល់តែត្រូវគ្រូនាយកអញ្ជើញឱ្យត្រឡប់ទៅផ្ទះ។

ថ្ងៃណាដែលមានប្រជុំអាណាព្យាបាល អាលិហ្សា ក៏មកអង្គុយដោះដូរ



បទពិសោធជាមួយអ្នកម្តាយឯទៀត និងមានអ្នកម្តាយមីឌីសច្រើននាក់ដែល
តាមស្វាមីមកប្រចាំការនៅស្ថានទូតនេះ។ ពេលពួកគេយក *សាំប៊ូសា* មានភិន
ភាគស្រដៀងសម្លការីរាងបីជ្រុង ខាងក្នុងជាស្ពៃឬសាច់សត្វលាយខ្ទឹមបារាំង
ផ្សំគ្រឿងទេសរាងចាស់ ញាំជាមួយ *ឈុវ៉ាថា* ឬស៊ុបខាប់ ធ្វើពីសាច់ត្វ និងបន្លែ
ដែលឃើញហើយ ធ្វើឱ្យនឹកដល់ សារីហ្វ។

"សាទ្បាប...ខ្ញុំសុំញាំខ្លះបានទេ វាឈ្ងុយខ្លាំងណាស់"

"អ៎! ច្បាស់ជាបាន អ្នកស្រីមើលទៅសុំនឹងអាហាររបស់យើងមែនទែន"

"ខ្ញុំធ្លាប់ទៅមីឌីសមួយរយៈកាលពីច្រើនឆ្នាំមុន ពេលកំពុងមានផ្ទៃពោះ
លំបាកណាស់ ខ្ញុំនឹកចង់ញាំអាហារឆ្ងាញ់ៗអស់នេះ តែមិនដឹងថារកនៅឯណា
ថ្ងៃនេះ លោកស្រីៗចិត្តល្អចែកឱ្យញាំបំបាត់ការចង់ ខ្ញុំសប្បាយចិត្តណាស់"

"បើអ្នកស្រីចូលចិត្ត ចាំខ្ញុំបង្រៀន"

"ល្អណាស់"

ពេលអ្វីៗរលូនហើយ អ្នកម្តាយពេញវេលាដូច អាលិហ្សា ក៏ពង្រីកហាង

គ្រឿងអលង្ការរបស់គ្រួសារឱ្យកាន់តែធំ ត្រឡប់ទៅកាន់វិស័យត្បូងមណីម្តង

ទៀត ហើយលើកនេះ នាងលះបង់ទាំងកម្លាំងកាយកម្លាំងចិត្តដើម្បីអនាគត

របស់កូន ៗ ស្មាមញ្ញឹមរបស់ពួកគេ ជាពិភពលោកទាំងមូលរបស់នាង។

"មុនទៅយកកូនភ្លោះ ចូលចាក់សាំងផង"

"ចាំ"

អាលិហ្សា កំពុងតែរវល់ ពេលងើយមើលនាឡិកាក៏ប្រញាប់បបួលម្តាយ

ឡើងឡានទៅយកចៅៗជាមួយគ្នា ហើយទៅទិញរបស់នៅផ្សារទំនើបបន្ត។

នាងឡើងឡាន និងត្រៀមខាសុីតនិងនំចំណីទុកឱ្យកូនៗញ៉ាំពេលជិះ

ឡាន។ ក្នុងមួយថ្ងៃៗ មានតារាងពេលវេលាដែលត្រូវធ្វើណែនផ្ទឹស ស្ទើរតែគ្មាន

ពេលគិតដល់អតីត។ នាងកំពុងតែដើរទៅខាងមុខ ដោយបិទទ្វារចាក់សោរ

រឿងរ៉ាវដែលកើតនៅមីឌីសចោល ប៉ុន្តែ...



"ម៉ាក់ ជួយយកក្រេឌីតកាតនៅក្នុងកាបូបឱ្យខ្ញុំបន្តិច"

បូបូ និង យ៉ូយ៉ូ យំចេចចាចចង់បានរបស់ ប៉ុន្តែ អាលិហ្សា មិនទិញឱ្យ

កូនៗក៏ងរង៉ក់ ទើបនាងលើកពម្នាក់ម្ខាង ឯអ្នកម្តាយជួយរើកាបូបលុយ។

"កាតមួយណា ?"

"ពណ៌មាសម៉ាក់...បូបូ យ៉ូយ៉ូ ឈប់យំទៅ បើកូនរម្ងាប់អារម្មណ៍ខ្លួនឯង

បានពេលណា ម៉ាក់នឹងនាំទៅញ៉ាំការ៉េមដែលកូនចង់ញ៉ាំ"

"ខ្ញុំឈប់យំហើយម៉ាក់"

អាលិហ្សា កំពុងតែធ្វើការព្រមព្រៀងជាមួយកូនៗព្រោះកតិការបស់នាង

គឺបើមិនឈប់យំ ឈប់ងរង៉ក់ នាងនឹងនាំត្រឡប់ទៅផ្ទះភ្លាម។ យ៉ូយ៉ូ ជួយជូត

ទឹកភ្នែកឱ្យបងស្រី ទើបនាងមិនបានជាមើលថាម្តាយយកក្រេឌីតកាតដែល

នាងលាក់ទុកមកហុចឱ្យបុគ្គលិកគិតលុយ ឆូតនឹងម៉ាស៊ីន ចេញវិកយបត្រឱ្យ

រួចរាល់ ហើយសញ្ញានៃការប្រើប្រាស់កាតក្រេឌីត ក៏រត់ឆ្លងសមុទ្រក្នុងពេល

មួយវិនាទី ធ្វើឱ្យជីវិតរបស់នាងប្រែប្រួលម្តងទៀត។

ខណៈនោះ សារីហ្វ នៅតែមិនបោះបង់ការព្យាយាមក្នុងការតាមរកនាង។

គេមានអារម្មណ៍ថាកំពុងតែប្រមាញ់ជិតដល់នាងហើយ សុំត្រឹមកុំឈប់ប៉ុណ្ណោះ គេនឹងចាប់នាងឱបឱ្យជាប់ម្តងទៀតដូចដែលធ្លាប់ធ្វើម្តងរួចមកហើយ។

"ការដោះសានេះយើងស្តាប់ឡើងទ្រលាន់ទៅហើយ ចេញទៅ បើគ្មានអីរីកចម្រើនមិនបាច់ម៉ោឱ្យយើងឃើញមុខទៀតទេ"

ពេលនេះគេអង្គុយនៅក្រោយតុធ្វើការឈើម៉ាប៉ូល កំពុងតែស្តីឱ្យមនុស្សរបស់ខ្លួន ហើយបញ្ចប់ការសន្ទនានេះ ដោយការបង្វិលកៅអីទៅមើលផ្ទៃមេឃនៅក្រៅជញ្ជាំងកញ្ចក់ ដោយទឹកមុខស្មើ ប៉ុន្តែចិត្តកំពុងតែក្តៅអន្ទះអន្ទែងដោយកំហឹង ខឹងដល់ថ្នាក់គ្មានអ្នកណាហ៊ានមើលមុខចំ រហូតដល់មានបុរសពាក់ឈុតគ្រែរហ្សេពណ៌ប្រផេះ អាវសឺមិពណ៌ផ្ទៃមេឃស្រាល ចងក្រវាត់កក្រណាត់



សូត្រពណ៌ផ្ទៃមេឃចាស់ដើរចូលមក។

"ឡូឡាឮទៅដល់ខាងក្រៅតែម្តង"

"ព្រះអង្គ"

សារីហ្វ ងាកទៅរក ព្រមទាំងលើកបាតដៃដាក់លើដើមទ្រូងខាងឆ្វេង

ដើម្បីសម្តែងការគោរព បន្ទាប់មកក៏ដកដង្ហើមធំ។

"មានកិច្ចការអីឱ្យទូលបង្គំបម្រើឬ ?"

"យើងម៉ោនិយាយជាមួយឯងរឿងផ្ទាល់ខ្លួន ឧបមាថាបើរកស្រីម្នាក់នោះ

មិនឃើញ តើធ្វើយ៉ាងម៉េចបន្ត ?"

"គឺរកបន្តទាល់តែឃើញ"

"មិនស្មានថាឯងមានស្នេហាដូចអ្នកដទៃដែរ ប៉ុន្តែស្នេហាចាប់ផ្តើម

ហើយ វាក៏ត្រូវមានថ្ងៃបញ្ចប់ កន្លងមកវាអាចគ្រាន់តែជាអារម្មណ៍ឈ្លក់វង្វេងក៏

ថាបាន"

សារីហ្វ ស្តាប់ តែមិនតបត ខណៈនោះ ក៏ស្រាយក្រវាត់កឱ្យធូរ ទឹកមុខ
នៅតែតានតឹង។

"សារីហ្វ រឿងកន្លងផុតទៅហើយ កុំទៅចាប់អារម្មណ៍ពេក មនុស្សស្រី
មានច្រើន ក្នុងពេលដែលមានចេតនារត់ គឺព្រោះមិនស្រឡាញ់ បើកចិត្តឱ្យ
ទូលាយ ហើយរកថ្មីល្អជាង"

អ្នកនិយាយ ធ្វើការដាស់តឿននិងណែនាំ ព្រមទាំងងាកដៃទៅក្រោយខ្នង
រូបភាពដែលបញ្ចាំងនៅលើអេក្រង់ គឺជាបន្ទប់ប្រជុំដែលនៅជាប់គ្នា មានស្រី
ស្អាតជាងដប់នាក់អង្គុយនៅជុំវិញតុមូល ពួកនាងសុទ្ធតែមានវង្សត្រកូលល្អ
ការសិក្សាខ្ពស់ រូបរាងស្អាត ប៉ុន្តែ សារីហ្វ មិនយកភ្នែកមើល។

"ទូលបង្គំមិនត្រូវការ អញ្ជើញពួកនាងចេញទៅ"

"កុំអីចឹងអី នេះកន្លងផុតទៅច្រើនឆ្នាំហើយ បំភ្លេចស្រីម្នាក់នោះទៅល្អ
ជាង"



សារីហ្វ មិនត្រូវការអ្នកណាទាំងអស់ តែពន្លឺភ្នែករបស់គេមិនបញ្ឆាក់ពីអ្វី

ហើយសុំងើបទៅធ្វើការ មិនយកចិត្តទុកដាក់ចំពោះខ្សែភ្នែកទាក់ទាញរបស់ស្រី

ស្អាតទាំងនោះ។

"ទូលបង្គំសូមថ្វាយបង្គំលា"

"ចិត្តរឹងមែន មើលទៅស្រឡាញ់មែន"

ប្រមុខនៃមីឌីសដកដង្ហើមធំពេលប្អូនប្រុសដើរចេញពីបន្ទប់។ បើត្រឡប់

ពេលវេលាបាន គេនឹងមិននិយាយដាក់ អាលិហ្សា បែបនោះជាដាច់ខាត។

"យើងធ្វើបាបពួកគេ ធ្វើបាបមនុស្សពីរនាក់ដែលស្រឡាញ់គ្នា យើងធ្វើ

ជ្រុលពេកហើយ"

សារីហ្វ ក្តាប់ដៃណែន មិនអាចរម្ងាប់កំហឹងដែលមាននៅក្នុងចិត្តបាន

ខណៈដែលនៅក្នុងជណ្តើរយន្ត។ ផែនដីនេះ ចំជាកណ្តោចកណ្តែង ទទេស្អាត

មិននៅសល់អ្នកណា ជាងនោះទៅទៀត ព្រះជាម្ចាស់នៅខាងលើ នៅបញ្ជូនព្យុះ ខ្យាច់មកញាំញីបេះដូងរបស់គេឱ្យកាន់តែខ្ទេចខ្ទី នេះជាបរិយាកាសចង្រៃយក៏របស់មនុស្សប្រុសចង្រៃយក៏។ គេគ្មានចិត្តធ្វើអីទាំងអស់ ខ្ជិលសូម្បីតែកម្រើកខ្លួន។

គេដកដង្ហើមធំ ហើយឈប់គិតរឿងដែលធ្វើឱ្យមួម៉ៅ ព្រោះមានការងារដែលត្រូវត្រឡប់ទៅធ្វើឱ្យរួចរាល់។ ការធ្វើការទៅវិញទេ គឺជាអ្វីដែលគេគួរធ្វើប៉ុន្តែមានអ៊ីម៉ែលមកពីក្រុមហ៊ុនក្រេឌីតកាតដែលគេដាក់សំណើ ឱ្យតាមដានសកម្មភាពគ្រប់ពេលវេលាអស់រយៈពេលជាច្រើនឆ្នាំ ប្រាប់ថាមានការប្រើប្រាស់ក្រេឌីតកាតទិញទំនិញ ដោយចំនួនទឹកប្រាក់មិនប៉ុន្មានដុល្លារប៉ុណ្ណោះ នៅរាជធានី សេអ៊ូល សាធារណរដ្ឋកូរ៉េ។

ត្រឹមប៉ុណ្ណឹង បេះដូងរបស់គេស្ទើរតែឈប់លោត សប្បាយចិត្តបំផុតដែលនាងបង្ហាញខ្លួននៅក្នុងខ្សែភ្នែករបស់គេម្តងទៀត សាច់ដុំទាំងអស់ ឡើងរឹង។



គេអានសារនៅក្នុងអ៊ីម៉ែលម្តងហើយម្តងទៀត ស្រីជើងល្អ គិតឬថាអាច
គេចពីគេផុតហើយដើរចេញពីជណ្តើរយន្តដោយទឹកមុខដូចមនុស្សទើបតែកើត
ឬ។

"ទាក់ទងទៅរដ្ឋាភិបាលកូរ៉េខាងត្បូង ថាយើងនឹងធ្វើដំណើរទៅស្អែក
នេះ"

"ក្រាបទូល"

ហើយពេលគេជាន់ទឹកដីកូរ៉េខាងត្បូងស្រូបយកខ្យល់អាកាសនៅកន្លែង
តែមួយជាមួយនាង អ្វីម៉្យាងនៅក្នុងរាងកាយ ក៏ជ្រួលច្រាល់ ដូចខ្សាច់ដែល
ហួតហែង ទទួលបានតំណក់ទឹកភ្លៀង ដោយគេជឿតាមសញ្ញាតិញ្ញាណថា
នាងនៅទីនេះ នៅជិតនេះឯង។

ពេលធ្វើដំណើរមកដល់ស្ថានទូតមីឌីសប្រចាំសាធារណរដ្ឋកូរ៉េ ដែល
មានទីតាំងស្ថិតនៅកណ្តាលរដ្ឋធានីសេអ៊ូល សារីហ្វ ក៏ចុះពីឡាន ហើយភ្នែក

388

សម្លឹងមើលក្មេងៗ ដែលតែងខ្លួនស្អាតៗ ចាំទទួលជាមួយមន្ត្រីទាំងឡាយ ក្នុង ចំណោមនោះមានក្មេងស្រីម្នាក់កាន់ផ្កា ញញឹមស្រស់ចែងចាំងដូចព្រះអាទិត្យ នាងតូចដែលជាកូនស្រីរបស់គេ។

"លោកធ្វើជាខ្ញុំបានអត់ ខ្ញុំចង់មានប៉ា"

"ប៉ានាងតូចទៅណា?"

"មិនដឹងទេ ម៉ាក់ប្រាប់ថាធុញប៉ា"

បូបូ រាយការណ៍តាមអ្វីដែលឮបានឮ តែស្តាប់ហើយ ឆ្ងល់ចុងច្រមុះភ្លាម។

"ម៉ាក់ប្រាប់ថាប៉ាចិត្តអាក្រក់ ប្តូរប៉ាថ្មីល្អជាង"

ប៉ាចិត្តអាក្រក់ស្តាប់ដោយចិត្តត្រជាក់។

"ហើយម៉ាក់នាងតូចរកប៉ាថ្មីបានហើយនៅ?"

"នៅទេ ទើបខ្ញុំចង់រកឱ្យម៉ាក់ ញ៉ែម៉ាក់ខ្ញុំសាកមើលទេ"



"បានតើ យើងច្បាស់ជាញ៉ែ"

គេញញឹមចុងមាត់ តែពន្លឺភ្នែកមិនញញឹម ព្រោះទីបំផុតរកប្រពន្ធជើងល្អ ឃើញហើយ។ ស្វាមីនៅដកដង្ហើមឱ្យជ្រងោ ម៉ែចក៏ហ៊ានប្រកាសរកប៉ាថ្មីឱ្យកូន មិនទាន់បូកបញ្ចូលបំណុលចាស់ដែលមិនទាន់ជម្រះ គេនឹងគិតបញ្ជីពីនាង ទាំងដើមទាំងការ។

"យ៉ូយ៉ូៗ ម៉ោណេះឱ្យឆាប់ឡើង ឱ្យឆាប់ឡើង នេះអីប៉ាថ្មី មើលចុះ ប៉ាថ្មី សង្ហាៗ ម៉ាក់ច្បាស់ជាពេញចិត្ត"

"បងបូបូៗ ម៉ោជួយយួរ កុំលេង"

ប្អូនប្រុសច្រត់ចង្កេះ បងស្រីក៏ច្រត់ចង្កេះ ត្រាប់តាមគំរូដើមដូចបេះបិទ។

"ប៉ារបស់ខ្ញុំ ឈ្មោះ សារីហ្វ ខ្ញុំមិនយកប៉ាថ្មីទេ"

"អាល្អិតក៏ជាកូនរបស់ម៉ាក់ អាលិហ្សា ដែរឬ?"

"បាទ"

យ៉ូយ៉ូ សម្លឹងមើលបុរសមាឌធំ ដែលមានមុខមាត់ដូចខ្លួនឯង។

"បូបូ កើតមុនមួយនាទី តែចូលចិត្តធ្វើខ្លួនជាអ៊ំស្រី"

"បើបងចាស់ ខ្លួនឯងក៏ចាស់ដូចគ្នា"

គេធ្លាប់គិតថាខ្លួនឯងភ្លេចទៅហើយ ថាការសើចគឺជាអ្វី តែពេលនេះ គេកំពុងតែសើច ព្រមទាំងទាញក្មេងទាំងពីរមកឱប ឱ្យសប្បាយចិត្ត។

ពីរនាក់បងប្អូនភ្លោះ ដូចគេដល់ថ្នាក់មិនគួរឱ្យជឿ ធ្វើឱ្យដៃរបស់គេ ដែលកំពុងឱបសាច់ឈាមខ្លួនឯងញ័រទន្ទ្រើត ទឹកភ្នែកមិនដឹងមកពីណា...

អាល់សាដុលឡោះ សីហ៍នៃហ្វេសសាន កំពុងតែហូរទឹកភ្នែកនៅចំពោះមុខក្មេងប្រុស និងក្មេងស្រីដោយគ្មានការអៀនខ្មាស។

"មើលចុះ បូបូ ធ្វើឱ្យអ៊ំប្រុសយំហើយ អ៊ូៗ"

"អ៊ំប្រុសឈឺត្រង់ណា យំធ្វើអី"

"ធូលីចូលភ្នែកតិចតួច គ្មានអីទេ ធូលីចេញទៅហើយ"



សារីហ្វ សើចដោយមានសេចក្តីសុខ និងលើកកូនទាំងពីរឱ្យអង្គុយលើ
ស្មារឹងមាំរបស់ខ្លួនម្ខាងម្នាក់ ដែលពីរនាក់បងប្អូន នាំគ្នាបើកភ្នែកធំៗ ស្រែក
អ៊ូហូ។

"បើហៅខ្ញុំថាប៉ា ខ្ញុំនឹងឱ្យតោងសាច់ដុំ"

"ប៉ា-"

"ចរិតដូចម្តាយបេះបិទ ត្រូវតែមានរបស់មកបញ្ឆោត"

សារីហ្វ សើច និងឱបក្មេងៗណែនដៃ ព្រមទាំងឱ្យក្មេងៗ តោងសាច់ដុំ
របស់ខ្លួនតាមចិត្ត ធ្វើឱ្យ អាលី និងកូនចៅ នាំគ្នាញីភ្នែក មើលមកដោយការ
ភ្ញាក់ផ្អើល ព្រោះច្រើនឆ្នាំកន្លងមកនេះ ព្រះបុត្រា សារីហ្វ ក្តៅគគុកដូចភ្លើង
ប៉ុន្តែពេលជួបកូនភ្លោះ មិនប៉ុន្មាននាទី ភ្លើងនោះក៏រលត់។

"អឺ...ហើយរឿងចរចាជំនួញក្រាបទូល?"

"លើកពេលទៅ យើងទៅសួរសុខទុក្ខម៉ាក់របស់កូនយើងសិន ទៅដាក់
ពាក្យជាស្វាមី"

១៧

ជួបគ្នាវិញ

ជំនួញរបស់ អាលិហ្សា ពង្រីកកាន់តែធំ បើកសាខានៅតំបន់សេដ្ឋកិច្ច

មិនឆ្ងាយពីស្ថានទូតមីឌីស ដោយដាក់ឈ្មោះថា ហាង Asiana Jewelry ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាង ដែលត្រឹមមិនប៉ុន្មានឆ្នាំប៉ុណ្ណោះ ក្លាយជាហាងត្បូងមនីនាំមុខ មានទាំងភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ជាពិសេសឈ្មួញត្បូងមនីដែលតែងតែមកទាក់ទងលក់ដូរ។

មានត្បូងមនីជាច្រើន ដែលសុទ្ធតែស្អាតៗ តាំងនៅក្នុងទូរកញ្ចក់សុវត្ថិភាព រង់ចាំឱ្យមានស៊ីមានចុកទាំងឡាយមកទិញយកទៅលម្អរាងកាយ។

"អ្នកនាង ឈិន ភ្នែកមុតដល់ហើយ នេះជាពេជ្រដែលល្អបំផុតតាមដែល



ខ្ញុំមាន ជានាថាពេជ្រគ្រប់គ្រាប់របស់ខ្ញុំ មានគុណភាពល្អ"

ពេជ្រគ្រាប់ធំៗ មិនថាគុណភាពអីក៏ដោយ ក៏កម្រកបានជាងពេជ្រគ្រាប់តូចៗ។ ពណ៌ដែលស្អាតបំផុតរបស់ប្រព័ន្ធស្តេនឌីណេវៀគឺ *វីវី* ធៀបបាននឹងពណ៌សព្រលាំផ្ទៃមេឃរបស់ប្រព័ន្ធអង់គ្លេស ស្ថិតនៅក្រោមស្តង់ការការរៀបចំលំដាប់ពណ៌ដោយស្ថាប័នត្បូងមនីនៃសហរដ្ឋអាមេរិក។

ឈ្មួញពេជ្រម្នាក់នោះ បើកស្រោមរក្សាទុកពេជ្រគ្រាប់ធំៗឱ្យ អាលិហ្សាពិចារណាដោយការជឿជាក់ ប៉ុន្តែនាង ឆ្លុះមើលតែមួយភ្លែត ក៏ដាក់វាចុះ ព្រោះពេជ្រទាំងនោះ គឺពេជ្ររុស្សី មានតម្លៃត្រឹមជាដុំគ្រួសរោយក្នុងទូរត្រីប៉ុណ្ណោះ។

"ពេជ្ររុស្សីមួយគ្រាប់នេះ មានគុណភាពល្អក្រៃដអេ តែខាងយើងមិនទិញ"

នាងលក់ដូរដោយភាពស្មោះត្រង់ មិនធ្លាប់កេងចំណេញពីអ្នកណា និងមិនធ្លាប់ឱ្យអ្នកណាកេងចំណេញដូចគ្នា ពួកឈ្មួញត្បូងពេជ្រ ចូលចិត្តយកមក

លក់ឱ្យនាង ព្រោះមិនចេះរអ៊ូរទាំ រញ៉ាំរញ៉ូវ តម្លៃខុសគ្នាតិចតួច ក៏អាចឈិនឆៃ

បាន ឬជួនកាលនាងមិនតថ្លៃ បើឃើញថាជាតម្លៃសក្តិសម តែអ្នកខ្លះ ប្រមាថ

ពេលឃើញថាជាមនុស្សស្រី ទើបយករបស់មិនល្អ មកសាកដោយមិនស្គាល់

កាលទេស: ទើបត្រូវនាងអញ្ជើញឱ្យចេញពីហាង មិនបានលក់ដូរច្រើនករណី

មកហើយ។

"ថ្មែនេះ កុំភ្លេចទៅនិយាយជាមួយនាយរង ទី ម្ចាស់អណ្តូងត្បូងនៅ

សណ្ឋាគារផង អាលីស គេយកគំរូត្បូងមិនទាន់ថ្មែមកឱ្យមើល បើឃើញថាទំនង

ណាត់ទៅមើលអណ្តូងត្បូងជាមួយគ្នាបាន"

"ចំ៉ា ប៉ា"

ម្ចាស់អណ្តូងត្បូងជាប៉ូលិស មិត្តភក្តិរបស់ថៅកែ ឈិន នេះឯង មាន

អណ្តូងដែលទើបតែបើកថ្មីនៅខេត្ត អ្នកនៅក្នុងវិស័យនេះ ដឹងច្បាស់ថា ត្បូងនៅ

ខេត្តនោះត្រូវជីកយកអស់ហើយ រកត្បូងក្រែដល្អ គុណភាពល្អ ស្អាតៗ គឺកម្រក



បានណាស់ ប៉ុន្តែនាយរង ទី ប្រកាសថា ទើបតែបានសម្បទានបើកថ្មី ទើបអ្នក

ទទួលទិញត្បូងទាំងឡាយចាប់អារម្មណ៍ ក្នុងនោះមាននាងម្នាក់ដែរ។

ពេលកំពុងរង់ចាំដល់ម៉ោងសាលារៀនចេញទៅផ្ទះ អាលិហ្សា ក៏យក

ត្បូងកំដៀងទឹកល្អមកឆ្លុះមើល ម្តងមួយគ្រាប់ៗ ដើម្បីវាយតម្លៃគុណភាពនិង

តម្លៃ មើលដោយការយកចិត្តទុកដាក់។

"អ្នកនាង ឈិន មានភ្នែរវំងមកទាក់ទងសុំទិញត្បូងគ្រប់ប្រភេទដែល

យើងមាន"

"អ្នកណា"

"ជាជនជាតិអារ៉ាប់ មើលទៅជាអ្នកធំ មានអ្នកដើរតាមច្រើន"

អាលិហ្សា មិនទាន់បានងើយមុខចេញពីកែវពង្រីក និងមិនរីករាយ មិន

ស្អីទាំងអស់ ព្រោះកន្លងមក ក៏មានសេដ្ឋីជាច្រើននាក់ មកម៉ៅទិញ ទៅចែកស្រីៗ

របស់គេញឹកញាប់។

"អញ្ជើញភ្ញៀវទៅបន្ទប់វីអាយភី លើកភេសជ្ជៈឱ្យផង ហើយសួរនាំផងថា គេចាប់អារម្មណ៍ត្បូងប្រភេទណាជាពិសេស"

"បាទ"

បុគ្គលិកផ្នែកលក់ទទួលបញ្ជា ហើយប្រញាប់ប្រញាល់ទៅចាត់ការ ប៉ុន្តែ ងឿងឆ្ងល់ជាខ្លាំងព្រោះភ្ញៀវដែលជាបុរសសង្គាជនជាតិអារ៉ាប់គិតតែសម្លឹងមើលម្ចាស់ហាងមិនដាក់ភ្នែក តាមមើលគ្រប់អាកប្បកិរិយាដែលគួរឱ្យសង្ស័យ។

"អញ្ជើញខាងណេះលោក"

បុគ្គលិកផ្នែកលក់ នាំភ្ញៀវដែលតែងខ្លួនតាមទំនៀមទម្លាប់ ប្រពៃណី ចូលទៅក្នុងបន្ទប់វីអាយភី ខណៈនោះ ភ្ញៀវក៏ទន្ទឹងរង់ចាំម្ចាស់ហាងដោយមិនមាត់មិនក។

"សាឡាម...ចាប់អារម្មណ៍ត្បូងណាដែរ ?"

សំឡេងដ៏ពីរោះរបស់នាង ឆ្ពុះភ្លើងនៅក្នុងខ្លួនរបស់គេឱ្យឆាបឆេះ។ នាង



ដើរញញឹមញញែមចូលមកក្នុងបន្ទប់ទទួលភ្ញៀវ ដោយនាំយកក្លិនក្រអូបរបស់
កុលាបមកជាមួយ ប៉ុន្តែពេលមកដល់ ហើយក៏ទច់ដំណើរ ពេលប្រសព្វភ្នែក
ជាមួយគេ ប្រសព្វភ្នែកជាមួយ សារីហ្វ។

នាងស្រឡាំងកាំងមួយខណៈ អនុស្សាវរីយ៍ទាំងឡាយរត់ចូលមកក្នុង
ការចងចាំ វាច្បាស់លាស់ហាក់ដូចទើបតែកើតឡើងកាលពីម្សិល។ មើលទៅ
គេរឹងមាំ គួរឱ្យខ្លាចក្រែង ជាងកាលមុនដែលនាងចងចាំបានមិនដឹងប៉ុន្មានរយ
ប៉ុន្មានពាន់ដង។

"ខ្ញុំចង់ទិញត្បូងកណ្តៀងបួនដប់គ្រាប់ ធ្វើខ្សែក ក្រវិល និងចិញ្ចៀន
សម្រាប់ភរិយារបស់ខ្ញុំ"

គ្រឿងអលង្កាសម្រាប់ភរិយា...ស្តាប់ទៅ ទន់ភ្លន់ ផ្អែមល្ហែមណាស់ ធ្វើឱ្យ
នាងនឹកដល់ សាហិរ៉ា ស្ត្រីដ៏ខ្ពង់ខ្ពស់។ ជួនកាលពួកគេអាចមានកូនគួរឱ្យ
ស្រឡាញ់ជាមួយគ្នា ខណៈនោះ នាងក៏នឹកដល់កូនប្រុសកូនស្រីរបស់ខ្លួន ដែល

ក្លាយជាកូនឥតខាន់ស្លា ដែលទោះស្តាប់ទៅជូរចត់ ប៉ុន្តែនាងមានសេចក្តីសុខ

ទើបរម្ងាប់អារម្មណ៍ ធ្វើជាទើបតែបានជួបបុរសម្នាក់នេះជាលើកដំបូង ហើយ

ងាកទៅបញ្ជាកូនចៅឱ្យយកត្បូងកណ្តៀងនិងត្បូងអំបូរហ៊ាន់ដាំដែលមានទាំង

អស់នៅក្នុងទូរ មកឱ្យ។

"គ្រាប់ណាស្អាត សក្តិសមបំផុត ជួយណែនាំបន្តិច"

"ចាំ"

នាងប្រើដងៀបចង្អុលត្បូងកណ្តៀងស្អាត ទាក់ទាញភ្នែកមួយគ្រាប់

ដោយក្នុងចិត្តកំពុងតែរិះរកចម្លើយថាហេតុអ្វីបានជាគេលេចមុខមកទីនេះ។

"ត្បូងកណ្តៀង ទម្ងន់ដប់កា៉ាត់ តម្លៃ..."

យ៉ាប់មែន សំឡេងរបស់នាងញ័រ ខ្លួនប្រាណក៏ញ័រដែរ។

"ចុះគ្រាប់នេះ?"

សម្តីរបស់គេសុភាព ទន់ភ្លន់ តែបង្កប់ភាពកំណាចនៅក្នុងនោះ។



បុគ្គលិកលក្ខណៈរបស់គេ ថ្លៃថ្នូរ ខ្ពង់ខ្ពស់ កែវភ្នែកមុតស្រួចសណ្តាំគ្រប់គ្នាដែល
មើលមក។ នាងសារភាពថា មិនដឹងថាគេចង្អុលត្បូងមួយណា ព្រោះរវល់តែ
ព្រិលភ្នែក បេះដូងលោតញាប់ ប៉ុន្តែពេលឃើញគេធ្វើឫកថា ចងចាំនាងមិនបាន
ទើបនាងរសាយភាពតានតឹង។មែនហើយគេចាំនាងមិនបានទេ មិនឃើញមាន
អ្វីគួរឱ្យចងចាំ ពេលវេលាដូចស្ថានសួគ៌វាចប់តាំងពីយូរមកម្ល៉េះ។

"ត្បូងកណ្តៀងពណ៌ខៀវដប់មួយគ្រាប់នេះ ថ្មៃម៉ូតពិសេស"

"ខ្ញុំចង់ថាគ្រាប់មួយនេះ"

"ចាស ?"

នាងឈ្លោកមើលសារថ្មី ទើបឃើញថាចុងម្រាមដៃរបស់គេ ចង្អុលមក
នាង។

"បួនឆ្នាំ...បងតាមរកអូនបួនឆ្នាំ ដឹងទេថារឿងដំបូងដែលបងចង់ធ្វើគឺអ្វី"

គេនិយាយដោយសំឡេងស្ទើរ ហើយសម្លឹងមើលភ្នែករបស់នាង ឱ្យនាង

ដកដង្ហើមដង្ហក់ ធ្វើឱ្យដង្កៀបរបូតពីដៃ បេះដូងលោតញាប់ ក្តៅភាយៗតាំងពី

ក្បាលដល់ចុងជើងហើយរំពេចនោះក៏ត្រូវគេស្រវាចាប់កដៃប៉ុន្តែនាងលឿនជាង

ប្រញាប់រលាស់ចេញ ហើយស្ទុះងើប ដើម្បីចូលទៅខាងក្នុង។

"ចង់ទៅណា មិនបារម្ភពីកូនទេឬ"

គេដឹងដោយរបៀបណា ?

អាលិហ្សា ងាកទៅប្រសព្វភ្នែកជាមួយអ្នកនិយាយ ខ្លួនប្រាណទៅជារឹង

ឆ្អឺត។

"កូនរបស់ខ្ញុំម្ចាស់នៅឯណា ?"

"អូនគិតយ៉ាងម៉េចបើបងនាំក្មេងៗត្រឡប់ទៅមីឌីស ?"

"ខ្ញុំម្ចាស់មិនព្រម !"

អាលិហ្សា ឆ្លើយបែបនោះទាំងដែលដឹងថាមិនអាចប្រឆាំងនឹងអំណាច

របស់បុរសម្នាក់នេះបាន ថ្នាក់ប្រសព្វភ្នែកជាមួយ នាងធ្វើមិនបានទៅហើយ



ប៉ុន្តែមុនពេលបាននិយាយអ្វីទៀត ក៏ត្រូវគេទាញទៅឱប ឱ្យថ្ពាល់ផ្អឹបនឹងដើម
ទ្រូងធំទូលាយ។

នាងកំពុងមានអារម្មណ៍ដូចធ្លាក់ទៅក្នុងជ្រលងជ្រោះជ្រៅ ដែលប្រឹងវារ
ឡើងមកលើយូរមកហើយ ចំហាយក្តៅឧណ្ហៗ ដែលនាងគិតថាភ្លេចទៅហើយ
ក៏កើតឡើងម្តងទៀត ដៃទាំងពីរដែលគិតថា ប្រឆាំងនឹងគេតាមការគួរ បែរជា
លើកមកត្បួតពិនិត្យសាច់ដុំមាំមួន និងដាក់លើស្មាធំទូលាយ ជ្រប់ថ្ពាល់នឹង
ប្រទ្បោះស្មា ព្រមទាំងដកដង្ហើមធំ ដោយអារម្មណ៍ធូរស្រាល ប៉ុន្តែពេលដឹងខ្លួន
នាងក៏ប្រញាប់រុញគេចេញ ខណៈនោះឯង ដែលឪពុកម្តាយស្ទុះចូលមក បន្ទាប់
ពីកូនចៅរត់ទៅតាម។

"មានអីកើតឡើង គេជាអ្នកណា លែងកូនស្រីខ្ញុំភ្លាម"

ថៅកែ ឈិន ស្រែកជាភាសាកូរ៉េ ប៉ុន្តែពេលឃើញថាម្នាក់នោះជាបុរស
បរទេសមាឌធំ ទើបស្រែកម្តងទៀត ជាភាសាអង់គ្លេស ទាស់ត្រង់ថា សារីហ្វ

ធ្វើព្រងើយមិនចាប់អារម្មណ៍អ្នកណា ក្រៅពី អាលិហ្សា។

"ទៅវិញជាមួយបងភ្លាម"

"មិនទៅ យើងគ្មានអីពាក់ព័ន្ធគ្នាទៀតទេ ក្មេងៗជាកូនរបស់ខ្ញុំម្ចាស់ ទ្រង់ចង់លួចកូនអីខ្ញុំម្ចាស់មិនបានទេ"

នាងនៅតែប្រកែកតវ៉ា ធ្វើឱ្យពន្លឺភ្នែករបស់គេឡើងរឹងកំព្រឹស ទាញនាងទៅបុកនឹងដើមទ្រូងម្តងទៀត ដែលធ្វើឱ្យឪពុកម្តាយកាន់តែភិតភ័យ។

"ម៉ាក់ៗ"

វ៉ាយ៉ូ ដឹកដៃបងស្រី រត់មករកដោយទឹកមុខញញឹម ក្នុងដៃម្ខាងទៀតមានប៉ែងប៉ោងស្អាតម្នាក់មួយ និងឈុតថ្មីគួរឱ្យស្រឡាញ់ ដែលនាងចាំម៉ាកនិងតម្លៃបានថា វាថ្លៃកប់ពពក ហើយក្មេងៗក៏ចូលមកឱបជើងឪពុក ដោយ បូបូ ប្រឹងទាញឈុតយ៉ោបាឡា ដើម្បីឱ្យព។

"នេះទ្រង់ទៅក្មេងៗពីសាលារៀនដោយមិនសុំការអនុញ្ញាតពីខ្ញុំម្ចាស់ជា



មុនអីចឹង"

"បងជាប៉ា ហេតុអីទៅយកមិនបាន"

"ម៉ាក់ៗ ចាំប៉ាមិនបានឬ នេះប៉ាហ្នឹងអី ប៉ាតាមរកម៉ាក់ឡើងយូរ ប៉ាមក

វិញហើយ"

"បូបូ ចៅប្រាប់ថាគេជាអ្នកណា ?"

"លោកយាយ...នេះប៉ារបស់ បូបូ"

ក្មេងស្រីរត់ទៅឱ្យលោកយាយបី លោកយាយ ក៏មើលមនុស្សមួយក្រុម

ជាងដប់នាក់ និងបុរសជនជាតិអារ៉ាប់ម្នាក់នេះហើយ កាន់តែងឿងឆ្ងល់។

"និយាយមួយៗ ម៉ាក់មិនពូកែអង់គ្លេស អម្បាញ់មិញម៉ាក់ស្តាប់ច្រឡំអីឬ

អត់ ក្រែងប្រាប់ថាបែកគ្នាហើយនោះអី ហើយម៉េចក៏លេចមក លេងដង្កៃដូចក្នុង

កុណា អ្នកណាជាអ្នកណានេ៎ះ"

"ម៉ាក់កុំទាន់អាលសួរ ជួយខ្ញុំសិន"

"គេជាអ្នកណា"

ថៅកែ ឈិន ចាប់ផ្តើមខឹងហើយ ប៉ុន្តែមានចៅជាទីស្រឡាញ់នៅជាមួយ

ទើបរក្សាកម្រិតសំឡេងខណៈដែលអាលិហ្សាគិតអីមិនចេញហើយពេលឃើញ

កូនប្រុសស្រី សម្លឹងមើលមកបែបនេះ ក៏ទន់ចិត្តល្អក។

"គេ...គេជា..."

"ខ្ញុំជាស្វាមីរបស់នាង"

ពេលឃើញអាការៈរបស់ស្រីជើងល្អ ទើប សារីហ្វ ដែលស្តាប់ភាសាកូរ៉េ

មិនយល់ន័យ តែក៏អាចសន្និដ្ឋានបានថាឪពុកកូននិយាយគ្នាពីអ្វី ដូច្នេះហើយ

ទើបណែនាំខ្លួនភ្លាម។

"ស្អីគេ! ជាស្វាមី?"

"ឱ្យហៅប៉ូលិសទេ ថៅកែ ឈិន?"

ថៅកែស្រីសួរស្វាមី។



"មិនបាច់ៗទេម៉ាក់" អាលិហ្សា ហាមប្រាមអ្នកម្តាយភ្លាម ហើយគ្រវែងខ្លួនចេញពីរង្វង់ដៃរឹងមាំ ប៉ុន្តែប្រឹងគ្រវែងយ៉ាងណា ក៏មិនរបូត ទើបខាំ ហើយប្រញាប់លើកបីកូនៗ នាំចេញទៅភ្លាម ទុកឱ្យឪពុកម្តាយ ឈរមិងមាំង។

"វាខាំគេហើយក៏ដើរចេញឆុយៗបែបនេះនៃ?"

"ខ្ញុំសុំហើយ"

សារីហ្វ ឆ្លើយប្រាប់ ព្រមទាំងតាមមើលប្រពន្ធកូនដែលកំពុងតែដើរញាប់ស្មេរចេញទៅ ទើបបូញមាត់ឱ្យអង្គរក្ស ដើរតាម ខណៈនោះថៅកែ ឈិន ក៏ស្រវាចាប់ដៃរបស់ អាលី ដើម្បីសុំការបកស្រាយដែលច្បាស់លាស់ជាងនេះ។

"ទ្រង់គឺព្រះបុត្រា សារីហ្វ អាល់ មីឌីស ព្រះអនុជរបស់ព្រះអង្គ ហ្វារីហ្វ ប្រមុខប្រទេសមីឌីស ទ្រង់ត្រូវការមកតាមយកអាមិរ៉ាត្រឡប់ទៅវិញ"

"អាមិរ៉ា?"

"ប្រែថា ព្រះជាយា"

អាលី ឆ្លើយប្រាប់ហើយ ក៏សុំទៅតាមបុរសដ៏ខ្ពង់ខ្ពស់ចេញពីបន្ទប់ ទុក
ឱ្យថៅកែធំទាំងពីរចំហមាត់ផ្អង និងមើលមុខគ្នាដោយការភ្ញាក់ផ្អើល។



១៨

យល់ពីគ្នា

តេដឹងដោយរបៀបណា ហេតុអីតេដឹង ?

អាលិហ្សា គិតហើយគិតទៀត ខណៈនោះក៏ពកូនភ្លោះ ទៅបន្ទប់នៅជាន់ទៅបី ខណៈនោះក្មេងៗក៏មើលដឹងពីភាពមិនប្រក្រតី ទើបនាំគ្នាយំ ទើបនាងឪ្យបប្រាប់ថាមិនអីទេ គ្មានអីត្រូវខ្លាចទេ ដោយនិយាយដដែលៗ បែបនោះតែចុះទ្បើងៗក៏នឹកឃើញថានាងកំពុងលួងលោមខ្លួនឯងច្រើនជាង។

"ម៉ាក់ ហេតុអីម៉ាក់មិននិយាយជាមួយប៉ា?" យ៉ូយ៉ូ សួរ ពេលម្តាយជូនមកដល់បន្ទប់ដេក ខណៈនោះអ្នកមើលថែដែលដើរតាមក្រោយ ស្រៀវឆ្អឹងខ្នងព្រោះមានបុរសអារ៉ាប់ដើរតាម មុខរបស់គេកាច គួរឱ្យខ្លាច។

"ម៉ាក់សុំពេលបន្តិច ម៉ាក់នឹងព្យាយាមធ្វើឱ្យល្អបំផុត ស្អីដែលនឹងកើតវា ត្រូវតែកើត"

នាងច្រៀងបទ Que sera Whatever will be, will be ដែលកូនៗ ចូលចិត្តឱ្យស្តាប់ ដើម្បីឱ្យអារម្មណ៍ត្រជាក់ ដែលក្មេងឆ្លាតដូច អាបូ ឃើញឪពុក លួចស្តាប់ តែមិនឆោឡោ ថែមទាំងនាំនិយាយជាភាសាអង់គ្លេសទៀត ដើម្បី ឱ្យឪពុកស្តាប់ដែរ ដែលកូនភ្លោះអាចនិយាយបានបីភាសា កូរ៉េ ចិន អង់គ្លេស។

"ម៉ាក់ស្អប់ប៉ាឬ?"

"អត់ទេកូន មិនមែនទេ ម៉ាក់ស្រឡាញ់ប៉ាណាស់ តែ..."

នាងនិយាយលែងចេញ មិនដឹងអធិប្បាយយ៉ាងណាឱ្យកូនស្តាប់ ខុសពី អ្នកកំពុងលួចស្តាប់នៅមាត់ទ្វារ បានឮហើយក៏ញញឹម ធូរទ្រូង។

"បងក៏ស្រឡាញ់អូន អាលិហ្សា"

នាងភ្ញាក់ព្រឺត ងាកយឺតៗ ទៅប្រឈមមុខ ពន្លឺភ្នែកពោរពេញដោយ



អំណាចមួយគូនោះបង្កប់ភាគគួរឱ្យខ្លាចក្រែង ដែលធ្វើឱ្យនាងភាំង ហើយពេល
គេដើរចូលមកបែបនេះ ក៏ធ្វើអីលែងកើត។

"ប៉ាចាប់ផ្តើមញ៉ែម៉ាក់ហើយ អូខេទេ ?"

សារីហ្វ ឱនទៅនិយាយរកកូនៗ។

"អូខេៗ"

កូនស្លោះធ្វើសញ្ញាអូខេដាក់ឪពុក។

"ប៉ាប្រឹងឡើង ញ៉ែម៉ាក់ឱ្យឆាប់បាន"

"ម៉ាក់រឹងណាស់ បូបូ និង យ៉ូយ៉ូ ជួយប៉ាទេ ?"

"ទុកចិត្តបាន យប់នេះខ្ញុំនិងប្អូនឆាប់ចូលដេក ឱ្យប៉ានិងម៉ាក់និយាយគ្នា
ពេញមួយយប់"

"ប៉ាទិញពេជ្រលួងម៉ាក់ទៅ ម៉ាក់ចូលចិត្តពេជ្រ"

"អូខេ ប៉ានឹងទិញឱ្យទាំងអណ្តូង"

ត្រឹមមួយប៉ប្រិចភ្នែកប៉ុណ្ណោះ សារីហ្វ ក៏ចងសម្ព័ន្ធជាមួយកូនៗ បាន ទើប អាលិហ្សា ងាកមកសម្លក់សម្លឹងមនុស្សពូកែរកវិធី ហើយងាកមករកកូនៗ។

"ម៉ាក់ប្រញាប់ជួបភ្ញៀវ បូបូ និង យ៉ូយ៉ូ នៅជាមួយអ្នកមើលថែសិនទៅ ម៉ាក់នឹងប្រញាប់មកវិញ"

"មនុស្សពូកែប្រមាត់តូចហើយ"

សារីហ្វ ងើបឈរពេញកម្ពស់ និងមើលនាងដោយការផ្ងាញ់ផ្ងាល។

"បងចង់ចាប់អូនដោះខោអាវ ហើយគ្រញីអូនឱ្យបាត់ស្គិញដល់ហើយ"

បូបូ និង យ៉ូយ៉ូ មើលមុខឪពុកផង មើលមុខម្តាយម្តង ហើយសួរ។

"គ្រញីប្រែថាម៉េចប៉ា?"

"ប្រែថាប៉ានឹងឃុំឃាំងម៉ាក់ពីរបីម៉ោង ហើយប្រាំបួនខែក្រោយមកក៏មានប្អូនឱ្យពួកយើងហ្នឹងអ្អែ ជួយមើលថែប្អូនទេ?"

"ជួយៗ"



"នែ៎! កុំម៉ោធ្វើអីឡប់ៗ នៅចំពោះមុខកូន"

"អីចឹងបើកូនមិនឃើញគឺអូខេមែនទេ ?"

ខ្សែភ្នែករបស់គេជ្រាលជ្រៅ ពេលសម្លឹងមើលនាងមិនព្រិច ហើយមើលទៅជុំវិញបន្ទប់របស់កូន ដែលឃើញថាមានរបស់គ្រប់យ៉ាងដែលសក្តិសមនឹងក្មេងៗ និងទុកដាក់យ៉ាងមានរបៀប។

"ផ្ទះនេះតុបតែងគួរឱ្យស្រឡាញ់ នៅហ្វេសសានក៏ដូចគ្នា"

"កុំមកដាក់សម្ពាធខ្ញុំម្ចាស់ដោយវិធីនេះ សារីហ្វ វាមិនបានសម្រេចទេ យើងនឹងរកពេលនិយាយគ្នាពីរឿងនេះនៅពេលក្រោយ តែថ្ងៃនេះខ្ញុំម្ចាស់ត្រូវទៅជួបភ្ញៀវ ទ្រង់យាងទៅវិញសិនទៅ"

"ហើយអូននឹងរកវិធីនាំកូនរត់ទៀតមែនទេ ?"

"ខ្ញុំម្ចាស់សោកស្តាយដែលធ្លាប់ធ្វើឱ្យទ្រង់ឈឺចាប់ តែខ្ញុំម្ចាស់ត្រឡប់ទៅមីឌីសមិនបានទេ"

"ហេតុអី ?"

អាលិហ្សា ដើរចុះជណ្តើរ ទើបគេដើរតាម ព្រមទាំងគិតក្នុងចិត្តថានាង នៅតែរឹងទទឹង មិនប្រែប្រួល ហើយអាកប្បកិរិយាមិនអាឡោះអាល័យរបស់នាង ធ្វើឱ្យគេខឹងសម្បារ ទើបស្រវាចាប់ដៃរបស់នាង នាំចូលបន្ទប់មួយដែលកំពុងដើរកាត់ ដើម្បីបញ្ជាក់ឱ្យនាងចាំបានថាគេជាស្វាមីរបស់នាង។

"សារីហ្វ ចង់ធ្វើអី ?"

អាលិហ្សា ភ្ញាក់ក្រញាង ពេលត្រូវរុញពិតក្នុងនឹងជញ្ជាំង និងឃុំឃាំងដោយដៃរឹងមាំ។

"ទោះហេតុផលអីក៏ដោយ បងប្រាប់អូនហើយ ថាបងមិនព្រមបាត់បង់អូនទេ"

និយាយចប់គេក៏ឱនថើបបបូរមាត់ ដែលធ្វើឱ្យនាងស្រឡាំងកាំង ព្រោះមិនស្មានថាគេហ៊ានដល់ម្ល៉ឹង។



និងខឹងនៅក្នុងពេលតែមួយ ដែលធ្វើឱ្យខួរក្បាលរបស់នាងគិតអីមិនចេញ។

"បានហើយ វាចប់ហើយ គ្រប់យ៉ាងចប់ហើយ"

ពេលស្មារតីមកវិញ នាងក៏រុញគេចេញ ហើយឈរដង្ហើមចូលឱ្យពេញ

ពោះ។

"តែសម្រាប់បង វាទើបតែចាប់ផ្តើម អូនជាបិសាច ចង់ហែកបេះដូងបង

ឱ្យរបួសប៉ុន្មានដងទៀត ទើបពេញចិត្ត"

ទឹកមុខរបស់គេបង្ហាញឱ្យឃើញការឈឺចាប់ ខណៈដែល អាលិហ្សា យំ

ក្នុងចិត្ត គិតថានាងមិនឈឺឬយ៉ាងម៉េច។

នាងប្រឹងទប់ទឹកភ្នែក ដើរទៅបើកទ្វារបន្ទប់ និងបិទលាន់ប៉ុង ហើយចុះ

ជណ្តើរទៅជាន់ក្រោម ដោយមាន សារីហ្វ ដើរតាមដដែល។

"អាលីស មកអធិប្បាយសិនថាមានអីកើតឡើង ម៉េចក៏ស្គាល់គេ?"

ពេលចុះមកដល់ជាន់ក្រោម នាងក៏ត្រូវឪពុកម្តាយស្ទាក់សួរ។

"សុំទោសម៉ាក់ ខ្ញុំប្រញាប់ទៅនិយាយជាមួយភ្ញៀវ ណាត់គ្នាហើយ"

"អាលីស កុំគេចម៉ាក់"

នាងបិទត្រចៀក ដើរឈ្លោកមុខ សំដៅរោងទ្បានក្រោមដី តែពេលចូលក្នុងទ្បាន បិទទ្វារ ក៏ត្រូវគេតាមមកស្រវាចាប់ទ្វារជាប់ និងទាញនាងឱ្យងាកមកប្រឈមមុខជាមួយ។

"អូនចង់គេចពីបងក៏គេចទៅ បងតាមអូនមិនលែងទេ បងនឹងយកអូនទៅមីឌីសឱ្យបាន"

"ហេតុអីនិយាយមិនចេះស្តាប់គ្នាបែបនេះ ខ្ញុំម្ចាស់ប្រាប់ហើយថាមិនទៅគឺមិនទៅ"

"អីចឹងប្រាប់ម៉ោ ថាហេតុអីមិនព្រមទៅ?"

"ព្រោះវត្តមានរបស់ខ្ញុំម្ចាស់ នឹងធ្វើឱ្យទ្រង់អំពល់ទុក្ខ!"



ពេលទប់លែងបាន នាងក៏បំផ្ទុះចេញមក និងប្រសព្វភ្នែកជាមួយគេ ដោយការឈឺចាប់ ហើយត្រឹមមួយភ្លែតប៉ុណ្ណោះ ពេលសម្លឹងចំកែវភ្នែករបស់នាងហើយ សារីហ្វ ក៏រកបានចម្លើយ។

"មានអីកើតឡើង ហេតុអីមិនប្រាប់បង មានមនុស្សគំរាមអូនមែនទេ គេជាអ្នកណា?"

"ខុំម្ចាស់សម្រេចចិត្តដោយខ្លួនឯង គ្មានអ្នកណាគំរាមទេ ខុំម្ចាស់ធ្លាប់ប្រាប់តាំងពីដំបូងម្ល៉េះ ថាមិនត្រូវការទំនួលខុសត្រូវអីទាំងអស់ បូបូ និង យ៉ូយ៉ូ ជាកូនរបស់ខុំម្ចាស់តែម្នាក់ឯង វិថីជីវិតរបស់យើងគ្រាន់តែធ្លាប់ប្រសព្វគ្នា តែវាបំបែកគ្នាទៅផ្សេងគ្នាហើយ"

"បំបែកគ្នាស្អី អូននិយាយរឿងអី?"

"សាហ៊ីរ៉ា នាងសុខសប្បាយទេ?"

សុខៗ នាងក៏ធ្លាយមាត់សួរនាំពីមនុស្សស្រីដែលជាអតីតគូដណ្តឹង តែ

ត្រូវផ្សំផ្គុំសាច្ចីរបស់ សារីហ្វ។

"សាហ៊ីរ៉ា! សុខៗ អូនសួរពីនាងធ្វើអី?"

"វាជារឿងគ្មានមារយាទ បើខ្ញុំម្ចាស់មិនបានសួរសុខទុក្ខអាមិរ៉ារបស់ទ្រង់"

អ៊ូ! ព្រះអាទ្ធា!

សារីហ្វ ញញឹមចង់រហែកមាត់ដល់គុម្ពត្រចៀក និងមានចេតនានិយាយបេះបួយនាង។

"នៅចាំចិញ្ចៀនពេជ្រមួយវង់នោះបានទេ បងធ្វើតួថ្មីរួចយូរហើយ ដើម្បីប្រគល់ឱ្យអ្នកដែលត្រូវការ និងឃើញតម្លៃរបស់វា អាមិរ៉ារបស់បងបង្កើតកូនឱ្យបងពីរនាក់ បងមានសេចក្តីសុខណាស់"

"អ៊ូ! ល្អតើ"

ត្របកភ្នែករបស់នាងក្តៅភាយៗ។

"បើមានសេចក្តីសុខជាមួយប្រពន្ធកូនហើយ..."



ទាំងដែលបញ្ជាខ្លួនឯងមិនឱ្យយំហើយ តែនាងមិនអាចធ្វើបាន ទឹកភ្នែក
វាហូរមកបកអាក្រាតភាពទន់ជ្រាយរបស់ម្ចាស់ឱ្យទាល់តែបាន។

"អីចឹងដោះលែងខ្ញុំម្ចាស់ទៅ ហ៊ឹក!"

"កុំយំ"

ទឹកភ្នែករបស់នាង ធ្វើឱ្យ សារីហ្វ រំជួលចិត្ត ទាញនាងមកឱប និងខ្សឹប
ដោយសំឡេងញ័រៗ។

"អានែ បងស្រឡាញ់អូន"

គេអង្អែលខ្នងនាងតិចៗ ជាការលួងលោម។

"ទៅមីឌីសជាមួយបងទៅ"

បបួលហើយ គេក៏ឱនមកថើបកណ្តាលក្បាលនាង តែនាងគ្រវីក្បាល។

"ខ្ញុំម្ចាស់... ខ្ញុំ... ម្ចាស់ទៅមិនបាន"

"ហេតុអី?"

គេឆ្ងលចុងច្រមុះ ហើយរុញនាងចេញបន្តិច និងសម្លឹងមុខចំៗ។

"អូនគិតតែបដិសេធ ប្រាប់ហេតុផលបងម៉ោ"

"ខ្ញុំម្ចាស់មិនត្រូវការធ្វើជាស្រីកំណាន់របស់ទ្រង់ មិនចង់ទេ"

នាងនិយាយបណ្តើរ យំបណ្តើរ និងគិតតែគ្រវីក្បាល ទឹកភ្នែកហូររហាម។

"បងប្រាប់អូនរួចហើយ ថាបងមានប្រពន្ធតែម្នាក់ទេ អូនជាអាមិ៉ារបស់បងតែម្នាក់គត់ បងប្រាប់អូនរួចហើយ"

គេនិយាយមួយៗ សម្លឹងចំភ្នែករបស់នាងដោយខ្សែភ្នែករឹងកំព្រឹស។

"ទៅមីឌីសជាមួយបងវិញទៅ"

អាលិហ្សា ទម្លាក់ភ្នែកចុះ មិនព្រមឆ្លើយ។

"អូនលែងស្រឡាញ់បងហើយឬ?"

"លែងស្រឡាញ់បង"

"កុហក"



សារីហ្វ តួកវិញស្លាម ហើយក្រសោបមុខនាង ឱ្យងើយមកប្រសព្វភ្នែក
ជាមួយម្តងទៀត។

"និយាយម្តងទៀតម៉ោ បើអូននៅតែអះអាងថាលែងស្រឡាញ់បងហើយ
មិនត្រូវការបង បងនឹងទៅ!"

ព្រោះត្រូវការដាក់សម្ពាធនាង ទើប សារីហ្វ និយាយបែបនេះ ទាំងដែល
បុកពោះភឺបៗ ខ្លាចចម្លើយរបស់នាងនៅតែបដិសេធគេ ហើយកាន់តែធឺតពោះ
ពេលនាងមិនព្រមនិយាយអីទាំងអស់គិតតែសម្លឹងមុខគេ។

"អូខេ បងព្រមចាញ់អូន"

សារីហ្វ ដកដង្ហើមធំ ដកដៃពីមុខរបស់នាង ហើយបែរខ្នង ដើម្បីចុះពី
ឡាន តែចិត្តនៅតែលួចមានសង្ឃឹម ហើយក៏លួចញញឹម ពេលត្រូវនាងស្រវា
ឱបពីក្រោយ ពេលគេបើកទ្វារឡាន។



អាលិហ្សា សុំនាង និងចៅទាំងពីរត្រឡប់ទៅមីឌីសជាមួយ ដែលដំបូងឪពុក
មិនព្រមដាច់ខាត តែដោយសារអាណិតកូនភ្លោះ ទើបយល់ព្រមទាំងទឹកភ្នែក
ព្រោះចៅចិញ្ចឹមបីបាច់ផ្ចាល់ដៃទាំងពីនៅក្នុងពោះ រហូតដល់អាយុបីខួប ពេល
ត្រូវឃ្លាតឆ្ងាយគ្នាបែបនេះ ក៏ហេងហាងចិត្ត។

ពេលមកដល់មីឌីស សារីហ្វ មិនទាន់នាំប្រពន្ធកូនទៅហ្វេសសានភ្លាមៗ
តែនាំចូលគាស់សម្តេចព្រះមាតា ដែលទ្រង់ស្វាគមន៍ព្រះសុណិសាម្នាក់នេះ
ដោយមិននិយាយពីរឿងអតីត ព្រោះទ្រង់ថាវាកន្លងទៅហើយ កុំយកវាមកគិត
នាំឱ្យឈឺចាប់ ហើយទ្រង់ស្រឡាញ់ចៅ លង់ចៅភ្លោះណាស់ សុំឱ្យនៅក្នុងវាំង
ជាមួយ កុំឱ្យទៅនៅហ្វេសសានអី ដែលធ្វើឱ្យ សារីហ្វ អស់សំណើច និងបង្អាប់
ថាបានចៅ ភ្លេចកូន។

សារីហ្វ រៀបចំឱ្យកូនភ្លោះចូលរៀនសាលាអន្តរជាតិ ដែលទើបបើកថ្មី

បូបូ និង យ៉ូយ៉ូ យំ តែពេលអង្គុយឱបឪពុកម្តាយដូចខ្លាឃ្មុំខូអាទ្បាមួយសន្ទុះ ឃើញមិត្តភក្តិវ័យស្រករគ្នាកំពុងលេងយ៉ាងរីករាយ ពីរនាក់បងប្អូនក៏ដឹកដៃគ្នាទៅលួចមើល បន្ទាប់មកក៏ចូលរួមលេងជាមួយ។

"បូបូ និង យ៉ូយ៉ូ ចង់ឱ្យព្រះមាតា ព្រះបិតានៅកំដរទេ ?"

"មិនអីទេ យ៉ូយ៉ូ មានមិត្តភក្តិហើយ"

"ចេញពីរៀនចាំមកយក បូបូ ព្រះមាតាទៅចុះ"

ពេលកូនៗ មិនទំនេរនិយាយជាមួយម្តាយ ធ្វើឱ្យ សារីហ្វ អស់សំណើចហើយកេះភរិយា តែម្តាយគឺម្តាយ នៅតែបារម្ភ នៅលួចមើលជាងមួយម៉ោងទើបព្រមទុកចិត្ត។

ក្រៅពីរៀបចំឱ្យកូនរៀនសូត្រនៅសាលាល្អហើយ គេក៏បើកហាងពេជ្រឱ្យភរិយាដែរ ដោយដាក់ឈ្មោះថាហាង ALISHA ដែលធ្វើឱ្យម្ចាស់ឈ្មោះជា

ខ្លាំង ហើយថ្ងៃមួយ ហ្សឺក ហ្វារីស ក៏មកដល់ហាង ដោយមិនបានមកម្នាក់ឯង តែនាំស្រីស្អាតម្នាក់មកជាមួយដែរ។

អាលិហ្សា មើលឃើញថាស្រីស្អាតត្រូវបង្គាប់ឱ្យមកជាមួយច្រើនជាង ទើបធ្វើឱ្យនាងនឹកដល់រឿងកន្លងមកវាងនាង និង សារីហ្វ។

មុននេះស្វាមីបានប្រាប់នាងថា ហ្សឺក ហ្វារីស ផ្តាំមកសុំទោសចំពោះរឿងកន្លងមក និងប្រាប់ទៀតថា ប្រមុខនៃអាមីឌីសកំពុងលង់ស្នេហ៍ស្រីស្អាតថែមទាំងជាស្រីកូរ៉េខាងត្បូងទៀត។

"សួស្តីប្អូនថ្លៃ មើលទៅដំណើរការល្អ"

ពេលមកដល់ ហ្វារីស ក៏ដាក់បង្គុយនៅមុខតុរបស់ អាលិហ្សា និងចាប់ដៃស្រីស្អាតជាប់ មិនព្រមឱ្យនៅឆ្ងាយពីខ្លួន អង្គរក្សរាប់សិបនាក់យួរចង់សបតីបរយីងរយោង។

"ព្រះពរម្ចាស់ តែកម្រៃមិនច្រើនទេ"

"កម្រៃមិនច្រើន តែសាងសង់សាលារៀននារីនៅជនបទបានបីកន្លែង"

"កន្លែងទីបួនកំពុងបោះសរសរ ព្រះពរម្ចាស់" នាងខ្ចប់មាត់ខ្សឹបប្រាប់ ព្រមទាំងសើចស្រួល។

នាងនៅចងចាំពេលជួប ហ្វារីស លើកចុងក្រោយបានច្បាស់ ទើបមានចេតនាសើចសងសឹក ព្រោះបានបង្ហាញឱ្យពួកដៃណូស័រឃើញថាមនុស្សស្រីក៏ធ្វើការងារបាន មិនចាញ់មនុស្សប្រុសដែរ ហើយ ហ្វារីស ក៏ជួយគាំទ្រឋាន: ក្នុងសង្គមរបស់មនុស្សស្រីកាន់តែច្រើន ទើបពួកដែលប្រឆាំងនឹងតំណែងរបស់នាង នាំគ្នាស្លាប់មាត់។

"សារីហ្វ មិននៅទេអី?"

"ជូនកូនភ្លោះទៅសាលា បន្តិចទៀតម៉ោវិញហើយ អ៊ូហ៎! ខ្ញុំម្ចាស់មិនគិតទេថាទ្រង់ក៏ជាប់ព្រះទ័យស្រីបរទេសដែរ"

"នាងនិយាយដូច សារីហ្វ បេះបិទ តែអាល្អិតនោះដៀមដាមយើងឈឺៗ

ណាស់"

ហ្វារីស អស់សំណើច ហើយណែនាំឱ្យស្គាល់ស្រីស្អាតដែលខ្លួនចាប់ដៃជាប់។

"ស៊ូជីន នេះ អាលិហ្សា ជាប្អូនថ្លៃរបស់យើង ពេលនេះមានកូនពីរហើយ នាងមានតំណែងជាព្រះជាយានៃហ្វេសសាន... អាលិហ្សា នេះ ស៊ូជីន បងប្អូនរួមជាតិរបស់នាង"

អ្នកដែលត្រូវណែនាំឱនក្បាលបន្តិចដាក់គ្នា និងញញឹមដាក់គ្នា បន្តិចក្រោយមក សារីហ្វ ក៏មកដល់ ហើយពីរនាក់បងប្អូន និងប្អូនថ្លៃ រួមទាំងអនាគតព្រះសុណិសាក៏ផឹកតែ និយាយគ្នាលេង ដែលភាគច្រើនប្រុសៗ និយាយគ្នាពីរបៀបស្រឡាញ់ស្រី ធ្វើបែបណាឱ្យមនុស្សស្រីជាប់ចិត្ត ដែលធ្វើឱ្យស្រីៗអៀនជាពិសេស ស៊ូជីន។



បូបូ និង យ៉ូយ៉ូ វីដេអូខលទៅរកលោកតាលោកយាយជារៀងរាល់ថ្ងៃ

និងសន្យាថាខែក្រោយ លោកតាលោកយាយនឹងមកលេង ទើប អាលិហ្សា គិតថាឱ្យឪពុកម្តាយបិទហាង មកលម្ហែនៅមីឌីសបានមួយខែពីរ សឹមត្រឡប់ទៅវិញ ហើយមិនយូរប៉ុន្មាន លោកតាលោកយាយក៏ទទួលបានដំណឹងល្អថា កូនស្រីមានផ្ទៃពោះខ្ចីខែ ដែលធ្វើឱ្យ សារីហ្វ សប្បាយចិត្តដល់ថ្នាក់ម៉ៅទិញ ហ៊ុនក្រុមហ៊ុនខោទឹកនោមកូនង៉ា និងរង់ចាំបើកផលិតផលថ្មី ដោយប្រើរូបរបស់កូនបិទលើស្លាកម៉ាក គេលង់កូនជាងឪពុករបស់នាងទៅទៀត។

"បូបូ ជិតបានធ្វើជាបងធំហើយ ចំណែក យ៉ូយ៉ូ ជិតបានធ្វើជាបងប្រុស"

"ប្អូនរបស់ខ្ញុំជាស្រី ឬប្រុស?"

បូបូ ចង់បានប្អូនស្រី តែ យ៉ូយ៉ូ ចង់បានប្អូនប្រុស។

"មិនទាន់ដឹងច្បាស់ទេ ត្រូវរង់ចាំបីបួនខែទៀត ទើបប្រាប់បាន"

អាលិហ្សា លាក់ទុកសិន ព្រោះការពិតទៅ នាងយល់សប្តិឃើញក្មេង គួរឱ្យស្រឡាញ់ ហៅនាងថា *ម៉ាក់ៗ ខ្ញុំមកសុំធ្វើជាកូនរបស់ម៉ាក់* មានមុខមាត់ដូច សារីហ្វ បេះបិទ ថែមទាំងពេលត្រឡប់មកនៅមីឌីសថ្មីៗ ក៏ចាញ់កូនចង់ញុំអាហារចិនទៀត។ នាងមិនប្រាប់នរណាឱ្យដឹង ព្រោះមិនចង់ឱ្យចលាចលតែពេល សារីហ្វ ដឹងប៉ុប គេក៏បញ្ជូនមនុស្សទៅម៉ៅហាងអាហារចិនមួយមកទុកក្នុងដំណាក់តែម្តង។

ថ្ងៃមួយ ខណៈដែលពេលក្មេងៗ កំពុងគូររូបលេងជាមួយសម្តេចយាយ ចំណែក អាលិហ្សា យកការងារឯកសាររបស់ហាងមកអង្គុយធ្វើក្បែរ សារីហ្វ ក៏ស្ទុះចូលមកថើបថ្ពាល់ម្តាយ ថើបថ្ងាសនាង និងថើបកូនប្រុសកូនស្រី ដែលការប៉ះពាល់ថ្នមៗ នេះធ្វើឱ្យកក់ក្តៅដល់បេះដូង ហើយពេលរាក់ទាក់រួច គេក៏



ប្រាប់ដោយទឹកមុខរំភើប។

"ភ្លៀងធ្លាក់ហើយ ទៅកសិដ្ឋានទៅ"

"ភ្លៀងធ្លាក់ហើយ យ៉ាងម៉េចឬ ព្រះពរ?"

បូបូ សង្ស័យដែលឃើញឪពុកម្តាយឆ្លើឆ្លាបញ្ជាមនុស្សក្នុងវាំងត្រៀមខ្លួន លើកអីវ៉ាន់ដាក់ឡាន ដែលគ្រប់គ្នាមើលទៅឆោឡោណាស់ ទើបសម្តេចយាយ ជួយស្រាយបំភ្លឺការសង្ស័យរបស់ចៅស្រី។

"បិតារបស់ចៅៗ ធ្វើកសិដ្ឋានកណ្តាលសមុទ្រខ្សាច់ធំណាស់ បើមានភ្លៀងធ្លាក់ពេលណា បញ្ហាក់ថាយើងនឹងបានញ៉ាំរបស់ឆ្ងាញ់ៗ នោះអ្អែ"

សម្តេចយាយនិយាយថាពេលភ្លៀងធ្លាក់ ទឹកជ្រោះ និអូរជាច្រើនកន្លែង ដែលហួតហែងនឹងមានទឹក ហើយពេលភ្លៀងធ្លាក់ជាប់គ្នាច្រើនថ្ងៃ វាលផ្កានឹងរីកផ្ការហង់ ហើយបើសំណាងល្អនឹងជួប អរីកស៍ ឬរមាំងអាហ្វ្រិច កាស៊ែល ឬខ្សាច់អាហ្វ្រិច ក្រសា ក្អែក ស្ទាំងខ្មៅ ទន្សាយ ហ្វូងស្វាបាបូន និងក្តាន់អ៊ែនធីឡូ

ចេញមករកចំណីពេលវាលៗ

"បូបូ ចង់ទៅមើលទន្សាយសម្តេចយាយ"

"យ៉ូយ៉ូ ក៏ចង់ទៅ"

"អីចឹងទៅទាំងអស់គ្នា"

សារីហ្វ នាំគ្រួសារ និងមនុស្សទៅជិតអស់មួយដំណាក់តែម្តងដោយ

ក្បួនឡានដ៏វែង ព្រោះក្រៅពីក្រុមអង្គរក្សហើយ គឺត្រូវមានបរិវារ ខ្ញុំបម្រើ តីលៀង

ផ្នែកចុងភៅ និងជាងថែរក្សាសម្ផស្សប្រចាំខ្លួន ធ្វើដំណើរចាកចេញពីរាជធានី

ទៅក្រុងហ្វេសសាន។

"កាលមុន ពេលម៉ាក់មកទីនេះ មិនបានជិះឡានទេ"

"ហើយម៉ាក់ម៉ោយ៉ាងម៉េចឬ ព្រះបិតា ?"

"រត់មកហ្នឹងអ្អែ"

"អ៉ូហ៎! ម៉ាក់វិះរយថ្លៃឡានឬ ព្រះពរ គំរិះមែន"



ជិះទ្បានជាមួយសម្តេចយាយ មិនអីចឹងមុខជាបានរអ៊ូរទាំដាក់គេមិនខាន។

សមុទ្រខ្សាច់ធំល្វឹងល្វើយនៅចំពោះមុខ ទួលខ្សាច់ខ្ពស់ ទាប មើលទៅ ស្អាតដូចរូបគំនូរ នៅឆ្ងាយគឺជួរភ្នំខ្មៅស្តើលជាឆាកក្រោយ។ នៅសមុទ្រខ្សាច់ មានដើអាខេសៀ គុម្ពោធផ្កា គុម្ពោធស្មៅ បើត្រង់ណាមានសម្បូរទឹកនឹងមាន ដើមលម៉ើ ត្នោត និង អេព្រិខត។

ក្បួនទ្បានរត់កាត់វាលស្រូវសាឡី លម៉ើ ឈើហូបផ្លែ បន្លែ អូលីវ និង សណ្តែកសម្បកវឹងច្រើនប្រភេទ។ ពេលមកដល់កសិដ្ឋាន អាកាសធាតុកំពុង ត្រជាក់ស្រួល ឮសំឡេងចៀមពពែស្រែកមកតាមខ្យល់ បរិយាកាសស្ងប់ស្ងាត់ និងមានសំឡេងបក្សាបក្សីស្រែកចៀងយ៉ាងពីរោះ ទីនេះជាឋានសួគ៌លើដីដែល កសាងដោយថ្វីដៃស្វាមីរបស់ អាលិហ្សា។

កសិដ្ឋានកណ្តាលសមុទ្រខ្សាច់នៅហ្វេសសាន ដែលផ្លាប់យើញនៅ

កាលនោះកំពុងចាប់ផ្តើម ថ្ងៃនេះមានគ្រប់យ៉ាងហើយ។ ការធ្វើកសិដ្ឋាននៅ
សមុទ្រខ្សាច់ ដែលមានបរិមាណទឹកភ្លៀងមិនដល់មួយរយមីលីម៉ែត្រក្នុងមួយឆ្នាំ
ចាត់ទុកជារឿងគួរឱ្យស្ងើចណាស់ ទើបទីនេះមានការរៀបចំធ្វើប្រព័ន្ធជារាសាស្ត្រ
និងយកទឹកដែលប្រើប្រាស់រួចហើយមកប្រើសាថ្មី ព្រមទាំងជីកបឹងជាជំនួយ
ដែរ ហើយមិនយូរទេ នៅតំបន់នេះនឹងក្លាយជាតំបន់កសិកម្មដ៏សម្បូរបែប។

អាលិហ្សា ចូលចិត្តកសិដ្ឋាននេះណាស់ នាងដឹកដៃកូនដើរលេងតាម
ក្រោមម្លប់របស់ដើមលម៉ើ កាត់ចម្ការក្រូចផ្អែម និងក្រូចឆ្មារឃ្វីនស៍ ដែលឡើង
គុម្ពតូចៗ ផ្លែមានភិនភាគស្រដៀងផ្លែព័រ មានរសជាតិជូរ។ ពេលដើរទៅតាម
ក្រោមដើមអូលីវបាំងសំដៅស្រះធំ ទានិងក្វានកំពុងស្រែក នៅឆ្វេងដៃជាទ្រុង
ក្ងោកដ៏ធំ ពួកវាកំពុងរោំបង្ហួតកន្ទុយ ចំណែកនៅស្តាំដៃជារោងកញ្ចក់ដាំបន្លែ។

បូបូ ចូលចិត្តដើមប៉ែសដែលឪពុកដាំនៅក្នុងដំណាក់ ចំណែក យ៉ូយ៉ូ
ធម្មតាៗ ព្រោះរំភើបនឹងហ្វូងចៀម ហ្វូងពពែរបស់ឪពុកជាង។



"ព្រះបិតា ព្រះបិតាមើលនុះ!"

យ៉ូយ៉ូ ចង្អុលទៅបក្សីប្រមាញ់ដែលកំពុងហោះហើរ ហើយត្រដាងស្លាប ចុះមក ឆាបយកទន្សាយជាអាហារ។ គ្រប់យ៉ាងកើតឡើងលឿនណាស់ តែអាល្អិតបែរជាទះដៃចូលចិត្ត។

"បើចូលទៅសមុទ្រខ្សាច់ជ្រៅ នឹងឃើញខ្លាដំបង ឆ្កែចចក ឆ្កែព្រៃដែរ"

"ទូលបង្គំចង់ទៅ"

"មិនខ្លាចឬបុត្រ?"

"មិនខ្លាចទេ ទូលបង្គំរឹងមាំ"

"អឺចឹងបិតានាំទៅ"

សារីហ្វ លើកកូនប្រុសឱ្យអង្គុយលើខ្នងសេះ ហើយឡើងតាមពីក្រោយ ដោយកាយវិការអង់អាច។ គេបង្រៀនឱ្យកូនស្គាល់ឫសគល់របស់ខ្លួន ប្រាប់ដឹងថាគេមានដើមកំណើតពីសមុទ្រខ្សាច់។

"កាចណាស់ តែទ្រង់មានហេតុផល បិតាជឿជាក់ថា បើទ្រង់នៅមាន ព្រះជន្ម ទ្រង់នឹងពេញព្រះទ័យចំពោះភាពក្លាហានរបស់បុត្រ"

"ចុះសម្តេចអំ ហ្វារីស ?"

"សម្តេចអំរបស់បុត្ររឹងមាំ ជាបុគ្គលគួរឱ្យកោតក្រែងនិងពោរពេញទៅដោយសមត្ថភាព ដែលបានពីសម្តេចតា ទ្រង់ដឹកនាំគ្រប់គ្រងស្រុកទេសបានល្អ ធ្វើឱ្យក្លាយជាប្រទេសរឹងមាំ ធ្វើឱ្យប្រជាជនមានជីវភាពធូរធារ ស្រឡាញ់សុខភាពអនាម័យ មានការយល់ដឹង"

"ដោយមានព្រះបិតាជាជំនួយការមែនទេ ក្រាបទូល ?"

"មែនហើយ"

"ទូលបង្គំនឹងជួយព្រះបិតា និងសម្តេចអំ ហើយជួយព្រះបិតាបណ្តេញមនុស្សប្រុសដែលមកញ៉ែ បូបូ ដែរ"

កូនប្រុសវ័យបីឆ្នាំបញ្ជាក់ដោយទឹកមុខមាំ ធ្វើឱ្យឪពុកអស់សំណើច និង

គិតថាខ្លួនឯងមានសំណាងណាស់ដែលមានក្រុមគ្រួសារមួយនេះ ជាតិនេះគេ
លែងត្រូវការអ្វីទៀតហើយ។

ពេលយប់ អាកាសធាតុនៅសមុទ្រខ្សាច់ចុះត្រជាក់ដកសូន្យអង្សាសទើប សារីហ្វ នាំកូនប្រុសកូនស្រីចូលទៅជំនំនៅក្នុងតង់បែបបេឌូអ៊ីនពណ៌ខ្មៅ ធ្វើពីស្បែកចៀម មានចង្ក្រានដែលតបំពង់ផ្សែងទៅក្រៅតង់ នៅកណ្តាលតង់ បំពក់ភ្លើង មានដែកជើងបីសម្រាប់ដាក់ឆ្នាំកម្តៅទឹកដោះគោស្រស់ ពេលផឹកគឺ ចាក់ដាក់ពែងតូច និងដាក់ខ្ទីចូលបន្តិច។

បូបូ និង យ៉ូយ៉ូ រៀនអាំងម៉ាសមេលឡូជាលើកដំបូង ហើយញ៉ាំភែនខេក ដែលហៅថាបាក់ឡាវ៉ា ទាល់តែឆ្អែតកាងពោះ ទើបត្រូវម្តាយនាំទៅលាងមាត់ ដុសធ្មេញ ចូលដេក។

"ក្តៅខ្លួនតិចៗ មានសម្បារតិចៗ ត្រូវលេបថ្នាំមុនចូលគេង ក្មេងៗ"



"មិនលេបទេ"

កូនស្លោះគិតតែគ្រវីក្បាលដាក់។

"ការលេបថ្នាំគ្រាប់បាននៅដំណាក់កាលដំបូង បញ្ជាក់ថាយើងក្លាយជា

មនុស្សធំហើយកូន អ្នកណាលេបថ្នាំ បិតាឱ្យរង្វាន់"

"ជាស្អីឬ?"

"អ្នកណាលេបថ្នាំបាន បិតានឹងលើកអ្នកនោះផុតក្បាល"

ពីរនាក់បងប្អូនព្រមហាមាត់ យកថ្នាំ ហើយបិទភ្នែក ប្រឹងលេប និងផឹក

ទឹក បន្ទាប់មកហាមាត់ឱ្យមើល ទើប សារីហ្វ សរសើរពួនខ្លាំងៗថា *អ៊ូហ៎! ខ្លួនតូច*

ប៉ុណ្ណឹង តែលេបថ្នាំដោយខ្លួនឯងបាន ស្មានថាពិបាកលេបតើ។

"មិនឃើញពិបាកអីផង ងាយចង់ងាប់"

ពីរនាក់បងប្អូនហដៃឱ្យឪពុកលើកបី ទើប សារីហ្វ លើកកូនស្រីបោះទៅ

លើ និងស្រែកជយោៗឱ្យក្មេងពូកែ ហើយលើកកូនប្រុសធ្វើបែបនោះម្តង។

ពេលស្វាមីបំពេកូនៗ អាលិហ្សា ក៏អង្គុយមើល។

"បូបូ ដូចបងណាស់ ជាអ្នកដឹកនាំ ម៉ឺងម៉ាត់និងមាំមួន ចំណែល យ៉ូយ៉ូ បិននិយាយបិនចរចាំ ទន់ភ្លន់ តែក្លាហាន"

នាងញញឹម ដៃទាំងពីរក្តោបកែវទឹកដោះគោក្តៅៗ នៅក្រោមពន្លឺភ្លើងពណ៌ពងមាន់ មុខមាត់ស្រស់ស្អាតរបស់នាងមើលទៅស្រទន់បំផុត។

"ញញឹមអី អានែ"

"ចង់ញញឹម ញញឹមមិនបានឬ?"

"ឆ្លើយបេះបួយបែបនេះ តិចមានរឿង"

សារីហ្វ ចុះពីគ្រែរបស់កូនៗ ដើរមករក ហាក់ដូចរាជសីហ៍ ហើយឱនមកថើបបបូរមាត់ក្រហមប្រឿងៗ ជ្រែកអណ្តាតចូលមកដួសដងយករសផ្អែម។

"កូនដេកលក់ហើយ យើងទៅមើលផ្កាយទៅ"

"ពេលនេះឬ?"



"បងចង់មានកូនម្នាក់ទៀត លើកនេះឱ្យ មេដ អ៊ីន មីឌីស សុទ្ធសាធ"

"ឆ្កួត នៅក្នុងពោះនេះហើយតើ"

"ទៅទេ ?" គេសួរបញ្ជាក់ នាងក៏ញញឹមក្របួចមាត់។

"ទៅ មិនឃើញចាំបាច់អីសួរ"

ផ្ទៃមេឃពេលរាត្រីងងឹតដូចកាំម្ទីភ្លឺផ្លេកៗ ដោយដួងតារា សារីហ្វ ដឹកដៃ

អាលិហ្សា ដើរដោយជើងទទេលើដីខ្សាច់ស្អាតបរិសុទ្ធ និងទោះរងា តែពួកគេក៏

លង់ស្នេហ៍ពេលវេលាដ៏សូប់ស្ងាត់នេះ។

"បងនឹកដល់ថ្ងៃដំបូងដែលយើងជួបគ្នាជានិច្ច"

"ជាប់ចិត្តដល់ថ្នាក់នោះឬ ?"

"ស្រីឆ្មាស ទាំងរឹងក្បាល ទាំងតមាត់ប៉ប៉ែសបែបនោះពិបាករកណាស់

ឆ្មាសដល់ថ្នាក់បងចង់ចាប់ទំពា"

សារីហ្វ ចំអកចំអន់ ហើយឱនទៅខ្សឹបខ្សៀវដាក់ត្រចៀក។

"បងនឹកដល់រាត្រីដំបូងរបស់យើង"

"ក្មួងតង់បេឌូអ៊ីន"

នាងដកដង្ហើមធំ តែគេបែរជាញញឹមលាក់កំណួច។

"បងនិយាយពីយប់ដែលយើងជាប់ក្នុងឡាន ព្រោះព្យុះខ្សាច់"

"គឺ... គឺអូនគិតដល់ពេលនោះមែនហ្នឹងណ៎ា"

"ដូចបងដែរ"

បុរសម្នាក់នេះមានភាពជាបុរសពិត ស្មាធំទូលាយ សាច់ដុំហាប់ណែន រាងកាយមាំមួន ពោរពេញដោយមន្តស្នេហ៍របស់បុរស ជារាងកាយសម្បូរបែប បែបដែលបុរសគ្រប់គ្នាស្រមើស្រមៃចង់មាន ទើបនាងមិនអាចបដិសេធបាន ហើយកម្តៅក៏សាយភាយពេញរាងកាយពេលដៃអារវ៉ែត្រូវទាញទម្លាក់ពីស្មា ឯគេក៏ដោះឈុតយេបាឡាចេញ ទាញអារវ៉ែដៃវៀលពណ៌សចេញតាមក្បាលដោយភាពរហ័សរហន់ ហើយដោះក្រណាត់គុត្រាពីក្បាលមកក្រាលលើដីខ្សាច់ ប៉ុន្តែ



នាងគ្រវីក្បាលៗ

"ខ្សាច់វារមាស់"

"បងធ្វើកម្រាលឱ្យអូន"

គេមើលទៅល្អណាស់ ពេលប្រសព្វភ្នែកគ្នា។ អាលិហ្សា មានអារម្មណ៍ដល់ការប្រាថ្នាដែលច្រាល់ពេញកែវភ្នែកមុតស្រួចមួយគូនោះ ហើយនៅក្រោមភាពទន់ភ្លន់ ថ្លៃថ្នូរនោះ លាក់ភាពព្រៃផ្សៃបានល្អណាស់ និងដឹងពីការប្រាថ្នាដ៏ល្អខ្លាំងក្លា ពេលគេទាញទៅឱបរឹត ឱ្យដើមទ្រូងនៃបនិត្យគ្នា។

"បងចង់ឃើញអូនពេលពោះខ្ចាតធំឆាប់ៗដល់ហើយ"

"ក្នុងអាលប៊ុមរូបថតមានឱ្យមើលហើយតើ"

"តែបងចង់មើល ចង់ប៉ះដោយផ្ទាល់"

គេខ្សឹបប្រាប់ដោយសំឡេងស្អក ដៃទាំងពីរក៏អង្អែលពោះដែលកំពុងមានសាច់ឈាមរបស់គេក្នុងនោះ និងអន្ទះសាចង់ឃើញមុខកូនឆាប់ៗ ហើយ

ឱនទៅផ្អឹបត្រចៀកនឹងពោះរបស់នាង។

"គភ៌នៅខ្ចីពេកហើយ មានគេប្រាប់បងថាបើពោះធំជាងនេះ នឹងបានឮ

សំឡេងកូនហៅប៉ាម៉ាក់"

គេប៉ប៉ាច់ប៉ប៉ោច សុំកូនទីបួនទុកឱ្យហើយ។

"បូបូ និង យ៉ូយ៉ូ គួរឱ្យស្រឡាញ់ កូនម្នាក់នេះរបស់យើងដឹងតែគួរឱ្យ

ស្រឡាញ់ដូចបងៗ ពេទ្យប្រាប់បងថា អូននិងកូនរឹងមាំ អានែ... បងចង់ឱ្យអូន

បង្កើតកូនឱ្យបានច្រើន មេត្តាជួយបងបន្តិចទៅ អានែ"

"រឿងបែបនេះធ្វើម្នាក់ឯងបានពីអង្កាល់ទៅ បើចង់មានកូនច្រើន វាស្តិត

លើញ៉ក់ៗរបស់ សារីហ្វ ថាមានកម្លាំងឬអត់"

អាលិហ្សា សម្លក់សម្លឹង ហើយសើចខឹកៗ ព្រោះត្រូវគេចាក់ចង្កេះ។

"ពូកែផ្ចាញ់ផ្ចាលណាស់ ចាំមើលទៅធ្វើឱ្យមានផ្ទៃពោះដើមឆ្នាំចុងឆ្នាំ"

ស្បែកក្តៅគគុកត្រដុសនឹងស្បែកទន់ល្មើយ ធ្វើឱ្យនាងប៉ះអ្វីម៉្យាងដែល



វាកំពុងចាក់រាងកាយ។ វាកម្រើកដោយការស្រែកឃ្លាន និងប្រាថ្នាជ្រៀតជ្រែក
មកវក ដែលដំបូងគេធ្វើថ្នមៗ បន្ទាប់មកក៏ខ្លាំងក្លាតាមអារម្មណ៍ ព្រោះនាងបាន
ពុគេស្រែកគ្រហឹមដូចសត្វព្រៃរងរបួស ពេលនាំនាងទៅដល់គោលដៅ ហើយ
គេជួយតែងខ្លួនឱ្យនាង ដឹកដៃដើរសំដៅមកកសិដ្ឋានវិញ។

"សោកស្តាយឬអត់ដែលថ្ងៃនោះយើងបានជួបគ្នា"

"អត់ទេ"

នាងគ្រវីក្បាល ទឹកភ្នែករលីងរលោង ខណៈនោះក៏ប្រដេញម្រាមដៃលើ
មុខសង្ហារបស់បុរសដែលនាងលង់ស្នេហ៍។

"ការបានរួមរស់ជាមួយ សារីហ្វ ជាកាដូក្នុងជីវិតបង អូនសប្បាយចិត្ត
ដែលរយៈពេលច្រើនឆ្នាំមកនេះ បងរង់ចាំអូន"

"បងធ្លាប់ប្រាប់ថាស្រឡាញ់អូនតែម្នាក់គត់ វាគ្មានថ្ងៃប្រែប្រួលទេ"

គេផ្ទឹបថ្ងាសនឹងថ្ងាសរបស់នាង ស្រាក់ម្រាមដៃគ្នាឱ្យបេះដូងលោតញាប់

ម្តងទៀត។ នាងជាមនុស្សតែម្នាក់ដែលបំពេញអត្ថន័យក្នុងជីវិត គេស្រឡាញ់នាង សុំត្រឹមបានរួមរស់ជាមួយ ទោះត្រូវជួបនឹងអ្វីក៏ដោយ ក៏មិនព្រមបាត់បង់នាងទៀតដែរ។

សារីហ្វ ចាប់ដៃរបស់នាង លើកថើប ហើយវាសជើងសក់ទៅសៀតនឹងត្រចៀកឱ្យ បន្ទាប់មកក៏ឱនទៅថើប។

"ត្រឹមអូនដើរកាត់មុខបងនៅក្នុងភាំងថ្ងៃនោះ អូនក៏យកបានបេះដូងបងទៅហើយ"

"ខុសពីអូន ជួបគ្នាលើកដំបូងគឺស្អប់មហាស្អប់ មនុស្សស្អីអន់ចរិត កាចក៏កាច មុខដូចចោរ"

នាងសើចខឹកៗ ហើយស្រែកតិចៗ ពេលត្រូវខ្ទាំពោះតិចៗ ហើយសម្ងំនៅក្នុងលង្វែកទ្រូងធំទូលាយ បន្ទាប់មកក៏ងើយទៅថើបថ្ពាល់គ្រីម។

"ហើយពេលនេះស្រឡាញ់ចោរពាលដូចដើមទេ?"



"មិនដូចដើមទេ"

"ហ៊ឺ! ម៉េចទៅជាអីចឹង អានែ?"

"គឺត្រូវតែមិនដូចដើមហើយ មនុស្សស្អីក៏មិនដឹង ធ្វើឱ្យអូនស្រឡាញ់ខ្លាំងឡើងៗ រាល់ថ្ងៃ មើលចុះ ឃើញទេន៎ះ បេះដូងលោតពេញមេឃហើយ ខ្ចិលនឹងថ្ពក់យក"

"មិនបាច់ថ្ពក់ទេ យើងទាំងពីរជួយគ្នាបន្ថែមបរិមាណបេះដូងឱ្យពេញមេឃល្អជាងគ្នា"

សារីហ្វ សើច និងប៉ះពាល់រាងកាយស្រឡៅស្រឡូនម្តងទៀត នាងក៏ឱបក្រសោបរាងកាយមាំមួនដោយក្តីស្រឡាញ់ពេញប្រៀប។

ពេលវេលាកន្លងមកធ្វើឱ្យនឹកឃើញ និងសើចគ្រប់ពេល ក្តីស្រឡាញ់បញ្ចេញពន្លឺក្នុងកែវភ្នែកបួនដួង ជោរជន់ ជាបសមុទ្រខ្សាច់ឱ្យឡើងពណ៌ផ្កាឈូក។

(ចប់)